

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
# ទុតិយភាគ
# ៧០



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## KHUDDAKANIKĀYA

## PAṬISAMBHIDĀMAGGA

## DUTIYABHĀGA

## 70

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិរិយោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

## សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្លឹកប្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## ទុតិយភាគ

៧០

ព. ស. ២៥០៥

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស បដិសម្ភិទាមគ្គោ

# ទុតិយោ ភាគោ

---

## មហាវគ្គេ ទិដ្ឋិកថា

[១] កតិ[១] ទិដ្ឋិដ្ឋានានិ កតិ ទិដ្ឋិបរិយុដ្ឋានានិ កតិ ទិដ្ឋិយោ កតិ ទិដ្ឋាភិនិវេសា កតមោ ទិដ្ឋិដ្ឋានសមុគ្ឃាតោ កតិ អភិនិវេសបរាមាសោ[២] ទិដ្ឋិ ។

កតិ ទិដ្ឋិដ្ឋានានីតិ អដ្ឋ ទិដ្ឋិដ្ឋានានិ ។ កតិ ទិដ្ឋិបរិយុដ្ឋានានីតិ អដ្ឋារស ទិដ្ឋិបរិយុដ្ឋានានិ ។ កតិ ទិដ្ឋិយោតិ សោឡស ទិដ្ឋិយោ ។ កតិ ទិដ្ឋាភិនិវេសាតិ តីសសតំ[៣] ទិដ្ឋាភិនិវេសា ។ កតមោ ទិដ្ឋិដ្ឋានសមុគ្ឃាតោតិ សោតាបត្តិមគ្គោ ទិដ្ឋិដ្ឋានសមុគ្ឃាតោ ។

---

១ ឱ. ម. កា ទិដ្ឋិ ។ ២ ឱ. ម. កតមោ ទិដ្ឋិដ្ឋានសមុគ្ឃាតោតិ កា ទិដ្ឋីតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ ៣ ឱ. ម. តីណិ សតំ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# ទុតិយភាគ

---

## មហាវគ្គ ទិដ្ឋិកថា

[១] *ហេតុនៃទិដ្ឋិ*[១] *ប៉ុន្មានយ៉ាង ការរួបរឹតគឺទិដ្ឋិ ប៉ុន្មានយ៉ាង ទិដ្ឋិ ប៉ុន្មានយ៉ាង ការប្រកាន់ស្អិតគឺទិដ្ឋិ ប៉ុន្មានយ៉ាង ធម៌ជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិ តើដូចម្ដេច ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល តើដូចម្ដេច ។*

*ត្រង់សំណួរថា ហេតុនៃទិដ្ឋិ ប៉ុន្មានយ៉ាង ចម្លើយថា ហេតុនៃទិដ្ឋិ ៨ យ៉ាង ។ សំណួរថា ការរួបរឹតគឺទិដ្ឋិ ប៉ុន្មានយ៉ាង ការរួបរឹតគឺទិដ្ឋិ ១៨ យ៉ាង ។ សំណួរថា ទិដ្ឋិ ប៉ុន្មានយ៉ាង ទិដ្ឋិ ១៦ យ៉ាង ។ សំណួរថា ការប្រកាន់ស្អិតគឺទិដ្ឋិ ប៉ុន្មានយ៉ាង ការប្រកាន់ស្អិតគឺទិដ្ឋិ ១៣០ យ៉ាង ។ សំណួរថា ធម៌ជាគ្រឿងដកឡើង នូវហេតុនៃទិដ្ឋិ តើដូចម្ដេច សោតាបត្តិមគ្គ ជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិ ។*

---

១ ហេតុនាំឲ្យកើតទិដ្ឋិ ។

[២] កាតិ អភិនិវេសបរាមាសោ ទិដ្ឋីតិ រូបំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ វេទនំ ឯតំ មម ។ បេ ។ សញ្ញំ ឯតំ មម សង្ខារេ ឯតំ មម វិញ្ញាណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ ចក្ខុំ ឯតំ មម សោតំ ឯតំ មម ឃានំ ឯតំ មម ជិវ្ហំ ឯតំ មម កាយំ ឯតំ មម មនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ រូបំ ឯតំ មម[១] សទ្ទំ ឯតំ មម គន្ធំ ឯតំ មម រសំ ឯតំ មម ផោដ្ឋព្វំ ឯតំ មម ធម្មំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

---

១ ម. រូបេ ឯតំ មម ។

[២] សំណួរថា ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល តើដូចម្តេច ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលចំពោះរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលចំពោះវេទនាថា នុ៎ះរបស់អញ ។ បេ ។ ចំពោះសញ្ញាថា នុ៎ះរបស់អញ ចំពោះសង្ខារថា នុ៎ះរបស់អញ ចំពោះវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលចំពោះចក្ខុថា នុ៎ះរបស់អញ ចំពោះសោតៈថា នុ៎ះរបស់អញ ចំពោះឃានៈថា នុ៎ះរបស់អញ ចំពោះជិវ្ហាថា នុ៎ះរបស់អញ ចំពោះកាយថា នុ៎ះរបស់អញ ចំពោះចិត្តថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបថា នុ៎ះរបស់អញ ចំពោះសំឡេងថា នុ៎ះរបស់អញ ចំពោះក្លិនថា នុ៎ះរបស់អញ ចំពោះរសថា នុ៎ះរបស់អញ ចំពោះផ្សព្វថា នុ៎ះរបស់អញ ចំពោះធម្មារម្មណ៍ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៣] ចក្ខុវិញ្ញាណំ ឯតំ មម សោតវិញ្ញាណំ ឯតំ មម ឃានវិញ្ញាណំ ឯតំ មម ជិវ្ហាវិញ្ញាណំ ឯតំ មម កាយវិញ្ញាណំ ឯតំ មម មនោវិញ្ញាណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិ-និវេសបរាមាសោ ទិដ្ឋិ ។

ចក្ខុសម្ផស្សំ ឯតំ មម សោតសម្ផស្សំ ឯតំ មម ឃានសម្ផស្សំ ឯតំ មម ជិវ្ហាសម្ផស្សំ ឯតំ មម កាយសម្ផស្សំ ឯតំ មម មនោសម្ផស្សំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមា-សោ ទិដ្ឋិ ។ ចក្ខុសម្ផស្សជំ វេទនំ សោតសម្ផស្សជំ វេទនំ ឃានសម្ផស្សជំ វេទនំ ជិវ្ហាសម្ផស្សជំ វេទនំ កាយសម្ផស្សជំ វេទនំ មនោសម្ផស្សជំ វេទនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិ-វេសបរាមាសោ ទិដ្ឋិ ។

មហាវគ្គ ទិដ្ឋិកថា

[៣] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះចក្ខុវិញ្ញាណថា នុ៎ះរបស់អញ ចំពោះសោតវិញ្ញាណថា នុ៎ះរបស់អញ ចំពោះឃានវិញ្ញាណថា នុ៎ះរបស់អញ ចំពោះជិវ្ហាវិញ្ញាណថា នុ៎ះរបស់អញ ចំពោះកាយវិញ្ញាណថា នុ៎ះរបស់អញ ចំពោះមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះចក្ខុសម្ផស្សថា នុ៎ះរបស់អញ ចំពោះសោតសម្ផស្សថា នុ៎ះរបស់អញ ចំពោះឃានសម្ផស្សថា នុ៎ះរបស់អញ ចំពោះជិវ្ហាសម្ផស្សថា នុ៎ះរបស់អញ ចំពោះកាយសម្ផស្សថា នុ៎ះរបស់អញ ចំពោះមនោសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះវេទនា ដែលកើតអំពីចក្ខុសម្ផស្ស ចំពោះវេទនាដែលកើតអំពីសោតសម្ផស្ស ចំពោះវេទនាដែលកើតអំពីឃានសម្ផស្ស ចំពោះវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ចំពោះវេទនាដែលកើតអំពីកាយសម្ផស្ស ចំពោះវេទនាដែលកើតអំពីមនោសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

៤



[៤] រូបសញ្ញំ ឯតំ មម សទ្ទសញ្ញំ គន្ធសញ្ញំ រសសញ្ញំ ផោដ្ឋព្វសញ្ញំ ធម្មសញ្ញំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ រូបសញ្ចេតនំ ឯតំ មម សទ្ទសញ្ចេតនំ គន្ធសញ្ចេតនំ រសសញ្ចេតនំ ផោដ្ឋព្វសញ្ចេតនំ ធម្មសញ្ចេតនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ រូបតណ្ហំ ឯតំ មម សទ្ទតណ្ហំ ឯតំ មម គន្ធតណ្ហំ រសតណ្ហំ ផោដ្ឋព្វតណ្ហំ ធម្មតណ្ហំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ រូបវិតក្កំ ឯតំ មម សទ្ទវិតក្កំ គន្ធវិតក្កំ រសវិតក្កំ ផោដ្ឋព្វវិតក្កំ ធម្មវិតក្កំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

[៤] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបសញ្ញាថា នុ៎ះរបស់អញ ចំពោះសទ្ទសញ្ញា ចំពោះគន្ធសញ្ញា ចំពោះរសសញ្ញា ចំពោះផោដ្ឋព្វសញ្ញា ចំពោះធម្មសញ្ញាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបសញ្ចេតនាថា នុ៎ះរបស់អញ ចំពោះសទ្ទសញ្ចេតនា ចំពោះគន្ធ-សញ្ចេតនា ចំពោះរសសញ្ចេតនា ចំពោះផោដ្ឋព្វសញ្ចេតនា ចំពោះធម្ម-សញ្ចេតនាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបតណ្ហាថា នុ៎ះរបស់អញ ចំពោះសទ្ទតណ្ហាថា នុ៎ះរបស់អញ ចំពោះគន្ធតណ្ហា ចំពោះរសតណ្ហា ចំពោះផោដ្ឋព្វតណ្ហា ចំពោះធម្មតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបវិតក្កៈថា នុ៎ះរបស់អញ ចំពោះសទ្ទវិតក្កៈ ចំពោះគន្ធវិតក្កៈ ចំពោះរសវិតក្កៈ ចំពោះផោដ្ឋ-ព្វវិតក្កៈ ចំពោះធម្មវិតក្កៈថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

រូបវិចារំ ឯតំ មម សទ្ទវិចារំ ឯតំ មម គន្ធវិចារំ ឯតំ មម រសវិចារំ ឯតំ មម ផោដ្ឋព្វវិចារំ ឯតំ មម ធម្មវិចារំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

[៥] បឋវីធាតុំ ឯតំ មម អាបោធាតុំ ឯតំ មម តេជោធាតុំ ឯតំ មម វាយោធាតុំ ឯតំ មម អាកាសធាតុំ ឯតំ មម វិញ្ញាណធាតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។ បឋវីកសិណំ អាបោកសិណំ តេជោកសិណំ វាយោកសិណំ នីលកសិណំ បីតកសិណំ លោហិតកសិណំ ឱទាតកសិណំ អាកាសកសិណំ វិញ្ញាណកសិណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះរូបវិចារៈថា នុ៎ះរបស់អញ ចំពោះសទ្ទវិចារៈថា នុ៎ះរបស់អញ ចំពោះគន្ធវិចារៈថា នុ៎ះរបស់អញ ចំពោះរសវិចារៈថា នុ៎ះរបស់អញ ចំពោះផោដ្ឋព្វវិចារៈថា នុ៎ះរបស់អញ ចំពោះធម្មវិចារៈថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៥] ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះបឋវីធាតុថា នុ៎ះរបស់អញ ចំពោះអាបោធាតុថា នុ៎ះរបស់អញ ចំពោះតេជោធាតុថា នុ៎ះរបស់អញ ចំពោះវាយោធាតុថា នុ៎ះរបស់អញ ចំពោះអាកាសធាតុថា នុ៎ះរបស់អញ ចំពោះវិញ្ញាណធាតុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះបឋវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាកាសកសិណ និងវិញ្ញាណកសិណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៦] កេសំ ឯតំ មម លោមំ ឯតំ មម នខំ ឯតំ មម ទន្តំ ឯតំ មម តចំ ឯតំ មម មំសំ ឯតំ មម នហារុំ ឯតំ មម អដ្ឋឹ ឯតំ មម អដ្ឋិមិញ្ជំ ឯតំ មម វក្កំ ឯតំ មម ហទយំ ឯតំ មម យកានំ ឯតំ មម កិលោមកំ ឯតំ មម បិហកំ ឯតំ ។ ប ។ ខេឡំ ឯតំ មម សឹឃាណិកំ ឯតំ មម លសិកំ ឯតំ មម មុត្តំ ឯតំ មម មត្ថលុង្គំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេស-បរាមាសោ ទិដ្ឋិ ។

[៧] ចក្ខាយតនំ ឯតំ មម រូបាយតនំ ឯតំ មម សោតាយតនំ ឯតំ មម សទ្ទាយតនំ ឯតំ មម ឃានាយតនំ ឯតំ មម គន្ធាយតនំ ឯតំ មម ជិវ្ហាយ-តនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនា-យតនំ ធម្មាយតនំ ឯតំ មម ចក្ខុធាតុំ ឯតំ មម

[៦] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះសក់ថា នុ៎ះរបស់អញ ចំពោះរោមថា នុ៎ះរបស់អញ ចំពោះក្រចកថា នុ៎ះរបស់អញ ចំពោះធ្មេញថា នុ៎ះរបស់អញ ចំពោះស្បែកថា នុ៎ះរបស់អញ ចំពោះសាច់ថា នុ៎ះរបស់អញ ចំពោះសរសៃថា នុ៎ះរបស់អញ ចំពោះឆ្អឹងថា នុ៎ះរបស់អញ ចំពោះខួរក្នុងឆ្អឹងថា នុ៎ះរបស់អញ ចំពោះទាចថា នុ៎ះរបស់អញ ចំពោះបេះដូងថា នុ៎ះរបស់អញ ចំពោះថ្លើមថា នុ៎ះរបស់អញ ចំពោះវាវថា នុ៎ះរបស់អញ ចំពោះក្រពះថា នុ៎ះរបស់អញ ។ បេ ។ ចំពោះទឹកមាត់ថា នុ៎ះរបស់អញ ចំពោះទឹកសម្បោរថា នុ៎ះរបស់អញ ចំពោះទឹករំអិលថា នុ៎ះរបស់អញ ចំពោះទឹកមូត្រថា នុ៎ះរបស់អញ ចំពោះខួរក្នុងក្បាលថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៧] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះចក្ខាយតនៈថា នុ៎ះរបស់អញ ចំពោះរូបាយតនៈថា នុ៎ះរបស់អញ ចំពោះសោតាយតនៈថា នុ៎ះរបស់អញ ចំពោះសទ្ទាយតនៈថា នុ៎ះរបស់អញ ចំពោះឃានាយតនៈថា នុ៎ះរបស់អញ ចំពោះគន្ធាយតនៈថា នុ៎ះរបស់អញ ចំពោះជិវ្ហាយតនៈ សោតាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈថា នុ៎ះរបស់អញ ចំពោះចក្ខុធាតុថា នុ៎ះរបស់អញ

រូបធាតុំ ឯតំ មម ចក្ខុវិញ្ញាណធាតុំ ឯតំ មម សោតធាតុំ ឯតំ មម សទ្ទធាតុំ ឯតំ មម សោតវិញ្ញាណធាតុំ ឯតំ មម ឃានធាតុំ គន្ធធាតុំ ឃានវិញ្ញាណធាតុំ ជិវ្ហាធាតុំ រសធាតុំ ជិវ្ហាវិញ្ញាណធាតុំ កាយធាតុំ ផោដ្ឋព្វធាតុំ កាយវិញ្ញាណធាតុំ មនោធាតុំ ឯតំ មម ធម្មធាតុំ ឯតំ មម មនោវិញ្ញាណធាតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

[៨] ចក្ខុន្ទ្រិយំ ឯតំ មម សោតិន្ទ្រិយំ ឯតំ មម ឃានិន្ទ្រិយំ ឯតំ មម ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ជីវិតិន្ទ្រិយំ[១] សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

---

១ ឱ. កាយិន្ទ្រិយំ មនិន្ទ្រិយំ ជីវិតិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ ។ ម. កាយិន្ទ្រិយំ ឯតំ មម មនិន្ទ្រិយំ ឯតំ មម ជីវិតិន្ទ្រិយំ ឯតំ មម ឥត្ថិន្ទ្រិយំ ឯតំ មម បុរិសិន្ទ្រិយំ ឯតំ មម សុខិន្ទ្រិយំ ឯតំ មម ទុក្ខិន្ទ្រិយំ ឯតំ មម ។

ចំពោះរូបធាតុថា នុ៎ះរបស់អញ ចំពោះចក្ខុវិញ្ញាណធាតុថា នុ៎ះរបស់អញ ចំពោះសោតធាតុថា នុ៎ះរបស់អញ ចំពោះសទ្ទធាតុថា នុ៎ះរបស់អញ ចំពោះសោតវិញ្ញាណធាតុថា នុ៎ះរបស់អញ ចំពោះឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ និងមនោធាតុថា នុ៎ះរបស់អញ ចំពោះធម្មធាតុថា នុ៎ះរបស់អញ ចំពោះមនោវិញ្ញាណធាតុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៨] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះចក្ខុន្ទ្រិយថា នុ៎ះរបស់អញ ចំពោះសោតិន្ទ្រិយថា នុ៎ះរបស់អញ ចំពោះឃានិន្ទ្រិយថា នុ៎ះរបស់អញ ចំពោះជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជីវិតិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[៩] កាមធាតុំ ឯតំ មម រូបធាតុំ ឯតំ មម អរូបធាតុំ ឯតំ មម កាមភវំ ឯតំ មម រូបភវំ ឯតំ មម អរូបភវំ ឯតំ មម សញ្ញាភវំ ឯតំ មម អសញ្ញាភវំ ឯតំ មម នេវសញ្ញានាសញ្ញាភវំ ឯតំ មម ឯកវោការភវំ ឯតំ មម ចតុវោការភវំ ឯតំ មម បញ្ចវោការភវំ ឯតំ មម បឋមជ្ឈានំ ឯតំ មម ទុតិយជ្ឈានំ ឯតំ មម តតិយជ្ឈានំ ឯតំ មម ចតុត្ថជ្ឈានំ ឯតំ មម មេត្តាចេតោវិមុត្តឹ ឯតំ មម ករុណាចេតោវិមុត្តឹ ឯតំ មម មុទិតាចេតោវិមុត្តឹ ឯតំ មម ឧបេក្ខាចេតោវិមុត្តឹ ឯតំ មម អាកាសានញ្ចាយតនសមាបត្តឹ វិញ្ញាណញ្ចាយតនសមាបត្តឹ អាកិញ្ចញ្ញាយតនសមាបត្តឹ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ។

[៩] ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះកាមធាតុថា នុ៎ះរបស់អញ ចំពោះរូបធាតុថា នុ៎ះរបស់អញ ចំពោះអរូបធាតុថា នុ៎ះរបស់អញ ចំពោះកាមភពថា នុ៎ះរបស់អញ ចំពោះរូបភពថា នុ៎ះរបស់អញ ចំពោះអរូបភពថា នុ៎ះរបស់អញ ចំពោះសញ្ញាភពថា នុ៎ះរបស់អញ ចំពោះអសញ្ញាភពថា នុ៎ះរបស់អញ ចំពោះនេវសញ្ញានាសញ្ញាភពថា នុ៎ះរបស់អញ ចំពោះឯកវោការភពថា នុ៎ះរបស់អញ ចំពោះចតុវោ-ការភពថា នុ៎ះរបស់អញ ចំពោះបញ្ចវោការភពថា នុ៎ះរបស់អញ ចំពោះបឋមជ្ឈានថា នុ៎ះរបស់អញ ចំពោះទុតិយជ្ឈានថា នុ៎ះរបស់អញ ចំ-ពោះតតិយជ្ឈានថា នុ៎ះរបស់អញ ចំពោះចតុត្ថជ្ឈានថា នុ៎ះរបស់អញ ចំពោះមេត្តាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះករុណាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះមុទិតាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះឧបេក្ខា-ចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ និងនេវសញ្ញា-នាសញ្ញាយតនសមាបត្តិថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

៩

មហាវគ្គេ ទិដ្ឋិកថា

[១០] អវិជ្ជំ ឯតំ មម សង្ខារេ ឯតំ មម វិញ្ញាណំ ឯតំ មម នាមរូបំ ឯតំ មម សឡាយតនំ ឯតំ មម ផស្សំ .ឯតំ មម វេទនំ ឯតំ មម តណ្ហំ ឯតំ មម ឧបាទានំ ឯតំ មម ភវំ ឯតំ មម ជាតឹ ឯតំ មម ជរាមរណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ អភិនិវេសបរាមាសោ ទិដ្ឋិ ឯវំ អភិនិវេសបរាមាសោ ទិដ្ឋិ ។

[១១] កតមានិ អដ្ឋ ទិដ្ឋិដ្ឋានានិ ។ ខន្ធាបិ ទិដ្ឋិដ្ឋានំ អវិជ្ជាបិ ទិដ្ឋិដ្ឋានំ ផស្សោបិ ទិដ្ឋិដ្ឋានំ សញ្ញាបិ ទិដ្ឋិដ្ឋានំ វិតក្កាបិ ទិដ្ឋិដ្ឋានំ អយោនិសោមនសិការោបិ ទិដ្ឋិដ្ឋានំ បាបមិត្តោបិ ទិដ្ឋិដ្ឋានំ បរតោឃោសោបិ ទិដ្ឋិដ្ឋានំ ។

មហាវគ្គ ទិដ្ឋិកថា

[១០] ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល ចំពោះអវិជ្ជាថា នុ៎ះរបស់អញ ចំពោះសង្ខារទាំងឡាយថា នុ៎ះរបស់អញ ចំពោះវិញ្ញាណថា នុ៎ះរបស់អញ ចំពោះនាមរូបថា នុ៎ះរបស់អញ ចំពោះសឡាយតនៈថា នុ៎ះរបស់អញ ចំពោះផស្សៈថា នុ៎ះរបស់អញ ចំពោះវេទនាថា នុ៎ះរបស់អញ ចំពោះតណ្ហាថា នុ៎ះរបស់អញ ចំពោះឧបាទានថា នុ៎ះរបស់អញ ចំពោះភពថា នុ៎ះរបស់អញ ចំពោះជាតិថា នុ៎ះរបស់អញ ចំពោះជរាមរណៈថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលយ៉ាងនេះឯង ។

[១១] ហេតុនៃទិដ្ឋិ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ខន្ធជាហេតុនៃទិដ្ឋិ ១ អវិជ្ជាជាហេតុនៃទិដ្ឋិ ១ ផស្សៈជាហេតុនៃទិដ្ឋិ ១ សញ្ញាជាហេតុនៃទិដ្ឋិ ១ វិតក្កៈជាហេតុនៃទិដ្ឋិ ១ អយោនិសោមនសិការៈជាហេតុនៃទិដ្ឋិ ១ បាបមិត្តជាហេតុនៃទិដ្ឋិ ១ បរតោឃោសៈ (សម្ដីឃោសនារបស់បុគ្គលដទៃ) ជាហេតុនៃទិដ្ឋិ ១ ។

ឧទ្ធច្ចំ ហេតុ ឧទ្ធច្ចំ បច្ចយោ និព្វិជ្ជានំ ឧបា-ទាយ សមុដ្ឋានដ្ឋេន ឯវំ ឧទ្ធច្ចំបិ និព្វិជ្ជានំ អវិជ្ជា ហេតុ អវិជ្ជា បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋា-នដ្ឋេន ឯវំ អវិជ្ជាបិ និព្វិជ្ជានំ ផស្សោ ហេតុ ផស្សោ បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ ផស្សោបិ និព្វិជ្ជានំ សញ្ញា ហេតុ សញ្ញា បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ សញ្ញាបិ និព្វិជ្ជានំ វិតក្កោ ហេតុ វិតក្កោ បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ វិតក្កោបិ និព្វិជ្ជានំ អយោនិសោមនសិការោ ហេតុ អយោនិសោមនសិ-ការោ បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ អយោនិសោមនសិការោបិ និព្វិជ្ជានំ បាបមិត្តោ ហេតុ បាបមិត្តោ បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ បាបមិត្តោបិ និព្វិជ្ជានំ បរតោ-ឃោសោ ហេតុ បរតោឃោសោ បច្ចយោ និព្វិជ្ជានំ ឧបាទាយ សមុដ្ឋានដ្ឋេន ឯវំ បរតោឃោសោបិ និព្វិជ្ជានំ ឥមានិ អដ្ឋ និព្វិជ្ជានានិ ។

ខន្ធជាហេតុ ខន្ធជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យ នូវហេតុនៃទិដ្ឋិ ខន្ធ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ អវិជ្ជាជាហេតុ អវិជ្ជាជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យ នូវហេតុនៃទិដ្ឋិ អវិជ្ជា ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ ផស្សៈជាហេតុ ផស្សៈ ជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យ នូវហេតុនៃទិដ្ឋិ ផស្សៈ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ សញ្ញាជាហេតុ សញ្ញាជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ សញ្ញា ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ វិតក្កៈជាហេតុ វិតក្កៈជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ វិតក្កៈ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ អយោនិសោ-មនសិការៈជាហេតុ អយោនិសោមនសិការៈជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ អយោនិសោមនសិការៈ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ បាបមិត្តជាហេតុ បាបមិត្តជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ បាបមិត្ត ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ បរតោឃោសៈ (សម្ដីឃោសនានៃបុគ្គលដទៃ) ជាហេតុ បរតោឃោសៈ ជាបច្ច័យ ដោយអត្ថថាតាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ បរតោឃោសៈ ឈ្មោះថាហេតុនៃទិដ្ឋិ យ៉ាងនេះ ១ នេះ ហេតុនៃទិដ្ឋិ ៨ យ៉ាង ។

[១២] កតមានិ អដ្ឋារស ទិដ្ឋិបរិយុដ្ឋានានិ ។ យា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារំ ទិដ្ឋិវិសូកំ ទិដ្ឋិវិបន្ទតំ[១] ទិដ្ឋិសំយោជនំ ទិដ្ឋិសល្លំ ទិដ្ឋិសម្ភរោ[២] ទិដ្ឋិបលិពោធោ ទិដ្ឋិពន្ធនំ ទិដ្ឋិបបាតោ ទិដ្ឋានុសយោ ទិដ្ឋិសន្តាបោ ទិដ្ឋិបរិឡាហោ ទិដ្ឋិគន្ថោ ទិដ្ឋុបាទានំ ទិដ្ឋាភិនិវេសោ ទិដ្ឋិបរាមាសោ ឥមានិ អដ្ឋារស ទិដ្ឋិបរិយុដ្ឋានានិ ។

[១៣] កតមា សោឡស ទិដ្ឋិយោ ។ អស្សាទទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ សក្កាយទិដ្ឋិ សក្កាយវត្ថុកា សស្សតទិដ្ឋិ សក្កាយវត្ថុកា ឧច្ឆេទទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ បុព្វន្តានុទិដ្ឋិ អបរន្តានុទិដ្ឋិ សញ្ញោជនិកា ទិដ្ឋិ អហន្តិ មានវិនិពន្ធា ទិដ្ឋិ មមន្តិ មានវិនិពន្ធា ទិដ្ឋិ អត្តវាទប្បដិសំយុត្តា ទិដ្ឋិ លោកវាទប្បដិសំយុត្តា ទិដ្ឋិ ភវទិដ្ឋិ វិភវទិដ្ឋិ ឥមា សោឡស ទិដ្ឋិយោ ។

---

១ ឱ. ម. ទិដ្ឋិវិប្ផន្ទិតំ ។ ២ ឱ. ម. ទិដ្ឋិសម្ពាធោ ។

[១២] ការរួបរឹត គឺទិដ្ឋិ ១៨ យ៉ាង តើដូចម្ដេចខ្លះ ។ ទិដ្ឋិដំណើរគឺទិដ្ឋិ ១ ការប្រកាន់គឺទិដ្ឋិ ១ ផ្លូវកន្តារៈគឺទិដ្ឋិ ១ ចម្រូងគឺទិដ្ឋិ ១ ការវិបត្តិគឺទិដ្ឋិ ១ សំយោជនៈគឺទិដ្ឋិ ១ សរគឺទិដ្ឋិ ១ ការចង្អៀតចិត្តគឺទិដ្ឋិ ១ ការកង្វល់គឺទិដ្ឋិ ១ ចំណងគឺទិដ្ឋិ ១ ជ្រោះគឺទិដ្ឋិ ១ អនុស័យគឺទិដ្ឋិ ១ កម្ដៅគឺទិដ្ឋិ ១ ក្រហល់ក្រហាយគឺទិដ្ឋិ ១ គ្រឿងចាក់ស្រែះគឺទិដ្ឋិ ១ គ្រឿងប្រកាន់គឺទិដ្ឋិ ១ ការប្រកាន់ស្អិតគឺទិដ្ឋិ ១ ការស្ទាបអង្អែលគឺទិដ្ឋិ ១ នេះ ការរួបរឹតគឺទិដ្ឋិ ១៨ យ៉ាង ។

[១៣] ទិដ្ឋិ ១៦ យ៉ាង តើដូចម្ដេចខ្លះ ។ អស្សាទទិដ្ឋិ ១ អត្តានុទិដ្ឋិ ១ មិច្ឆាទិដ្ឋិ ១ សក្កាយទិដ្ឋិ ១ សក្កាយវត្ថុកសស្សតទិដ្ឋិ ១ សក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ១ អន្តគ្គាហិកទិដ្ឋិ ១ បុព្វន្តានុទិដ្ឋិ ១ អបរន្តានុទិដ្ឋិ ១ សញ្ញោជនិកទិដ្ឋិ ១ ទិដ្ឋិដែលជាប់ដោយមានះថាអញ ១ ទិដ្ឋិដែលជាប់ដោយមានះថារបស់អញ ១ អត្តវាទប្បដិសំយុត្តទិដ្ឋិ ១ លោកវាទប្បដិសំយុត្តទិដ្ឋិ ១ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ នេះ ទិដ្ឋិ ១៦ យ៉ាង ។

[១៤] (១)អស្សាទទិដ្ឋិយា កតិហាការេហិ(២) អភិនិវេសោ ហោតិ អត្តានុទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ មិច្ឆាទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ សក្កាយទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ បុព្វន្តានុទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ អបរន្តានុទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ សញ្ញោជនិកាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ អហន្តិ មានវិនិពន្ធាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ មមន្តិ មានវិនិពន្ធាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ

---

១ ម. ឯត្តន្តរេ កតមេហិ តីណិសតំ ទិដ្ឋាភិនិវេសាតិ ទិស្សន្តិ ។ ២ កតិហាការេហីតិ លិខិតំ វដ្ដតិ ។

[១៤] ការប្រកាន់ស្អិត នៃអស្សាទទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃអត្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃមិច្ឆាទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃសក្កាយទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃសក្កាយវត្ថុកសស្សតទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃសក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃបុព្វន្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃអបរន្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃសញ្ញោជនិកទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃទិដ្ឋិ ដែលជាប់ដោយមានះថាអញ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃទិដ្ឋិដែលជាប់ដោយមានះ ថារបស់អញ ដោយអាការប៉ុន្មានយ៉ាង

អត្តវាទប្បដិសំយុត្តាយ ទិដ្ឋិយា កតិហាការេហិ
អភិនិវេសោ ហោតិ លោកវាទប្បដិសំយុត្តាយ ទិ-
ដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ ភវទិដ្ឋិ-
យា កតិហាការេហិ អភិនិវេសោ ហោតិ វិភវទិដ្ឋិ-
យា កតិហាការេហិ អភិនិវេសោ ហោតិ ។

[១៤] អស្សាទទិដ្ឋិយា បញ្ចត្តឹសាយ អាការេហិ
អភិនិវេសោ ហោតិ អត្តានុទិដ្ឋិយា វីសតិយា អា-
ការេហិ អភិនិវេសោ ហោតិ មិច្ឆាទិដ្ឋិយា ទសហា-
ការេហិ អភិនិវេសោ ហោតិ សក្កាយទិដ្ឋិយា វីស-
តិយា អាការេហិ អភិនិវេសោ ហោតិ សក្កាយវត្ថុ-
កាយ សស្សតទិដ្ឋិយា បណ្ណរសហិ អាការេហិ
អភិនិវេសោ ហោតិ សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិ-
យា បញ្ចហាការេហិ អភិនិវេសោ ហោតិ អន្តគ្គាហិ-
កាយ ទិដ្ឋិយា បញ្ញាសាយ អាការេហិ អភិនិវេសោ
ហោតិ បុព្វន្តានុទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិ-
និវេសោ ហោតិ អបរន្តានុទិដ្ឋិយា ចតុចត្តាឡីសាយ
អាការេហិ អភិនិវេសោ ហោតិ សញ្ញោជនិកាយ
ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ

ការប្រកាន់ស្អិត នៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃភវទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិត នៃវិភវទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ។

[១៥] ការប្រកាន់ស្អិត នៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ យ៉ាង ការប្រកាន់ស្អិតនៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិត នៃមិច្ឆាទិដ្ឋិ ដោយអាការ ១០ យ៉ាង ការប្រកាន់ស្អិត នៃសក្កាយទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិត នៃសក្កាយវត្ថុកសស្សតទិដ្ឋិ ដោយអាការ ១៥ យ៉ាង ការប្រកាន់ស្អិត នៃសក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ដោយអាការ ៥ យ៉ាង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ យ៉ាង ការប្រកាន់ស្អិត នៃបុព្វន្តានុទិដ្ឋិ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិត នៃអបរន្តានុទិដ្ឋិ ដោយអាការ ៤៤ យ៉ាង ការប្រកាន់ស្អិត នៃសញ្ញោជនិកទិដ្ឋិ ដោយអាការ ១៨ យ៉ាង

អហន្តិ មានវិនិពន្ធាយ ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ មមន្តិ មានវិនិពន្ធាយ ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ អត្តវាទប្បដិសំយុត្តាយ ទិដ្ឋិយា វីសតិយា អាការេហិ អភិនិវេសោ ហោតិ លោកវាទប្បដិសំយុត្តាយ ទិដ្ឋិយា អដ្ឋហិ អាការេហិ អភិនិវេសោ ហោតិ ភវទិដ្ឋិយា ឯកូនវីសតិយា[១] អាការេហិ អភិនិវេសោ ហោតិ វិភវទិដ្ឋិយា ឯកូនវីសតិយា អាការេហិ អភិនិវេសោ ហោតិ ។

[១៦] អស្សាទទិដ្ឋិយា កតមេហិ បញ្ចត្តឹសាយ អាការេហិ អភិនិវេសោ ហោតិ ។ យំ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបស្ស អស្សាទោតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន អស្សាទោ អស្សាទោ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញោ អស្សាទោ យា ច ទិដ្ឋិ យោ ច អស្សាទោ អយំ វុច្ចតិ អស្សាទទិដ្ឋិ អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ[២] តាយ ទិដ្ឋិវិបត្តិយា សមន្នាគតោ បុគ្គលោ ទិដ្ឋិវិបន្នោ ទិដ្ឋិវិបន្នោ បុគ្គលោ

---

១ ឱ. ម. ឯកេន អាការេន ។ ២ ឱ. ម. មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។

ការប្រកាន់ស្អិត នៃទិដ្ឋិដែលជាប់ដោយមានះថាអញ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិត នៃទិដ្ឋិ ដែលជាប់ដោយមានះថារបស់អញ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិត នៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិត នៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ យ៉ាង ការប្រកាន់ស្អិត នៃភវទិដ្ឋិ ដោយអាការ ១៩ យ៉ាង ការប្រកាន់ស្អិត នៃវិភវទិដ្ឋិ ដោយអាការ ១៩ យ៉ាង ។

[១៦] ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ យ៉ាង តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា សុខនិងសោមនស្ស កើតឡើង ព្រោះអាស្រ័យរូប នេះ ឈ្មោះថាអស្សាទៈ (តម្រេក) ចំពោះរូបនោះ ទិដ្ឋិ មិនមែនអស្សាទៈ អស្សាទៈក៏មិនមែនទិដ្ឋិ ទិដ្ឋិ ដោយឡែក អស្សាទៈ ដោយឡែក ទិដ្ឋិណា និង អស្សាទៈណា នេះលោកហៅថា អស្សាទទិដ្ឋិ អស្សាទ-ទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ បុគ្គលដែលប្រកបដោយទិដ្ឋិវិបត្តិនោះ ឈ្មោះថា អ្នកវិបត្តិព្រោះទិដ្ឋិ បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ

១៨



ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា យា ទិដ្ឋិ យោ រាគោ សោ ន ទិដ្ឋិ ទិដ្ឋិ ន រាគោ អញ្ញា ទិដ្ឋិ អញ្ញោ រាគោ យា ច ទិដ្ឋិ យោ ច រាគោ អយំ វុច្ចតិ ទិដ្ឋិរាគោ តាយ ច ទិដ្ឋិយា តេន ច រាគេន សមន្នាគតោ បុគ្គលោ ទិដ្ឋិរាគរត្តោ ទិដ្ឋិរាគរត្តេ បុគ្គលេ ទិន្នទានំ ន មហប្ផលំ ហោតិ ន មហា-និសំសំ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គ-លស្ស ទ្វេ ច គតិយោ និរយោ វា តិរច្ឆានយោនិ វា មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កា-យកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ

គេមិនត្រូវសេពគប់ គេមិនត្រូវគប់រក គេមិនត្រូវចូលទៅអង្គុយជិតទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ទិដ្ឋិណា រាគៈណា រាគៈនោះមិនមែនទិដ្ឋិ ទិដ្ឋិក៏មិនមែនរាគៈ ទិដ្ឋិដោយឡែក រាគៈដោយឡែក ទិដ្ឋិណា និង រាគៈណា នេះហៅថា ទិដ្ឋិរាគៈ បុគ្គលប្រកបដោយទិដ្ឋិនោះផង ដោយរាគៈនោះផង ឈ្មោះថា អ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើនទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថាទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បុរសបុគ្គលប្រកបដោយមិច្ឆា-ទិដ្ឋិ មានគតិ ២ យ៉ាង គឺនរក ១ កំណើតតិរច្ឆាន ១ កាយកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្តី វចីកម្មណា មនោកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលកាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី (ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ

តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា សេយ្យថាបិ និម្ពពីជំ វា កោសាតកីពីជំ វា តិត្តកលាពុពីជំ វា អល្លាយ បឋវិយា និក្ខិត្តំ យញ្ចេវ បឋវីរសំ ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ តិត្តកតាយ កដុកតាយ អសារតាយ[១] សំវត្តតិ តំ កិស្សហេតុ ពីជំ ហិស្ស បាបិកំ ឯវមេវ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ យា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ។ បេ ។ ទិដ្ឋាភិនិវេសបរាមាសោ ហោតិ ។

១ អសាតត្តាយាតិ អង្គុត្តរេ ទិស្សតិ ។

ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្ម-ជាតិដ៏លាមក ប្រៀបដូចពូជស្ដៅក្ដី ពូជននោងព្រៃក្ដី ពូជឃ្លោកល្វីងក្ដី ដែលគេដាំ ក្នុងផែនដីសើម រមែងជញ្ជក់រសផែនដីណាក្ដី ជញ្ជក់យករសទឹកណាក្ដី ពូជទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីល្វីង ដើម្បីក្រពុល ដើម្បីមិនឆ្ងាញ់ពិសា ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ពូជឈើនោះ ជាវត្ថុដ៏អាក្រក់ មានឧបមាដូចម្ដេចមិញមានឧបមេយ្យដូចជា កាយកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយក្ដី វចីកម្មណា មនោកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្ដី ចេតនាណាក្ដី សេចក្ដីប្រាថ្នាណាក្ដី ការតម្កល់ទុកណាក្ដីសង្ខារទាំងឡាយណាក្ដី (ដែលបុរសបុគ្គល ប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នាមិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដំណើរនោះព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បានខាងទិដ្ឋិ ដំណើរគឺទិដ្ឋិព្រៀតស្បាតគឺទិដ្ឋិ ។ បេ ។ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលគឺទិដ្ឋិ ។

មហាវគ្គេ ទិដ្ឋិកថា

[១៧] យំ វេទនំ បដិច្ច យំ សញ្ញំ បដិច្ច យំ សង្ខារេ បដិច្ច យំ វិញ្ញាណំ បដិច្ច យំ ចក្ខុំ បដិច្ច យំ សោតំ បដិច្ច យំ ឃានំ បដិច្ច យំ ជិវ្ហំ បដិច្ច យំ កាយំ បដិច្ច យំ មនំ បដិច្ច យំ រូបេ បដិច្ច យំ សទ្ទេ បដិច្ច យំ គន្ធេ បដិច្ច យំ រសេ បដិច្ច យំ ផោដ្ឋព្វេ បដិច្ច យំ ធម្មេ បដិច្ច យំ ចក្ខុវិញ្ញាណំ បដិច្ច យំ សោត-វិញ្ញាណំ បដិច្ច យំ ឃានវិញ្ញាណំ បដិច្ច យំ ជិវ្ហាវិញ្ញាណំ បដិច្ច យំ កាយវិញ្ញាណំ បដិច្ច យំ មនោវិញ្ញាណំ បដិច្ច យំ ចក្ខុសម្ផស្សំ បដិច្ច យំ សោតសម្ផស្សំ បដិច្ច យំ ឃាន-សម្ផស្សំ បដិច្ច យំ ជិវ្ហាសម្ផស្សំ បដិច្ច យំ កាយសម្ផស្សំ បដិច្ច យំ មនោសម្ផស្សំ បដិច្ច យំ ចក្ខុសម្ផស្សជំ វេទនំ បដិច្ច យំ សោតសម្ផស្សជំ វេទនំ បដិច្ច យំ ឃានសម្ផស្សជំ វេទនំ បដិច្ច

មហាវគ្គ ទិដ្ឋិកថា

[១៧] ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា សុខនិងសោមនស្សកើតឡើង ព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ ព្រោះអាស្រ័យចក្ខុ ព្រោះអាស្រ័យសោតៈ ព្រោះអាស្រ័យឃានៈ ព្រោះអាស្រ័យជិវ្ហា ព្រោះអាស្រ័យកាយ ព្រោះអាស្រ័យចិត្ត ព្រោះអាស្រ័យរូប ព្រោះអាស្រ័យសទ្ទៈ ព្រោះអាស្រ័យគន្ធៈ ព្រោះអាស្រ័យរស ព្រោះអាស្រ័យផោដ្ឋព្វៈ ព្រោះអាស្រ័យធម្មារម្មណ៍ ព្រោះអាស្រ័យចក្ខុវិញ្ញាណ ព្រោះអាស្រ័យសោតវិញ្ញាណ ព្រោះអាស្រ័យឃានវិញ្ញាណ ព្រោះអាស្រ័យជិវ្ហាវិញ្ញាណ ព្រោះអាស្រ័យកាយវិញ្ញាណ ព្រោះអាស្រ័យមនោវិញ្ញាណ ព្រោះអាស្រ័យចក្ខុសម្ផស្ស ព្រោះអាស្រ័យសោតសម្ផស្ស ព្រោះអាស្រ័យឃានសម្ផស្ស ព្រោះអាស្រ័យជិវ្ហាសម្ផស្ស ព្រោះអាស្រ័យកាយសម្ផស្ស ព្រោះអាស្រ័យមនោសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីសោតសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីឃានសម្ផស្ស

១៨



យំ ជិវ្ហាសម្ផស្សជំ វេទនំ បដិច្ច យំ កាយសម្ផស្សជំ វេទនំ បដិច្ច យំ មនោសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ មនោសម្ផស្សជាយ វេទនាយ អស្សាទោតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន អស្សាទោ អស្សាទោ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញោ អស្សាទោ យា ច ទិដ្ឋិ យោ ច អស្សាទោ អយំ វុច្ចតិ អស្សាទទិដ្ឋិ អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ តាយ ទិដ្ឋិវិបត្តិយា សមន្នាគតោ បុគ្គលោ ទិដ្ឋិវិបន្នោ ទិដ្ឋិវិបន្នោ បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា យា ទិដ្ឋិ យោ រាគោ សោ ន ទិដ្ឋិ ទិដ្ឋិ ន រាគោ អញ្ញា ទិដ្ឋិ អញ្ញោ រាគោ យា ច ទិដ្ឋិ យោ ច រាគោ អយំ វុច្ចតិ ទិដ្ឋិរាគោ តាយ ច ទិដ្ឋិយា តេន ច រាគេន សមន្នាគតោ បុគ្គលោ ទិដ្ឋិរាគរត្តោ ទិដ្ឋិរាគរត្តេ បុគ្គលេ ទិន្នទានំ ន មហប្ផលំ ហោតិ

ព្រោះអាស្រ័យវេទនា ដែលកើតអំពីជិវ្ហាសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីកាយសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីមនោ-សម្ផស្ស នេះជាអស្សាទៈ ចំពោះវេទនា ដែលកើតអំពីមនោសម្ផស្ស ទិដ្ឋិ មិនមែនអស្សាទៈ អស្សាទៈ ក៏មិនមែនទិដ្ឋិ ទិដ្ឋិ ដោយឡែក អស្សាទៈ ដោយឡែក ទិដ្ឋិណា និង អស្សាទៈណា នេះលោកហៅថា អស្សាទទិដ្ឋិ អស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ បុគ្គលប្រកប ដោយទិដ្ឋិវិបត្តិនោះ ឈ្មោះថាអ្នកវិបត្តិព្រោះទិដ្ឋិ បុគ្គលដែលវិបត្តិ ព្រោះទិដ្ឋិ គេមិនត្រូវសេពគប់ គេមិនត្រូវគប់រក គេមិនត្រូវចូលទៅអង្គុយ ជិតទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ទិដ្ឋិណា រាគៈណា រាគៈនោះ មិនមែនទិដ្ឋិ ទិដ្ឋិ ក៏មិនមែនរាគៈ ទិដ្ឋិដោយឡែក រាគៈដោយឡែក ទិដ្ឋិណា និង រាគៈណា នេះលោកហៅថា ទិដ្ឋិរាគៈ បុគ្គលប្រកបដោយទិដ្ឋិនោះផង ដោយ រាគៈនោះផង ឈ្មោះថាអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ទានដែលទាយកឲ្យ ហើយ ដល់បុគ្គលអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ជាទានមិនមានផលច្រើន

ន មហានិសំសំ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស ទ្វេ ច គតិយោ និរយោ វា តិរច្ឆានយោនិ វា មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ តំ កិស្សហេតុ ទិដ្ឋិ ហិស្ស បាបិកា សេយ្យថាបិ និម្ពពីជំ វា កោសាតកីពីជំ វា តិត្តកលាពុពីជំ វា អល្លាយ បឋវិយា និក្ខិត្តំ យញ្ចេវ បឋវីរសំ ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ តិត្តកតាយ កដុកតាយ អសាតតាយ សំវត្តតិ តំ កិស្សហេតុ

មិនមានអានិសង្សច្រើនទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ មានគតិ ២ យ៉ាង គឺនរក ១ កំណើតតិរច្ឆាន ១ កាយកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្តី វចីកម្មណា មនោកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលកាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី (ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយ) ធម៌ទាំងអស់នោះប្រព្រឹត្តទៅដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ប្រៀបដូចពូជស្តៅក្តី ពូជននោងព្រៃក្តី ពូជឃ្លោកល្វីងក្តី ដែលគេដាំក្នុងផែនដីសើម រមែងជញ្ជក់យករសផែនដីណាក្តី ជញ្ជក់យករសទឹកណាក្តី ពូជទាំងអស់នោះរមែងប្រព្រឹត្តទៅដើម្បីល្វីង ដើម្បីក្រពុល ដើម្បីមិនឆ្ងាញ់ពិសា ដំណើរនោះ ព្រោះហេតុអ្វី

ពីជំ ហិស្ស បាបិកំ ឯវមេវ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិស-មត្តំ សមាទិន្នំ យញ្ច វចីកម្មំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិ-តាយ ទុក្ខាយ សំវត្តន្តិ តំ កិស្សហេតុ ទិដ្ឋិ ហិ-ស្ស បាបិកា អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ យា ទិដ្ឋិ ទិដ្ឋិ-គតំ ទិដ្ឋិគហនំ ។ បេ ។ ទិដ្ឋាភិនិវេសបរាមាសោ ហោតិ ឥមេហិ អដ្ឋារសហិ អាការេហិ បរិយុដ្ឋិត-ចិត្តស្ស សំយោគោ អស្សាទទិដ្ឋិភូតា មិច្ឆាទិដ្ឋិ ។

ព្រោះថា ពូជឈើនោះ ជាវត្ថុដ៏អាក្រក់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា កាយកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយក្តី វចីកម្មណា មនោកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី (ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិ របស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បានខាងទិដ្ឋិ ដំណើរគឺទិដ្ឋិ ញៀតស្បាតគឺទិដ្ឋិ ។ បេ ។ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលគឺទិដ្ឋិ ការប្រកបព្រមនៃចិត្តដែលត្រូវកិលេសរួបរឹត គឺមិច្ឆាទិដ្ឋិ ជាអស្សាទទិដ្ឋិ ដោយអាការ ១៨ យ៉ាងនេះឯង ។

[១៨] អត្ថិ សញ្ញោជនានិ ចេវ ទិដ្ឋិយោ ច អត្ថិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ។ កតមានិ សញ្ញោជនានិ ចេវ ទិដ្ឋិយោ ច ។ សក្កាយទិដ្ឋិបរាមាសោ[១] ចេវ សក្កាយទិដ្ឋិ សីលព្វតបរាមាសោ ច ឥមានិ សញ្ញោជនានិ ចេវ ទិដ្ឋិយោ ច ។ កតមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ។ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ មានសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ ភវរាគសញ្ញោជនំ ឥស្សាសញ្ញោជនំ មច្ឆរិយសញ្ញោជនំ អនុសយសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយា ។ អស្សាទទិដ្ឋិយា ឥមេហិ បញ្ចត្តឹសាយ អាការេហិ អភិនិវេសោ ហោតិ ។

[១៩] អត្តានុទិដ្ឋិយា កតមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសធម្មស្ស អកោវិទោ

១ ឱ. អយំ បាហោ នត្ថិ ។ ២ ឱ. សប្បុរិសានំ អទស្សាវី ។

[១៨] *សំយោជនៈផង ទិដ្ឋិផងក៏មាន សំយោជនៈ មិនមែនទិដ្ឋិក៏មាន ។ សំយោជនៈផង ទិដ្ឋិផង តើដូចម្តេចខ្លះ ។ សក្កាយទិដ្ឋិបរាមាសៈ និងសក្កាយទិដ្ឋិ សីលព្វតបរាមាសៈ ទាំងនេះ ឈ្មោះថាសំយោជនៈផង ទិដ្ឋិផង ។ សំយោជនៈ មិនមែនទិដ្ឋិ តើដូចម្តេចខ្លះ ។ កាមរាគសំយោជនៈ បដិឃសំយោជនៈ មានសំយោជនៈ វិចិកិច្ឆាសំយោជនៈ ភវរាគសំយោជនៈ ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ អនុសយសំយោជនៈ អវិជ្ជាសំយោជនៈ ទាំងនេះ ឈ្មោះថាសំយោជនៈ មិនមែនទិដ្ឋិ ។ នេះឯងការប្រកាន់ស្អិត នៃអស្សាទទិដ្ឋិដោយអាការ ៣៥ ។*

[១៩] *ការប្រកាន់ស្អិត នៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាងតើដូចម្តេចខ្លះ ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ចិត្តក្នុងធម៌របស់ព្រះអរិយៈ មិនឈ្លាសវៃចំពោះធម៌របស់សប្បុរស*

សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ............... សញ្ញំ ............. សង្ខារេ ............ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។

[២០] កថំ រូបំ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ បឋវីកសិណំ អត្តតោ សមនុបស្សតិ យំ បឋវីកសិណំ សោ អហំ យោ អហំ តំ បឋវីកសិណន្តិ បឋវីកសិណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈាយ-តោ យា អច្ចិ[១] សោ វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ បឋវីកសិណំ អត្តតោ សមនុបស្សតិ

១ ឱ. ម. អច្ចិ ។

មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស ពិចារណាឃើញរូប ថាជាខ្លួន ១ ពិចារណាឃើញខ្លួន ថាមានរូប ១ ពិចារណាឃើញរូប ថាមានក្នុងខ្លួន ១ ពិចារណាឃើញខ្លួន ថាមានក្នុងរូប ១ ពិចារណាឃើញវេទនា[១]... សញ្ញា[១] ... សង្ខារទាំងឡាយ[១] ... ពិចារណាឃើញវិញ្ញាណ ថាជាខ្លួន ១ ពិចារណាឃើញខ្លួន ថាមានវិញ្ញាណ ១ ពិចារណាឃើញវិញ្ញាណ ថាមានក្នុងខ្លួន ១ ពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ ១ (នេះការប្រកាន់ស្អិត នៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង) ។

[២០] បុគ្គលពិចារណាឃើញរូប ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ថាជាខ្លួន ថា ណា ជាបឋវីកសិណ នោះគឺអញ ណាជាអញ នោះ គឺបឋវីកសិណ ឈ្មោះថាពិចារណាឃើញបឋវីកសិណនិងខ្លួន ថាមិនមែនពីរ គឺតែមួយ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា នោះគឺរស្មី ណាជារស្មី នោះ ក៏គឺអណ្តាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ថាជាខ្លួន

---

១ ញែកចេញជា ៤ ដូចរូបខាងដើមនោះដែរ ។

យំ បឋវីកសិណំ សោ អហំ យោ អហំ តំ បឋវី-
កសិណន្តិ បឋវីកសិណញ្ច អត្តញ្ច អទ្វយំ សមនុ-
បស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ
ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ
យញ្ច វត្ថុ អយំ បឋមា រូបវត្ថុកា អត្តានុទិដ្ឋិ
អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ អត្តានុទិដ្ឋិកស្ស
បុរិសបុគ្គលស្ស ទ្វេ ច គតិយោ ។ បេ ។ ឥមានិ
សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯកច្ចោ អាបោ-
កសិណំ តេជោកសិណំ វាយោកសិណំ នីលក-
សិណំ បីតកសិណំ លោហិតកសិណំ ឱទាតក-
សិណំ អត្តតោ សមនុបស្សតិ យំ ឱទាតកសិណំ
សោ អហំ យោ អហំ តំ ឱទាតកសិណន្តិ ឱទា-
តកសិណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យ-
ថាបិ តេលប្បទីបស្ស ឈាយតោ យា អច្ចិ សោ
វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច
អទ្វយំ សមនុបស្សតិ ឯវមេវ ឯកច្ចោ ។ បេ ។

ថា ធម្មជាតណាជាបឋវីកសិណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺបឋវីកសិណ ឈ្មោះថាពិចារណាឃើញបឋវីកសិណនិង ខ្លួន ថាមិនមែនពីរ គឺតែមួយ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជារូប-វត្ថុកៈទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ បុរសបុគ្គលប្រកប ដោយអត្តានុទិដ្ឋិ មានគតិ ២ យ៉ាង ។ បេ ។ នេះឈ្មោះថាសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលក្នុងលោកនេះ ពិចារណាឃើញអាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិត-កសិណ ឱទាតកសិណ ថាជាខ្លួន ថា ធម្មជាតណា ជាឱទាតកសិណ សភាពនោះ គឺអញ សភាពណា ជាអញ ធម្មជាតនោះគឺឱទាតកសិណ ឈ្មោះថាពិចារណាឃើញឱទាតកសិណនិងខ្លួន ថាមិនមែនពីរ ប្រៀបដូច ប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះ ក៏គឺ រស្មី សភាពណាជារស្មី ធម្មជាតិនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូច ម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ។ បេ ។

ឱទាតកសិណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា រូបវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបំ អត្តតោ សមនុបស្សតិ ។

[២១] កថំ រូបវន្តំ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមិនា រូបេន រូបវាតិ រូបវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា

ឈ្មោះថាពិចារណាឃើញឱទាតកសិណានិងខ្លួន ថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជារូបវត្ថុកៈ ទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះឈ្មោះថាសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាជាខ្លួន យ៉ាងនេះឯង ។

[២១] បុគ្គលពិចារណាឃើញខ្លួន ថាមានរូប តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង មានរូបព្រោះរូបនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានរូប ប្រៀបដូចដើមឈើបរិបូណ៌ដោយម្លប់ បុរសគប្បីពោល ចំពោះដើមឈើនោះ យ៉ាងនេះថា នេះដើមឈើ នេះម្លប់ឈើ ដើមឈើដោយឡែក ម្លប់ដោយឡែក

២៨



សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយាវន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមិនា រូបេន រូបវាតិ រូបវន្តំ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ទុតិយា រូបវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបវន្តំ អត្តានំ សមនុបស្សតិ ។

តែដើមឈើនោះឯង  មានម្លប់ព្រោះម្លប់នេះ  ឈ្មោះថាពិចារណាឃើញដើមឈើ  ថាមានម្លប់  មានឧបមាដូចម្តេចមិញ  មានឧបមេយ្យដូចជាបុគ្គលខ្លះ  ក្នុងលោកនេះ  ពិចារណាឃើញវេទនា  សញ្ញា  សង្ខារ  និងវិញ្ញាណ  ថាជាខ្លួន  បុគ្គលនោះ  មានសេចក្តីត្រិះរិះយ៉ាងនេះថា  នេះឯងជាខ្លួនរបស់អញ  តែខ្លួនរបស់អញនោះឯង  មានរូបព្រោះរូបនេះ  ឈ្មោះថាពិចារណាឃើញខ្លួន  ថាមានរូប  ការប្រកាន់ស្អិតនិងការស្ទាបអង្អែលឈ្មោះថាទិដ្ឋិ  ទិដ្ឋិមិនមែនវត្ថុ  វត្ថុក៏មិនមែនទិដ្ឋិ  ទិដ្ឋិដោយឡែក  វត្ថុដោយឡែក  ទិដ្ឋិណា  និងវត្ថុណា  នេះឈ្មោះថាអត្តានុទិដ្ឋិ  ជារូបវត្ថុកៈទី ២  អត្តានុទិដ្ឋិ  ជាមិច្ឆាទិដ្ឋិ  ។  បេ  ។  នេះឈ្មោះថាសំយោជនៈ  មិនមែនទិដ្ឋិ  បុគ្គលពិចារណាឃើញខ្លួន  ថាមានរូប  យ៉ាងនេះឯង  ។

[២២] កថំ អត្តនិ រូបំ សមនុបស្សតិ ។ ឥធេ-កច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ ស-មនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ ឥទំ រូបន្តិ អត្តនិ រូបំ សមនុ-បស្សតិ សេយ្យថាបិ បុប្ផំ គន្ធសម្បន្នំ អស្ស តមេ-នំ បុរិសោ ឯវំ វទេយ្យ ឥទំ បុប្ផំ អយំ គន្ធោ អញ្ញំ បុប្ផំ អញ្ញោ គន្ធោ សោ ខោ បនាយំ គន្ធោ ឥមស្មឹ បុប្ផេតិ បុប្ផស្មឹ គន្ធំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ ឥទំ រូបន្តិ អត្តនិ រូបំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ ។ បេ ។ អយំ តតិយា រូបវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ អត្តនិ រូបំ សមនុបស្សតិ ។

[២២] បុគ្គលពិចារណាឃើញរូប ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯរូបនេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញរូប ថាមានក្នុងខ្លួន ប្រៀបដូចផ្កា ដែលបរិបូណ៌ដោយក្លិនបុរសគប្បីពោល ចំពោះផ្កានោះ យ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននោះឯង (មាន) ក្នុងផ្កានេះ ឈ្មោះថាពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯរូបនេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញរូប ថាមានក្នុងខ្លួន ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ។ បេ ។ នេះឈ្មោះថាអត្តានុទិដ្ឋិ ជារូបវត្ថុកៈ ទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

មហាវគ្គេ ទិដ្ឋិកថា

[២៣] កថំ រូបស្មឹ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្ត-តោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមស្មឹ រូបេតិ រូបស្មឹ អត្តានំ សមនុបស្សតិ សេយ្យថាបិ មណិ ករណ្ឌកេ បក្ខិត្តោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ មណិ អយំ ករណ្ឌកោ អញ្ញោ មណិ អញ្ញោ ករណ្ឌកោ សោ ខោ បនាយំ មណិ ឥមស្មឹ ករណ្ឌកេតិ ករណ្ឌកស្មឹ មណឹ សមនុប-ស្សតិ ឯវមេវ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមស្មឹ រូបេតិ រូបស្មឹ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ចតុត្ថា រូបវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបស្មឹ អត្តានំ សមនុបស្សតិ ។

មហាវគ្គ ទិដ្ឋិកថា

[២៣] បុគ្គលពិចារណាឃើញខ្លួនថាមានក្នុងរូប តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង (មាន) ក្នុងរូបនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងរូប ប្រៀបដូចកែវមណី ដែលគេដាក់ក្នុងដប បុរសគប្បីពោលចំពោះកែវមណីនោះយ៉ាងនេះថា នេះកែវមណី នេះដប កែវមណីដោយឡែក ដបដោយឡែក តែកែវមណីនោះឯង មានក្នុងដបនេះ ឈ្មោះថាពិនិត្យឃើញកែវមណីថាមានក្នុងដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារនិងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង (មាន) ក្នុងរូបនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងរូប ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជារូបវត្ថុកៈទី ៤ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងរូប យ៉ាងនេះឯង ។

[២៤] កាចំ វេទនំ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ ចក្ខុសម្ផស្សជំ វេទនំ សោតសម្ផស្សជំ វេទនំ ឃានសម្ផស្សជំ វេទនំ ជិវ្ហាសម្ផស្សជំ វេទនំ កាយសម្ផស្សជំ វេទនំ មនោសម្ផស្សជំ វេទនំ អត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា វេទ-នា សោ អហំ យោ អហំ សា មនោសម្ផស្សជា វេទនាតិ មនោសម្ផស្សជំ វេទនញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈា-យតោ យា អច្ចិ សោ វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯ-វមេវ ឥធេកច្ចោ មនោសម្ផស្សជំ វេទនំ អត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា វេទនា សោ អហំ យោ អហំ សា មនោសម្ផស្សជា វេទនាតិ

[២៤] បុគ្គលពិចារណាឃើញវេទនា ថាជាខ្លួន ដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា ដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថាធម្មជាតិណា ជាវេទនាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺវេទនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថាពិចារណាឃើញ នូវវេទនាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូច ប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះជារស្មី សភាពណាជារស្មី ធម្មជាតិនោះ គឺអណ្តាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថាធម្មជាតិណា ជាវេទនាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺវេទនាដែលកើតអំពីមនោសម្ផស្ស

មនោសម្ផស្សជំ វេទនញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា វេទនាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ វេទនំ អត្តតោ សមនុបស្សតិ ។

[២៨] កថំ វេទនាវន្តំ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ វេទនាយ វេទនាវាតិ វេទនាវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយាវន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ

ឈ្មោះថាពិចារណាឃើញ នូវវេទនាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ឯវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណានិងវត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវេទនា ថាជាខ្លួន យ៉ាងនេះឯង ។

[២៥] បុគ្គលពិចារណាឃើញខ្លួន ថាមានវេទនា តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះមានសេចក្ដីត្រិះរិះ យ៉ាងនេះថា នេះឯង ជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯងមានវេទនា ព្រោះវេទនានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានវេទនា ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះ យ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនោះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថាពិចារណាឃើញដើមឈើ ថាមានម្លប់ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជា

ឥធេកច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ វេទនាយ វេទនាវាតិ វេទនាវន្តំ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ទុតិយា វេទនាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆា-ទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ វេទនាវន្តំ អត្តានំ សមនុបស្សតិ ។

[៦៦] កថំ អត្តនិ វេទនំ សមនុបស្សតិ ។ ឥធេកច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ អយំ វេទនាតិ អត្តនិ វេទនំ សមនុបស្សតិ សេយ្យថាបិ បុប្ផំ គន្ធសម្បន្នំ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ ឥទំ បុប្ផំ អយំ គន្ធោ អញ្ញំ បុប្ផំ អញ្ញោ គន្ធោ

បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និង រូប ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង មានវេទនា ព្រោះវេទនានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានវេទនា ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ឯវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិជាវេទនាវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានវេទនា យ៉ាងនេះឯង ។

[២៦] បុគ្គលពិចារណាឃើញវេទនាថាមានក្នុងខ្លួនតើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯវេទនានេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញវេទនាថាមានក្នុងខ្លួន ប្រៀបដូចផ្កាឈើ ដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កាឈើនោះ យ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក

សោ ខោ បនាយំ កន្ធោ ឥមស្មឹ បុប្ផេតិ បុប្ផស្មឹ កន្ធំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ អយំ វេទនាតិ អត្តនិ វេទនំ សម-នុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ ។ បេ ។ អយំ តតិយា វេទនាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ អត្តនិ វេទនំ សមនុបស្សតិ ។

[២៧] កថំ វេទនាយ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ វេទនាយាតិ វេទនាយ អត្តានំ សមនុបស្សតិ សេយ្យថាបិ ។ បេ ។

តែក្លិននោះឯងក៏មានក្នុងផ្កានេះ ឈ្មោះថាពិចារណាឃើញក្លិនថាមានក្នុងផ្កាមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯវេទនានេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញវេទនា ថាមានក្នុងខ្លួន ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ។ បេ ។ នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវេទនា ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[២៧] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវេទនា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង (មាន) ក្នុងវេទនានេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានក្នុងវេទនា ប្រៀបដូច ។ បេ ។

ការណ្ឌាកស្មឹ មណឹ សមនុបស្សតិ ឯវមេវ ឥធេ-
កច្ចោ សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុ-
បស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា
សោ ខោ បន មេ អយំ អត្តា ឥមាយ វេទនា-
យាតិ វេទនាយ អត្តានំ សមនុបស្សតិ អភិ-
និវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ
អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ
អយំ ចតុត្ថា វេទនាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ
មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ
ន ច ទិដ្ឋិយោ ឯវំ វេទនាយ អត្តានំ សមនុប-
ស្សតិ ។

[២៨] កថំ សញ្ញំ អត្តតោ សមនុបស្សតិ ។
ឥធេកច្ចោ ចក្ខុសម្ផស្សជំ សញ្ញំ សោតសម្ផស្សជំ
សញ្ញំ ឃានសម្ផស្សជំ សញ្ញំ ជិវ្ហាសម្ផស្សជំ សញ្ញំ
កាយសម្ផស្សជំ សញ្ញំ មនោសម្ផស្សជំ សញ្ញំ អ-
ត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា សញ្ញា

ឈ្មោះថាពិចារណាឃើញកែវមណីថាមានក្នុងជប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង (មាន) ក្នុងវេទនានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងវេទនា ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ៤ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវេទនា យ៉ាងនេះឯង ។

[២៨] បុគ្គលពិចារណាឃើញសញ្ញា ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញាដែលកើតអំពីចក្ខុសម្ផស្ស សញ្ញាដែលកើតអំពីសោតសម្ផស្ស សញ្ញាដែលកើតអំពីឃានសម្ផស្ស សញ្ញាដែលកើតអំពីជិវ្ហាសម្ផស្ស សញ្ញាដែលកើតអំពីកាយសម្ផស្ស សញ្ញាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថា សញ្ញាណាដែលកើតអំពីមនោសម្ផស្ស

៣៣



សោ អហំ យោ អហំ សា មនោសម្ផស្សជា សញ្ញាតិ មនោសម្ផស្សជំ សញ្ញញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ យា អច្ចិ សោ វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ មនោសម្ផស្សជំ សញ្ញំ អត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា សញ្ញា សោ អហំ យោ អហំ សា មនោសម្ផស្សជា សញ្ញាតិ មនោសម្ផស្សជំ សញ្ញញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា សញ្ញាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ សញ្ញំ អត្តតោ សមនុបស្សតិ ។

សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺសញ្ញាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថាពិចារណាឃើញ នូវសញ្ញាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះក៏គឺរស្មី សភាពណាជារស្មី ធម្មជាតិនោះក៏គឺអណ្តាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញនូវសញ្ញាដែលកើតអំពីមនោ-សម្ផស្ស ថាជាខ្លួន ថា សញ្ញាណាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺសញ្ញាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថាពិចារណាឃើញសញ្ញាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណានិងវត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិបុគ្គលពិចារណាឃើញសញ្ញា ថាជាខ្លួន យ៉ាងនេះឯង ។

[២៩] កថំ សញ្ញាវន្តំ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ ស-ញ្ញាយ សញ្ញាវាតិ សញ្ញាវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយាវន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ សញ្ញាយ សញ្ញាវាតិ សញ្ញាវន្តំ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ទុតិយា សញ្ញា-វត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។

[២៩] បុគ្គលពិចារណាឃើញខ្លួន ថាមានសញ្ញា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូបនិងវេទនា ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះ ថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានសញ្ញាព្រោះ សញ្ញានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានសញ្ញា ប្រៀបដូច ដើមឈើ ដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើ នោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ ដោយឡែក តែដើមឈើនេះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើ ថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧប-មេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូបនិងវេទនា ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានសញ្ញាព្រោះសញ្ញា នេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានសញ្ញា ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែន ទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះ ថាអត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។

ឥមានិ សញ្ញោជនានិ ន ច និដ្ឋិយោ ឯវំ សញ្ញាវត្ថុំ អត្តានំ សមនុបស្សតិ ។

[៣០] កថំ អត្តនិ សញ្ញំ សមនុបស្សតិ ។ ឥ-ធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សម-នុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ អយំ សញ្ញាតិ អត្តនិ សញ្ញំ សមនុបស្សតិ សេយ្យថាបិ បុប្ផំ គន្ធសម្បន្នំ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ ឥទំ បុប្ផំ អយំ គន្ធោ អញ្ញំ បុប្ផំ អញ្ញោ គន្ធោ សោ ខោ បនាយំ គន្ធោ ឥមស្មឹ បុប្ផេតិ បុប្ផស្មឹ គន្ធំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ អយំ សញ្ញាតិ អត្តនិ សញ្ញំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ

នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានសញ្ញា យ៉ាងនេះឯង ។

[៣០] បុគ្គលពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូបនិងវេទនា ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសញ្ញានេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននោះឯង (មាន) ក្នុងផ្កានេះ ឈ្មោះថាពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូបនិងវេទនា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសញ្ញានេះ (ក៏មាន) ក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិ

ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ តតិយា សញ្ញាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ អត្តនិ សញ្ញំ សមនុបស្សតិ ។

[៣១] កថំ សញ្ញាយ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ សញ្ញាយាតិ សញ្ញាយ អត្តានំ សមនុបស្សតិ សេយ្យថាបិ មណិ ករណ្ឌកេ បក្ខិត្តោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ មណិ អយំ ករណ្ឌកោ អញ្ញោ មណិ អញ្ញោ ករណ្ឌកោ សោ ខោ បនាយំ មណិ ឥមស្មឹ ករណ្ឌកេតិ ករណ្ឌកស្មឹ មណឹ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ សង្ខារេ វិញ្ញាណំ រូបំ វេទនំ អត្តតោ សមនុបស្សតិ

មិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[៣១] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូបនិងវេទនា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង (មាន) ក្នុងសញ្ញានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញា ប្រៀបដូចកែវមណីដែលបុគ្គលដាក់ក្នុងដប បុរសគប្បីពោលចំពោះកែវមណីនោះ យ៉ាងនេះថា នេះកែវមណីនេះដប កែវមណីដោយឡែក ដបដោយឡែក តែកែវមណីនេះឯង (មាន) ក្នុងដបនេះ ឈ្មោះថាពិចារណាឃើញកែវមណី ថាមានក្នុងដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនា ថាជាខ្លួន

តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមាយ សញ្ញាយាតិ សញ្ញាយ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ចតុត្ថោ សញ្ញាវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ សញ្ញាយ អត្តានំ សមនុបស្សតិ ។

[៣២] កថំ សង្ខារេ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ ចក្ខុសម្ផស្សជំ ចេតនំ សោតសម្ផស្សជំ ចេតនំ ឃានសម្ផស្សជំ ចេតនំ ជិវ្ហាសម្ផស្សជំ ចេតនំ កាយសម្ផស្សជំ ចេតនំ មនោសម្ផស្សជំ ចេតនំ អត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា ចេតនា សោ អហំ យោ អហំ សា មនោសម្ផស្សជា ចេតនាតិ មនោសម្ផស្សជំ ចេតនញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ

បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង (មាន) ក្នុងសញ្ញានេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញា ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ៤ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញា យ៉ាងនេះឯង ។

[៣២] បុគ្គលពិចារណាឃើញសង្ខារ ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញចេតនាដែលកើតអំពីចក្ខុសម្ផស្ស ចេតនាដែលកើតអំពីសោតសម្ផស្ស ចេតនាដែលកើតអំពីឃានសម្ផស្ស ចេតនាដែលកើតអំពីជិវ្ហាសម្ផស្ស ចេតនាដែលកើតអំពីកាយសម្ផស្ស ចេតនាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថា ធម្មជាតិណាជាចេតនាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺចេតនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថាពិចារណាឃើញនូវចេតនាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ

សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ យា អច្ចិ សោ វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ មនោសម្ផស្សជំ ចេតនំ អត្តតោ សមនុបស្សតិ យា មនោសម្ផស្សជា ចេតនា សោ អហំ យោ អហំ សា មនោសម្ផស្សជា ចេតនាតិ មនោសម្ផស្សជំ ចេតនញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា សក្កាយវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ សង្ខារេ អត្តតោ សមនុបស្សតិ ។

ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះគឺរស្មី សភាពណាជារស្មី ធម្មជាតិនោះ គឺអណ្តាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញចេតនាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថា ធម្មជាតិណា ជាចេតនាដែលកើតអំពីមនោសម្ផស្ស សភាពនោះ គឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺចេតនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថាពិចារណាឃើញនូវចេតនា ដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសង្ខារជាខ្លួន យ៉ាងនេះឯង ។

[៣៣] កថំ សង្ខារវន្តំ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមេហិ សង្ខារេហិ សង្ខារវាតិ សង្ខារវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយាវន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមេហិ សង្ខារេហិ សង្ខារវាតិ សង្ខារវន្តំ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ

មហាវគ្គ ទិដ្ឋិកថា

[៣៣] បុគ្គលពិចារណាឃើញខ្លួន ថាមានសង្ខារ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និង សញ្ញា ថាជាខ្លួន បុគ្គលនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា នេះឯង ខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានសង្ខារព្រោះសង្ខារនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានសង្ខារ ប្រៀបដូចដើមឈើដែល បរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះយ៉ាងនេះថា នេះ ដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើ នេះឯង មានម្លប់ ព្រោះម្លប់នេះ ឈ្មោះថាពិចារណាឃើញដើមឈើ ថាមានម្លប់ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញា ថាជាខ្លួន បុគ្គលនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា នេះឯង ខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានសង្ខារ ព្រោះ សង្ខារទាំងនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានសង្ខារ ការ ប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុ

ន និដ្ឋិ អញ្ញា និដ្ឋិ អញ្ញំ វត្ថុ យា ច និដ្ឋិ យញ្ច វត្ថុ អយំ ទុតិយា សង្ខារវត្ថុកា អត្តានុនិដ្ឋិ អត្តានុនិដ្ឋិ មិច្ឆានិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច និដ្ឋិ-យោ ឯវំ សង្ខារវន្តំ អត្តានំ សមនុបស្សតិ ។

[៣៤] កថំ អត្តនិ សង្ខារេ សមនុបស្សតិ ។ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ ឥមេ សង្ខារាតិ អត្តនិ សង្ខារេ សមនុបស្សតិ សេយ្យថាបិ បុប្ផំ គន្ធស-ម្បន្នំ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ ឥទំ បុប្ផំ អយំ គន្ធោ អញ្ញំ បុប្ផំ អញ្ញោ គន្ធោ សោ ខោ បនាយំ គន្ធោ ឥមស្មឹ បុប្ផេតិ បុប្ផស្មឹ គន្ធំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្ត-និ ឥមេ សង្ខារាតិ អត្តនិ សង្ខារេ សមនុបស្សតិ

ក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានសង្ខារ យ៉ាងនេះឯង ។

[៣៤] បុគ្គលពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញា ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសង្ខារទាំងនេះ (ក៏មាន) ក្នុងខ្លួននេះឯង ឈ្មោះថាពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននេះឯង (ក៏មាន) ក្នុងផ្កានេះ ឈ្មោះថាពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសង្ខារទាំងនេះ (ក៏មាន) ក្នុងខ្លួននេះឯង ឈ្មោះថាពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន

អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ តតិយា សង្ខារវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ អត្តនិ សង្ខារេ សមនុបស្សតិ ។

[៣៩] កថំ សង្ខារេសុ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមេសុ សង្ខារេសូតិ សង្ខារេសុ អត្តានំ សមនុបស្សតិ សេយ្យថាបិ មណិ ករណ្ឌកេ បក្ខិត្តោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ មណិ អយំ ករណ្ឌកោ អញ្ញោ មណិ អញ្ញោ ករណ្ឌកោ

ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[៣៥] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និង សញ្ញា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង (មាន) ក្នុងសង្ខារទាំងនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ ប្រៀបដូចកែវមណី ដែលគេដាក់ក្នុងដប បុរសគប្បីពោល ចំពោះកែវមណីនោះ យ៉ាងនេះថា នេះកែវមណី នេះដប កែវមណីដោយឡែក ដបដោយឡែក

សោ ខោ បនាយំ មណិ ឥមស្មឹ ករណ្ឌកេតិ ករណ្ឌកស្មឹ មណិ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វិញ្ញាណំ រូបំ វេទនំ សញ្ញំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមេសុ សង្ខារេសូតិ សង្ខារេសុ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ចតុត្ថា សង្ខារវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ សង្ខារេសុ អត្តានំ សមនុបស្សតិ ។

[៣៦] កថំ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ អត្តតោ សមនុបស្សតិ យំ មនោវិញ្ញាណំ សោ អហំ យោ អហំ តំ មនោវិញ្ញាណន្តិ មនោវិញ្ញាណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ

តែកែវមណីនេះឯង (មាន) ក្នុងដបនេះ ឈ្មោះថាពិចារណាឃើញកែវមណី ថាមានក្នុងដប មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនានិងសញ្ញា ថាជាខ្លួន បុគ្គលនោះមានសេចក្ដីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានក្នុងសង្ខារនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ៤ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ យ៉ាងនេះឯង ។

[៣៦] បុគ្គលពិចារណាឃើញវិញ្ញាណ ថាជាខ្លួន តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ថាជាខ្លួន ថា ធម្មជាតណា ជាមនោវិញ្ញាណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺមនោវិញ្ញាណ ឈ្មោះថាពិចារណាឃើញ នូវមនោវិញ្ញាណផង នូវខ្លួនផង ថាមិនមែនពីរ

សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ យា អច្ចិ សោ វណ្ណោ យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ មនោវិញ្ញាណំ អត្តតោ សមនុបស្សតិ យំ មនោវិ-ញ្ញាណំ សោ អហំ យោ អហំ តំ មនោវិញ្ញាណន្តិ មនោវិញ្ញាណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា វិញ្ញាណវត្ថុកា អត្តានុទិដ្ឋិ អត្តានុ-ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។

[៣៧] កថំ វិញ្ញាណវន្តំ អត្តានំ សមនុប-ស្សតិ ។ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ

ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្ដាតភ្លើងណា សភាពនោះគឺរស្មី សភាពណាជារស្មី ធម្មជាតិនោះគឺអណ្ដាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្ដាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញមនោវិញ្ញាណថាជាខ្លួន ថា ធម្មជាតណា ជាមនោវិញ្ញាណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះគឺមនោវិញ្ញាណ ឈ្មោះថាពិចារណាឃើញនូវមនោវិញ្ញាណផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវិញ្ញាណ-វត្ថុកៈទី ១ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវិញ្ញាណ ថាជាខ្លួន យ៉ាងនេះឯង ។

[៣៧] បុគ្គលពិចារណាឃើញខ្លួន ថាមានវិញ្ញាណ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា និងសង្ខារ ថាជាខ្លួន បុគ្គលនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួន របស់អញ តែខ្លួនរបស់អញនេះឯង

អយំ អត្តា ឥមិនា វិញ្ញាណេន វិញ្ញាណវាតិ វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយាវន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមិនា វិញ្ញាណេន វិញ្ញាណវាតិ វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ទុតិយា វិញ្ញាណវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ ។

មានវិញ្ញាណ ព្រោះវិញ្ញាណនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមាន វិញ្ញាណ ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោល ចំពោះដើមឈើនោះ យ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើ ដោយឡែក ម្លប់ដោយឡែក តែដើមឈើនេះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថាពិចារណាឃើញដើមឈើថាមានម្លប់ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញានិងសង្ខារ ថាជាខ្លួន បុគ្គលនោះមានសេចក្ដីត្រិះរិះ យ៉ាង នេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានវិញ្ញាណ ព្រោះវិញ្ញាណនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានវិញ្ញាណ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុ ក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានវិញ្ញាណ យ៉ាងនេះឯង ។

[៣៨] កថំ អត្តនិ វិញ្ញាណំ សមនុបស្សតិ ។ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ ឥទំ វិញ្ញាណន្តិ អត្តនិ វិញ្ញាណំ សមនុបស្សតិ សេយ្យថាបិ បុប្ផំ គន្ធសម្បន្នំ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ ឥទំ បុប្ផំ អយំ គន្ធោ អញ្ញំ បុប្ផំ អញ្ញោ គន្ធោ សោ ខោ បនាយំ គន្ធោ ឥមស្មឹ បុប្ផេតិ បុប្ផស្មឹ គន្ធំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា ឥមស្មិញ្ច បន អត្តនិ ឥទំ វិញ្ញាណន្តិ អត្តនិ វិញ្ញាណំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ តតិយា វិញ្ញាណវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ អត្តនិ វិញ្ញាណំ សមនុបស្សតិ ។

មហាវគ្គ ទិដ្ឋិកថា

[៣៨] បុគ្គលពិចារណាឃើញវិញ្ញាណថា មានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯវិញ្ញាណនេះ ក៏មានក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានុ៎ះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននេះឯង (មាន) ក្នុងផ្កានេះ ឈ្មោះថាពិចារណាឃើញក្លិនថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួន របស់អញ ឯវិញ្ញាណនេះ ក៏មានក្នុងខ្លួននេះដែរ ឈ្មោះថាពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវិញ្ញាណ ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[៣៩] កថំ វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមស្មឹ វិញ្ញាណេតិ វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ សេយ្យថាបិ មណិ ករណ្ឌកេ បក្ខិត្តោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ មណិ អយំ ករណ្ឌកោ អញ្ញោ មណិ អញ្ញោ ករណ្ឌកោ សោ ខោ បនាយំ មណិ ឥមស្មឹ ករណ្ឌកេតិ ករណ្ឌកស្មឹ មណឹ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ រូបំ វេទនំ សញ្ញំ សង្ខារេ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមស្មឹ វិញ្ញាណេតិ វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ចតុត្ថា វិញ្ញាណវត្ថុកា អត្តានុទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។

[៣៩] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានក្នុងវិញ្ញាណនេះ ឈ្មោះថាពិចារណាឃើញខ្លួនថាមានក្នុងវិញ្ញាណ ប្រៀបដូចកែវមណីដែលបុគ្គលដាក់ក្នុងដប បុរសគប្បីពោលចំពោះកែវមណីនុ៎ះយ៉ាងនេះថា នេះកែវមណី នេះដប កែវមណីដោយឡែក ដបដោយឡែក តែកែវមណីនេះឯង មានក្នុងដបនេះ ឈ្មោះថាពិចារណាឃើញកែវមណី ថាមានក្នុងដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានក្នុងវិញ្ញាណនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថាអត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ៤ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។

ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ អត្តានុទិដ្ឋិយា ឥមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។

[៤០] មិច្ឆាទិដ្ឋិយា កតមេហិ ទសហាការេហិ អភិនិវេសោ ហោតិ ។ នត្ថិ ទិន្នន្តិ វត្ថុំ ឯវំវាទោ មិច្ឆាទិដ្ឋិ អភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា មិច្ឆាវត្ថុកា មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ នត្ថិ យិដ្ឋន្តិ វត្ថុំ ។ បេ ។ នត្ថិ ហុតន្តិ វត្ថុំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ វត្ថុំ នត្ថិ អយំ លោកោតិ វត្ថុំ នត្ថិ បរលោកោតិ វត្ថុំ នត្ថិ មាតាតិ វត្ថុំ នត្ថិ បិតាតិ វត្ថុំ នត្ថិ សត្តា ឱបបាតិកាតិ

នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ យ៉ាងនេះឯង នេះឯង ការប្រកាន់ស្អិត របស់អត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង ។

[៤០] ការប្រកាន់ស្អិតរបស់មិច្ឆាទិដ្ឋិដោយអាការ ១០ តើដូចម្តេច ។ ការប្រកាន់ពោលយ៉ាងនេះ ចំពោះវត្ថុថា ទានដែលបុគ្គលឲ្យហើយ មិនមានផលដូច្នេះ ឈ្មោះថាទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលនៃមិច្ឆាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណានិងវត្ថុណា នេះឈ្មោះថាមិច្ឆាទិដ្ឋិ ជាមិច្ឆាវត្ថុកៈទី ១ មិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ចំពោះវត្ថុថា ការបូជាធំមិនមានផល ។ បេ ។ ចំពោះវត្ថុថា ការបូជាតូច មិនមានផល ចំពោះវត្ថុថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនិងអាក្រក់ មិនមាន ចំពោះវត្ថុថា លោកនេះ មិនមាន ចំពោះវត្ថុថា លោកខាងមុខ មិនមាន ចំពោះវត្ថុថា មាតាមិនមានគុណ ចំពោះវត្ថុថា បិតាមិនមានគុណ ចំពោះវត្ថុថា សត្វជាឱបបាតិកៈកំណើតមិនមាន

វត្ថុំ នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមំបិ លោកំ បរំបិ លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ វត្ថុំ ឯវំវាទោ មិច្ឆាទិដ្ឋាភិនិវេសបរាមាសោ ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ ទសវត្ថុកា[១] មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស ទ្វេ គតិយោ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ មិច្ឆាទិដ្ឋិយា ឥមេហិ ទសហាការេហិ អភិនិវេសោ ហោតិ ។

[៤១] សក្កាយទិដ្ឋិយា កតមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ

---

១ ឱ. អយំ ទសមា មិច្ឆាវត្ថុកា ។ ម. អយំ ទស មិច្ឆាវត្ថុកា ។

ការប្រកាន់ពោលយ៉ាងនេះ ចំពោះវត្ថុថា ពួកសមណៈនិងព្រាហ្មណ៍ ក្នុងលោក ដែលជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួន នូវលោកនេះនិងលោកខាងមុខ ហើយប្រកាសបាន មិនមានឡើយ ដូច្នេះឈ្មោះថាទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែល នៃមិច្ឆាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថាមិច្ឆាទិដ្ឋិ មានវត្ថុ ១០ មិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ បុរសបុគ្គលអ្នកប្រកបដោយមិច្ឆាទិដ្ឋិ តែងមានគតិពីរយ៉ាង ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិត នៃមិច្ឆាទិដ្ឋិ ដោយអាការ ១០ យ៉ាង ។

[៤១] ការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ ដោយអាការ ២០ តើដូចម្តេច ។ បុថុជ្ជន ក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈមិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានចួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌ របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញរូប ថាជាខ្លួន

រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។

កថំ រូបំ អត្តតោ សមនុបស្សតិ ។ ឥធេក-ច្ចោ បឋវីកសិណំ ។ បេ ។ ឱទាតកសិណំ អត្តតោ សមនុបស្សតិ យំ ឱទាតកសិណំ សោ អហំ យោ អហំ តំ ឱទាតកសិណន្តិ ឱទាតកសិណ-ញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ ។ បេ ។ ឯវមេវ ឥធេ-កច្ចោ ឱទាតកសិណំ អត្តតោ សមនុបស្សតិ អ-ភិនិវេសបរាមាសោ ទិដ្ឋិ ។ បេ ។ អយំ បឋមា រូប-វត្ថុកា សក្កាយទិដ្ឋិ សក្កាយទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបំ អត្តតោ សមនុបស្សតិ ។ បេ ។ សក្កាយទិដ្ឋិយា ឥមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។

ពិចារណាឃើញខ្លួន ថាមានរូបខ្លះ ពិចារណាឃើញរូប ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួន ថាមានក្នុងរូបខ្លះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ពិចារណាឃើញខ្លួន ថាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ។

បុគ្គលពិចារណាឃើញរូប ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញ បឋវីកសិណ ។ បេ ។ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ថា ធម្មជាតណា ជាឱទាតកសិណ សភាពនោះគឺអញ សភាពណាគឺអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថាពិចារណាឃើញឱទាតកសិណនិងខ្លួន ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះ ។ បេ ។ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ។ បេ ។ នេះឈ្មោះថាសក្កាយទិដ្ឋិ ជារូបវត្ថុកៈទី ១ សក្កាយទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាជាខ្លួន យ៉ាងនេះឯង ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃសក្កាយទិដ្ឋិ ដោយអាការ ២០ យ៉ាង ។

[៤២] សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា កតមេហិ បណ្ណរសហិ អាការេហិ អភិនិវេសោ ហោតិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបវន្តំ វា អត្តានំ សមនុបស្សតិ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនាវន្តំ វា អត្តានំ សញ្ញាវន្តំ វា អត្តានំ សង្ខារវន្តំ វា អត្តានំ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។

កថំ រូបវន្តំ អត្តានំ សមនុបស្សតិ ។ ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ តស្ស ឯវំ ហោតិ អយំ ខោ មេ អត្តា សោ ខោ បន មេ អយំ អត្តា ឥមិនា រូបេន រូបវាតិ រូបវន្តំ អត្តានំ សមនុបស្សតិ សេយ្យថាបិ រុក្ខោ ឆាយាសម្បន្នោ អស្ស តមេនំ បុរិសោ ឯវំ វទេយ្យ អយំ រុក្ខោ

[៤២] ការប្រកាន់ស្អិត នៃសស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ១៥ យ៉ាង តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញ នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ នូវខ្លួនថាមានវេទនាខ្លះ នូវខ្លួនថាមានសញ្ញាខ្លះ នូវខ្លួនថាមានសង្ខារខ្លះ នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។

បុគ្គលពិចារណាឃើញខ្លួន ថាមានរូប តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង មានរូបព្រោះរូបនេះ ឈ្មោះថាពិចារណាឃើញខ្លួន ថាមានរូប ប្រៀបដូចដើមឈើ ដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនុ៎ះ យ៉ាងនេះថា នេះដើមឈើ

អយំ ឆាយា អញ្ញោ រុក្ខោ អញ្ញា ឆាយា សោ ខោ បនាយំ រុក្ខោ ឥមាយ ឆាយាយ ឆាយាវាតិ ឆាយា-វន្តំ រុក្ខំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ វេទនំ ។ បេ ។ អយំ បឋមា សក្កាយវត្ថុកា សស្សតទិដ្ឋិ សស្សតទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបវន្តំ អត្តានំ សមនុបស្សតិ ។ បេ ។ សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា ឥមេហិ បណ្ណរសហិ អាការេហិ អភិនិវេសោ ហោតិ ។

[៤៣] សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិយា កត-មេហិ បញ្ចហិ អាការេហិ អភិនិវេសោ ហោតិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយ-ធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិស-ធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ វេទនំ អត្តតោ សមនុបស្សតិ សញ្ញំ អត្តតោ សមនុបស្សតិ សង្ខារេ អត្តតោ សមនុបស្សតិ វិញ្ញាណំ អត្តតោ សមនុបស្សតិ ។

នេះម្ញប់ ដើមឈើដោយឡែក ម្ញប់ដោយឡែក តែដើមឈើនេះឯង មានម្ញប់ព្រោះម្ញប់នេះ ឈ្មោះថាពិចារណាឃើញដើមឈើ ថាមានម្ញប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ (ពិចារណាឃើញ) នូវវេទនា ។ បេ ។ នេះឈ្មោះថាសស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈទី ១ សស្សតទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោ-ជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានរូប យ៉ាងនេះឯង ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃសស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ១៥ យ៉ាង ។

[៤៣] ការប្រកាន់ស្អិត នៃឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ៥ យ៉ាង តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈមិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌ របស់ព្រះអរិយៈ មិនបានចួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌ របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញរូប ថាជាខ្លួន ពិចារណាឃើញវេទនា ថាជាខ្លួន ពិចារណាឃើញសញ្ញា ថាជាខ្លួន ពិចារណាឃើញសង្ខារ ថាជាខ្លួន ពិចារណាឃើញវិញ្ញាណ ថាជាខ្លួន ។

កាថំ រូបំ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ បឋវីកសិណំ ។ បេ ។ ឱទាតកសិណំ អត្តតោ សមនុបស្សតិ យំ ឱទាតកសិណំ សោ អហំ យោ អហំ តំ ឱទាតកសិណន្តិ ឱទាតកសិណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ ។ បេ ។ អយំ បឋមា សក្កាយវត្ថុកា ឧច្ឆេទទិដ្ឋិ ឧច្ឆេទទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឯវំ រូបំ អត្តតោ សមនុបស្សតិ ។ បេ ។ សក្កាយវត្ថុកា ឧច្ឆេទទិដ្ឋិយា ឥមេហិ បញ្ចហិ អាការេហិ អភិនិវេសោ ហោតិ ។

[៤៤] អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ញាសាយ អាការេហិ អភិនិវេសោ ហោតិ សស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ អសស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេសោ ហោតិ

បុគ្គលពិចារណាឃើញរូប ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ។ បេ ។ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ថា ធម្មជាតណា ជាឱទាតកសិណ សភាពនោះគឺអញ សភាពណាគឺអញ ធម្មជាតនោះគឺឱទាតកសិណ ឈ្មោះថាពិចារណាឃើញឱទាតកសិណផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេង ដែលឆេះ ។ បេ ។ នេះឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈទី ១ ឧច្ឆេទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាជាខ្លួន យ៉ាងនេះឯង ។ បេ ។ នេះការប្រកាន់ស្អិត នៃឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ៥ យ៉ាង ។

[៤៤] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ តើដូចម្តេច ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកទៀង ដោយអាការប៉ុន្មាន ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង ដោយអាការប៉ុន្មាន

អន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា អនន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា តំ ជីវន្តំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា ហោតិ តថាគតោ បរម្ម-រណាតិ ។ បេ ។ ន ហោតិ តថាគតោ បរម្មរណាតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតិហាការេហិ អភិនិវេ-សោ ហោតិ ។ សស្សតោ លោកោតិ អន្តគ្គាហិ-កាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាកា-រេហិ អភិនិវេសោ ហោតិ ។

មហាវគ្គ ទិដ្ឋិកថា

ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុត នៃអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុត នៃអន្តគ្គាហិកទិដ្ឋិថា ជីវៈនោះ សរីរៈនោះ នៃអន្តគ្គាហិកទិដ្ឋិថា ជីវៈដទៃ សរីរៈដទៃ ថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ។ បេ ។ ថា សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត ថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន តើដោយអាការប៉ុន្មាន ។ ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកទៀង ដោយអាការ ៥ យ៉ាង ។ បេ ។ ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ដោយអាការ ៥ យ៉ាង ។

[៤៩] សស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ លោកោ ចេវ សស្សតញ្ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា សស្សតោ លោកោតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា លោកោ ចេវ សស្សតា ចាតិ ។ បេ ។ សញ្ញា លោកោ ចេវ សស្សតា ចាតិ ។ បេ ។ សង្ខារា លោកោ ចេវ សស្សតា ចាតិ ។ បេ ។ វិញ្ញាណំ លោកោ ចេវ សស្សតញ្ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បញ្ចមី

[៤៥] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកទៀង ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបជាលោកផង ជាធម្មជាតទៀងផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា លោកទៀង ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ បេ ។ នេះ សំយោជនៈ មិនមែនទិដ្ឋិ ។ ថា វេទនា ជាលោកផង ជាធម្មជាតទៀងផង ។ បេ ។ ថា សញ្ញា ជាលោកផង ជាធម្មជាតទៀងផង ។ បេ ។ ថា សង្ខារ ជាលោកផង ជាធម្មជាតទៀងផង ។ បេ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វិញ្ញាណ ជាលោកផង ជាធម្មជាតទៀងផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិ

សស្សតោ លោកោតិ អន្តគ្គាហិកា ទិដ្ឋិ អន្ត-
គ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ ស-
ញ្ញោជនានិ ន ច ទិដ្ឋិយោ សស្សតោ លោកោតិ
អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ
អភិនិវេសោ ហោតិ ។

[៤៦] អសស្សតោ លោកោតិ អន្តគ្គាហិកាយ
ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ
ហោតិ ។ រូបំ លោកោ ចេវ អសស្សតញ្ចាតិ អ-
ភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ
គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ អយំ បឋមា
អសស្សតោ លោកោតិ អន្តគ្គាហិកា ទិដ្ឋិ អន្ត-
គ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ទិដ្ឋិវិបត្តិ ។ បេ ។ ឥមានិ
សញ្ញោជនានិ ន ច ទិដ្ឋិយោ ។ បេ ។ វេទនា
លោកោ ចេវ អសស្សតា ចាតិ ។ បេ ។ សញ្ញា
លោកោ ចេវ អសស្សតា ចាតិ ។ បេ ។ សង្ខារា
លោកោ ចេវ អសស្សតា ចាតិ ។ បេ ។ វិញ្ញាណំ
លោកោ ចេវ អសស្សតញ្ចាតិ អភិនិវេសបរាមាសោ

ថា លោកទៀង ជាទិដ្ឋិ ទី ៩ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកទៀង ដោយអាការ ៥ យ៉ាង ។

[៤៦] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង ដោយអាការ ៥ តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបជាលោកផង ជាធម្មជាតមិនទៀងផងបុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ បេ ។ ថា វេទនា ជាលោកផង ជាធម្មជាតិមិនទៀងផង ។ បេ ។ ថា សញ្ញា ជាលោកផង ជាធម្មជាតិមិនទៀងផង ។ បេ ។ ថាសង្ខារ ជាលោកផង ជាធម្មជាតមិនទៀងផង ។ បេ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វិញ្ញាណ ជាលោកផង ជាធម្មជាតមិនទៀងផង

ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ អសស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៤៧] អន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ ឥធេកច្ចោ បរិត្តំ ឱកាសំ នីលកតោ ផរតិ តស្ស ឯវំ ហោតិ អន្តវា អយំ លោកោ បរិវដុមោតិ អន្តសញ្ញី ហោតិ យំ ផរតិ តំ វត្ថុញ្ចេវ លោកោ ច យេន ផរតិ សោ អត្តា ចេវ លោកោ ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា អន្តវា លោកោតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។

បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង ដោយអាការ ៥ យ៉ាង ។

[៤៧] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុត ដោយអាការ ៥ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មាននីលកសិណបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសតិចតួច បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ មានទីបំផុត មានផ្លូវជុំវិញ បុគ្គលនោះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់នូវទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ធម្មជាតណា ផ្សាយទៅ ធម្មជាតនោះ ឈ្មោះថាវត្ថុផង ឈ្មោះថាលោកផង វត្ថុនិងលោកផ្សាយទៅ ដោយសភាវៈណា សភាវៈនោះ ឈ្មោះថាខ្លួនផង ឈ្មោះថាលោកផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។

៩៧



ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឥធេកច្ចោ បរិត្តំ ឱកាសំ បីតកតោ ផរតិ លោហិតកតោ ផរតិ ឱទាតកតោ ផរតិ ឱភាសកតោ ផរតិ តស្ស ឯវំ ហោតិ អន្តវា អយំ លោកោ បរិវដ្ដុមោតិ អន្តសញ្ញី ហោតិ យំ ផរតិ វត្ថុញ្ចេវ លោកោ ច យេន ផរតិ សោ អត្តា ចេវ លោកោ ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ អន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលខ្លះ ក្នុងលោកនេះ មានបីតកសិណ បរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសតិចតួច មានលោហិតកសិណ បរិកម្មហើយ តែងផ្សាយទៅ មានឱទាតកសិណបរិកម្មហើយ តែងផ្សាយទៅ មានឱកាសកសិណបរិកម្មហើយ តែងផ្សាយទៅ បុគ្គលនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា លោកនេះ មានទីបំផុត មានផ្លូវជុំវិញ បុគ្គលនោះ ឈ្មោះថាមានសេចក្តីសម្គាល់នូវទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថាវត្ថុផង ឈ្មោះថាលោកផង វត្ថុនិងលោកផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថាខ្លួនផង ឈ្មោះថាលោកផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុត ដោយអាការ ៥ យ៉ាង ។

[៤៨] អនន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ ឥធេកច្ចោ វិបុលំ ឱភាសំ នីលកតោ ផរតិ តស្ស ឯវំ ហោតិ អនន្តវា អយំ លោកោ អបរិយន្តោតិ អនន្តសញ្ញី ហោតិ យំ ផរតិ តំ វត្ថុ ចេវ លោកោ ច យេន ផរតិ សោ អត្តា ចេវ លោកោ ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា អនន្តវា លោកោតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ ឥធេកច្ចោ វិបុលំ ឱភាសំ បីតកតោ ផរតិ លោហិតកតោ ផរតិ ឱទាតកតោ ផរតិ ឱភាសកតោ ផរតិ

[៤៨] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុត ដោយអាការ ៥ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មាននីលកសិណបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសដ៏ធំទូលាយ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះមិនមានទីបំផុត មិនមានទីបំផុតដោយជុំវិញ បុគ្គលនោះឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាមិនមានទីបំផុត ទិដ្ឋិគឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថាវត្ថុផង ឈ្មោះថាលោកផង វត្ថុនិងលោកផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថាខ្លួនផង ឈ្មោះថាលោកផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុត ជាទិដ្ឋិ ទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលខ្លះ ក្នុងលោកនេះ មានបីតកសិណបរិកម្មហើយ តែងផ្សាយទៅ កាន់ឱកាស ដ៏ធំទូលាយ មានលោហិតកសិណ បរិកម្មហើយ តែងផ្សាយទៅ មានឱទាតកសិណបរិកម្មហើយ តែងផ្សាយទៅ មានឱភាសកសិណបរិកម្មហើយ តែងផ្សាយទៅ

តស្ស ឯវំ ហោតិ អនន្តវា អយំ លោកោ អបរិយន្តោតិ អនន្តសញ្ញី ហោតិ យំ ផរតិ តំ វត្ថុញ្ចេវ លោកោ ច យេន ផរតិ សោ អត្តា ចេវ លោកោ ចាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ អនន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៤៩] តំ ជីវំ តំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ[១] ជីវញ្ចេវ សរីរញ្ច យំ ជីវំ តំ សរីរន្តិ[២] អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា តំ ជីវំ តំ សរីរន្តិ

១ ម. តំ រូបំ ។ ២ ម. យំ ជីវំ តំ សរីរំ យំ សរីរំ តំ ជីវន្តិ ។

បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ មិនមានទីបំផុត មិនមានទីបំផុតដោយជុំវិញ បុគ្គលនោះ ឈ្មោះថាអ្នកមានសេចក្តីសម្គាល់ថាមិនមានទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថាវត្ថុផង ឈ្មោះថាលោកផង វត្ថុនិងលោក តែងផ្សាយទៅ ដោយសភាវៈណា សភាវៈនោះ ឈ្មោះថាខ្លួនផង ឈ្មោះថាលោកផង បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុត ដោយអាការ ៥ យ៉ាង ។

[៤៩] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូប ជាជីវិតផង ជាសរីរៈផង ធម្មជាតណាជាជីវិត ធម្មជាតនោះ ជាសរីរៈ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ ជាទិដ្ឋិ ទី ១

អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា ជីវា ចេវ សរីរញ្ច សញ្ញា ជីវា ចេវ សរីរញ្ច សង្ខារា ជីវា ចេវ សរីរញ្ច វិញ្ញាណំ ជីវញ្ចេវ សរីរញ្ច យំ ជីវំ តំ សរីរន្តិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ តំ ជីវំ តំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៩០] អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ សរីរំ ន ជីវំ តំ សរីរំ[១] អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ

១ ឱ. ម. រូបំ សរីរំ ន ជីវំ ន សរីរំ ។

អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះ សំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា វេទនា ជាជីវិតផង ជាសរីរៈផង សញ្ញា ជាជីវិតផង ជាសរីរៈផង សង្ខារ ជាជីវិតផង ជាសរីរៈផង វិញ្ញាណ ជាជីវិតផង ជាសរីរៈផង ធម្មជាតណា ជាជីវិត ធម្មជាតនោះ ជាសរីរៈ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ ដោយអាការ ៥ យ៉ាង ។

[៥០] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ ដោយអាការ ៥ តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបជាសរីរៈ មិនមែនជាជីវិតទេ រូបនោះពិតជាសរីរៈ ជីវិតដទៃ សរីរៈដទៃ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ

អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា សរីរំ ន ជីវំ សញ្ញា សរីរំ ន ជីវំ សង្ខារា សរីរំ ន ជីវំ វិញ្ញាណំ សរីរំ ន ជីវំ តំ សរីរំ(១) អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៤១] ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា(២) ហោតិបិ តិដ្ឋតិបិ ឧប្បជ្ជតិបិ និព្វត្តតិបីតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា

១ ឱ. ម. សរីរំ ន ជីវំ ជីវំ ន សរីរំ ។ ២ ម. ភេទា បរម្មរណា ។

*ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណានិងវត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា វេទនា ជាសរីរៈ មិនមែនជាជីវិតទេ សញ្ញា ជាសរីរៈ មិនមែនជាជីវិតទេ សង្ខារ ជាសរីរៈ មិនមែនជាជីវិតទេ វិញ្ញាណ ជាសរីរៈ មិនមែនជាជីវិតទេ វិញ្ញាណនោះ ពិតជាសរីរៈ ជីវិតដទៃ សរីរៈដទៃ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ ដោយអាការ ៥ យ៉ាង ។*

[៥១] *ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់ កើតទៀត ដោយអាការ ៥ តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតខ្លះ តាំងនៅខ្លះ កើតឡើងខ្លះ កើតប្រាកដខ្លះ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ*

ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា ឥធេវ មរណធម្មា សញ្ញា ឥធេវ មរណធម្មា សង្ខារា ឥធេវ មរណធម្មា វិញ្ញាណំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា ហោតិបិ តិដ្ឋតិបិ ឧប្បជ្ជតិបិ និព្វត្តតិបីតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆា-ទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា វេទនា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សញ្ញា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារ ក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណ ក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតខ្លះ តាំងនៅខ្លះ កើតឡើងខ្លះ កើតប្រាកដខ្លះ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ដោយអាការ ៥ យ៉ាង ។

[៤២] ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ តថាគតោ បរម្មរណាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា ឥធេវ មរណធម្មា សញ្ញា ឥធេវ មរណធម្មា សង្ខារា ឥធេវ មរណធម្មា វិញ្ញាណំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ តថាគតោ បរម្មរណាតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។

[៥២] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ តែងសូន្យ តែងវិនាស សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតទេ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា នឹងវត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និង ការស្ទាបអង្អែលថា វេទនា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សញ្ញា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារ ក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណ ក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ តែងសូន្យ តែងវិនាស សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតទេ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ។ បេ ។

ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៤៣] ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា ហោតិ ច ន ច ហោតីតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោ-ជនានិ ន ច ទិដ្ឋិយោ វេទនា ឥធេវ មរណធម្មា សញ្ញា ឥធេវ មរណធម្មា សង្ខារា ឥធេវ មរណធម្មា វិញ្ញាណំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា ហោតិ ច ន ច ហោតីតិ អភិនិវេសបរាមាសោ

នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត ដោយអាការ ៥ យ៉ាង ។

[៥៣] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈមិនមែនទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វេទនាក្នុងលោកនេះឯង មានមរណៈជាធម្មតា សញ្ញាក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណ ក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន

ទិដ្ឋិ តាយ ទិដ្ឋិយា សោ អត្ថោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ។ បេ ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។

[៨៤] នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា កតមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ ។ រូបំ នេវ មរណាធម្មំ តថាគតោ កាយស្ស ភេទា នេវ ហោតិ ន ន ហោតីតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អត្ថោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ វេទនា នេវ មរណាធម្មា សញ្ញា នេវ មរណាធម្មា សង្ខារា នេវ មរណាធម្មា

បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។ បេ ។ នេះឯង ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដោយអាការ ៥ យ៉ាង ។

[៥៤] ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា វេទនា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សញ្ញា ក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារ ក្នុងលោកនេះឯង មានមរណៈជាធម្មតា

វិញ្ញាណំ ឥធេវ មរណធម្មំ តថាគតោ កាយស្ស ភេទា នេវ ហោតិ ន ន ហោតីតិ អភិនិវេសបរាមាសោ ទិដ្ឋិ តាយ ទិដ្ឋិយា សោ អន្តោ គហិតោតិ អន្តគ្គាហិកា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បញ្ចមី នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកា ទិដ្ឋិ អន្តគ្គាហិកា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ចហាការេហិ អភិនិវេសោ ហោតិ អន្តគ្គាហិកាយ ទិដ្ឋិយា ឥមេហិ បញ្ញាសាយ អាការេហិ អភិនិវេសោ ហោតិ ។

វិញ្ញាណក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាង កាយស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន បុគ្គល ប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថាអន្តគ្គា-ហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយ ឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ថា សត្វ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ជាទិដ្ឋិ ទី ៥ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពី សេចក្ដីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដោយ អាការ ៥ យ៉ាង នេះឯង ការប្រកាន់ស្អិត នៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ យ៉ាង ។

[៥៥] បុព្វន្តានុទិដ្ឋិយា កតមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។ ចត្តារោ សស្ស-តវាទា ចត្តារោ ឯកច្ចសស្សតិកា ចត្តារោ អន្តាន-ន្តិកា ចត្តារោ អមរាវិក្ខេបិកា ទ្វេ អធិច្ចសមុប្បន្និ-កា បុព្វន្តានុទិដ្ឋិយា ឥមេហិ អដ្ឋារសហិ អាការេ-ហិ អភិនិវេសោ ហោតិ ។

[៥៦] អបរន្តានុទិដ្ឋិយា កតមេហិ ចតុចត្តាឡី-សាយ អាការេហិ អភិនិវេសោ ហោតិ ។ សោឡ-ស សញ្ញីវាទា អដ្ឋ អសញ្ញីវាទា អដ្ឋ នេវសញ្ញីនា-សញ្ញីវាទា សត្ត ឧច្ឆេទវាទា បញ្ច ទិដ្ឋធម្មនិព្វានវាទា អបរន្តានុទិដ្ឋិយា ឥមេហិ ចតុចត្តាឡីសាយ អាការេ-ហិ អភិនិវេសោ ហោតិ ។

[៥៧] សញ្ញោជនិកាយ ទិដ្ឋិយា កតមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។ យា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហណំ ។ បេ ។ ទិដ្ឋាភិនិវេសោ ទិដ្ឋិបរាមាសោ សញ្ញោជនិកាយ ទិដ្ឋិយា ឥមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។

[៩៥] ការប្រកាន់ស្អិត នៃបុព្វន្តានុទិដ្ឋិ ដោយអាការ ១៨ តើដូចម្ដេច ។ សស្សតវាទ ៤ ឯកច្ចសស្សតវាទ ៤ អន្តានន្តវាទ ៤ អមរាវិក្ខេបវាទ ៤ អធិច្ចសមុប្បន្នវាទ ២ នេះការប្រកាន់ស្អិត នៃបុព្វន្តានុ-ទិដ្ឋិ ដោយអាការ ១៨ យ៉ាង ។

[៩៦] ការប្រកាន់ស្អិត នៃអបរន្តានុទិដ្ឋិ ដោយអាការ ៤៤ តើដូចម្ដេច ។ សញ្ញិវាទ ១៦ អសញ្ញិវាទ ៨ នេវសញ្ញិនាសញ្ញិវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ នេះការប្រកាន់ស្អិត នៃអបរន្តានុទិដ្ឋិ ដោយអាការ ៤៤ យ៉ាង ។

[៩៧] ការប្រកាន់ស្អិត នៃទិដ្ឋិប្រកបដោយសំយោជនៈ ដោយអាការ ១៨ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការប្រកាន់គឺទិដ្ឋិ ។ បេ ។ ការប្រកាន់ស្អិតគឺទិដ្ឋិ ការស្ទាបអង្អែលគឺទិដ្ឋិ ឯណា នេះការប្រកាន់ស្អិត នៃទិដ្ឋិប្រកបដោយសំយោជនៈ ដោយអាការ ១៨ យ៉ាង ។

[៤៨] អហាន្តិ មានវិនិពន្ធាយ ទិដ្ឋិយា កាតមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។ ចក្ខុំ អហាន្តិ[១] មានវិនិពន្ធា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា អហាន្តិ មានវិនិពន្ធា ទិដ្ឋិ មានវិនិពន្ធា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ សោតំ អហាន្តិ ។ បេ ។ ឃានំ អហាន្តិ ជិវ្ហា អហាន្តិ កាយោ អហាន្តិ មនោ អហាន្តិ ។ បេ ។ ធម្មា អហាន្តិ ចក្ខុវិញ្ញាណំ អហាន្តិ ។ បេ ។ មនោវិញ្ញាណំ អហាន្តិ អភិនិវេសបរាមាសោ អហាន្តិ មានវិនិពន្ធា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ អដ្ឋារសមី អហាន្តិ មានវិនិពន្ធា ទិដ្ឋិ មានវិនិពន្ធា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ អហាន្តិ មានវិនិពន្ធាយ ទិដ្ឋិយា ឥមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។

---

១ ឱ. ម. ឯត្ថន្តរេ អភិនិវេសបរាមាសោ អហាន្តីតិ ទិស្សន្តិ ។

[៩៨] ការប្រកាន់ស្អិត នៃមានវិនិពន្ធទិដ្ឋិថាអញ ដោយអាការ ១៨ តើដូចម្តេច ។ ការប្រកាន់ស្អិតថា ត្រចៀកជាអញ ឈ្មោះថាមានវិនិពន្ធទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាមានវិនិពន្ធទិដ្ឋិថាអញ ជាទិដ្ឋិទី ១ មានវិនិពន្ធទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ការប្រកាន់ស្អិតថា ត្រចៀកជាអញ ។ បេ ។ ថា ច្រមុះជាអញ ថា អណ្តាតជាអញ ថា កាយជាអញ ថា ចិត្តជាអញ ។ បេ ។ ថា ធម៌ទាំងឡាយជាអញ ថា ចក្ខុវិញ្ញាណជាអញ ។ បេ ។ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា មនោវិញ្ញាណជាអញ ឈ្មោះថាមានវិនិ-ពន្ធទិដ្ឋិថាអញ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាមានវិនិពន្ធទិដ្ឋិថាអញ ជាទិដ្ឋិទី ១៨ មានវិនិពន្ធទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិត នៃមានវិនិពន្ធទិដ្ឋិថាអញ ដោយអាការ ១៨ យ៉ាង ។

[៤៩] មមន្តិ មានវិនិពន្ធាយ ទិដ្ឋិយា កតមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។ ចក្ខុំ មមន្តិ[១] មានវិនិពន្ធា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា មមន្តិ មានវិនិពន្ធា ទិដ្ឋិ មានវិនិពន្ធា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ សោតំ មមន្តិ ។ បេ ។ ឃានំ មមន្តិ ជិវ្ហា មមន្តិ ។ បេ ។ មនោ មមន្តិ ។ បេ ។ ធម្មា មមន្តិ ចក្ខុវិញ្ញាណំ មមន្តិ ។ បេ ។ មនោវិញ្ញាណំ មមន្តិ អភិនិវេសបរាមាសោ មមន្តិ មានវិនិពន្ធា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ អដ្ឋារសមី មមន្តិ មានវិនិពន្ធា ទិដ្ឋិ មានវិនិពន្ធា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ មមន្តិ មានវិនិពន្ធាយ ទិដ្ឋិយា ឥមេហិ អដ្ឋារសហិ អាការេហិ អភិនិវេសោ ហោតិ ។

---

១ ឱ. ម. ឯត្ថន្តរេ អភិនិវេសបរាមាសោ មមន្តីតិ ទិស្សន្តិ ។

[៥៩] ការប្រកាន់ស្អិត នៃមានវិនិពន្ធទិដ្ឋិថា របស់អញ ដោយអាការ ១៨ តើដូចម្ដេច ។ ការប្រកាន់ស្អិត ថា ភ្នែករបស់អញ ឈ្មោះថា មានវិនិពន្ធទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថា មានវិនិពន្ធទិដ្ឋិថា របស់អញ ជាទិដ្ឋិទី ១ មានវិនិពន្ធទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ការប្រកាន់ស្អិតថា ត្រចៀករបស់អញ ។ បេ ។ ថា ច្រមុះរបស់អញ ថា អណ្ដាតរបស់អញ ។ បេ ។ ថា ចិត្តរបស់អញ ។ បេ ។ ថា ធម៌ទាំងឡាយរបស់អញ ថាចក្ខុវិញ្ញាណរបស់អញ ។ បេ ។ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា មនោវិញ្ញាណរបស់អញ ឈ្មោះថាមានវិនិពន្ធទិដ្ឋិថា របស់អញ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាមានវិនិពន្ធទិដ្ឋិថា របស់អញ ជាទិដ្ឋិ ទី ១៨ មានវិនិពន្ធទិដ្ឋិ ជាមិច្ឆា-ទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិត នៃមានវិនិពន្ធទិដ្ឋិថា របស់អញ ដោយអាការ ១៨ យ៉ាង ។

[៦០] អត្តវានុបស្សនាដិសំយុត្តាយ ទិដ្ឋិយា កាតមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ បេ ។ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ បេ ។

កាថំ រូបំ អត្តតោ សមនុបស្សតិ ។ ឥធេកច្ចោ បឋវីកសិណំ ។ បេ ។ ឱទាតកសិណំ អត្តតោ សមនុបស្សតិ យំ ឱទាតកសិណំ សោ អហំ យោ អហំ តំ ឱទាតកសិណន្តិ ឱទាតកសិណញ្ច អត្តញ្ច អទ្វយំ សមនុបស្សតិ សេយ្យថាបិ តេលប្បទីបស្ស ឈាយតោ យា អច្ចិ សោ វណ្ណោ

[៦០] ការប្រកាន់ស្អិត នៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានចួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញនូវរូប ថាជាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ ។ បេ ។ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។ បេ ។

បុគ្គលពិចារណាឃើញរូប ថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ។ បេ ។ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ថា ធម្មជាតណា ជាឱទាតកសិណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថាពិចារណាឃើញឱទាតកសិណនិងខ្លួន ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេង ដែលឆេះ មានអណ្តាតភ្លើងណា សភាពនោះ គឺរស្មី

យោ វណ្ណោ សា អច្ចីតិ អច្ចិញ្ច វណ្ណញ្ច អទ្វយំ សមនុបស្សតិ ឯវមេវ ឥធេកច្ចោ ឥធេកច្ចោ ឱទាតកសិណំ អត្តតោ សមនុបស្សតិ ។ បេ ។ អយំ បឋមា រូបវត្ថុកា អត្តវាទប្បដិសំយុត្តា ទិដ្ឋិ អត្តវាទប្បដិសំយុត្តា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ[១] អត្តវាទប្បដិសំយុត្តាយ ទិដ្ឋិយា ឥមេហិ វីសតិយា អាការេហិ អភិនិវេសោ ហោតិ ។

[៦១] លោកវាទប្បដិសំយុត្តាយ ទិដ្ឋិយា កតមេហិ អដ្ឋហិ អាការេហិ អភិនិវេសោ ហោតិ ។ សស្សតោ អត្តា ច លោកោ ចាតិ អភិនិវេសបរាមាសោ លោកវាទប្បដិសំយុត្តា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ បឋមា លោកវាទប្បដិសំយុត្តា ទិដ្ឋិ លោកវាទប្បដិសំយុត្តា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ អសស្សតោ អត្តា ច លោកោ ចាតិ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ចាតិ ។ បេ ។

---

១ ឱ. ម. ឯត្ថន្តរេ ឯវំ រូបំ អត្តតោ សមនុបស្សតិ ។ បេ ។ ឥតិ ទិស្សតិ ។

សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថាពិចារណាឃើញអណ្តាតភ្លើងនិងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ។ បេ ។ នេះឈ្មោះថា អត្តវាទប្បដិសំយុត្តទិដ្ឋិជារូបវត្ថុកៈ ទី ១ អត្តវាទប្បដិសំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិត នៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ យ៉ាង ។

[៦១] ការប្រកាន់ស្អិត នៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ តើដូចម្តេច ។ ការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ខ្លួនក្តីលោកក្តី ទៀង ឈ្មោះថាលោកវាទប្បដិសំយុត្តទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និង វត្ថុណា នេះឈ្មោះថាលោកវាទប្បដិសំយុត្តទិដ្ឋិ ទី ១ លោកវាទប្បដិសំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ (ការប្រកាន់ស្អិតនិងការស្ទាបអង្អែល) ថា ខ្លួនក្តី លោកក្តី មិនទៀង ថា ខ្លួនក្តី លោកក្តី ទៀងក៏មាន មិនទៀងក៏មាន ។ បេ ។

នេវសស្សតោ នាសស្សតោ អត្តា ច លោកោ ចាតិ អន្តវា អត្តា ច លោកោ ចាតិ អនន្តវា អត្តា ច លោកោ ចាតិ អន្តវា ច អនន្តវា អត្តា ច លោកោ ចាតិ នេវន្តវា នានន្តវា អត្តា ច លោកោ ចាតិ អភិនិវេសបរាមាសោ លោកវាទប្បដិសំយុត្តា ទិដ្ឋិ ទិដ្ឋិ ន វត្ថុ វត្ថុ ន ទិដ្ឋិ អញ្ញា ទិដ្ឋិ អញ្ញំ វត្ថុ យា ច ទិដ្ឋិ យញ្ច វត្ថុ អយំ អដ្ឋមី លោកវាទប្បដិសំយុត្តា ទិដ្ឋិ លោកវាទប្បដិសំយុត្តា ទិដ្ឋិ មិច្ឆាទិដ្ឋិ ។ បេ ។ ឥមានិ សញ្ញោជនានិ ន ច ទិដ្ឋិយោ លោកវាទប្បដិសំយុត្តាយ ទិដ្ឋិយា ឥមេហិ អដ្ឋហិ អាការេហិ អភិនិវេសោ ហោតិ ។

[៦២] ឱលិយនាភិនិវេសោ ភវទិដ្ឋិ អតិធាវនាភិនិវេសោ វិភវទិដ្ឋិ អស្សាទទិដ្ឋិយា បញ្ចត្តឹសាយ អាការេហិ អភិនិវេសោ កតិ ភវទិដ្ឋិយោ កតិ វិភវទិដ្ឋិយោ អត្តានុទិដ្ឋិយា វីសតិយា អាការេហិ អភិនិវេសោ កតិ ភវទិដ្ឋិយោ កតិ វិភវទិដ្ឋិយោ ។ បេ ។

ការប្រកាន់ស្អិតនិងការស្ទាបអង្អែលថា ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ថា ខ្លួនក្តី លោកក្តី មានទីបំផុត ថា ខ្លួនក្តី លោកក្តី មិនមានទីបំផុត ថា ខ្លួនក្តី លោកក្តី មានទីបំផុតក៏មាន មិនមានទីបំផុតក៏មាន ថា ខ្លួនក្តី លោកក្តី មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ឈ្មោះថា លោកវាទប្បដិសំយុត្តទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថាលោកវាទប្បដិសំយុត្តទិដ្ឋិ ទី ៨ លោកវាទប្បដិ-សំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បេ ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិត នៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ យ៉ាង ។

[៦២] ការប្រកាន់ស្អិត ដោយការក្រាញនៅ ឈ្មោះថាភវទិដ្ឋិ ការប្រកាន់ស្អិត ដោយការស្ទុះទៅក្រៃលែង ឈ្មោះថាវិភវទិដ្ឋិ អស្សាទទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ៣៥ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន អត្តានុទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ២០ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន ។ បេ ។

## ៧៣



លោកវាទប្បដិសំយុត្តាយ ទិដ្ឋិយា អដ្ឋហិ អាការេហិ អភិនិវេសោ កាតិ ភវទិដ្ឋិយោ កាតិ វិភវទិដ្ឋិយោ ។ អស្សាទទិដ្ឋិយា បញ្ចត្តឹសាយ អាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ អត្តានុទិដ្ឋិយា វីសតិយា អាការេហិ អភិនិវេសោ បណ្ណរស ភវទិដ្ឋិយោ បញ្ច វិភវទិដ្ឋិយោ មិច្ឆាទិដ្ឋិយា ទសហិ អាការេហិ អភិនិវេសោ សព្វាវតា វិភវទិដ្ឋិយោ សក្កាយទិដ្ឋិយា វីសតិយា អាការេហិ អភិនិវេសោ បណ្ណរស ភវទិដ្ឋិយោ បញ្ច វិភវទិដ្ឋិយោ សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា បណ្ណរសហិ អាការេហិ អភិនិវេសោ សព្វាវតា ភវទិដ្ឋិយោ សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា វិភវទិដ្ឋិយោ សស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា ភវទិដ្ឋិយោ

លោកវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ៨ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន ។ អស្សាទទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ៣៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អត្តានុទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥ មិច្ឆាទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ១០ គឺជាវិភវទិដ្ឋិទាំងអស់ សក្កាយទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥ សស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈ មានការប្រកាន់ស្អិត ដោយអាការ ១៥ គឺជាភវទិដ្ឋិ ទាំងអស់ ឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាវិភវទិដ្ឋិ ទាំងអស់ អន្តគ្គាហិកទិដ្ឋិថា លោកទៀង មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិ ទាំងអស់

អសស្សតោ លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា វិភវទិដ្ឋិយោ អន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ អនន្តវា លោកោតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ តំ ជីវំ តំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា វិភវទិដ្ឋិយោ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា ភវទិដ្ឋិយោ ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា ភវទិដ្ឋិយោ ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សព្វាវតា វិភវទិដ្ឋិយោ

អន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាវិភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុត មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អន្តគ្គា-ហិកទិដ្ឋិថា លោកមិនមានទីបំផុត មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាវិភវទិដ្ឋិ ទាំងអស់ អន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាវិភវទិដ្ឋិ ទាំងអស់

ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ(១) អបរន្តានុទិដ្ឋិយា ចតុច្ចត្តាឡីសាយ អាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ សញ្ញោជនិកាយ ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ អហន្តិ មានវិនិពទ្ធាយ ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ សព្វាវេតា វិភវទិដ្ឋិយោ មមន្តិ មានវិនិពទ្ធាយ ទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ សព្វាវេតា ភវទិដ្ឋិយោ អត្តវាទប្បដិសំយុត្តាយ ទិដ្ឋិយា វីសតិយា អាការេហិ អភិនិវេសោ បណ្ណរស ភវទិដ្ឋិយោ បញ្ច វិភវទិដ្ឋិយោ

---

១ ឱ. ម. ឯត្តន្តរេ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ អន្តគ្គាហិកាយ ទិដ្ឋិយា បញ្ចហាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ ។ បុព្វន្តានុទិដ្ឋិយា អដ្ឋារសហិ អាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោតិ ទិស្សតិ ។

អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន មានការប្រកាន់ស្អិត ដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អបរន្តានុទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ៤៤ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ទិដ្ឋិប្រកបដោយសំយោជនៈ មានការប្រកាន់ស្អិត ដោយអាការ ១៨ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន មាន-វិនិពន្ធទិដ្ឋិថាអញ មានការប្រកាន់ស្អិត ដោយអាការ ១៨ គឺជាវិភវទិដ្ឋិទាំងអស់ មានវិនិពន្ធទិដ្ឋិថា របស់អញ មានការប្រកាន់ស្អិត ដោយអាការ ១៨ គឺជាភវទិដ្ឋិ ទាំងអស់ អត្តវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥

លោកវាទប្បដិសំយុត្តាយ ទិដ្ឋិយា អដ្ឋហិ អាការេហិ អភិនិវេសោ សិយា ភវទិដ្ឋិយោ សិយា វិភវទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោ(១) អត្តានុទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោ មិច្ឆាទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោ សក្កាយទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោ អន្តគ្គាហិកា ទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោ សញ្ញោជនិកា ទិដ្ឋិយោ(២) អត្តវាទប្បដិសំយុត្តា ទិដ្ឋិយោ ភវទិដ្ឋិយោ វិភវទិដ្ឋិយោ(៣) ឯតំ ទ្វយំ តក្កិតា(៤) និស្សិតា យេ(៥) តេសំ និរោធម្ហិ នត្ថិ(៦) ញាណំ យត្ថាយំ លោកោ វីបរិតសញ្ញីតិ(៧) ។

[៦៣] ទ្វីហិ ភិក្ខវេ ទិដ្ឋិគតេហិ បរិយុដ្ឋិតា ទេវមនុស្សា ឱលិយន្តិ ឯកេ អតិធាវន្តិ ឯកេ ចក្ខុមន្តោ ច បស្សន្តិ ។

---

១ ឱ. ម. ឯត្ថន្តរេ អស្សាទទិដ្ឋិយោ សព្វាវតា ទិដ្ឋិយោតិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ សព្វាវតា ទិដ្ឋិយោតិ ទិស្សតិ ។ ៣ ម. ភវញ្ច ទិដ្ឋឹ វិភវញ្ច ទិដ្ឋឹ ។ ៤ ម. តក្កិកា ។ ៥ ម. សេ ។ ៦ ឱ. ម. នអត្ថិ ។ ៧ ឱ. ម. វិបរីតសញ្ញីតិ ។

លោកវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិត ដោយអាការ ៨ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ទិដ្ឋិទាំងអស់ ឈ្មោះថាអត្តានុទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថាមិច្ឆាទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថាសក្កាយទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថាអន្តគ្គាហិកទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថាសញ្ញោ-ជនិកទិដ្ឋិ ឈ្មោះថាអត្តវាទប្បដិសំយុត្តទិដ្ឋិ ឈ្មោះថាភវទិដ្ឋិ ឈ្មោះថាវិភវទិដ្ឋិ ពួកជនណា ជាអ្នកត្រិះរិះ ហើយអាស្រ័យ នូវទិដ្ឋិទាំងពីរនុ៎ះ ការដឹងក្នុងនិរោធ របស់ពួកជននោះ មិនមានឡើយ ដ្បិតថា សត្វ-លោកនេះ តែងមានសេចក្តីសម្គាល់ខុស ។

[៦៣] ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សមួយពួក ដែលត្រូវទិដ្ឋិទាំងពីររួបរឹតហើយ តែងក្រាញ មួយពួក តែងស្ទុះស្ទា ឯពួក បុគ្គលអ្នកមានចក្ខុ តែងឃើញច្បាស់ ។

កថញ្ច ភិក្ខវេ ឱលិយន្តិ ឯកេ ភវារាមា ភិក្ខវេ ទេវមនុស្សា ភវរតា ភវសម្មុទិតា តេសំ ភវនិរោធាយ ធម្មេ ទេសិយមានេ ចិត្តំ ន បក្ខន្ទតិ ន សម្បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតិ ឯវំ ខោ ភិក្ខវេ ឱលិយន្តិ ឯកេ ។

កថញ្ច ភិក្ខវេ អតិធាវន្តិ ឯកេ ភវេន[១] ខោ បនេកេ អដ្ដិយមានា ហរាយមានា ជិគុច្ឆមានា វិភវំ អភិនន្ទន្តិ យតោ កិរ ភោ អត្តា[២] កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណាតិ ឯតំ សន្តំ ឯតំ បណីតំ យថាភវន្តិ[៣] ឯវំ ខោ ភិក្ខវេ អតិធាវន្តិ ឯកេ ។

---

១ ឱ. ម. ភវេនេវ ។ ២ ឱ. ម. អយំ អត្តា ។ ៣ ម. យាថាវន្តិ ។

មហាវគ្គ ទិដ្ឋិកថា

ម្នាលភិក្ខុទាំងឡាយ ចុះទេវតានិងមនុស្សមួយពួក តែងក្រាញ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ មានភពជាទីត្រេកអរ ត្រេកអរក្នុងភព រីករាយក្នុងភព កាលដែលតថាគតកំពុងសម្ដែងធម៌ (ឲ្យស្ដាប់) ដើម្បីរំលត់ភព ចិត្តរបស់ទេវតានិងមនុស្សទាំងនោះ រមែងមិនស្ទុះស្ទា មិនជ្រះថ្លា មិនតាំងនៅ មិនជឿស៊ប់ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សមួយពួក តែងក្រាញ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះទេវតានិងមនុស្សមួយពួក តែងស្ទុះស្ទា តើដូចម្ដេច ទេវតានិងមនុស្សមួយពួក កាលនឿយណាយ ធុញទ្រាន់ ជិនឆ្អន់ដោយសារភព ក៏ត្រេកអរចំពោះការប្រាសចាកភព ដោយគិតថា ឱហ្ន៎អង្គាល់ណា ខ្លួននឹងទម្លាយកាយទៅ ហើយសូន្យ វិនាស ខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀត (ឬដោយគិតថា) នេះជាធម្មជាតស្ងប់ នេះជាធម្មជាតដ៏ឧត្ដមដោយពិត ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សមួយពួក តែងស្ទុះស្ទា យ៉ាងនេះឯង ។

កាចញ្ច ភិក្ខវេ ចក្ខុមន្តោ ច បស្សន្តិ ឥធ ភិក្ខវេ ភិក្ខុ ភូតំ ភូតតោ បស្សតិ ភូតំ ភូតតោ ទិស្វា ភូតស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ឯវំ ខោ ភិក្ខវេ ចក្ខុមន្តោ ច បស្សន្តិ ។

យោ ភូតំ ភូតតោ ទិស្វា ភូតស្ស ច អតិក្កម[១]
យថាភូតេធិមុច្ចតិ ភវតណ្ហាបរិក្ខយា
សចេ ភូតស្ស បរិញ្ញាតោ សោ វីតតណ្ហោ[២]ភវាភវេ
ភូតស្ស វិភវា ភិក្ខុ នាគច្ឆតិ បុនព្ភវន្តិ ។

[៦៤] តយោ បុគ្គលា វិបន្នទិដ្ឋី តយោ បុគ្គលា សម្បន្នទិដ្ឋី ។

កតមេ តយោ បុគ្គលា វិបន្នទិដ្ឋី ។ តិត្ថិយោ ច តិត្ថិយសាវកោ ច យោ ច មិច្ឆាទិដ្ឋិកោ ឥមេ តយោ បុគ្គលា វិបន្នទិដ្ឋី ។

---

១ ឱ. ម. អតិក្កមំ ។ ២ ឱ. សវេ ភូតស្សបរិញ្ញា វីតតណ្ហោ ។ ម. សវេ ភូតបរិញ្ញាសោ វីតតណ្ហោ ។

ម្នាលភិក្ខុទាំងឡាយ ចុះពួកបុគ្គលអ្នកមានចក្ខុ តែងឃើញច្បាស់ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវភូតរូប ថាជាភូតរូប លុះឃើញនូវភូតរូប ថាជាភូតរូបហើយ តែងជាអ្នកប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់នូវភូតរូប ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលអ្នកមានចក្ខុ តែងឃើញច្បាស់ យ៉ាងនេះឯង ។

ភិក្ខុណា ឃើញនូវភូតរូប ថាជាភូតរូប ហើយប្រព្រឹត្ត
កន្លងនូវភូតរូប រមែងជឿស៊ប់ ក្នុងការពិត ព្រោះការ
អស់ទៅនៃភវតណ្ហា ថាបើភិក្ខុនោះ បានកំណត់ដឹង
នូវភូតរូបហើយ ទាំងជាអ្នកមានតណ្ហាទៅប្រាសហើយ
ក្នុងរូបភពនិងអរូបភព រមែងមិនបាននូវភពថ្មីទៀតទេ
ព្រោះការមិនមានភូតរូប ។

[៦៤] បុគ្គល ៣ ពួក មានទិដ្ឋិវិបត្តិ បុគ្គល ៣ ពួក បរិបូណ៌ដោយទិដ្ឋិ ។ បុគ្គល ៣ ពួក មានទិដ្ឋិវិបត្តិ តើដូចម្តេច ។ ពួកតិរ្ថិយ ១ ពួកសាវ័កនៃតិរ្ថិយ ១ ពួកជនដែលជាមិច្ឆាទិដ្ឋិ ១ នេះបុគ្គល ៣ ពួក ដែលមានទិដ្ឋិវិបត្តិ ។

កតមេ តយោ បុគ្គលា សម្បន្នទិដ្ឋី ។ តថាគ-
តោ ច តថាគតស្ស សាវកោ ច យោ ច សម្មា-
ទិដ្ឋិកោ ឥមេ តយោ បុគ្គលា សម្បន្នទិដ្ឋី ។

កោធនោ ឧបនាហិ ច បាបមក្ខី ច យោ នរោ
វិបន្នទិដ្ឋិ មាយាវី តំ ជញ្ញា វសលោ ឥមេតិ ។
អក្កោធនោ អនុបនាហី អមក្ខី សុទ្ធតំ គតោ
សម្បន្នទិដ្ឋិ មេធាវី តំ ជញ្ញា អរិយោ ឥមេតិ ។

[៦៨] តិស្សោ វិបន្នទិដ្ឋិយោ តិស្សោ សម្បន្ន-
ទិដ្ឋិយោ ។

កតមា តិស្សោ វិបន្នទិដ្ឋិយោ ។ ឯតំ មមន្តិ
វិបន្នទិដ្ឋិ ឯសោហមស្មីតិ វិបន្នទិដ្ឋិ ឯសោ មេ
អត្តាតិ វិបន្នទិដ្ឋិ ឥមា តិស្សោ វិបន្នទិដ្ឋិយោ ។

បុគ្គល ៣ ពួក បរិបូណ៌ដោយទិដ្ឋិ តើដូចម្តេច ។ ព្រះតថាគត ១ សាវ័កនៃព្រះតថាគត ១ ពួកជនដែលជាសម្មាទិដ្ឋិ ១ នេះបុគ្គល ៣ ពួក ដែលបរិបូណ៌ដោយទិដ្ឋិ ។

នរជនណា មានសេចក្តីក្រោធផង ចងសេចក្តីក្រោធ
ទុកផង ជាសត្វលាមក លុបគុណគេផង មានទិដ្ឋិ-
វិបត្តិផង មានពុតត្បុតផង បុគ្គលគប្បីដឹង នូវ
នរជននោះថា អ្នកទាំងនេះ ជាមនុស្សថោកទាប ។
អ្នកប្រាជ្ញ មិនមានសេចក្តីក្រោធ មិនចងសេចក្តីក្រោធ
ទុក មិនលុបគុណគេ ដល់នូវភាពជាអ្នកបរិសុទ្ធ មាន
ទិដ្ឋិបរិបូណ៌ បុគ្គលគប្បីដឹងនូវអ្នកប្រាជ្ញនោះថា អ្នកនេះ
ជាមនុស្សប្រសើរ ។

[៦៥] ទិដ្ឋិវិបត្តិ ៣ យ៉ាង ទិដ្ឋិសម្បត្តិ ៣ យ៉ាង ។

ទិដ្ឋិវិបត្តិ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ការយល់ឃើញថា នុ៎ះជារបស់អញ ឈ្មោះថាទិដ្ឋិវិបត្តិ ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះថាទិដ្ឋិវិបត្តិ ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះថាទិដ្ឋិវិបត្តិ នេះឯង ទិដ្ឋិវិបត្តិ ៣ យ៉ាង ។

កតមា តិស្សោ សម្បន្នទិដ្ឋិយោ ។ នេតំ មមន្តិ សម្បន្នទិដ្ឋិ នេសោហមស្មីតិ សម្បន្នទិដ្ឋិ ន មេសោ អត្តាតិ សម្បន្នទិដ្ឋិ ឥមា តិស្សោ សម្បន្នទិដ្ឋិយោ ។

[៦៦] ឯតំ មមន្តិ កា ទិដ្ឋិ កតិ ទិដ្ឋិយោ កតមន្តានុគ្គហិតា តា ទិដ្ឋិយោ ឯសោហមស្មីតិ កា ទិដ្ឋិ កតិ ទិដ្ឋិយោ កតមន្តានុគ្គហិតា តា ទិដ្ឋិយោ ឯសោ មេ អត្តាតិ កា ទិដ្ឋិ កតិ ទិដ្ឋិយោ កតមន្តានុគ្គហិតា តា ទិដ្ឋិយោ ។ ឯតំ មមន្តិ បុព្វន្តានុទិដ្ឋិ អដ្ឋារស ទិដ្ឋិយោ បុព្វន្តានុគ្គហិតា តា ទិដ្ឋិយោ ឯសោហមស្មីតិ អបរន្តានុទិដ្ឋិ ចតុចត្តាឡីសំ ទិដ្ឋិយោ អបរន្តានុគ្គហិតា តា ទិដ្ឋិយោ ឯសោ មេ អត្តាតិ វីសតិវត្ថុកា អត្តានុទិដ្ឋិ វីសតិវត្ថុកា សក្កាយទិដ្ឋិ សក្កាយទិដ្ឋិប្បមុខេន[១] ទ្វាសដ្ឋី ទិដ្ឋិគតានិ បុព្វន្តាបរន្តានុគ្គហិតា តា ទិដ្ឋិយោ ។

---

១ ឱ. ម. សក្កាយទិដ្ឋិប្បមុខានិ ។

ទិដ្ឋិសម្បត្តិ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ការយល់ឃើញថា នុ៎ះមិនមែនជារបស់អញ ឈ្មោះថាទិដ្ឋិសម្បត្តិ ការយល់ឃើញថា នុ៎ះមិនមែនជាអញ ឈ្មោះថាទិដ្ឋិសម្បត្តិ ការយល់ឃើញថា នុ៎ះមិនមែនជាខ្លួនរបស់អញ ឈ្មោះថាទិដ្ឋិសម្បត្តិ នេះឯង ទិដ្ឋិសម្បត្តិ ៣ យ៉ាង ។

[៦៦] ការយល់ឃើញថា នុ៎ះរបស់អញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ។ ការយល់ឃើញថា នុ៎ះរបស់អញ ឈ្មោះបុព្វន្តានុទិដ្ឋិ មានទិដ្ឋិ ១៨ ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកខាងដើម ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះអបរន្តានុទិដ្ឋិ មានទិដ្ឋិ ៤៤ ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកខាងចុង ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះវីសតិវត្ថុកអត្តានុទិដ្ឋិ ឈ្មោះវីសតិវត្ថុសក្កាយទិដ្ឋិ មានទិដ្ឋិ ៦២ ដោយមានសក្កាយទិដ្ឋិជាប្រធាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកខាងដើម និងចំណែកខាងចុង ។

[៦៧] យេ កេចិ ភិក្ខវេ មយិ និដ្ឋង្គតា សព្វេ តេ ទិដ្ឋិសម្បន្នា បញ្ចន្នំ ឥធ និដ្ឋា បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។

កតមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ សត្តក្ខត្តុបរមស្ស កោលង្កោលស្ស ឯកពីជិស្ស សកទាគាមិស្ស យោ ច ទិដ្ឋេវ ធម្មេ អរហា ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ។

កតមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ អន្តរាបរិនិព្វាយិស្ស ឧបហច្ចបរិនិព្វាយិស្ស អសង្ខារបរិនិព្វាយិស្ស សសង្ខារបរិនិព្វាយិស្ស ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។

យេ[១] កេចិ ភិក្ខវេ មយិ និដ្ឋង្គតា សព្វេ តេ ទិដ្ឋិសម្បន្នា ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។

១ ឱ. ម. ឯត្ថន្តរេ តេសំ ទិដ្ឋិសម្បន្នានន្តិ ទិស្សតិ ។

មហាវគ្គ ទិដ្ឋិកថា

[៦៧] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ដល់នូវការសម្រេច ព្រោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថាអ្នកបរិបូណ៌ដោយទិដ្ឋិ បុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច ។

បុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ តើដូចម្តេច ។ សត្តក្ខត្តុបរមបុគ្គល ១ កោលង្កោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ បុគ្គលដែលជាព្រះអរហន្តក្នុងបច្ចុប្បន្ន ១ នេះបុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ ។

បុគ្គល ៥ ពួក លះលោកនេះហើយសម្រេច តើដូចម្តេច ។ អន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ នេះបុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ដល់នូវការសម្រេច ព្រោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថាអ្នកបរិបូណ៌ដោយទិដ្ឋិ នេះឯងបុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ នេះឯង បុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច ។

[៦៨] យេ កេចិ ភិក្ខវេ មយិ អវេច្ចប្បសន្នា សព្វេ តេ សោតាបន្នា តេសំ សោតាបន្នានំ ឥមេ-សំ បញ្ចន្នំ ឥធ និដ្ឋា បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។

កតមេសំ បញ្ចន្នំ ឥធ និដ្ឋា ។ សត្តក្ខត្តុបរ-មស្ស កោលង្កោលស្ស ឯកពីជិស្ស សកទាគាមិ-ស្ស យោ ច ទិដ្ឋេវ ធម្មេ អរហា ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ។

កតមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។ អន្ត-រាបរិនិព្វាយិស្ស ឧបហច្ចបរិនិព្វាយិស្ស អសង្ខារបរិ-និព្វាយិស្ស សសង្ខារបរិនិព្វាយិស្ស ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា ។

យេ កេចិ ភិក្ខវេ មយិ អវេច្ចប្បសន្នា សព្វេ តេ សោតាបន្នា តេសំ សោតាបន្នានំ ឥមេសំ បញ្ចន្នំ ឥធ និដ្ឋា ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋាតិ ។

ទិដ្ឋិកថា សមត្តា ។

[៦៨] ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណានីមួយ ជ្រះថ្លាមិនកម្រើកចំពោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថាសោតាបន្នបុគ្គល សោតាបន្នបុគ្គលទាំងនោះ ៥ ពួកនេះ សម្រេចក្នុងលោកនេះ ឯបុគ្គល ៥ ពួកទៀត លះលោកនេះហើយ សម្រេច ។

បុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ តើដូចម្តេច ។ សត្តក្ខត្តុបរមបុគ្គល ១ កោលង្កោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ បុគ្គលដែលជាព្រះអរហន្តក្នុងបច្ចុប្បន្ន ១ នេះបុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ ។

បុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច តើដូចម្តេច ។ អន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ នេះបុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច ។

ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណានីមួយ ជ្រះថ្លាមិនកម្រើកចំពោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថាសោតាបន្នបុគ្គល នេះឯងសោតាបន្នបុគ្គលទាំង ៥ ពួកនោះ សម្រេចក្នុងលោកនេះ នេះឯងបុគ្គល ៥ ពួក លះលោកនេះហើយ សម្រេច ។

ចប់ ទិដ្ឋិកថា ។

# មហាវគ្គេ អានាបានកថា

[៦៩] សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ វីសាធិកានិ ទ្វេ ញាណសតានិ ឧប្បជ្ជន្តិ អដ្ឋ បរិបន្ថេ(១) ញាណានិ អដ្ឋ ច ឧបការេ ញាណានិ អដ្ឋារស ឧបក្កិលេសេ ញាណានិ តេរស វោទានេ ញាណានិ ពត្តឹសំ សតោការីសុ(២) ញាណានិ ចតុវីសតិ សមាធិវសេន ញាណានិ ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ(៣) អដ្ឋ និព្វិទាញាណានិ អដ្ឋ និព្វិទានុលោមេ ញាណានិ អដ្ឋ និព្វិទាបដិប្បស្សទ្ធិញាណានិ(៤) ឯកវីសតិ វិមុត្តិសុខេ ញាណានិ ។

[៧០] កតមានិ អដ្ឋ បរិបន្ថេ ញាណានិ អដ្ឋ ច ឧបការេ ញាណានិ ។ កាមច្ឆន្ទោ សមាធិស្ស បរិបន្ថោ នេក្ខម្មំ សមាធិស្ស ឧបការំ ព្យាបាទោ សមាធិស្ស បរិបន្ថោ អព្យាបាទោ សមាធិស្ស ឧបការំ ថីនមិទ្ធំ សមាធិស្ស បរិបន្ថោ អាលោកសញ្ញា សមាធិស្ស ឧបការំ ឧទ្ធច្ចំ សមាធិស្ស បរិបន្ថោ អវិក្ខេបោ សមាធិស្ស ឧបការំ វិចិកិច្ឆា

---

១ ម. បរិពន្ធេ ។ ២ ម. សតោការិយេ ។ ៣ ឱ. ម. និព្វិទានុលោមញ្ញាណានិ ។ ៤ ឱ. ម. និព្វិទាយ បដិបស្សទ្ធិ ។

# មហាវគ្គ អានាបានកថា

[៦៩] កាលភិក្ខុចម្រើនអានាបានស្សតិសមាធិ មានវត្ថុ ១៦ ញាណចំនួន ២២០ ក៏កើតឡើង គឺបរិបន្ថញ្ញាណ ៨ ឧបការញ្ញាណ ៨ ឧបក្កិលេសញ្ញាណ ១៨ វោទានញ្ញាណ ១៣ សតោការិញ្ញាណ ៣២ សមាធិញ្ញាណ ២៤ វិបស្សនាញាណ ៧២ និព្វិទាញាណ ៨ និព្វិទានុលោមញ្ញាណ ៨ និព្វិទាបដិប្បស្សទ្ធិញ្ញាណ ៨ វិមុត្តិសុខញ្ញាណ ២១ ។

[៧០] បរិបន្ថញ្ញាណ ៨ និងឧបការញ្ញាណ ៨ តើដូចម្តេច ។ កាមច្ឆន្ទៈ ជាសត្រូវដល់សមាធិ នេក្ខម្មៈ ជាឧបការៈដល់សមាធិ ព្យាបាទ ជាសត្រូវដល់សមាធិ អព្យាបាទ ជាឧបការៈដល់សមាធិ ថីនមិទ្ធៈ ជាសត្រូវដល់សមាធិ អាលោកសញ្ញា ជាឧបការៈដល់សមាធិ ឧទ្ធច្ចៈ ជាសត្រូវដល់សមាធិ អវិក្ខេបៈ ជាឧបការៈដល់សមាធិ វិចិកិច្ឆា

សមាធិស្ស បរិបន្ថោ ធម្មវវត្ថានំ សមាធិស្ស ឧបការំ អវិជ្ជា សមាធិស្ស បរិបន្ថោ ញាណំ សមាធិស្ស ឧបការំ អរតិ សមាធិស្ស បរិបន្ថោ បាមុជ្ជំ សមាធិស្ស ឧបការំ សព្វេបិ អកុសលា ធម្មា សមាធិស្ស បរិបន្ថោ[១] សព្វេបិ កុសលា ធម្មា សមាធិស្ស ឧបការំ[២] ឥមានិ អដ្ឋ បរិបន្ថេ ញាណានិ អដ្ឋ ច ឧបការេ ញាណានិ ឥមេហិ សោឡសហិ អាការេហិ ឧទុបិតចិត្តំ សមុទុបិតចិត្តំ[៣] ឯកត្តេ សន្តិដ្ឋតិ នីវរណេហិ វិសុជ្ឈតិ ។

[៧១] កតមេ តេ ឯកត្តា ។ នេក្ខម្មំ ឯកត្តំ អព្យាបាទោ ឯកត្តំ អាលោកសញ្ញា ឯកត្តំ អវិក្ខេបោ ឯកត្តំ ធម្មវវត្ថានំ ឯកត្តំ ញាណំ ឯកត្តំ បាមុជ្ជំ ឯកត្តំ សព្វេ[៤] កុសលា ធម្មា ឯកត្តា ។

---

១ ម. បរិពន្ធា ។ ២ ម. ឧបការា ។ ៣ ឱ. ឧទ្ធតំ ចិត្តំ សមុទ្ធុចិត្តំ ។ ម. ឧទុចិតំ ចិត្តំ សមុទុចិតំ ចិត្តំ ។ ៤ ម. សព្វេបិ ។

ជាសត្រូវដល់សមាធិ ធម្មវវត្ថានៈ ជាឧបការៈដល់សមាធិ អវិជ្ជា ជាសត្រូវដល់សមាធិ ញាណ ជាឧបការៈដល់សមាធិ អរតិ ជាសត្រូវដល់សមាធិ បាមុជ្ជៈ ជាឧបការៈដល់សមាធិ អកុសលធម៌ទាំងអស់សុទ្ធតែជាសត្រូវដល់សមាធិ កុសលធម៌ទាំងអស់ សុទ្ធតែជាឧបការៈដល់សមាធិ ទាំងនេះ ឈ្មោះថាបរិបន្ថញ្ញាណ ៨ និងឧបការញ្ញាណ ៨ ចិត្តដែលស្ទុះខ្ពស់ឡើង ចិត្តដែលអណ្តែតត្រសែតផុតឡើង រមែងតាំងនៅស៊ប់ ក្នុងឯកត្តៈ រមែងស្អាតចាកនីវរណៈ ដោយអាការទាំង ១៦ នេះ ។

[៧១] ឯកត្តៈទាំងនោះ តើដូចម្តេច ។ នេក្ខម្មៈ ឈ្មោះថាឯកត្តៈ អព្យាបាទ ឈ្មោះថាឯកត្តៈ អាលោកសញ្ញា ឈ្មោះថាឯកត្តៈ អវិក្ខេបៈ ឈ្មោះថាឯកត្តៈ ធម្មវវត្ថានៈ ឈ្មោះថាឯកត្តៈ ញាណ ឈ្មោះថាឯកត្តៈ បាមុជ្ជៈ ឈ្មោះថាឯកត្តៈ កុសលធម៌ទាំងអស់ ឈ្មោះថាឯកត្តៈ ។

កតមេ តេ នីវរណា ។ កាមច្ឆន្ទោ នីវរណំ ព្យាបាទោ នីវរណំ ថីនមិទ្ធំ នីវរណំ ឧទ្ធច្ចកុក្កុច្ចំ នីវរណំ វិចិកិច្ឆា នីវរណំ អវិជ្ជា នីវរណំ អរតិ នីវរណំ សព្វេ អកុសលា ធម្មា នីវរណា ។

[៧២] នីវរណាតិ កេនដ្ឋេន នីវរណា ។ និយ្យានាវរណដ្ឋេន នីវរណា ។ កតមេ តេ និយ្យានា ។ នេក្ខម្មំ អរិយានំ និយ្យានំ តេន ច នេក្ខម្មេន អរិយា និយន្តិ កាមច្ឆន្ទោ និយ្យានាវរណំ តេន ច កាមច្ឆន្ទេន និវុតត្តា នេក្ខម្មំ អរិយានំ និយ្យានំ នប្បជានាតីតិ កាមច្ឆន្ទោ និយ្យានាវរណំ អព្យាបាទោ អរិយានំ និយ្យានំ តេន ច អព្យាបាទេន អរិយា និយន្តិ ព្យាបាទោ និយ្យានាវរណំ តេន ច ព្យាបាទេន និវុតត្តា អព្យាបាទំ[១] អរិយានំ និយ្យានំ នប្បជានាតីតិ ព្យាបាទោ

១ ម. អព្យាបាទា ។

នីវរណៈទាំងនោះ តើដូចម្ដេច ។ កាមច្ឆន្ទៈ ឈ្មោះថានីវរណៈ ព្យាបាទ ឈ្មោះថានីវរណៈ ថីនមិទ្ធៈ ឈ្មោះថានីវរណៈ ឧទ្ធច្ចកុក្កុច្ចៈ ឈ្មោះថានីវរណៈ វិចិកិច្ឆា ឈ្មោះថានីវរណៈ អវិជ្ជា ឈ្មោះថានីវរណៈ អរតិ ឈ្មោះថានីវរណៈ អកុសលធម៌ទាំងអស់ ឈ្មោះថានីវរណៈ ។

[៧២] សំណួរត្រង់ពាក្យថា នីវរណៈ ចុះនីវរណៈ ដោយអត្ថដូចម្ដេច ។ នីវរណៈ ដោយអត្ថថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) ។ ដំណើរទៅ (កាន់ព្រះនិព្វាន) ទាំងនោះ តើដូចម្ដេច ។ នេក្ខម្មៈ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារនេក្ខម្មៈនោះ កាមច្ឆន្ទៈ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់នេក្ខម្មៈដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវកាមច្ឆន្ទៈនោះបិទបាំង ហេតុនោះ កាមច្ឆន្ទៈ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) អព្យាបាទ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារអព្យាបាទនោះ ព្យាបាទ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់ អព្យាបាទដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវព្យាបាទនោះបិទបាំង ហេតុនោះ ព្យាបាទ ឈ្មោះថាធម៌ជា

និយ្យានាវរណំ អាលោកសញ្ញា អរិយានំ និយ្យានំ តាយ ច អាលោកសញ្ញាយ អរិយា នីយន្តិ ថីន-មិទ្ធំ និយ្យានាវរណំ តេន ច ថីនមិទ្ធេន និវុត្តា អាលោកសញ្ញំ អរិយានំ និយ្យានំ នប្បជានាតីតិ ថីនមិទ្ធំ និយ្យានាវរណំ អវិក្ខេបោ អរិយានំ និយ្យានំ តេន ច អវិក្ខេបេន អរិយា នីយន្តិ ឧទ្ធច្ចំ និយ្យានាវរណំ តេន ច ឧទ្ធច្ចេន និវុត្តា អវិក្ខេបំ អរិយានំ និយ្យានំ នប្បជានាតីតិ ឧទ្ធច្ចំ និយ្យានាវរណំ ធម្មវវត្ថានំ អរិយានំ និយ្យានំ តេន ច ធម្មវវត្ថានេន អរិយា នីយន្តិ វិចិកិច្ឆា និយ្យានាវរណំ តាយ ច វិចិកិច្ឆាយ និវុត្តា ធម្ម-វវត្ថានំ អរិយានំ និយ្យានំ នប្បជានាតីតិ វិចិកិច្ឆា

គ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) អាលោកសញ្ញា ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារអាលោកសញ្ញានោះ ថីនមិទ្ធៈ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់អាលោកសញ្ញាដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវថីនមិទ្ធៈនោះបិទបាំង ហេតុនោះ ថីនមិទ្ធៈ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) អវិក្ខេបៈ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារអវិក្ខេបៈនោះ ឧទ្ធច្ចៈ ឈ្មោះធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់អវិក្ខេបៈ ដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវឧទ្ធច្ចៈនោះបិទបាំង ហេតុនោះ ឧទ្ធច្ចៈ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) ធម្មវវត្ថានៈ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារធម្មវវត្ថានៈនោះ វិចិកិច្ឆា ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់ធម្មវវត្ថានៈដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវវិចិកិច្ឆានោះបិទបាំង ហេតុនោះ វិចិកិច្ឆា ឈ្មោះថាធម៌ជា

៨៧



និយ្យានាវរណំ ញាណំ អរិយានំ និយ្យានំ តេន ច ញាណេន អរិយា នីយន្តិ អវិជ្ជា និយ្យានាវរណំ តាយ ច អវិជ្ជាយ និវុតត្តា ញាណំ អរិយានំ និយ្យានំ នប្បជានាតីតិ អវិជ្ជា និយ្យានាវរណំ ចា-មុជ្ជំ អរិយានំ និយ្យានំ តេន ច ចាមុជ្ជេន អរិយា នីយន្តិ អរតិ និយ្យានាវរណំ តាយ ច អរតិយា និវុតត្តា ចាមុជ្ជំ អរិយានំ និយ្យានំ នប្បជានាតីតិ អរតិ និយ្យានាវរណំ សព្វេបិ កុសលា ធម្មា អរិយានំ និយ្យានំ តេហិ ច ធម្មេហិ អរិយា នីយន្តិ សព្វេបិ អកុសលា ធម្មា និយ្យានា-វរណា តេហិ ច អកុសលេហិ ធម្មេហិ និវុតត្តា កុសលេ ធម្មេ អរិយានំ និយ្យានំ នប្បជានាតីតិ

គ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) ញាណ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារញាណនោះ អវិជ្ជា ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនដឹងច្បាស់ញាណដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវអវិជ្ជានោះបិទបាំង ហេតុនោះ អវិជ្ជា ឈ្មោះថាជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បាមុជ្ជៈ ឈ្មោះថាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារបាមុជ្ជៈនោះ អរតិ ឈ្មោះថាធម៌ជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនដឹងច្បាស់បាមុជ្ជៈ ដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ព្រោះត្រូវអរតិនោះបិទបាំង ហេតុនោះ អរតិ ឈ្មោះថាជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) កុសលធម៌ទាំងអស់ ជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ (កាន់ព្រះនិព្វាន) ដោយសារធម៌ទាំងឡាយនោះ អកុសលធម៌ទាំងអស់ សុទ្ធតែជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) បុគ្គលមិនស្គាល់ច្បាស់នូវកុសលធម៌ ដែលជាដំណើរទៅ (កាន់ព្រះនិព្វាន) របស់ពួកអរិយជន

សព្វេបិ អកុសលា ធម្មា និយ្យានាវរណា ឥមេហិ ច បន នីវរណេហិ វិសុទ្ធចិត្តស្ស សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ ខណិកសមោធានា ។

[៧៣] កតមេ អដ្ឋារស ឧបក្កិលេសា ឧប្បជ្ជន្តិ ។ អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្តវិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធាវិក្ខេបគតំ ចិត្តំ សមាធិស្ស បរិបន្ថោ អស្សាសបដិកង្ខណា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ បស្សាសបដិកង្ខណា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ អស្សាសេនាភិតុន្នស្ស បស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ បស្សាសេនាភិតុន្នស្ស អស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ ។

ព្រោះត្រូវពួកអកុសលធម៌នោះបិទបាំង ហេតុនោះ ពួកអកុសលធម៌ទាំងអស់នោះ ឈ្មោះថាជាគ្រឿងរារាំងដំណើរទៅ (កាន់ព្រះនិព្វាន) កាលភិក្ខុមានចិត្តបរិសុទ្ធ ចាកនីវរណធម៌ទាំងនេះ ចម្រើនអានាបានស្សតិសមាធិដែលមានវត្ថុ ១៦ ខណិកសមោធាន (ក៏កើតមាន) ។

[៧៣] ឧបក្កិលេសញ្ញាណ ១៨ កើតឡើង តើដូចម្តេច ។ កាលបុគ្គលផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្តាល និងខាងចុង ចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុង ជាសត្រូវរបស់សមាធិ កាលបុគ្គលផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចូល ខាងដើម កណ្តាល និងខាងចុង ចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ ជាសត្រូវរបស់សមាធិ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចេញ សេចក្តីត្រេកត្រអាល សេចក្តីប្រព្រឹត្តនៃចំណង់ ជាសត្រូវរបស់សមាធិ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចូល សេចក្តីត្រេកត្រអាល សេចក្តីប្រព្រឹត្តនៃចំណង់ ជាសត្រូវរបស់សមាធិ ការជ្រប់ចិត្តក្នុងការបានចំពោះ នូវខ្យល់ដកដង្ហើមចូលសម្រាប់បុគ្គលដែលលំបាកដោយខ្យល់ដកដង្ហើមចេញ ជាសត្រូវរបស់សមាធិការជ្រប់ចិត្តក្នុងការបានចំពោះ នូវខ្យល់ដកដង្ហើមចេញ សម្រាប់បុគ្គលដែលទប់ខ្យល់ដកដង្ហើមចូល ជាសត្រូវរបស់សមាធិ ។

អនុគច្ឆតា ច អស្សាសំ បស្សាសំ អនុគច្ឆតា
សតិ អជ្ឈត្តវិក្ខេបា កង្ខណា ពហិទ្ធាវិក្ខេបបត្ថនា[១]
ឆ ឯតេ ឧបក្កិលេសា អានាបានស្សតិសមាធិស្ស
យេហិ វិកម្បមានស្ស[២] នោ ចេ ចិត្តំ វិមុច្ចតិ
វិមោក្ខំ អប្បជានន្តា តេ ហោន្តិ បរបត្តិយាតិ ។

[៧៤] និមិត្តំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ អស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ និមិត្តំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ បស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ អស្សាសំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ បស្សាសំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បតិ សមាធិស្ស បរិបន្ថោ ។

១ ឱ. ម. ពហិទ្ធាវិក្ខេបបត្ថនា អស្សាសេនាភិតុន្នស្ស បស្សាសបដិលាភេ មុច្ឆនា បស្សាសេនាភិតុន្នស្ស អស្សាសបដិលាភេ មុច្ឆនា ។ ២ ឱ. ម. វិក្ខេបមានស្ស ។

ប្រសិនបើចិត្ត របស់បុគ្គលកាលនៅញាប់ញ័រ មិនទាន់ផុតស្រឡះ ចាកឧបក្កិលេសទាំងឡាយណា ឧបក្កិលេសរបស់អានាបានស្សតិសមាធិនោះ មាន ៦ គឺ ការផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញ ១ ការផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចូល ១ សតិ ១ ការបោះចិត្តទៅក្នុងខ្យល់ដង្ហើមខាងក្នុង ១ សេចក្ដីប៉ុនប៉ង ១ សេចក្ដីប្រាថ្នាក្នុងការបោះចិត្តទៅក្នុងខ្យល់ដង្ហើមខាងក្រៅ ១ ពួកជននោះ កាលដែលមិនទាន់ដឹងច្បាស់នូវវិមោក្ខ តែងនៅជឿអ្នកដទៃ ។

[៧៤] កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចេញ ជាសត្រូវរបស់សមាធិ ។

និមិត្តំ អាវជ្ជមានស្ស អស្សាសេ វិក្ខិប្បតេ មនោ
អស្សាសំ អាវជ្ជមានស្ស និមិត្តេ ចិត្តំ វិកម្បតិ
និមិត្តំ អាវជ្ជមានស្ស បស្សាសេ វិក្ខិប្បតេ មនោ
បស្សាសំ អាវជ្ជមានស្ស និមិត្តេ ចិត្តំ វិកម្បតិ
អស្សាសំ អាវជ្ជមានស្ស បស្សាសេ វិក្ខិប្បតេ មនោ
បស្សាសំ អាវជ្ជមានស្ស អស្សាសេ ចិត្តំ វិកម្បតិ
ឆ ឯតេ ឧបក្កិលេសា អានាបានស្សតិសមាធិស្ស
យេហិ វិកម្បមានស្ស(១) នោ ចេ ចិត្តំ វិមុច្ចតិ
វិមោក្ខំ អប្បជានន្តា តេ ហោន្តិ បរបត្តិយាតិ ។

[៧៤] អតីតានុធាវនំ ចិត្តំ វិក្ខេបានុបតិតំ ស-មាធិស្ស បរិបន្ថោ អនាគតប្បដិកង្ខណំ ចិត្តំ វិកម្បិតំ(២) សមាធិស្ស បរិបន្ថោ លីនំ ចិត្តំ កោសជ្ជានុបតិតំ សមាធិស្ស បរិបន្ថោ អតិប្បគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ សមាធិស្ស បរិបន្ថោ អភិញ្ញាតំ(៣) ចិត្តំ

១ ឱ. ម. វិក្ខេបមានស្ស ។ ២ ឱ. វិក្ខម្ភិតំ ។ ៣ ឱ. អពិលាតំ ។ ម. អពិនតំ ។

ប្រសិនបើចិត្តរបស់បុគ្គល កាលនៅញាប់ញ័រ មិនទាន់ផុតស្រឡះ ចាកឧបក្កិលេសទាំងឡាយណា ឧបក្កិលេសទាំងឡាយនោះ របស់អានាបានស្សតិសមាធិ មាន ៦ យ៉ាង គឺ កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចេញ ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ១ កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចូល ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ ១ ជនទាំងនោះ កាលមិនទាន់ដឹងច្បាស់នូវវិមោក្ខ តែងនៅជឿអ្នកដទៃ ។

[៧៩] ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត ដែលធ្លាក់ទៅ ក្នុងសេចក្តីរាយមាយ ជាសត្រូវ របស់សមាធិ ចិត្តប្រាថ្នារកអារម្មណ៍ ជាអនាគត ដែលញាប់ញ័រ ជាសត្រូវ របស់សមាធិ ចិត្តរួញរា ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ជាសត្រូវ របស់សមាធិ ចិត្តផ្គងហួសពេក ដែលធ្លាក់ទៅ ក្នុងឧទ្ធច្ចៈ ជាសត្រូវ របស់សមាធិ ចិត្តប្រាកដ

រាគានុបតិតំ សមាធិស្ស បរិបន្ថោ អបញ្ញាតំ[១] ចិត្តំ ព្យាបាទានុបតិតំ សមាធិស្ស បរិបន្ថោ ។

អតីតានុធាវនំ ចិត្តំ
អនាគតបាដិកង្ខណំ
លីនំ អតិបគ្គហិតំ អភិញ្ញាតំ
អបញ្ញាតំ ចិត្តំ ន សមាធិយតិ
ឆ ឯតេ ឧបក្កិលេសា
អានាបានស្សតិសមាធិស្ស
យេហិ[២] ឧបក្កិលិដ្ឋសង្កប្បោ
អធិចិត្តំ នប្បជានាតីតិ ។

[៧៦] អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្តំ វិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធា វិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អស្សាសប្បដិកង្ខណាយ និកន្តិយា តណ្ហាចរិយាយ កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច

១ ឱ. អបណតំ ។ ម. អបនតំ ។ ២ ម. តេហិ ។

ដែលធ្លាក់ទៅក្នុងរាគៈ ជាសត្រូវរបស់សមាធិ ចិត្តមិនប្រាកដ ដែលធ្លាក់ទៅក្នុងព្យាបាទ ជាសត្រូវរបស់សមាធិ ។

បុគ្គលមានសង្កប្បៈសៅហ្មងហើយ រមែងមិនស្គាល់ច្បាស់នូវអធិចិត្ត ដោយសារពួកឧបក្កិលេសណា ឧបក្កិលេស ទាំងឡាយនោះ របស់អានាបានស្សតិសមាធិ មាន ៦ យ៉ាង គឺ ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីតៈ ១ ចិត្តប្រាថ្នារកអារម្មណ៍ជាអនាគត ១ ចិត្តរួញរា ១ ចិត្តផ្គងហួសពេក ១ ចិត្តប្រាកដ ១ ចិត្តមិនប្រាកដ ១ រមែងមិនតម្កល់នៅមាំឡើយ ។

[៧៦] កាលភិក្ខុផ្ចង់ស្មារតីទៅ កាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្តាល នឹងខាងចុង កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅ ក្នុងខ្យល់ដង្ហើមខាងក្នុង កាលភិក្ខុផ្ចង់ស្មារតីទៅ កាន់ខ្យល់ដកដង្ហើមចូលខាងដើម កណ្តាល និងខាងចុង កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្ត ដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសេចក្តីប្រាថ្នារកខ្យល់ដកដង្ហើមចេញ

បស្សាសប្បដិកង្ខណាយ និកន្តិយា តណ្ហាចរិយាយ កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អស្សាសេជាភិតុន្នស្ស បស្សាសប្បដិលាភេ មុច្ឆិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច[១] និមិត្តំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច និមិត្តំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច បស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អស្សាសំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច

១ ឱ. ម. ឯត្តន្តរេ បស្សាសេនាភិតុន្នស្ស អស្សាសប្បដិលាភេ មុច្ឆិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ចាតិ ទិស្សតិ ។

ដោយសេចក្តីត្រេកអរ ដោយសេចក្តីប្រព្រឹត្តនៃចំណង់ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារសេចក្តីប្រាថ្នារកខ្យល់ដកដង្ហើមចូល ដោយសេចក្តីត្រេកអរ ដោយសេចក្តីប្រព្រឹត្តនៃចំណង់ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះជ្រប់ចិត្តក្នុងការបានចំពោះ នូវខ្យល់ដកដង្ហើមចូល សម្រាប់អ្នកទប់ខ្យល់ដកដង្ហើមចេញ កាលភិក្ខុនឹកនិមិត្ត កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ កាលភិក្ខុនឹកខ្យល់ដកដង្ហើមចេញ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងនិមិត្ត កាលភិក្ខុនឹកនិមិត្ត កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល កាលភិក្ខុនឹកខ្យល់ដកដង្ហើមចូល កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រ ក្នុងនិមិត្ត កាលភិក្ខុ នឹកខ្យល់ដកដង្ហើមចេញ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង

បស្សាសំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អតីតានុធាវនេន ចិត្តេន វិក្ខេបានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អនាគតបាដិកង្ខេន ចិត្តេន វិកម្បិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច លីនេន ចិត្តេន កោសជ្ជានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អតិប្បគ្គហិតេន ចិត្តេន ឧទ្ធច្ចានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អភិញ្ញាតេន ចិត្តេន រាគានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច អបញ្ញាតេន ចិត្តេន ព្យាបាទានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច ។

ព្រោះចិត្តញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល កាលភិក្ខុ នឹកខ្យល់ដកដង្ហើមចូល កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តស្ទុះទៅរកអារម្មណ៍ជាអតីតៈ ដែលធ្លាក់ទៅក្នុងសេចក្តីរាយមាយ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តប្រាថ្នារកអារម្មណ៍ជាអនាគត ដែលញាប់ញ័រ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តរួញរាដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តដែលប្រាកដ ដែលធ្លាក់ទៅក្នុងរាគៈ កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តមិនប្រាកដ ដែលធ្លាក់ទៅក្នុងព្យាបាទ ។

អានាបានស្សតិ យស្ស អបរិបុណ្ណា[១] អភាវិតា កាយោបិ ឥញ្ជិតោ ហោតិ ចិត្តម្បិ ហោតិ ឥញ្ជិតំ កាយោបិ ផន្ទិតោ ហោតិ ចិត្តម្បិ ហោតិ ផន្ទិតំ អានាបានស្សតិ យស្ស បរិបុណ្ណា សុភាវិតា កាយោបិ អនិញ្ជិតោ ហោតិ ចិត្តម្បិ ហោតិ អនិញ្ជិតំ កាយោបិ អផន្ទិតោ ហោតិ ចិត្តម្បិ ហោតិ អផន្ទិតន្តិ ។

តេហិ ច បន នីវរណេហិ វិសុទ្ធចិត្តស្ស សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ ខណិកសមោធានា ឥមេ អដ្ឋារស ឧបក្កិលេសា ឧប្បជ្ជន្តិ ។

[៧៧] កតមានិ តេរស វោទានេ ញាណានិ ។ អតីតានុធាវនំ ចិត្តំ វិក្ខេបានុបតិតំ តំ វិវជ្ជយិត្វា ឯកដ្ឋានេ សមាទហតិ ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ អនាគតបដិកង្ខណំ ចិត្តំ វិកម្បិតំ[២] តំ វិវជ្ជយិត្វា តត្ថេវ អធិមោក្ខេតិ[៣] ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ លីនំ ចិត្តំ កោសជ្ជានុបតិតំ

១ ម. បរិបុណ្ណា ។ ២ ឱ. វិក្ខម្ភតិ ។ ៣ ឱ. ម. អធិមោចេតិ ។

បុគ្គលណាមិនបានបំពេញ មិនបានចម្រើនអានាបានស្សតិ បុគ្គលនោះរមែងមានកាយរំភើបផង មានចិត្តរំភើបផង មានកាយញាប់ញ័រផង មានចិត្តញាប់ញ័រផង បុគ្គលណាបានបំពេញ បានចម្រើនល្អនូវអានាបានស្សតិ បុគ្គលនោះ រមែងមានកាយមិនរំភើបផង មានចិត្តមិនរំភើបផង មានកាយមិនញាប់ញ័រផង មានចិត្តមិនញាប់ញ័រផង ។

កាលភិក្ខុមានចិត្តស្អាត ចាកនីវរណធម៌ទាំងនោះ ចម្រើនអានាបានស្សតិសមាធិ មានវត្ថុ ១៦ ខណិកសមោធាន (ក៏កើតមាន) នេះឯងឧបក្កិលេសទាំង ១៨ កើតឡើង ។

[៧៧] វោទានញ្ញាណ ១៣ តើដូចម្តេច ។ ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត ដែលធ្លាក់ទៅក្នុងសេចក្តីរាយមាយ បុគ្គលវៀរ នូវចិត្តនោះហើយតម្កល់ទុកក្នុងឋានមួយ ចិត្តមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ចិត្តប្រាថ្នារកអារម្មណ៍ជាអនាគត ដែលញាប់ញ័រ បុគ្គលវៀរនូវចិត្តនោះហើយ រមែងរួចស្រឡះ ចាកចិត្តនោះឯង ចិត្តមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ចិត្តរួញរា ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស

តំ បគ្គណ្ហិត្វា កោសជ្ជំ បជហតិ ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ អតិប្បគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ តំ និគ្គណ្ហិត្វា ឧទ្ធច្ចំ បជហតិ ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ អភិញ្ញាតំ ចិត្តំ រាគានុបតិតំ តំ សម្បជានោ ហុត្វា រាគំ បជហតិ ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ អបញ្ញាតំ ចិត្តំ ព្យាបាទានុបតិតំ តំ សម្បជានោ ហុត្វា ព្យាបាទំ បជហតិ ឯវំបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ ឥមេហិ ឆហិ ឋានេហិ បរិសុទ្ធំ ចិត្តំ បរិ-យោទាតំ ឯកត្តគតំ ហោតិ ។

[៧៨] កតមេ តេ ឯកត្តា ។ ទានវោស្សគ្គុប-ដ្ឋានេកត្តំ សមថនិមិត្តុបដ្ឋានេកត្តំ វយលក្ខណុប-ដ្ឋានេកត្តំ និរោធុបដ្ឋានេកត្តំ ទានវោស្សគ្គុបដ្ឋា-នេកត្តំ ចាគាធិមុត្តានំ សមថនិមិត្តុបដ្ឋានេកត្តញ្ច អធិចិត្តមនុយុត្តានំ វយលក្ខណុបដ្ឋានេកត្តញ្ច វិប-ស្សកានំ និរោធុបដ្ឋានេកត្តញ្ច អរិយបុគ្គលានំ

បុគ្គលផ្គងនូវចិត្តនោះ ហើយលះបង់សេចក្តីខ្ជិលច្រអូស ចិត្តមិនដល់សេចក្តីពាយមាយ យ៉ាងនេះខ្វះ ចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ បុគ្គល សង្កត់សង្កិនចិត្តនោះ ហើយលះបង់ឧទ្ធច្ចៈ ចិត្តរមែងមិនដល់សេចក្តីពាយមាយ យ៉ាងនេះខ្វះ ចិត្តប្រាកដ ដែលធ្លាក់ទៅក្នុងរាគៈ បុគ្គលជាអ្នកស្គាល់ចិត្តនោះច្បាស់ លះបង់រាគៈ ចិត្តរមែងមិនដល់សេចក្តីពាយមាយ យ៉ាងនេះខ្វះ ចិត្តមិនប្រាកដ ដែលធ្លាក់ទៅក្នុងព្យាបាទ បុគ្គលជាអ្នកស្គាល់ចិត្តនោះច្បាស់ លះបង់ព្យាបាទ ចិត្តរមែងមិនដល់សេចក្តីពាយមាយ យ៉ាងនេះខ្វះ ចិត្តរមែងស្អាត ផូរផង់ ដល់នូវឯកត្តៈដោយឋានទាំងឡាយ ៦ នេះឯង ។

[៧៨] ឯកត្តៈទាំងនោះ តើដូចម្តេច ។ ទានវោស្សគ្គុបដ្ឋាន ឈ្មោះថាឯកត្តៈ សមថនិមិត្តុបដ្ឋាន ឈ្មោះថាឯកត្តៈ វយលក្ខណុបដ្ឋាន ឈ្មោះថាឯកត្តៈ និរោធុបដ្ឋាន ឈ្មោះថាឯកត្តៈ ទានវោស្សគ្គុបដ្ឋាន របស់បុគ្គលអ្នកចុះចិត្តស៊ប់ ក្នុងការលះបង់ ឈ្មោះថាឯកត្តៈ សមថនិមិត្តុបដ្ឋាន របស់ពួកបុគ្គលអ្នកប្រកបរឿយ ៗ ក្នុងអធិចិត្ត ឈ្មោះថាឯកត្តៈ វយលក្ខណុបដ្ឋាន របស់បុគ្គលអ្នកពិចារណា ឈ្មោះថាឯកត្តៈ និង និរោធុបដ្ឋាន របស់ពួកអរិយបុគ្គល ឈ្មោះថាឯកត្តៈ

ឥមេហិ ចតូហិ ហានេហិ ឯកត្តគតំ ចិត្តំ បដិបទា-
វិសុទ្ធិប្បសន្នញ្ចេវ ហោតិ ឧបេក្ខានុព្រូហិតញ្ច ញា-
ណេន ច សម្បហំសិតំ ។

[៧៩] បឋមជ្ឈានស្ស កោ អាទិ កឹ មជ្ឈេ
កឹ បរិយោសានំ ។ បឋមជ្ឈានស្ស បដិបទាវិសុទ្ធិ
អាទិ ឧបេក្ខានុព្រូហនា មជ្ឈេ សម្បហំសនា បរិ-
យោសានំ ។

[៨០] បឋមជ្ឈានស្ស បដិបទាវិសុទ្ធិ អាទិ អា-
ទិស្ស កតិ លក្ខណានិ ។ អាទិស្ស តីណិ លក្ខ-
ណានិ យោ តស្ស បរិបន្ថោ តតោ ចិត្តំ វិសុជ្ឈតិ
វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ បដិ-
បន្នត្តា តត្ថ ចិត្តំ បក្ខន្ទតិ យញ្ច បរិបន្ថតោ ចិត្តំ
វិសុជ្ឈតិ យញ្ច វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិ-
មិត្តំ បដិបជ្ជតិ យញ្ច បដិបន្នត្តា តត្ថ ចិត្តំ បក្ខ-
ន្ទតិ បឋមជ្ឈានស្ស បដិបទាវិសុទ្ធិ អាទិ អាទិស្ស
ឥមានិ តីណិ លក្ខណានិ តេន វុច្ចតិ បឋមជ្ឈានំ
អាទិកល្យាណញ្ចេវ ហោតិ លក្ខណសម្បន្នញ្ច ។

ចិត្តដែលដល់នូវឯកត្តៈ ដោយឋានទាំង ៤ នេះ ឈ្មោះថាជាធម្មជាតជ្រះ-ថ្លា ដោយបដិបទាវិសុទ្ធិផង ឈ្មោះថាការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យផង ឈ្មោះថារីករាយដោយញាណផង ។

[៧៩] បឋមជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ បឋមជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម មានការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល មានការរីករាយព្រមជាខាងចុង ។

[៨០] បឋមជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម តើបដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈប៉ុន្មានយ៉ាង ។ បដិបទាវិសុទ្ធិ ជាខាងដើម មានលក្ខណៈ ៣ យ៉ាង គឺ ធម៌ណាជាសត្រូវនៃបឋមជ្ឈាននោះ ចិត្តរមែងបរិសុទ្ធចាកធម៌នោះ ចិត្តរមែងដើរឆ្ពោះទៅ កាន់សមថនិមិត្តជាកណ្តាលព្រោះសេចក្តីស្អាត ចិត្តរមែងស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ គឺត្រង់ដែលចិត្តបរិសុទ្ធ ចាកធម៌ជាសត្រូវ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ១ ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ (ទាំង ៣ នេះ) ឈ្មោះថា បដិបទាវិសុទ្ធិ ជាខាងដើម របស់បឋមជ្ឈាន នេះឯងលក្ខណៈ ៣ យ៉ាង របស់បដិបទាវិសុទ្ធិ ជាខាងដើម ហេតុនោះ លោកពោលថា បឋមជ្ឈាន មានលម្អខាងដើមផង បរិបូរដោយលក្ខណៈផង ។

៩៧

មហាវគ្គេ អានាបានកថា

[៨១] បឋមជ្ឈានស្ស ឧបេក្ខានុព្រូហនា មជ្ឈេ មជ្ឈស្ស កតិ លក្ខណានិ ។ មជ្ឈស្ស តីណិ លក្ខណានិ វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ សមថប្បដិបន្នំ អជ្ឈុបេក្ខតិ ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ យញ្ច វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ យញ្ច សមថប្បដិបន្នំ អជ្ឈុបេក្ខតិ យញ្ច ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ បឋមជ្ឈានស្ស ឧបេក្ខានុព្រូហនា មជ្ឈេ មជ្ឈស្ស ឥមានិ តីណិ លក្ខណានិ តេន វុច្ចតិ បឋមជ្ឈានំ មជ្ឈេកល្យាណញ្ចេវ ហោតិ លក្ខណសម្បន្នញ្ច ។

[៨១] បឋមជ្ឈាន មានការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល តើការសម្លឹងពិនិត្យ ជាកិច្ចកណ្តាល មានលក្ខណៈប៉ុន្មានយ៉ាង ។ ការសម្លឹងពិនិត្យ ទុកជាកិច្ចកណ្តាល មានលក្ខណៈ ៣ យ៉ាង គឺ ចិត្តដែលបរិសុទ្ធ រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលដើរឆ្ពោះទៅរកសមថៈ រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលតាំងឡើង ក្នុងឯកត្តៈ រមែងសម្លឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តបរិសុទ្ធ សម្លឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថៈ សម្លឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តតាំងឡើងក្នុងឯកត្តៈ សម្លឹងផ្ទៀងផ្ទាត់ ១ (ទាំង ៣ នេះ) ឈ្មោះថាការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ទុកជាកិច្ចកណ្តាល នៃបឋមជ្ឈាន នេះឯងលក្ខណៈ ៣ យ៉ាង របស់ការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកិច្ចកណ្តាល ហេតុនោះ លោកពោលថា បឋមជ្ឈានមានលម្អក្នុងកណ្តាលផង បរិបូរដោយលក្ខណៈផង ។

[៨២] បឋមជ្ឈានស្ស សម្បហំសនាបរិយោសានំ បរិយោសានស្ស កតិ លក្ខណានិ ។ បរិយោសានស្ស ចត្តារិ លក្ខណានិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សម្បហំសនា ឥន្ទ្រិយានំ ឯករសដ្ឋេន សម្បហំសនា តទុបគវីរិយវាហនដ្ឋេន សម្បហំសនា អាសេវនដ្ឋេន សម្បហំសនា បឋមជ្ឈានស្ស សម្បហំសនា បរិយោសានំ បរិយោសានស្ស ឥមានិ ចត្តារិ លក្ខណានិ តេន វុច្ចតិ បឋមជ្ឈានំ បរិយោសានកល្យាណញ្ចេវ ហោតិ លក្ខណសម្បន្នញ្ច ឯវំ តិវត្តគតំ ចិត្តំ តិវិធកល្យាណំ ទសលក្ខណសម្បន្នំ វិតក្កសម្បន្នញ្ចេវ ហោតិ វិចារសម្បន្នញ្ច បីតិសម្បន្នញ្ច សុខសម្បន្នញ្ច ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធាសម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិសម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។

[៨២] បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង តើការរីករាយព្រម ជាខាងចុង មានលក្ខណៈ ប៉ុន្មានយ៉ាង ។ ការរីករាយព្រម ជាខាងចុង មានលក្ខណៈ ៤ យ៉ាង គឺ ការរីករាយព្រម ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ ដែលកើតក្នុងបឋមជ្ឈាននោះ ១ ការរីករាយព្រម ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ការរីករាយព្រម ដោយអត្ថថានាំទៅនូវព្យាយាម គួរដល់ឥន្ទ្រិយនោះ ១ ការរីករាយព្រម ដោយអត្ថថាសេព ១ (ទាំង ៤ នេះ ) ឈ្មោះថាការរីករាយព្រម ជាខាងចុង របស់បឋមជ្ឈាន នេះឯងការរីករាយព្រម ជាខាងចុង មានលក្ខណៈ ៤ យ៉ាង ហេតុនោះ លោកពោលថា បឋមជ្ឈាន មានលម្អខាងចុងផង បរិបូរដោយលក្ខណៈផង ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាង នេះឯង រមែងជាចិត្តបរិបូរដោយលក្ខណៈ ១០ យ៉ាង គឺ បរិបូរដោយវិតក្កៈ ១ បរិបូរដោយវិចារៈ ១ បរិបូរដោយបីតិ ១ បរិបូរដោយសុខៈ ១ បរិបូរដោយអធិដ្ឋានចិត្ត ១ បរិបូរដោយសទ្ធា ១ បរិបូរដោយវីរិយៈ ១ បរិបូរដោយសតិ ១ បរិបូរដោយសមាធិ ១ បរិបូរដោយបញ្ញា ១ ។

[៨៣] ទុតិយជ្ឈានស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ ទុតិយជ្ឈានស្ស បដិបទាវិសុទ្ធិ អាទិ ឧបេក្ខានុព្រូហនា មជ្ឈេ សម្បហំសនា បរិយោសានំ ។ បេ ។ ឯវំ តិវត្តគតំ ចិត្តំ តិវិធកល្យាណកំ ទសលក្ខណសម្បន្នំ វិចារសម្បន្នញ្ចេវ(១) បីតិសម្បន្នញ្ចេវ ហោតិ សុខសម្បន្នញ្ច ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធាសម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិសម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។

[៨៤] តតិយជ្ឈានស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ បេ ។ ឯវំ តិវត្តគតំ ចិត្តំ តិវិធកល្យាណកំ ទសលក្ខណសម្បន្នំ បីតិសម្បន្នញ្ច(២) សុខសម្បន្នញ្ចេវ ហោតិ ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធាសម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិសម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។

---

១ ឱ. ម. អយំ បាឋោ នត្ថិ ។ ២ ឱ. ម. អយំ បាឋោ នត្ថិ ។

[៨៣] ទុតិយជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ ទុតិយជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម មានការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល មានការរីករាយព្រម ជាខាងចុង ។ បេ ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្តបរិបូរ ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូរដោយវិចារៈ ១ បរិបូរដោយបីតិ ១ បរិបូរដោយសុខ ១ បរិបូរដោយអធិដ្ឋានចិត្ត ១ បរិបូរដោយសទ្ធា ១ បរិបូរដោយវីរិយៈ ១ បរិបូរដោយសតិ ១ បរិបូរដោយសមាធិ ១ បរិបូរដោយបញ្ញា ១ ។

[៨៤] តតិយជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ បេ ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្តបរិបូរដោយលក្ខណៈ ១០ យ៉ាង គឺបរិបូរដោយបីតិ ១ បរិបូរដោយសុខ ១ បរិបូរដោយអធិដ្ឋានចិត្ត ១ បរិបូរដោយសទ្ធា ១ បរិបូរដោយវីរិយៈ ១ បរិបូរដោយសតិ ១ បរិបូរដោយសមាធិ ១ បរិបូរដោយបញ្ញា ១ ។

[៨៥] ចតុត្ថជ្ឈានស្ស កោ អាទិ កិំ មជ្ឈេ កិំ បរិយោសានំ ។ បេ ។ ឯវំ តិវត្តកតំ ចិត្តំ តិវិធ-កល្យាណកំ ទសលក្ខណសម្បន្នំ ឧបេក្ខាសម្ប-ន្នញ្ចេវ ហោតិ ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធា-សម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិ-សម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។

[៨៦] អាកាសានញ្ចាយតនសមាបត្តិយា វិញ្ញា-ណញ្ចាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសមា-បត្តិយា នេវសញ្ញានាសញ្ញាយតនសមាបត្តិយា កោ អាទិ កិំ មជ្ឈេ កិំ បរិយោសានំ ។ បេ ។ ឯវំ តិវត្តកតំ ចិត្តំ តិវិធកល្យាណកំ ទសលក្ខណសម្បន្នំ ឧបេក្ខាសម្បន្នញ្ចេវ ហោតិ ចិត្តស្ស អធិដ្ឋានស-ម្បន្នញ្ច ។ បេ ។ បញ្ញាសម្បន្នញ្ច ។

[៨៥] ចតុត្ថជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាខាងចុង ។ បេ ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូរ ដោយលក្ខណៈ ១០ យ៉ាង គឺ បរិបូរដោយឧបេក្ខា ១ បរិបូរដោយអធិដ្ឋានចិត្ត ១ បរិបូរដោយសទ្ធា ១ បរិបូរដោយវីរិយៈ ១ បរិបូរដោយសតិ ១ បរិបូរដោយសមាធិ ១ បរិបូរដោយបញ្ញា ១ ។

[៨៦] អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ និងនេវសញ្ញានាសញ្ញាយតនសមាបត្តិ មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាខាងចុង ។ បេ ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូរដោយលក្ខណៈ ១០ យ៉ាង គឺបរិបូរដោយឧបេក្ខា ១ បរិបូរដោយអធិដ្ឋានចិត្ត ១ ។ បេ ។ បរិបូរដោយបញ្ញា ១ ។

[៨៧] អនិច្ចានុបស្សនាយ កោ អាទិ កិំ មជ្ឈេ កិំ បរិយោសានំ ។ បេ ។ ឯវំ តិវត្តកតំ ចិត្តំ តិវិធ-កល្យាណកំ ទសលក្ខណសម្បន្នញ្ចេវ ហោតិ វិចារសម្បន្នញ្ច បីតិសម្បន្នញ្ច សុខសម្បន្នញ្ច ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធាសម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិសម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។ ទុក្ខានុបស្សនាយ អនត្តានុបស្សនាយ និព្វិទានុប-ស្សនាយ វិរាគានុបស្សនាយ និរោធានុបស្សនាយ បដិនិស្សគ្គានុបស្សនាយ ខយានុបស្សនាយ វយានុ-បស្សនាយ វិបរិណាមានុបស្សនាយ អនិមិត្តានុប-ស្សនាយ អប្បណិហិតានុបស្សនាយ សុញ្ញតានុ-បស្សនាយ អធិប្បញ្ញាធម្មវិបស្សនាយ យថាភូត-ញ្ញាណទស្សនាយ អាទីនវានុបស្សនាយ បដិសង្ខានុ-បស្សនាយ វិវដ្ដនានុបស្សនាយ សោតាបត្តិមគ្គស្ស សកទាគាមិមគ្គស្ស អនាគាមិមគ្គស្ស ។ បេ ។

[៨៧] អនិច្ចានុបស្សនា មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាខាងចុង ។ បេ ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្តបរិបូរ ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូរដោយវិចារៈ ១ បរិបូរដោយបីតិ ១ បរិបូរដោយសុខ ១ បរិបូរដោយអធិដ្ឋានចិត្ត ១ បរិបូរដោយសទ្ធា ១ បរិបូរដោយវីរិយៈ ១ បរិបូរដោយសតិ ១ បរិបូរដោយសមាធិ ១ បរិបូរ ដោយបញ្ញា ១ ។ ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិនិស្សគ្គានុបស្សនា ខយានុបស្សនា វយានុបស្សនា វិបរិណាមានុបស្សនា អនិមិត្តានុបស្សនា អប្បណិហិតានុបស្សនា សុញ្ញតានុបស្សនា អធិប្បញ្ញាធម្មវិបស្សនា យថាភូតញ្ញាណទស្សនៈ អាទីនវានុបស្សនា បដិសង្ខានុបស្សនា វិវដ្តនានុបស្សនា សោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គ (មានអ្វីជាខាងដើម មានអ្វីជាកណ្ដាល មានអ្វីជាខាងចុង) ។ បេ ។

[៨៨] អរហត្តមគ្គស្ស កោ អាទិ កឹ មជ្ឈេ កឹ បរិយោសានំ ។ អរហត្តមគ្គស្ស បដិបទាវិសុទ្ធិ អាទិ ឧបេក្ខានុព្រូហនា មជ្ឈេ សម្បហំសនា បរិយោសានំ ។ អរហត្តមគ្គស្ស បដិបទាវិសុទ្ធិ អាទិ អាទិស្ស កតិ លក្ខណានិ ។ អាទិស្ស តីណិ លក្ខណានិ យោ តស្ស បរិបន្ថោ តតោ ចិត្តំ វិសុជ្ឈតិ វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ បដិបន្នត្តា តត្ថ ចិត្តំ បក្ខន្ទតិ យញ្ច បរិបន្ថតោ ចិត្តំ វិសុជ្ឈតិ យញ្ច វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ យញ្ច បដិបន្នត្តា តត្ថ ចិត្តំ បក្ខន្ទតិ អរហត្តមគ្គស្ស បដិបទាវិសុទ្ធិ អាទិ អាទិស្ស ឥមានិ តីណិ លក្ខណានិ តេន វុច្ចតិ អរហត្តមគ្គោ អាទិកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច ។

[៨៨] អរហត្តមគ្គ មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ អរហត្តមគ្គ មានបដិបទាវិសុទ្ធិ ជាខាងដើម មានការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល មានការរីករាយព្រម ជាខាងចុង ។ អរហត្តមគ្គ មានបដិបទាវិសុទ្ធិ ជាខាងដើម តើបដិបទាវិសុទ្ធិ ជាខាងដើម មានលក្ខណៈប៉ុន្មានយ៉ាង ។ បដិបទាវិសុទ្ធិ ជាខាងដើម មានលក្ខណៈ ៣ យ៉ាង គឺ ធម៌ណាជាសត្រូវរបស់អរហត្តមគ្គនោះ ចិត្តបរិសុទ្ធចាកធម៌នោះ ចិត្តរមែងដើរឆ្ពោះទៅកាន់សមថនិមិត្ត ជាកណ្តាលព្រោះសេចក្តីស្អាត ចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ គឺត្រង់ដែលចិត្តស្អាតចាកធម៌ជាសត្រូវ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្ត ជាកណ្តាលព្រោះសេចក្តីស្អាត ១ ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ (ទាំង ៣ នេះ) ឈ្មោះថា បដិបទាវិសុទ្ធិ ជាខាងដើម របស់អរហត្តមគ្គ នេះឯងលក្ខណៈ ៣ យ៉ាង របស់បដិបទាវិសុទ្ធិ ជាខាងដើម ហេតុនោះ លោកពោលថា អរហត្តមគ្គ មានលម្អខាងដើមផង បរិបូរដោយលក្ខណៈផង ។

[៨៩] អរហត្តមគ្គស្ស ឧបេក្ខានុព្រូហនា មជ្ឈេ មជ្ឈស្ស កតិ លក្ខណានិ ។ មជ្ឈស្ស តីណិ លក្ខណានិ វិសុទ្ធចិត្តំ អជ្ឈុបេក្ខតិ សមថប្បដិបន្នំ អជ្ឈុបេក្ខតិ ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ យញ្ច វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ យញ្ច សមថប្បដិបន្នំ អជ្ឈុបេក្ខតិ យញ្ច ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ[១] តេន វុច្ចតិ អរហត្តមគ្គោ មជ្ឈេកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច ។

[៩០] អរហត្តមគ្គស្ស សម្បហំសនា បរិយោសានំ បរិយោសានស្ស កតិ លក្ខណានិ ។ បរិយោសានស្ស ចត្តារិ លក្ខណានិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សម្បហំសនា ឥន្ទ្រិយានំ ឯករសដ្ឋេន សម្បហំសនា តទុបគវីរិយវាហនដ្ឋេន សម្បហំសនា អាសេវនដ្ឋេន សម្បហំសនា អរហត្តមគ្គស្ស សម្បហំសនា បរិយោសានំ បរិយោសានស្ស ឥមានិ ចត្តារិ លក្ខណានិ

១. ឱ. ឯត្ថន្តរេ អរហត្តមគ្គស្ស ឧបេក្ខានុព្រូហនា មជ្ឈេ មជ្ឈស្ស ឥមានិ តីណិ លក្ខណានីតិ ទិស្សន្តិ ។

[៨៩] អរហត្តមគ្គ មានការចម្រើនរឿយ ៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល តើការសម្លឹងពិនិត្យ ជាកិច្ចកណ្តាល មានលក្ខណៈប៉ុន្មាន ។ ការសម្លឹងពិនិត្យ ជាកិច្ចកណ្តាល មានលក្ខណៈ ៣ យ៉ាង គឺ ចិត្តដែលស្អាត រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលដើរឆ្ពោះទៅរកសមថៈ រមែងសម្លឹងផ្ទៀងផ្ទាត់ ចិត្តដែលតាំងឡើងក្នុងឯកត្តៈ រមែងសម្លឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តស្អាតសម្លឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថៈសម្លឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តតាំងឡើង ក្នុងឯកត្តៈសម្លឹងផ្ទៀងផ្ទាត់ ១ ហេតុនោះ លោកពោលថា អរហត្តមគ្គ មានលម្អត្រង់កណ្តាលផង បរិបូណ៌ដោយលក្ខណៈផង ។

[៩០] អរហត្តមគ្គ មានការរីករាយព្រម ជាខាងចុង តើការរីករាយព្រមជាខាងចុង មានលក្ខណៈប៉ុន្មាន ។ ការរីករាយព្រម ជាខាងចុង មានលក្ខណៈ ៤ យ៉ាង គឺ ការរីករាយព្រម ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតហើយ ក្នុងអរហត្តមគ្គនោះ ១ ការរីករាយព្រម ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ការរីករាយព្រម ដោយអត្ថថានាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ការរីករាយព្រម ដោយអត្ថថាសេព ១ (ទាំង ៤ នេះ) ឈ្មោះថាការរីករាយព្រម ជាខាងចុង របស់អរហត្តមគ្គ នេះឯងការរីករាយព្រម ជាខាងចុង មានលក្ខណៈ ៤ យ៉ាង

តេន វុច្ចតិ អរហត្តមគ្គោ បរិយោសានកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច ឯវំ តិវត្តគតំ ចិត្តំ តិវិធកល្យាណកំ ទសលក្ខណសម្បន្នំ[(១)] វិតក្កសម្បន្នញ្ចេវ ហោតិ វិចារសម្បន្នញ្ច បីតិសម្បន្នញ្ច សុខសម្បន្នញ្ច ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច សទ្ធាសម្បន្នញ្ច វីរិយសម្បន្នញ្ច សតិសម្បន្នញ្ច សមាធិសម្បន្នញ្ច បញ្ញាសម្បន្នញ្ច ។ បេ ។

[៩១] និមិត្តំ អស្សាសបស្សាសា អនារម្មណមេកចិត្តស្ស
អជានតោ ច តយោ ធម្មេ ភាវនា នុបលព្ភតិ
និមិត្តំ អស្សាសបស្សាសា អនារម្មណមេកចិត្តស្ស
ជានតោ ច តយោ ធម្មេ ភាវនា ឧបលព្ភតីតិ ។

---

១ ឱ. ទសលក្ខណាសម្បន្នោ ។

ហេតុនោះ លោកពោលថា អរហត្តមគ្គ មានលម្អខាងចុងផង បរិបូណ៌ដោយលក្ខណៈផង ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺ បរិបូណ៌ដោយវិតក្កៈ ១ បរិបូណ៌ដោយវិចារៈ ១ បរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវីរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។ បេ ។

[៩១] កាលបុគ្គលមិនស្គាល់ នូវអនារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងមិនបាន កាលបុគ្គលដឹង នូវអនារម្មណ៍នៃចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន ។

[៩២] កថំ ឥមេ ច តយោ ធម្មា ឯកចិត្ត-
ស្ស អារម្មណា ន ហោន្តិ ន ចិមេ តយោ ធម្មា
អវិទិតា ហោន្តិ ន ច ចិត្តំ វិក្ខេបំ គច្ឆតិ បធា-
នញ្ច បញ្ញាយតិ បយោគញ្ច សាធេតិ វិសេសម-
ធិគច្ឆតិ ។ សេយ្យថាបិ រុក្ខោ សមេ ភូមិភាគេ
និក្ខិត្តោ តមេនំ បុរិសោ កកចេន ឆិន្ទេយ្យ រុក្ខេ
ផុដ្ឋកកចទន្តានំ វសេន បុរិសស្ស សតិ ឧបដ្ឋិតា
ហោតិ ន អាគតេ វា គតេ វា កកចទន្តេ មន-
សិករោតិ ន អាគតា វា គតា វា កកចទន្តា
អវិទិតា ហោន្តិ បធានញ្ច បញ្ញាយតិ បយោគញ្ច
សាធេតិ វិសេសមធិគច្ឆតិ យថា រុក្ខោ សមេ ភូមិ-
ភាគេ និក្ខិត្តោ ឯវំ ឧបនិពន្ធនា និមិត្តំ យថា កក-
ចទន្តា ឯវំ អស្សាសបស្សាសា យថា រុក្ខេ ផុដ្ឋក-
កចទន្តានំ វសេន បុរិសស្ស សតិ ឧបដ្ឋិតា ហោតិ
ន អាគតេ វា គតេ វា កកចទន្តេ មនសិករោតិ
ន អាគតា វា គតា វា កកចទន្តា អវិទិតា ហោន្តិ

[៩២] ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាអារម្មណ៍នៃចិត្តមួយផង ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាមិនប្រាកដផង តើដូចម្ដេច ចិត្តមិនដល់នូវសេចក្ដីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញុំាងព្យាយាមឲ្យសម្រេចបាននូវគុណវិសេស ១ ។ ប្រៀបដូចដើមឈើដែលគេដាំលើភូមិភាគរាបស្មើ បុរសអារដើមឈើនោះដោយរណារ ស្មារតីបុរសរមែងតាំងឡើងចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារ ដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្ដី ទាញទៅក្ដី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង បុរសរមែងញុំាងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ឯការចូលទៅជិតចងនិមិត្ត ទុកដូចដើមឈើដែលគេដាំ លើភូមិភាគដ៏រាបស្មើ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ទុកដូចធ្មេញរណារ ភិក្ខុតម្កល់ទុកនូវស្មារតីត្រង់ចុងច្រមុះឬទ្វារមាត់ ហើយអង្គុយមិនធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល ទាំងដែលមកទាំងដែលទៅ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ដែលមកក្ដី ដែលទៅក្ដី

បធានញ្ច បញ្ញាយតិ បយោគញ្ច សាធេតិ វិសេសមធិគច្ឆតិ ឯវមេវ ភិក្ខុ នាសិកគ្គេ វា មុខនិមិត្តេ វា សតឹ ឧបដ្ឋបេត្វា និសិន្នោ ហោតិ ន អាគតេ វា គតេ វា អស្សាសបស្សាសេ មនសិករោតិ ន អាគតា វា គតា វា អស្សាសបស្សាសា អវិទិតា ហោន្តិ បធានញ្ច បញ្ញាយតិ បយោគញ្ច សាធេតិ វិសេសមធិគច្ឆតិ[១] ។

[៩៣] កតមំ បធានំ ។ អារទ្ធវីរិយស្ស កាយោបិ ចិត្តម្បិ កម្មនីយំ ហោតិ ឥទំ បធានំ ។ កតមោ បយោគោ ។ អារទ្ធវីរិយស្ស ឧបក្កិលេសា បហីយន្តិ វិតក្កា វូបសមន្តិ អយំ បយោគោ ។ កតមោ វិសេសោ ។ អារទ្ធវីរិយស្ស សញ្ញោជនានិ បហីយន្តិ អនុសយា ព្យាសន្តិ[២] អយំ វិសេសោ ។ ឯវំ ឥមេ ច តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តិ ន ចិមេ តយោ ធម្មា អវិទិតា ហោន្តិ ន ច ចិត្តំ វិក្ខេបំ គច្ឆតិ បធានញ្ច បញ្ញាយតិ បយោគញ្ច សាធេតិ វិសេសមធិគច្ឆតិ ។

---

១ ម. វិសេសមធិគច្ឆតិ បធានញ្ច ។ ២ ឱ. ម. ព្យន្តិ ហោន្តិ ។

មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេច បាននូវគុណវិសេសផង ប្រៀបដូចជាស្នារតីបុរសតាំងឡើងចំពោះដើមឈើដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារ ដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមប្រាកដផង បុរសញ៉ាំងព្យាយាមឲ្យសម្រេច បានគុណវិសេសផង ។

[៩៣] ការព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ តែងមានកាយនិងចិត្តគួរដល់ការងារ នេះ ឈ្មោះថាការព្យាយាម ។ ការប្រកបព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់នូវពួកឧបក្កិលេស មានវិតក្កៈស្ងប់រម្ងាប់ នេះ ឈ្មោះថាការប្រកបព្យាយាម ។ គុណវិសេស តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់ស្រឡះនូវពួកសញ្ញោជនៈ មានពួកអនុសយធម៌វិនាស នេះ ឈ្មោះថាគុណវិសេស ។ នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯកចិត្ត នេះធម៌ ៣ យ៉ាង ដែលភិក្ខុមិនមែនជាមិនដឹង គឺ ចិត្តមិនដល់នូវសេចក្តីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេស ១ យ៉ាងនេះឯង ។

[៩៤] អានាបានស្សតិ យស្ស បរិបុណ្ណា សុភាវិតា
អនុបុព្វំ បរិចិតា យថា ពុទ្ធេន ទេសិតា
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមាតិ ។

អានន្តិ អស្សាសោ នោ បស្សាសោ ។ អបានន្តិ បស្សាសោ នោ អស្សាសោ ។ អស្សាសបស្សាសវសេន ឧបដ្ឋានំ សតិ[១] យោ អស្សសតិ តស្សុបដ្ឋាតិ យោ បស្សសតិ តស្សុបដ្ឋាតិ ។ បរិបុណ្ណាតិ បរិគ្គហដ្ឋេន បរិបុណ្ណា បរិវារដ្ឋេន បរិបុណ្ណា បរិបូរដ្ឋេន បរិបុណ្ណា ។

សុភាវិតាតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន

---
១ ឱ. ម. អស្សាសវសេន ឧបដ្ឋានំ សតិ បស្សាសវសេន ឧបដ្ឋានំ សតិ ។

[៩៤] អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចម្រើនហើយដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់សម្តែងទុកហើយ បុគ្គលនោះរមែង ញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទ្រ ដែលផុត ស្រឡះចាកពពក ។

ពាក្យថា អានៈ ប្រែថា ខ្យល់ដកដង្ហើមចេញ មិនមែនប្រែថា ខ្យល់ដកដង្ហើមចូល ទេ ។ ពាក្យថា អបានៈ ប្រែថា ខ្យល់ដកដង្ហើមចូល មិនមែនប្រែថា ខ្យល់ដកដង្ហើមចេញ ទេ ។ សតិ (ស្មារតី)ជាទីតាំងមាំ រមែងតាំងមាំដល់ភិក្ខុដែលដកដង្ហើមចេញ តាំងមាំដល់ភិក្ខុដែលដកដង្ហើមចូល ដោយអំណាចនៃខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ។ ពាក្យថា បានបំពេញហើយ គឺបានបំពេញហើយ ដោយអត្ថថាថៃជួន បានបំពេញហើយ ដោយអត្ថថាជាបរិវារ បានបំពេញហើយដោយអត្ថថាគ្រប់គ្រាន់ ។

ពាក្យថា ចម្រើនហើយដោយប្រពៃ បានដល់ភាវនា ៤ យ៉ាង គឺ ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវពួកធម៌ដែលកើតក្នុងមគ្គនោះ ១ ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយ មានរសតែមួយ ១ ភាវនា ដោយអត្ថថានាំទៅ នូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១

ភាវិតា អាសេវិតា ភាវិតា តស្សិមេ ចត្តារោ ភាវនដ្ឋា យានីកតា ហោន្តិ វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា ។

យានីកតាតិ យត្ថ យត្ថ អាកង្ខតិ តត្ថ តត្ថ វសិប្បត្តោ ហោតិ ពលប្បត្តោ វេសារជ្ជប្បត្តោ តស្ស តេ[១] ធម្មា អាវជ្ជនប្បដិពទ្ធា ហោន្តិ អាកង្ខណប្បដិពទ្ធា មនសិការប្បដិពទ្ធា ចិត្តុប្បាទប្បដិពទ្ធា តេន វុច្ចតិ យានីកតាតិ ។

វត្ថុកតាតិ យស្មឹ យស្មឹ វត្ថុស្មឹ ចិត្តំ ស្វាធិដ្ឋិតំ ហោតិ តស្មឹ តស្មឹ វត្ថុស្មឹ សតិ សុប្បតិដ្ឋិតា ហោតិ យស្មឹ យស្មឹ វា បន វត្ថុស្មឹ សតិ សុប្បតិដ្ឋិតា ហោតិ តស្មឹ តស្មឹ វត្ថុស្មឹ ចិត្តំ ស្វាធិដ្ឋិតំ ហោតិ តេន វុច្ចតិ វត្ថុកតាតិ ។

អនុដ្ឋិតាតិ[២] យេន យេន ចិត្តំ អភិនីហរតិ តេន តេន សតិ អនុបរិវត្តតិ យេន យេន វា បន សតិ អនុបរិវត្តតិ តេន តេន ចិត្តំ អភិនីហរតិ តេន វុច្ចតិ អនុដ្ឋិតាតិ ។

---

១ ម. តស្ស មេ តេ ។ ២ ម. ឯត្ថន្តរេ វត្ថុស្មិន្តិ ទិស្សតិ ។

ភាវនា ដោយអត្ថថាសេព ១ នេះឯង អត្ថរបស់ភាវនា ៤ យ៉ាង ដែលគេធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាវត្ថុជាទីតាំង ឲ្យតាំងឡើងរឿយ ៗ សន្សំហើយ ប្រារព្ធសេចក្ដីស្ងប់ប្រពៃហើយ ។

ពាក្យថា ធ្វើឲ្យដូចជាយាន សេចក្ដីថា ភិក្ខុប៉ុនប៉ងធម៌ណា ៗ រមែងជាអ្នកដល់នូវការស្ទាត់ជំនាញ ដល់នូវកម្លាំង ដល់នូវសេចក្ដីក្លៀវក្លាក្នុងធម៌នោះ ៗ ធម៌ទាំងឡាយនោះ ៗ របស់ភិក្ខុនោះ រមែងជាប់ចំពោះដោយការនឹករំពឹង ជាប់ចំពោះដោយការប៉ុនប៉ង ជាប់ចំពោះដោយការធ្វើទុកក្នុងចិត្ត ជាប់ចំពោះដោយការកើតឡើងនៃចិត្ត ហេតុនោះ លោកទើបពោលថា ធ្វើឲ្យដូចជាយាន ។

ពាក្យថា ធ្វើឲ្យដូចជាវត្ថុជាទីតាំង សេចក្ដីថា ចិត្តដែលភិក្ខុអធិដ្ឋានល្អចំពោះវត្ថុណា ៗ ស្មារតីរមែងតម្កល់ស៊ប់ចំពោះវត្ថុនោះ ៗ ឬក៏ ស្មារតីតម្កល់ស៊ប់ចំពោះវត្ថុណា ៗ ចិត្តភិក្ខុនោះក៏អធិដ្ឋានល្អ ក្នុងវត្ថុនោះ ៗ ហេតុនោះ លោកទើបពោលថា ធ្វើឲ្យដូចជាវត្ថុជាទីតាំង ។

ពាក្យថា ឲ្យតាំងឡើងរឿយ ៗ សេចក្ដីថា ចិត្តឱនទៅក្នុងធម៌ណា ៗ ស្មារតីក៏ប្រព្រឹត្តទៅក្នុងធម៌នោះ ៗ ឬក៏ ស្មារតីប្រព្រឹត្តទៅក្នុងធម៌ណា ៗ ចិត្តភិក្ខុនោះក៏ឱនទៅក្នុងធម៌នោះ ៗ ហេតុនោះ លោកទើបពោលថា ឲ្យតាំងឡើងរឿយ ៗ ។

បរិចិតាតិ បរិគ្គហដ្ឋេន បរិចិតា បរិវារដ្ឋេន បរិចិតា បរិបូរដ្ឋេន បរិចិតា សតិយា បរិគ្គណ្ហន្តោ ជិនាតិ បាបកេ អកុសលេ ធម្មេ តេន វុច្ចតិ បរិចិតាតិ ។

សុសមារទ្ធាតិ ចត្តារោ សុសមារទ្ធា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សុសមារទ្ធា ឥន្ទ្រិយានំ ឯករសដ្ឋេន សុសមារទ្ធា តទុបគវីរិយវាហនដ្ឋេន សុសមារទ្ធា តប្បច្ចនីកានំ កិលេសានំ សុសមុគ្ឃាតត្តា[១] សុសមារទ្ធា ។

---

១ ម. សុសមុហតត្តា ។

ពាក្យថា សន្សំហើយ សេចក្តីថា សន្សំហើយ ដោយអត្ថថាគ្រប់គ្រង សន្សំហើយ ដោយអត្ថថាជាបរិវារ សន្សំហើយ ដោយអត្ថថាបំពេញ បុគ្គលកាលគ្រប់គ្រង (ធម៌) ដោយស្មារតី រមែងឈ្នះពួកអកុសលធម៌ដ៏លាមក ហេតុនោះ លោកទើបពោលថា សន្សំហើយ ។

ពាក្យថា ប្រារព្ធសេចក្តីស្ងប់ប្រពៃ សេចក្តីថា ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ៤ យ៉ាង គឺ ការប្រារព្ធនូវសេចក្តីស្ងប់ប្រពៃ ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងមគ្គនោះ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយអត្ថថានាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ព្រោះគាស់រំលើងនូវពួកកិលេសជាសត្រូវរបស់មគ្គនោះ ១ ។

សុសមន្តិ អត្ថិ សមំ អត្ថិ សុសមំ ។ កតមំ សមំ ។ យេ តត្ថ ជាតា អនវជ្ជា កុសលា ពោធិ-បក្ខិយា[១] ឥទំ សមំ ។ កតមំ សុសមំ ។ យំ តេសំ[២] ធម្មានំ អារម្មណំ និរោធោ និព្វានំ ឥទំ សុសមំ ។ ឥតិ ឥទញ្ច សមំ សុសមំ[៣] ញាតំ ហោតិ ទិដ្ឋំ[៤] វិទិតំ សច្ឆិកតំ ផស្សិតំ បញ្ញាយ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អារទ្ធោ[៥] សមាហិតំ ចិត្តំ ឯកគ្គំ តេន វុច្ចតិ សុសមារទ្ធាតិ ។

---

១ ឱ. ព្យាធិបក្ខិយា ។ ២ ឱ. ម. យំ តេសំ តេសំ ។ ៣ ឱ. ម. ឥទញ្ច សុសមំ ។ ៤ ឱ. ឥដ្ឋំ ។ ៥ ឱ. ម. អសារទ្ធោ ។

ពាក្យថា សេចក្តីស្ងប់ប្រពៃ សេចក្តីថា ការស្ងប់ក៏មាន ការស្ងប់ប្រពៃក៏មាន ។ ការស្ងប់ តើដូចម្តេច ។ ពួកពោធិបក្ខិយធម៌ណាដែលកើតក្នុងភាវនានោះ ជាធម៌មិនមានទោស ជាកុសល នេះឈ្មោះថា ការស្ងប់ ។ ការស្ងប់ប្រពៃ តើដូចម្តេច ។ អារម្មណ៍ គឺការរំលត់ការរម្ងាប់នូវពួកធម៌នោះ ឯណា នេះ ឈ្មោះថាការស្ងប់ប្រពៃ ។ ឯការស្ងប់និងការស្ងប់ប្រពៃនេះ ព្រះអរិយៈទាំងឡាយដឹងហើយ ឃើញហើយ ជ្រាបច្បាស់ហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា ព្យាយាមដ៏មិនថោកថយ ព្រះអរិយៈទាំងឡាយប្រារព្ធហើយ ស្មាតីដែលលោកតម្កល់មាំហើយ រមែងមិនវង្វេងភ្លេច កាយដែលស្ងប់ហើយ ព្រះអរិយៈទាំងឡាយប្រារព្ធហើយ ចិត្តដែលតម្កល់មាំហើយ រមែងមានអារម្មណ៍តែមួយ ហេតុនោះ លោកទើបពោលថា ប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយប្រការដូច្នេះឯង ។

អនុបុព្វំ បរិចិតាតិ ទីឃំ អស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា ទីឃំ បស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា រស្សំ អស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា រស្សំ បស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា បដិនិស្សគ្គានុបស្សី បស្សាសវសេន បុរិមា បុរិមា បរិចិតា បច្ឆិមា បច្ឆិមា អនុបរិចិតា សព្វាបិ សោឡសវត្ថុកា អានាបានស្សតិយោ អញ្ញមញ្ញំ បរិចិតា ចេវ ហោន្តិ អនុបរិចិតា ច តេន វុច្ចតិ អនុបុព្វំ បរិចិតាតិ ។

ពាក្យថា សន្សំហើយដោយលំដាប់ គឺអានាបានស្សតិការនាខាង ដើម ៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុង ៗ បុគ្គល សន្សំរឿយ ៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើមចេញវែង អានា-បានស្សតិការនាខាងដើម ៗ បុគ្គលសន្សំហើយ អានាបានស្សតិការនា ខាងចុង ៗ បុគ្គលសន្សំរឿយ ៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើម ចូលវែង អានាបានស្សតិការនាខាងដើម ៗ បុគ្គលសន្សំហើយ អានាបាន-ស្សតិការនាខាងចុង ៗ បុគ្គលសន្សំរឿយ ៗ ហើយ ដោយអំណាចនៃ ខ្យល់ដកដង្ហើមចេញខ្លី អានាបានស្សតិការនាខាងដើម ៗ បុគ្គលសន្សំ ហើយ អានាបានស្សតិការនាខាងចុង ៗ បុគ្គលសន្សំរឿយ ៗ ហើយ ដោយអំណាចនៃខ្យល់ ដកដង្ហើមចូលខ្លី ។ បេ ។ អានាបានស្សតិ-ការនាខាងដើម ៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុង ៗ បុគ្គលសន្សំរឿយ ៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើមចេញ របស់ បុគ្គលអ្នកពិចារណានូវការលះបង់ស្រឡះ អានាបានស្សតិការនាខាង ដើម ៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុង ៗ បុគ្គល សន្សំរឿយ ៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើមចូល របស់បុគ្គល អ្នកពិចារណានូវការលះបង់ស្រឡះ រួមអានាបានស្សតិទាំងអស់ មាន វត្ថុ ១៦ បុគ្គលសន្សំហើយផង សន្សំរឿយ ៗ ហើយ ទៅវិញទៅមកផង ហេតុនោះ លោកទើបពោលថា សន្សំហើយដោយលំដាប់ ។

យថាតិ ទស យថត្ថា អត្តទមថដ្ឋោ យថត្ថោ អត្តសមថដ្ឋោ យថត្ថោ អត្តបរិនិព្វាបនដ្ឋោ យថត្ថោ អភិញ្ញដ្ឋោ យថត្ថោ បរិញ្ញដ្ឋោ យថត្ថោ បហានដ្ឋោ យថត្ថោ ភាវនដ្ឋោ យថត្ថោ សច្ឆិកិរិយដ្ឋោ យថត្ថោ សច្ចាភិសមយត្ថោ យថត្ថោ និរោធេ បតិដ្ឋាបកដ្ឋោ យថត្ថោ ។

ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ[១] តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។

១ ម. ឱ. អភិសម្ពុជ្ឈតិ ។

ពាក្យថា ដូចជា សេចក្តីថា អត្ថថាដូចជា មាន ១០ យ៉ាង គឺ អត្ថថាទូន្មាននូវខ្លួន ឈ្មោះអត្ថថាដូចជា ១ អត្ថថារម្ងាប់នូវខ្លួន ឈ្មោះ អត្ថថាដូចជា ១ អត្ថថារំលត់នូវខ្លួន ឈ្មោះអត្ថថាដូចជា ១ អត្ថថាដឹង ច្បាស់ ឈ្មោះអត្ថថាដូចជា ១ អត្ថថាកំណត់ដឹង ឈ្មោះអត្ថថាដូចជា ១ អត្ថថាលះបង់ ឈ្មោះអត្ថថាដូចជា ១ អត្ថថាចម្រើន ឈ្មោះអត្ថថាដូច ជា ១ អត្ថថាធ្វើឲ្យជាក់ច្បាស់ ឈ្មោះអត្ថថាដូចជា ១ អត្ថថាត្រាស់ដឹងនូវ សច្ចៈ ឈ្មោះអត្ថថាដូចជា ១ អត្ថថាតម្កល់ខ្លួនស៊ប់ក្នុងនិរោធ ឈ្មោះអត្ថ ថាដូចជា ១ ។

ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ដែលត្រាស់ដឹង ដោយព្រះអង្គឯង ទ្រង់ពុំមានអាចារ្យ ទ្រង់ត្រាស់ដឹងនូវសច្ចៈក្នុងធម៌ ទាំងឡាយ ដែលទ្រង់មិនធ្លាប់ឮក្នុងពេលមុន ដោយព្រះអង្គឯង ទ្រង់ ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយនោះ ទ្រង់ដល់នូវសេចក្តី ស្ទាត់ក្នុងពលៈទាំងឡាយផង ។

ពុទ្ធោតិ កេនត្ថេន ពុទ្ធោ ។ ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ ពោធេត្តា(១) បជាយាតិ ពុទ្ធោ សព្វញ្ញុតាយ ពុទ្ធោ សព្វទស្សាវិតាយ ពុទ្ធោ អនញ្ញនេយ្យតាយ ពុទ្ធោ វិសតិតាយ(២) ពុទ្ធោ ខីណាសវសង្ខាតេន ពុទ្ធោ និរុបក្កិលេសសង្ខាតេន(៣) ពុទ្ធោ ឯកន្តវីតរាគោតិ ពុទ្ធោ ឯកន្តវីតទោសោតិ ពុទ្ធោ ឯកន្តវីតមោហោតិ ពុទ្ធោ ឯកន្តនិក្កិលេសោតិ ពុទ្ធោ ឯកាយនមគ្គំ គតោតិ ពុទ្ធោ ឯកោ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោតិ ពុទ្ធោ អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភា ពុទ្ធោ ។

---

១ ឱ. ម. ពោធេតា ។ ២ ឱ. ម. វិសវិតាយ ។ ៣ ឱ. ម. និរុបធិសង្ខាតេន ។

*សំណួរត្រង់ពាក្យថា ព្រះពុទ្ធ តើព្រះពុទ្ធ ដោយអត្ថថាដូចម្តេច ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុត្រាស់ដឹងនូវសច្ចៈទាំងឡាយ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គញុំាងពពួកសត្វឲ្យត្រាស់ដឹង ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងសព្វ ឈ្មោះថាព្រះពុទ្ធ ព្រោះទ្រង់ឃើញសព្វ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គឥតមានបុគ្គលដទៃណែនាំ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គមានការរព្ញកដោយវិសេស ឈ្មោះថាព្រះពុទ្ធ ព្រោះគេអាចរាប់ថា ព្រះអង្គមានអាសវៈអស់ហើយ ឈ្មោះថាព្រះពុទ្ធ ព្រោះគេអាចរាប់ថាព្រះអង្គមិនមានឧបក្កិលេស ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គប្រាសចាករាគៈ ដោយដាច់ខាត ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គប្រាសចាកទោសៈ ដោយដាច់ខាត ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុ ព្រះអង្គប្រាសចាកមោហៈដោយដាច់ខាត ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុ ព្រះអង្គមិនមានកិលេសដោយដាច់ខាត ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គតែម្នាក់ឯង ត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ឈ្មោះថាព្រះពុទ្ធ ព្រោះការបានចំពោះនូវបញ្ញា ដោយហេតុព្រះអង្គកម្ចាត់ចោលនូវធម្មជាតិផ្ទុយនឹងប្រាជ្ញាចេញ ។*

ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។

ទេសិតាតិ អត្តទមថដ្ឋោ យថត្ថោ យថា ពុទ្ធេន ទេសិតោ អត្តសមថដ្ឋោ យថត្ថោ យថា ពុទ្ធេន ទេសិតោ អត្តបរិនិព្វាបនដ្ឋោ យថត្ថោ យថា ពុទ្ធេន ទេសិតោ ។ បេ ។ និរោធេ បតិដ្ឋាបកដ្ឋោ យថត្ថោ យថា ពុទ្ធេន ទេសិតោ ហោតិ គហដ្ឋោ វា ហោតិ បព្វជិតោ វា ។

ព្រះនាមថា ព្រះពុទ្ធ នេះ មិនមែនជាព្រះនាម ដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនព្រះភាតាថ្វាយទេ មិនមែនព្រះភគិនីថ្វាយទេ មិនមែនពួកមិត្តនិងអាមាត្យថ្វាយទេ មិនមែនពួកញាតិសាលោហិតថ្វាយទេ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយទេ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធ នេះ ជាវិមោក្ខន្តិកនាម[១] របស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ជានាមបញ្ញត្តិ ព្រោះការត្រាស់ដឹង ដំណាលនឹងការបាន នូវសព្វញ្ញុតញ្ញាណ ក្រោមម្លប់ពោធិព្រឹក្ស ។

ពាក្យថា ទ្រង់សម្តែងហើយ សេចក្តីថា អត្ថជាទូន្មាននូវខ្លួន ឈ្មោះអត្ថជាដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ អត្ថជារម្ងាប់នូវខ្លួន ឈ្មោះអត្ថជាដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ អត្ថជារំលត់នូវខ្លួន ឈ្មោះអត្ថជាដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ ។ បេ ។ អត្ថជាឲ្យតម្កល់ខ្លួនស៊ប់ក្នុងនិរោធធម៌ ឈ្មោះអត្ថជាដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ។

---

១ នាមដែលកើតមានក្នុងទីបំផុតនៃការរួចចាកកិលេស ។

លោកោតិ ខន្ធលោកោ ធាតុលោកោ អា-យតនលោកោ វិបត្តិភវលោកោ វិបត្តិសម្ភវលោកោ សម្បត្តិភវលោកោ សម្បត្តិសម្ភវលោកោ ឯកោ លោកោ សព្វេ សត្តា អាហារដ្ឋិតិកា ។ បេ ។ អដ្ឋារស លោកា អដ្ឋារស ធាតុយោ ។

បភាសេតីតិ អត្តទមថដ្ឋំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ[១] បភាសេតិ អត្ត-សមថដ្ឋំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ បភាសេតិ អត្តបរិនិព្វាបនដ្ឋំ យថត្តំ អភិ-សម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ ។ បេ ។ និរោធេ បតិដ្ឋាបកដ្ឋំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ បភាសេតិ ។

---

១ ឱ. ឯត្ថន្តរេ ភាសេតីតិ ទិស្សតិ ។

ពាក្យថា លោក បានដល់ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក វិបត្តិសម្ភវលោក សម្បត្តិភវលោក សម្បត្តិសម្ភវលោក លោក ១ បានដល់ពួកសត្វទាំងអស់ដែលតាំងនៅដោយសារអាហារ ។ បេ ។ លោក ១៨ បានដល់ធាតុ ១៨ ។

ពាក្យថា រមែងឲ្យភ្លឺច្បាស់ គឺ បុគ្គលនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹង នូវអត្ថថាទូន្មាននូវខ្លួន ឈ្មោះអត្ថថាដូចជា បុគ្គលនោះរមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹង នូវអត្ថថារម្ងាប់នូវខ្លួន ឈ្មោះអត្ថថាដូចជា បុគ្គលនោះរមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ព្រោះត្រាស់ដឹង នូវអត្ថថារំលត់នូវខ្លួន ឈ្មោះអត្ថថាដូចជា ។ បេ ។ បុគ្គលនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹង នូវអត្ថថាតម្កល់ខ្លួនស៊ប់ក្នុងនិរោធធម៌ ឈ្មោះអត្ថថាដូចជា ។

អគ្គោ មុត្តោវ ចន្ទិមាតិ យថា អគ្គោ ឯវំ កិលេសា យថា ចន្ទោ ឯវំ អរិយញ្ញាណំ យថា ចន្ទិមា ទេវបុត្តោ ឯវំ ភិក្ខុ យថា ចន្ទោ អគ្គោ មុត្តោ មហិយា ធូមរជមុត្តោ រាហុចាណា[១] វិប្បមុត្តោ ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវ ភិក្ខុ សព្វក្កិលេសេហិ វិមុត្តោ ភាសតេ ច តបតេ ច វិរោចតិ ច តេន វុច្ចតិ អគ្គោ មុត្តោវ ចន្ទិមាតិ ឥមានិ តេរស វោទានេ ញាណានិ ។

ភាណវារំ ។

[៩៥] កតមានិ ពត្តឹសំ សតោការីសុ ញាណានិ[២] ។ ឥធ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ សតោវ អស្សសតិ ។ បេ ។

១ ឱ. ម. រាហុគហណា ។ ២ ម. សតោការិយញ្ញាណានិ ។

ពាក្យថា ដូចជាព្រះចន្ទ្រដែលផុតស្រឡះចាកពពក គឺពពកយ៉ាងណា កិលេសយ៉ាងនោះ ព្រះចន្ទ្រយ៉ាងណា អរិយញ្ញាណយ៉ាងនោះ ចន្ទិមទេវបុត្តយ៉ាងណា ភិក្ខុយ៉ាងនោះ ព្រះចន្ទ្រដែលផុតស្រឡះហើយ ចាកពពក ផុតស្រឡះហើយ ចាកផ្សែងនិងធូលីលើផែនដី ផុតស្រឡះហើយ ចាកបាតដៃនៃរាហូ រមែងភ្លឺផង រុងរឿងផង ថ្កើងថ្កានផង យ៉ាងណា ភិក្ខុដែលផុតស្រឡះហើយ ចាកកិលេសទាំងអស់ រមែងភ្លឺផង រុងរឿងផង ថ្កើងថ្កានផង យ៉ាងនោះដែរ ហេតុនោះ លោកពោលថា ដូចជាព្រះចន្ទ្រដែលផុតស្រឡះចាកពពក ទាំងនេះឈ្មោះថា វោទានញ្ញាណ ១៣ ប្រការ ។

ចប់ ភាណវារៈ ។

[៩៥] សតោការិញ្ញាណ ៣២ តើដូចម្តេច ។ ភិក្ខុ ក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់គល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តាំងសតិ ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ភិក្ខុនោះ មានសតិ ដកដង្ហើមចេញ ។ បេ ។

១១៧

មហាវគ្គេ  អានាបានកថា

សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី សុខប្បដិសំវេទី ចិត្តសង្ខារប្បដិសំវេទី បស្សម្ភយំ ចិត្តសង្ខារំ ចិត្តប្បដិសំវេទី អភិប្បមោទយំ ចិត្តំ សមាទហំ ចិត្តំ វិមោចយំ ចិត្តំ អនិច្ចានុបស្សី វិរាគានុបស្សី និរោធានុបស្សី បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្ស-សិស្សាមីតិ សិក្ខតិ ។

សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញកាលរម្ងាប់កាយសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់កាយ-សង្ខារ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវបីតិ កំណត់ដឹងច្បាស់នូវសេចក្ដីសុខ កំណត់ដឹងច្បាស់នូវចិត្តសង្ខារ គឺវេទនានិងសញ្ញា កាលរម្ងាប់នូវចិត្តសង្ខារ ជាអ្នកកំណត់ដឹងច្បាស់ចិត្ត កាលញុំាងចិត្តឲ្យរីករាយខ្លាំង កាលតម្កល់ចិត្ត កាលដោះចិត្ត ជាអ្នកពិចា-រណានូវអនិច្ចលក្ខណៈ ជាអ្នកពិចារណានូវការប្រាសចាករាគៈ ជាអ្នកពិចារណានូវធម៌ជាទីរលត់ ជាអ្នកពិចារណានូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារ-ណានូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស នឹងដកដង្ហើមចូល ។

[៩៦] ឥជាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិ-
យា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥមស្មឹ
ធម្មេ ឥមស្មឹ វិនយេ ឥមស្មឹ ធម្មវិនយេ ឥមស្មឹ
បាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុសាសនេ
តេន វុច្ចតិ ឥជាតិ ។

ភិក្ខូតិ បុថុជ្ជនកល្យាណកោ វា ហោតិ ភិក្ខុ
សេក្ខោ វា អរហា វា អកុប្បធម្មោ ។

អរញ្ញន្តិ និក្ខមិត្វា ពហិ ឥន្ទខីលា សព្វមេតំ
អរញ្ញំ ។

រុក្ខមូលន្តិ តត្ថ[១] ភិក្ខុនោ អាសនំ បញ្ញត្តំ
ហោតិ មញ្ចោ វា បីឋំ វា ភិសិ វា តដ្ដិកា វា
ចម្មក្ខណ្ឌោ វា តិណសន្ថារោ វា បណ្ណសន្ថារោ
វា បលាសសន្ថារោ[២] វា តត្ថ ភិក្ខុ ចង្កមតិ វា
តិដ្ឋតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ ។

សុញ្ញន្តិ កេនចិ អនាកិណ្ណំ ហោតិ គហដ្ឋេហិ
វា បព្វជិតេហិ វា ។

---

១ ឱ. ម. យត្ថ ។ ២ ឱ. បលាលសន្ថារោ ។ ម. បលាលសន្ថរោ ។

[៩៦] ពាក្យថា ក្នុងសាសនានេះ គឺ ក្នុងទិដ្ឋិនេះ ក្នុងសេចក្តីពេញចិត្តនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ហេតុនោះ លោកពោលថា ក្នុងសាសនានេះ ។

ពាក្យថា ភិក្ខុ បានដល់ភិក្ខុជាកល្យាណបុថុជ្ជន ឬជាសេក្ខៈ ឬក៏ជាអរហន្ត ដែលមានធម៌មិនកម្រើក ។

ពាក្យថា ព្រៃ បានដល់ទី ចេញទៅខាងក្រៅ អំពីសសរគោលទាំងអស់នេះ ឈ្មោះថាព្រៃ ។

ពាក្យថា គល់ឈើ បានដល់អាសនៈ គឺគ្រែក្តី តាំងក្តី ពូកក្តី កន្ទេលក្តី ផ្ទាំងស្បែកក្តី កម្រាលស្មៅក្តី កម្រាលស្លឹកឈើក្តី កម្រាលចំបើងក្តី ដែលគេក្រាលសម្រាប់ភិក្ខុទៀបគល់ឈើនោះ ភិក្ខុចង្ក្រមក៏បាន ឈរក៏បាន អង្គុយក៏បាន សឹងក៏បាន លើអាសនៈនោះ ។

ពាក្យថា ស្ងាត់ គឺមិនកុះករដោយពួកគ្រហស្ថ ឬពួកបព្វជិតណាមួយ ។

អាគារន្តិ វិហារោ អព្ភោកាសោ បាសាទោ ហម្មិយំ គុហាតិ ។ និសីទតិ បល្លង្កំ អាភុជិត្វាតិ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ[១] ឧជុកោ ហោតិ កាយោ ឋបិតោ បណិហិតោ[២] ។

បរិមុខំ សតឹ ឧបដ្ឋបេត្វាតិ បរីតិ បរិគ្គហដ្ឋោ មុខន្តិ និយ្យានដ្ឋោ សតីតិ ឧបដ្ឋានដ្ឋោ តេន វុច្ចតិ បរិមុខំ សតឹ ឧបដ្ឋបេត្វាតិ ។

[៩៧] សតោវ អស្សសតីតិ[៣] ពត្តឹសាយ អាការេហិ សតោការី[៤] ទីឃំ អស្សាសវសេន ចិត្តស្សេកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន សតោការី ហោតិ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ

---

១ ឱ. ម. បណិធាយាតិ ។ ២ ឱ. ម. ឋិតោ សុបណិហិតោ ។ ៣ ឱ. ម. សតោវ អស្សសតិ សតោ បស្សសតីតិ ។ ៤ ឱ. ម. សតោការី ហោតិ ។

ពាក្យថា ផ្ទះ បានដល់វិហារ អឌ្ឍយោគ ប្រាសាទវែង ប្រាសាទមានដំបូលរលីង គុហា ។

ពាក្យថា អង្គុយពែនភ្នែន គឺ ជាអ្នកអង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ មានកាយត្រង់ នឹងធឹង នឹងនួន ។

អធិប្បាយពាក្យថា តាំងសតិ ឲ្យមានមុខឆ្ពោះទៅរក(កម្មដ្ឋាន) ត្រង់ពាក្យថា បរិ មានអត្ថថាកំណត់ ពាក្យថា មុខៈ មានអត្ថថាធម៌ជាគ្រឿងចេញទៅ ពាក្យថា សតិ មានអត្ថថាប្រុងប្រយ័ត្ន ហេតុនោះលោកពោលថា តាំងសតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។

[៩៧] ពាក្យថា មានសតិដកដង្ហើមចេញ អធិប្បាយថា បុគ្គលធ្វើសតិ ដោយអាការ ៣២ គឺ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវសភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ បុគ្គលធ្វើសតិ

តាយ សតិយា តេន ញាណេន សតោការី ហោតិ រស្សំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន សតោការី ហោតិ រស្សំ បស្សាស-វសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន សតោការី ហោតិ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសវសេន បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន សតោការី ហោតិ ។

ដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចូលខ្លី សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ សម្រាប់អ្នកពិចារណាឃើញ នូវធម៌ជាគ្រឿងរលាស់ចេញចាកកិលេស ដោយអំណាចនៃដង្ហើមចូល សម្រាប់អ្នកពិចារណាឃើញ នូវធម៌ជាគ្រឿងរលាស់ចេញចាកកិលេស សតិក៏តម្កល់មាំ បុគ្គលធ្វើសតិ ដោយស្មារតីនោះ ដោយញាណនោះ ។

[៩៨] កាចំ ឥឋំ អស្សសន្តោ ឥឋំ អស្សសាមីតិ បជានាតិ ឥឋំ បស្សសន្តោ ឥឋំ បស្សសាមីតិ បជានាតិ ។ ឥឋំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ ឥឋំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ ឥឋំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ ឥឋំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ ឆន្ទោ ឧប្បជ្ជតិ ឆន្ទវសេន តតោ សុខុមតរំ ឥឋំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ ឆន្ទវសេន តតោ សុខុមតរំ ឥឋំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ ឆន្ទវសេន តតោ សុខុមតរំ ឥឋំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ ឆន្ទវសេន តតោ សុខុមតរំ ឥឋំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ បាមុជ្ជំ

[៩៨] ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង តើដូចម្តេច ។ ភិក្ខុដកចេញ នូវដង្ហើមចេញវែងក្នុងចំណែកនៃកាលវែង ដកចូល នូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង (ច្រើនដង) ឆន្ទៈ (ចំណង់ក្នុងអ្វីមួយ) រមែងកើតឡើង ភិក្ខុដកចេញ នូវដង្ហើមចេញវែងល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ដកចូល នូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចឆន្ទៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (ច្រើនដង) បាមុជ្ជៈ រមែងកើតឡើង

ឧប្បជ្ជតិ ចាមុជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ ចាមុជ្ជវសេន តតោ សុខុមតរំ ទីឃំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ ចាមុជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ ចាមុជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ ទីឃំ អស្សាសបស្សាសា ចិត្តំ វិវដ្ដតិ ឧបេក្ខា សណ្ឋាតិ ឥមេហិ នវហាការេហិ ទីឃំ អស្សាសបស្សាសកាយោ ឧបដ្ឋានំ សតិ អនុបស្ស-នាញាណំ កាយោ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញា-ណេន តំ កាយំ អនុបស្សតីតិ តេន វុច្ចតិ កាយេ កាយានុបស្សនា សតិបដ្ឋានភាវនា ។

ភិក្ខុដកចេញ នូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ ដកចូល នូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ (ច្រើនដង) ចិត្តក៏ឃ្លាតចេញ អំពីដង្ហើមចេញឬដង្ហើមចូលវែង ឧបេក្ខាក៏តាំងនៅស៊ប់ នេះកាយគឺដង្ហើមចេញនិងដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង ដែលឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ កាយ ឈ្មោះថាឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ សតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង ភិក្ខុពិចារណាឃើញ នូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិ-ប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[៩៩] អនុបស្សតីតិ កថំ តំ កាយំ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អនត្តតោ អនុបស្សតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហាតិ អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហាតិ និព្វិន្ទន្តោ នន្ទឹ បជហាតិ វិរជ្ជន្តោ រាគំ បជហាតិ និរោធេន្តោ សមុទយំ បជហាតិ បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ឯវន្តំ កាយំ អនុបស្សតិ ។

[៩៩] សំណួរត្រង់ពាក្យថា ភិក្ខុពិចារណាឃើញ តើភិក្ខុពិចារណាឃើញនូវកាយនោះ ដូចម្តេច ។ ភិក្ខុពិចារណាឃើញ ថាមិនទៀង មិនមែនថាទៀងទេ ពិចារណាឃើញ ថាជាទុក្ខ មិនមែនថាជាសុខទេ ពិចារណាឃើញ ថាមិនមែនខ្លួន មិនមែនថាខ្លួនទេ (តមក) តែងនឿយណាយ មិនមែនរីករាយទេ តែងជិនឆ្អន់ មិនមែនត្រេកត្រអាលទេ តែងរំលត់បង់ មិនមែនឲ្យកើតទេ តែងរលាស់ចោល មិនមែនក្តួចកាន់ទេ ភិក្ខុកាលពិចារណាឃើញ ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលពិចារណាឃើញ ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលពិចារណាឃើញថាមិនមែនខ្លួន រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលជិនឆ្អន់ រមែងលះបង់នូវរាគៈ កាលរំលត់ រមែងលះបង់នូវហេតុជាគ្រឿងឲ្យកើត កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់ ភិក្ខុពិចារណាឃើញនូវកាយនោះ យ៉ាងនេះឯង ។

[១០០] ភាវនាតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា តទុបគវីរិយវាហនដ្ឋេន ភាវនា អាសេវនដ្ឋេន ភាវនា ឥធេកច្ចោ អស្សាសបស្សាសវសេន ចិត្តស្សេកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

[១០១] កថំ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

[១០០] ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង គឺ ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងមគ្គនោះ ១ ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ភាវនា ដោយអត្ថថា នាំទៅនូវព្យាយាមដែលគួរដល់ឥន្ទ្រិយនោះ ១ ភាវនា ដោយអត្ថថា សេព ១ កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលវែង វេទនាដ៏ប្រាកដ រមែងកើតឡើង វេទនាដ៏ប្រាកដ រមែងតាំងឡើង វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស សញ្ញាដ៏ប្រាកដ រមែងកើតឡើង សញ្ញាដ៏ប្រាកដ រមែងតាំងឡើង សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស វិតក្កៈដ៏ប្រាកដ រមែងកើតឡើង វិតក្កៈដ៏ប្រាកដ រមែងតាំងឡើង វិតក្កៈដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស ។

[១០១] វេទនាដ៏ប្រាកដ រមែងកើតឡើង វេទនាដ៏ប្រាកដ រមែងតាំងឡើង វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ។

កថំ វេទនាយ ឧប្បាទោ វិទិតោ ហោតិ ។ អវិជ្ជាសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាយ ឧប្បាទោ វិទិតោ ហោតិ តណ្ហាសមុទយា វេទនាសមុទយោតិ កម្មសមុទយា វេទនាសមុទយោតិ ផស្សសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាយ ឧប្បាទោ វិទិតោ ហោតិ និព្វត្តិលក្ខណំ បស្សតោបិ វេទនាយ ឧប្បាទោ វិទិតោ ហោតិ ឯវំ វេទនាយ ឧប្បាទោ វិទិតោ ហោតិ ។

កថំ វេទនាយ ឧបដ្ឋានំ វិទិតំ ហោតិ ។ អនិច្ចតោ មនសិការោតោ ខយតុបដ្ឋានំ វិទិតំ ហោតិ ទុក្ខតោ មនសិការោតោ ភយតុបដ្ឋានំ វិទិតំ ហោតិ អនត្តតោ មនសិការោតោ សុញ្ញតុបដ្ឋានំ វិទិតំ ហោតិ ឯវំ វេទនាយ ឧបដ្ឋានំ វិទិតំ ហោតិ ។

ការកើតឡើងនៃវេទនា ដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃវេទនាដ៏ប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថាការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃវេទនាដ៏ប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃវេទនា ក៏ប្រាកដឡើង ការកើតឡើងនៃវេទនា ដ៏ប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងនៃវេទនា ដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ការតាំងឡើងថាអស់ទៅ រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ការតាំងឡើងថាគួរខ្លាច រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ការតាំងឡើងថាសូន្យ រមែងប្រាកដ ការតាំងឡើងនៃវេទនា ដ៏ប្រាកដ យ៉ាងនេះឯង ។

កថំ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ ។ អវិជ្ជានិរោធា វេទនានិរោធោតិ បច្ចយនិរោធដ្ឋេន វេទនាយ អត្ថង្គមោ វិទិតោ ហោតិ តណ្ហានិរោធា វេទនានិរោធោតិ កម្មនិរោធា វេទនានិរោធោតិ ផស្សនិរោធា វេទនានិរោធោតិ បច្ចយនិរោធដ្ឋេន វេទនាយ អត្ថង្គមោ វិទិតោ ហោតិ វិបរិណាមលក្ខណំ បស្សតោបិ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ ឯវំ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ ឯវំ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

[១០២] កថំ វិទិតា សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

ការដល់នូវសេចក្តីវិនាស នៃវេទនា ដ៏ប្រាកដ តើដូចម្តេច ។ ការដល់នូវសេចក្តីវិនាស នៃវេទនា រមែងប្រាកដ ដោយអត្ថថា រលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្តីវិនាស នៃវេទនា រមែងប្រាកដ ដោយអត្ថថារលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ កាលភិក្ខុពិចារណាឃើញ នូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្តីវិនាស នៃវេទនា រមែងប្រាកដ យ៉ាងនេះ វេទនាដ៏ប្រាកដ រមែងកើតឡើង វេទនាដ៏ប្រាកដ រមែងតាំងឡើង វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះឯង ។

[១០២] សញ្ញាដ៏ប្រាកដ រមែងកើតឡើង សញ្ញាដ៏ប្រាកដ រមែងតាំងឡើង សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ។

កថំ សញ្ញាយ ឧប្បាទោ វិទិតោ ហោតិ ។ អវិជ្ជាសមុទយា សញ្ញាសមុទយោតិ បច្ចយសមុទ-យដ្ឋេន សញ្ញាយ ឧប្បាទោ វិទិតោ ហោតិ ត-ណ្ហាសមុទយា សញ្ញាសមុទយោតិ កម្មសមុទយា សញ្ញាសមុទយោតិ ផស្សសមុទយា សញ្ញាសមុទ-យោតិ បច្ចយសមុទយដ្ឋេន សញ្ញាយ ឧប្បាទោ វិទិតោ ហោតិ និព្វត្តិលក្ខណំ បស្សតោបិ សញ្ញាយ ឧប្បាទោ វិទិតោ ហោតិ ឯវំ សញ្ញាយ ឧប្បាទោ វិទិតោ ហោតិ ។

កថំ សញ្ញាយ ឧបដ្ឋានំ វិទិតំ ហោតិ ។ អនិច្ចតោ មនសិករោតោ ខយតុបដ្ឋានំ វិទិតំ ហោតិ ទុក្ខតោ មនសិករោតោ ភយតុបដ្ឋានំ វិទិតំ ហោតិ អនត្តតោ មនសិករោតោ សុញ្ញតុបដ្ឋានំ វិទិតំ ហោតិ ឯវំ សញ្ញាយ ឧបដ្ឋានំ វិទិតំ ហោតិ ។

ការកើតឡើងនៃសញ្ញា ដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃសញ្ញា រមែងប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃសញ្ញា រមែងប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃសញ្ញា រមែងប្រាកដ ការកើតឡើងនៃសញ្ញា រមែងប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងនៃសញ្ញាដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ការតាំងឡើងថាអស់ទៅ រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ការតាំងឡើងថាគួរខ្លាច រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ការតាំងឡើងថាសូន្យ រមែងប្រាកដ ការតាំងឡើងនៃសញ្ញា ដ៏ប្រាកដ យ៉ាងនេះឯង ។

កថំ សញ្ញាយ អត្ថង្គមោ វិទិតោ ហោតិ ។ អវិជ្ជានិរោធា សញ្ញានិរោធោតិ បច្ចយនិរោធដ្ឋេន សញ្ញាយ អត្ថង្គមោ វិទិតោ ហោតិ តណ្ហានិរោធា សញ្ញានិរោធោតិ កម្មនិរោធា សញ្ញានិរោធោតិ ផស្ស-និរោធា សញ្ញានិរោធោតិ បច្ចយនិរោធដ្ឋេន សញ្ញាយ អត្ថង្គមោ វិទិតោ ហោតិ វិបរិណាមលក្ខណំ បស្ស-តោបិ សញ្ញាយ អត្ថង្គមោ វិទិតោ ហោតិ ឯវំ ស-ញ្ញាយ អត្ថង្គមោ វិទិតោ ហោតិ ឯវំ វិទិតា សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

[១០៣] កថំ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

ការដល់នូវសេចក្តីវិនាសនៃសញ្ញា ដ៏ប្រាកដ តើដូចម្តេច ។ ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ដោយអត្ថថារលត់បច្ច័យ ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ដោយអត្ថថារលត់បច្ច័យ ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់ផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈ នៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ យ៉ាងនេះ សញ្ញាដ៏ប្រាកដ រមែងកើតឡើង សញ្ញាដ៏ប្រាកដ រមែងតាំងឡើង សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះឯង ។

[១០៣] វិតក្កៈដ៏ប្រាកដ រមែងកើតឡើង វិតក្កៈដ៏ប្រាកដ រមែងតាំងឡើង វិតក្កៈដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ។

កថំ វិតក្កានំ ឧប្បាទោ វិទិតោ ហោតិ ។ អ-វិជ្ជាសមុទយា វិតក្កសមុទយោតិ បច្ចយសមុទយដ្ឋេ-ន វិតក្កានំ ឧប្បាទោ វិទិតោ ហោតិ តណ្ហាសមុទ-យា វិតក្កសមុទយោតិ កម្មសមុទយា វិតក្កសមុទ-យោតិ សញ្ញាសមុទយា វិតក្កសមុទយោតិ បច្ចយ-សមុទយដ្ឋេន វិតក្កានំ ឧប្បាទោ វិទិតោ ហោតិ និព្វត្តិលក្ខណំ បស្សតោបិ វិតក្កានំ ឧប្បាទោ វិទិតោ ហោតិ ឯវំ វិតក្កានំ ឧប្បាទោ វិទិតោ ហោតិ ។

កថំ វិតក្កានំ ឧបដ្ឋានំ វិទិតំ ហោតិ ។ អនិ-ច្ចតោ មនសិករោតោ ខយតុបដ្ឋានំ វិទិតំ ហោតិ ទុក្ខតោ មនសិករោតោ ភយតុបដ្ឋានំ វិទិតំ ហោតិ អនត្តតោ មនសិករោតោ សុញ្ញតុបដ្ឋានំ វិទិតំ ហោតិ ឯវំ វិតក្កានំ ឧបដ្ឋានំ វិទិតំ ហោតិ ។

ការកើតឡើងនៃវិតក្កៈ ដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ ដោយអត្ថថាកើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃសញ្ញា កាលភិក្ខុពិចារណាឃើញនូវលក្ខណៈ នៃកំណើត ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងនៃវិតក្កៈ ដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ការតាំងឡើងថាអស់ទៅ រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ការតាំងឡើងថាគួរខ្លាច រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ការតាំងឡើងថាសូន្យ រមែងប្រាកដ ការតាំងឡើងនៃវិតក្កៈ រមែងប្រាកដ យ៉ាងនេះឯង ។

កាចំ វិតក្កានំ អត្ថង្គមោ វិទិតោ ហោតិ ។ អវិជ្ជានិរោធា វិតក្កនិរោធោតិ បច្ចយនិរោធដ្ឋេន វិតក្កានំ អត្ថង្គមោ វិទិតោ ហោតិ តណ្ហានិរោធា វិតក្កនិរោធោតិ កម្មនិរោធា វិតក្កនិរោធោតិ សញ្ញា-និរោធា វិតក្កនិរោធោតិ បច្ចយនិរោធដ្ឋេន វិតក្កា-នំ អត្ថង្គមោ វិទិតោ ហោតិ វិបរិណាមលក្ខណំ បស្សតោបិ វិតក្កានំ អត្ថង្គមោ វិទិតោ ហោតិ ឯវំ វិតក្កានំ អត្ថង្គមោ វិទិតោ ហោតិ ឯវំ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

[១០៤] ឌីឃំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឥន្ទ្រិយានិ សមោ-ធានេតិ គោចរញ្ច បជានាតិ សមត្ថញ្ច បដិវិជ្ឈតិ ។ បេ ។ ធម្មេ សមោធានេតិ គោចរញ្ច បជានាតិ សមត្ថញ្ច បដិវិជ្ឈតិ ។

ការដល់នូវសេចក្ដីវិនាសនៃវិតក្កៈ ដ៏ប្រាកដ តើដូចម្ដេច ។ ការដល់នូវសេចក្ដីវិនាសនៃវិតក្កៈ រមែងប្រាកដ ដោយអត្ថថារលត់បច្ច័យ ព្រោះយល់ថា ការរលត់វិតក្កៈ ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្ដីវិនាស នៃវិតក្កៈ រមែងប្រាកដ ដោយអត្ថថារលត់បច្ច័យ ព្រោះយល់ថា ការរលត់វិតក្កៈ ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់វិតក្កៈ ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់វិតក្កៈ ព្រោះការរលត់សញ្ញា កាលភិក្ខុពិចារណាឃើញ នូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្ដីវិនាសនៃវិតក្កៈ រមែងប្រាកដ ការដល់នូវសេចក្ដីវិនាសនៃវិតក្កៈ រមែងប្រាកដ យ៉ាងនេះ វិតក្កៈដ៏ប្រាកដ រមែងកើតឡើង វិតក្កៈដ៏ប្រាកដ រមែងតាំងឡើង វិតក្កៈដ៏ប្រាកដរមែងដល់នូវសេចក្ដីវិនាស យ៉ាងនេះឯង ។

[១០៤] បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ រមែងប្រមូលឥន្ទ្រិយទាំងឡាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលវែង រមែងដឹងច្បាស់ នូវគោចរផង រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។ បេ ។ រមែងប្រមូលនូវធម៌ទាំងឡាយ រមែងដឹងច្បាស់នូវគោចរផង រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។

១៣១



ឥន្ទ្រិយានិ សមោធានេតីតិ កថំ ឥន្ទ្រិយានិ សមោធានេតិ ។ អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ ស-មោធានេតិ បគ្គហដ្ឋេន វីរិយិន្ទ្រិយំ សមោធានេតិ ឧបដ្ឋានដ្ឋេន សតិន្ទ្រិយំ សមោធានេតិ អវិក្ខេប-ដ្ឋេន សមាធិន្ទ្រិយំ សមោធានេតិ ទស្សនដ្ឋេន បញ្ញិន្ទ្រិយំ សមោធានេតិ អយំ បុគ្គលោ ឥមានិ ឥន្ទ្រិយានិ ឥមស្មឹ អារម្មណេ សមោធានេតីតិ តេន វុច្ចតិ ឥន្ទ្រិយានិ សមោធានេតិ ។

គោចរញ្ច បជានាតីតិ យន្តស្ស អារម្មណំ តំ តស្ស គោចរំ យំ តស្ស គោចរំ តំ តស្ស អា-រម្មណំ បជានាតីតិ បុគ្គលោ បជាននា បញ្ញា ។

សមត្ថំ អារម្មណស្ស ឧបដ្ឋានំ សមំ ចិត្តស្ស អវិក្ខេបោ សមំ ចិត្តស្ស អធិដ្ឋានំ សមំ ចិត្តស្ស វោទានំ សមំ ។

អត្ថោតិ អនវជ្ជដ្ឋោ និក្កិលេសដ្ឋោ វោទានដ្ឋោ បរមដ្ឋោ ។

*សំណួរត្រង់ពាក្យថា ប្រមូលនូវឥន្ទ្រិយទាំងឡាយ តើប្រមូលឥន្ទ្រិយទាំងឡាយ ដូចម្តេច ។ បុគ្គលប្រមូលនូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ប្រមូលនូវវីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងឡើង ប្រមូលនូវសតិន្ទ្រិយ ដោយអត្ថថាប្រុងប្រយ័ត្ន ប្រមូលនូវសមាធិន្ទ្រិយ ដោយអត្ថថាមិនរាយមាយ ប្រមូលនូវបញ្ញិន្ទ្រិយ ដោយអត្ថថាឃើញ បុគ្គលនេះឈ្មោះថាប្រមូលនូវឥន្ទ្រិយទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលនូវឥន្ទ្រិយទាំងឡាយ ដោយប្រការដូច្នេះ ។*

*ពាក្យថា ដឹងច្បាស់នូវគោចរ សេចក្តីថា បុគ្គលដឹងច្បាស់ថា ធម្មជាតណាជាអារម្មណ៍នៃចិត្តនោះ ធម្មជាតនោះ ជាគោចរនៃចិត្តនោះ ធម្មជាតណា ជាគោចរនៃចិត្តនោះ ធម្មជាតនោះ ជាអារម្មណ៍នៃចិត្តនោះ ព្រោះហេតុនោះ ការដឹងច្បាស់ ឈ្មោះថាបញ្ញា ។*

*ពាក្យថា ការស្ងប់ គឺ ការតម្កល់អារម្មណ៍ ឈ្មោះថាការស្ងប់ ការមិនរាយមាយចិត្ត ឈ្មោះថាការស្ងប់ ការអធិដ្ឋានចិត្ត ឈ្មោះថាការស្ងប់ សេចក្តីផូរផង់នៃចិត្ត ឈ្មោះថាការស្ងប់ ។*

*អត្ថនៃការមិនមានទោស អត្ថនៃការមិនសៅហ្មង អត្ថនៃការផូរផង់ អត្ថនៃគុណក្រៃលែង ឈ្មោះថាអត្ថ ។*

បដិវិជ្ឈតីតិ អារម្មណស្ស ឧបដ្ឋានដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស អភិក្ខេបដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស អធិដ្ឋានដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស វោទានដ្ឋំ បដិវិជ្ឈតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១០៩] ពលានិ សមោធានេតីតិ កថំ ពលានិ សមោធានេតិ ។ អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ សមោធានេតិ កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ សមោធានេតិ បមាទេ អកម្បិយដ្ឋេន សតិពលំ សមោធានេតិ ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ សមោធានេតិ អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ សមោធានេតិ អយំ បុគ្គលោ ឥមានិ ពលានិ ឥមស្មឹ អារម្មណេ សមោធានេតីតិ តេន វុច្ចតិ ពលានិ សមោធានេតិ[១] ។

គោចរញ្ច បជានាតីតិ ។ បេ ។ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

---

១ ឱ. ម. សមោធានេតីតិ ។

ពាក្យថា ចាក់ធ្លុះ គឺ ចាក់ធ្លុះនូវអត្ថនៃការតម្កល់មាំ នូវអារម្មណ៍ ចាក់ធ្លុះនូវអត្ថ នៃការមិនរាយមាយចិត្ត ចាក់ធ្លុះនូវអត្ថនៃការអធិដ្ឋានចិត្ត ចាក់ធ្លុះនូវអត្ថនៃការផូរផង់ចិត្ត ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១០៥] សំណួរត្រង់ពាក្យថា ប្រមូលមកនូវកម្លាំងទាំងឡាយ តើប្រមូលមកនូវកម្លាំង ដូចម្តេច ។ ប្រមូលមកនូវសទ្ធាពលៈ ដោយអត្ថថាមិនកម្រើកព្រោះសេចក្តីមិនជឿ ប្រមូលមកនូវវីរិយពលៈ ដោយអត្ថថាមិនកម្រើកព្រោះសេចក្តីខ្ជិល ប្រមូលមកនូវសតិពលៈ ដោយអត្ថថាមិនកម្រើកព្រោះបមាទៈ ប្រមូលមកនូវសមាធិពលៈ ដោយអត្ថថាមិនកម្រើកព្រោះឧទ្ធច្ចៈ ប្រមូលមកនូវបញ្ញាពលៈ ដោយអត្ថថាមិនកម្រើកព្រោះអវិជ្ជា បុគ្គលនេះ ឈ្មោះថាប្រមូលមកនូវកម្លាំងទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលមកនូវកម្លាំងទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ (អារម្មណ៍) ។ បេ ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១០៦] ពោជ្ឈង្គេ សមោធានេតីតិ កថំ ពោជ្ឈង្គេ សមោធានេតិ ។ ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គំ សមោធានេតិ បវិចយដ្ឋេន ធម្មវិចយសម្ពោជ្ឈង្គំ សមោធានេតិ បគ្គហដ្ឋេន វីរិយសម្ពោជ្ឈង្គំ សមោធានេតិ ផរណដ្ឋេន បីតិសម្ពោជ្ឈង្គំ សមោធានេតិ ឧបសមដ្ឋេន បស្សទ្ធិសម្ពោជ្ឈង្គំ សមោធានេតិ អវិក្ខេបដ្ឋេន សមាធិសម្ពោជ្ឈង្គំ សមោធានេតិ បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គំ សមោធានេតិ អយំ បុគ្គលោ ឥមេ ពោជ្ឈង្គេ ឥមស្មឹ អារម្មណេ សមោធានេតីតិ តេន វុច្ចតិ ពោជ្ឈង្គេ សមោធានេតិ ។

គោចរញ្ច បជានាតីតិ ។ បេ ។ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១០៦] សំណួរត្រង់ពាក្យថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ តើប្រមូលមកនូវពោជ្ឈង្គ ដូចម្តេច ។ ប្រមូលមកនូវសតិសម្ពោជ្ឈង្គ ដោយអត្ថថាប្រុងប្រយ័ត្ន ប្រមូលមកនូវធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថាឈ្វេចឈ្វីរក ប្រមូលមកនូវវិរិយសម្ពោជ្ឈង្គ ដោយអត្ថថាផ្គងឡើង ប្រមូលមកនូវបីតិសម្ពោជ្ឈង្គ ដោយអត្ថថាផ្សាយទៅ ប្រមូលមកនូវបស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថាស្ងប់រម្ងាប់ ប្រមូលមកនូវសមាធិសម្ពោជ្ឈង្គ ដោយអត្ថថាមិនរាយមាយ ប្រមូលមកនូវឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថាពិចារណាឃើញច្បាស់ បុគ្គលនេះ ឈ្មោះថាប្រមូលមកនូវពោជ្ឈង្គទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ (អារម្មណ៍) ។ បេ ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១០៧] មគ្គំ សមោធានេតីតិ កថំ មគ្គំ ស-
មោធានេតិ ។ ទស្សនដ្ឋេន សម្មាទិដ្ឋឹ សមោធានេ-
តិ អភិនិរោបនដ្ឋេន សម្មាសង្កប្បំ សមោធានេតិ
បរិគ្គហដ្ឋេន សម្មាវាចំ សមោធានេតិ សមុដ្ឋានដ្ឋេន
សម្មាកម្មន្តំ សមោធានេតិ វោទានដ្ឋេន សម្មាអា-
ជីវំ សមោធានេតិ បគ្គហដ្ឋេន សម្មាវាយាមំ សមោ-
ធានេតិ ឧបដ្ឋានដ្ឋេន សម្មាសតឹ សមោធានេតិ
អវិក្ខេបដ្ឋេន សម្មាសមាធឹ សមោធានេតិ អយំ
បុគ្គលោ ឥមំ មគ្គំ ឥមស្មឹ អារម្មណេ សមោធានេ-
តីតិ តេន វុច្ចតិ មគ្គំ សមោធានេតិ ។

គោចរញ្ច បជានាតីតិ ។ បេ ។ តេន វុច្ចតិ
សមត្ថញ្ច បដិវិជ្ឈតិ ។

[១០៧] សំណួរត្រង់ពាក្យថា ប្រមូលមកនូវមគ្គ តើប្រមូលមកនូវមគ្គ ដូចម្តេច ។ ប្រមូលមក នូវសម្មាទិដ្ឋិ ដោយអត្ថថាឃើញ ប្រមូលមក នូវសម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង កាន់អារម្មណ៍ ប្រមូលមកនូវសម្មាវាចា ដោយអត្ថថារក្សាទុក ប្រមូលមកនូវសម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើងដោយប្រពៃ ប្រមូលមកនូវសម្មាអាជីវៈ ដោយអត្ថថាផូរផង់ ប្រមូលមក នូវសម្មាវាយាមៈ ដោយអត្ថថាផ្គងឡើង ប្រមូលមកនូវសម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន ប្រមូលមកនូវសម្មា-សមាធិ ដោយអត្ថថាមិនរាយមាយ បុគ្គលនេះ ឈ្មោះថាប្រមូលមក នូវមគ្គនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលមកនូវមគ្គ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ (អារម្មណ៍) ។ បេ ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១០៨] ធម្មេ សមោធានេតីតិ កថំ ធម្មេ សមោធានេតិ ។ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយានិ សមោធានេតិ អកម្បិយដ្ឋេន ពលានិ សមោធានេតិ និយ្យានដ្ឋេន ពោជ្ឈង្គេ សមោធានេតិ ហេតដ្ឋេន មគ្គំ សមោធានេតិ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានំ សមោធានេតិ បទហានដ្ឋេន សម្មប្បធានំ សមោធានេតិ ឥជ្ឈនដ្ឋេន ឥទ្ធិចាទំ សមោធានេតិ តថដ្ឋេន សច្ចំ សមោធានេតិ អវិក្ខេបដ្ឋេន សមថំ សមោធានេតិ អនុបស្សនដ្ឋេន វិបស្សនំ សមោធានេតិ ឯករសដ្ឋេន សមថវិបស្សនំ សមោធានេតិ អនតិវត្តនដ្ឋេន យុគនទ្ធំ សមោធានេតិ សំវរដ្ឋេន សីលវិសុទ្ធឹ សមោធានេតិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធឹ សមោធានេតិ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធឹ សមោធានេតិ មុត្តដ្ឋេន[1] វិមោក្ខំ សមោធានេតិ បដិវេធដ្ឋេន វិជ្ជំ សមោធានេតិ បរិច្ចាគដ្ឋេន វិមុត្តឹ សមោធានេតិ សមុច្ឆេទដ្ឋេន ខយេ ញាណំ សមោធានេតិ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ សមោធានេតិ

---

១ ឱ. ម. វិមុត្តដ្ឋេន ។

[១០៨] សំណួរត្រង់ពាក្យថា ប្រមូលមកនូវធម៌ទាំងឡាយ តើប្រមូលមកនូវធម៌ ដូចម្តេច ។ ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដោយអត្ថថាជាធំ ប្រមូលមក នូវពលៈទាំងឡាយ ដោយអត្ថថាមិនកម្រើក ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ ដោយអត្ថថាចេញទៅ (ចាកធម៌ជាសត្រូវ) ប្រមូលមកនូវមគ្គ ដោយអត្ថថាជាហេតុ ប្រមូលមកនូវសតិប្បដ្ឋាន ដោយអត្ថថាប្រុងប្រយ័ត្ន ប្រមូលមកនូវសម្មប្បធាន ដោយអត្ថថាតម្កល់មាំ ប្រមូលមកនូវឥទ្ធិបាទ ដោយអត្ថថាសម្រេច ប្រមូលមកនូវសច្ចៈ ដោយអត្ថថាពិត ប្រមូលមកនូវសមថៈ ដោយអត្ថថាមិនរាយមាយ ប្រមូលមកនូវវិបស្សនា ដោយអត្ថថាពិចារណាឃើញរឿយ ៗ ប្រមូលមកនូវសមថៈនិងវិបស្សនា ដោយអត្ថថាមានរសតែមួយ ប្រមូលមកនូវធម៌ ដែលជាប់គ្នាជាគូ ដោយអត្ថថាមិនកន្លងគ្នា ប្រមូលមកនូវសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ប្រមូលមកនូវចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ប្រមូលមកនូវទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ប្រមូលមកនូវវិមោក្ខ ដោយអត្ថថារួច ប្រមូលមកនូវវិជ្ជា ដោយអត្ថថាចាក់ធ្លុះ ប្រមូលមកនូវវិមុត្តិ ដោយអត្ថថាលះស្រឡះ ប្រមូលមកនូវខយញ្ញាណ ដោយអត្ថថាផ្តាច់បង់ ប្រមូលមកនូវអនុប្បាទញ្ញាណ

ឆន្ទំ មូលដ្ឋេន សមោធានេតិ មនសិការំ សមុដ្ឋានដ្ឋេន សមោធានេតិ ផស្សំ សមោធានដ្ឋេន សមោធានេតិ វេទនំ សមោសរណដ្ឋេន សមោធានេតិ សមាធឹ បមុខដ្ឋេន សមោធានេតិ សតឹ អាធិបតេយ្យដ្ឋេន សមោធានេតិ សតិសម្បជញ្ញំ[១] តតុត្តរដ្ឋេន សមោធានេតិ វិមុត្តឹ សារដ្ឋេន សមោធានេតិ អមតោគធំ និព្វានំ បរិយោសានដ្ឋេន សមោធានេតិ អយំ បុគ្គលោ ឥមេ ធម្មេ ឥមស្មឹ អារម្មណេ សមោធានេតីតិ តេន វុច្ចតិ ធម្មេ សមោធានេតិ ។

គោចរញ្ច បជានាតីតិ យន្តស្ស អារម្មណំ តំ តស្ស គោចរំ យន្តស្ស គោចរំ តំ តស្ស អារម្មណំ បជានាតីតិ បុគ្គលោ បជានានា បញ្ញា ។

សមន្តិ អារម្មណស្ស ឧបដ្ឋានំ សមំ ចិត្តស្ស អវិក្ខេបោ សមំ ចិត្តស្ស អធិដ្ឋានំ សមំ ចិត្តស្ស វោទានំ សមំ ។

១ ឱ. ម. បញ្ញំ ។

ដោយអត្ថថាស្ងប់ ប្រមូលមកនូវឆន្ទៈ ដោយអត្ថថាជាឫសគល់ ប្រមូលមកនូវមនសិការៈ ដោយអត្ថថាតាំងឡើងព្រម ប្រមូលមកនូវផស្សៈ ដោយអត្ថថាប្រមូលមក (នូវអារម្មណ៍) ប្រមូលមកនូវវេទនា ដោយអត្ថថាប្រជុំចុះ ប្រមូលមកនូវសមាធិ ដោយអត្ថថាជាប្រធាន ប្រមូលមកនូវសតិ ដោយអត្ថថាជាធំ ប្រមូលមកនូវសតិសម្បជញ្ញៈ ដោយអត្ថថាប្រសើរជាងធម៌នោះ ប្រមូលមកនូវវិមុត្តិ ដោយអត្ថថាជាខ្លឹម ប្រមូលមកនូវនិព្វាន ឈ្មោះអមតៈ (ជាទីពឹងរបស់សត្វ) ដោយអត្ថថាទីបំផុត (នៃកិច្ចក្នុងសាសនា) បុគ្គលនេះ ឈ្មោះថាប្រមូលមកនូវធម៌ទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលមកនូវធម៌ទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ សេចក្តីថា បុគ្គលតែងដឹងច្បាស់ថា ធម្មជាតណា ជាអារម្មណ៍នៃចិត្តនោះ ធម្មជាតនោះ ជាគោចរនៃចិត្តនោះ ធម្មជាតណា ជាគោចរនៃចិត្តនោះ ធម្មជាតនោះ ជាអារម្មណ៍នៃចិត្តនោះ ព្រោះហេតុនោះ ការដឹងច្បាស់ ឈ្មោះថាបញ្ញា ។

ពាក្យថា ការស្ងប់ គឺការតម្កល់ទុកនូវអារម្មណ៍ ឈ្មោះថាការស្ងប់ ការមិនរាយមាយនៃចិត្ត ឈ្មោះថាការស្ងប់ ការអធិដ្ឋានចិត្ត ឈ្មោះថាការស្ងប់ ការផូរផង់នៃចិត្ត ឈ្មោះថាការស្ងប់ ។

អត្ថោតិ អនវជ្ជដ្ឋោ និក្កិលេសដ្ឋោ វោទានដ្ឋោ បរមដ្ឋោ ។

បដិវិជ្ឈតីតិ អារម្មណស្ស ឧបដ្ឋានដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស អភិរោបនដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស អធិដ្ឋានដ្ឋំ បដិវិជ្ឈតិ ចិត្តស្ស វោទានដ្ឋំ បដិវិជ្ឈតិ តេន វុច្ចតិ សមត្តញ្ច បដិវិជ្ឈតិ ។

[១០៩] កាជំ រស្សំ អស្សសន្តោ រស្សំ អស្ស-សាមីតិ បជានាតិ រស្សំ បស្សសន្តោ រស្សំ បស្ស-សាមីតិ បជានាតិ ។ រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ រស្សំ បស្សាសំ ឥត្តរសង្ខាតេ បស្សសតិ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតិបិ បស្សសតិបិ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតោបិ បស្សសតោបិ ឆន្ទោ ឧប្បជ្ជតិ ឆន្ទវ-សេន តតោ សុខុមតរំ រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ ឆន្ទវសេន តតោ សុខុមតរំ រស្សំ បស្សាសំ

*អត្ថនៃការមិនមានទោស អត្ថនៃការមិនមានកិលេស អត្ថនៃការផូរផង់ អត្ថនៃគុណដ៏ក្រៃលែង ឈ្មោះថាអត្ថ ។*

*ពាក្យថា ចាក់ធ្លុះ គឺ ចាក់ធ្លុះ នូវអត្ថនៃការតម្កល់មាំនូវអារម្មណ៍ ចាក់ធ្លុះនូវអត្ថនៃការមិនរាយមាយចិត្ត ចាក់ធ្លុះនូវអត្ថនៃការអធិដ្ឋានចិត្ត ចាក់ធ្លុះនូវអត្ថនៃការផូរផង់ចិត្ត ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។*

[១០៩] *បុគ្គលកាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី តើដូចម្តេច ។ បុគ្គល ដកចេញ នូវដង្ហើមចេញខ្លី ក្នុងចំណែកកាលខ្លី ដកចូល នូវដង្ហើមចូលខ្លី ក្នុងចំណែកកាលខ្លី ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ក្នុងចំណែកកាលខ្លី កាលបុគ្គលដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ក្នុងចំណែកកាលខ្លី* (*ច្រើនដង*) *ឆន្ទៈ* (*ចំណង់ក្នុងអ្វីមួយ*) *រមែងកើតឡើង បុគ្គលដកចេញ នូវដង្ហើមចេញខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចឆន្ទៈ ដកចូល នូវដង្ហើមចូលខ្លីល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចឆន្ទៈ*

ឥត្តរសង្ខាតេ បស្សសតិ ឆន្ទវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតិបិ បស្សសតិបិ ឆន្ទវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតោបិ បស្សសតោបិ បាមុជ្ជំ ឧប្បជ្ជតិ បាមុជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ បាមុជ្ជវសេន តតោ សុខុមតរំ រស្សំ បស្សាសំ ឥត្តរសង្ខាតេ បស្សសតិ បាមុជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតិបិ បស្សសតិបិ បាមុជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតោបិ បស្សសតោបិ រស្សំ អស្សាសបស្សាសា ចិត្តំ វិវដ្ដតិ ឧបេក្ខា សណ្ឋាតិ ឥមេហិ នវហាការេហិ រស្សំ[១] អស្សាសបស្សាសកាយោ ឧបដ្ឋានំ សតិ អនុបស្សនាញាណំ កាយោ ឧបដ្ឋានំ

១ ឱ. ម. រស្សា ។

ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចឆន្ទៈ កាលបុគ្គលដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចឆន្ទៈ (ច្រើនដង) បាមុជ្ជៈរមែងកើតឡើង បុគ្គលដកចេញ នូវដង្ហើមចេញខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចបាមុជ្ជៈ ដកចូលនូវដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចបាមុជ្ជៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចបាមុជ្ជៈ កាលបុគ្គលដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចបាមុជ្ជៈ (ច្រើនដង) ចិត្តក៏ឃ្លាតចេញអំពីដង្ហើមចេញឬដង្ហើមចូលខ្លី ឧបេក្ខា ក៏តាំងនៅស៊ប់ កាយគឺដង្ហើមចេញនិងដង្ហើមចូលខ្លី ដោយអាការ ៩ នេះ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ កាយឈ្មោះថាឧបដ្ឋាន

ដោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ ស-
តិយា តេន ញាណេន តំ កាយំ អនុបស្សតីតិ តេន
វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា ។

[១១០] អនុបស្សតីតិ កថំ តំ កាយំ អនុប-
ស្សតិ ។ បេ ។ ឯវន្តំ កាយំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវន-
ដ្ឋេន ភាវនា រស្សំ អស្សាសប្បស្សាសវសេន ចិត្ត-
ស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា
ឧប្បជ្ជន្តិ ។ បេ ។ រស្សំ អស្សាសប្បស្សាសវសេន
ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានន្តោ ឥន្ទ្រិយានិ
សមោធានេតិ ។ បេ ។ តេន វុច្ចតិ សមត្តញ្ច
បដិវិជ្ឈតិ ។

មិនមែនឈ្មោះថាសតិទេ ចំណែកខាងសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលរមែងពិចារណាឃើញ នូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[១១០] ពាក្យថា ពិចារណាឃើញ តើ ពិចារណាឃើញនូវកាយនោះ ដូចម្ដេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវកាយនោះយ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ភាវនាដោយអត្ថថាសេព កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ ឬដង្ហើមចូលខ្លី វេទនាទាំងឡាយដែលប្រាកដ រមែងកើតឡើង ។ បេ ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញឬដង្ហើមចូលខ្លី ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។ បេ ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[១១១] កថំ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

កាយោតិ ទ្វេ កាយា នាមកាយោ ច រូបកាយោ ច ។ កតមោ នាមកាយោ ។ វេទនា សញ្ញា ចេតនា ផស្សោ មនសិការោ នាមញ្ច នាមកាយោ ច យេ ច វុច្ចន្តិ ចិត្តសង្ខារា អយំ នាមកាយោ ។ កតមោ រូបកាយោ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ អស្សាសោ ច បស្សាសោ ច និមិត្តញ្ច ឧបនិពន្ធនា យេ ច វុច្ចន្តិ កាយសង្ខារា អយំ រូបកាយោ ។

[១១១] បុគ្គលសិក្សាថា អាត្មាអញកំណត់ដឹងនូវកាយ គឺដង្ហើមចេញទាំងពួង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវកាយ គឺដង្ហើមចូលទាំងពួង ទើបដកដង្ហើមចូល តើដូចម្តេច ។

ពាក្យថា កាយ បានដល់កាយ ២ យ៉ាង គឺនាមកាយ ១ រូបកាយ ១ នាមកាយ តើដូចម្តេច ។ វេទនា សញ្ញា ចេតនា ផស្សៈ មនសិការៈ ឈ្មោះថានាមផង ឈ្មោះថានាមកាយផង មួយទៀត ពួកធម៌ណាដែលលោកពោលថា ចិត្តសង្ខារ នេះ ឈ្មោះថានាមកាយ ។ រូបកាយ តើដូចម្តេច ។ មហាភូតរូប ៤ ផង ឧបាទាយរូប របស់មហាភូតរូប ៤ ផង ដង្ហើមចេញផង ដង្ហើមចូលផង និមិត្តផង ជាឧបនិពន្ធន៍ (ជាប់គ្នា) (ឈ្មោះថារូបកាយ) មួយទៀត ពួកធម៌ណា ដែលលោកពោលថា កាយសង្ខារ នេះ ឈ្មោះថារូបកាយ ។

១៤១



[១១២] កាថង្គ កាយា បដិវិទិតា ហោន្តិ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជាន-តោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជា-នតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ រស្សំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ រស្សំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ អាវជ្ជតោ តេ កាយា បដិវិទិតា ហោន្តិ ជានតោ តេ កាយា បដិវិទិតា ហោន្តិ បស្សតោ តេ កាយា បដិវិទិតា ហោន្តិ

[១១២] កាយទាំងឡាយនោះ ដែលបុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយ ដោយអំណាចនៃដង្ហើមចេញវែង កាយទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយ ដោយអំណាចនៃដង្ហើមចូលវែង កាយទាំងឡាយនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយ ដោយអំណាចនៃដង្ហើមចេញខ្លី កាយទាំងឡាយនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយ ដោយអំណាចនៃដង្ហើមចូលខ្លី កាយទាំងឡាយនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលរំពឹង កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលដឹង កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលឃើញ កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ

បច្ចវេក្ខតោ តេ កាយា បដិវិទិតា ហោន្តិ ចិត្តំ អធិដ្ឋហតោ តេ កាយា បដិវិទិតា ហោន្តិ សទ្ធាយ អធិមុច្ចតោ តេ កាយា បដិវិទិតា ហោន្តិ វីរិយំ បគ្គណ្ហតោ តេ កាយា បដិវិទិតា ហោន្តិ សតឹ ឧបដ្ឋាបយតោ តេ កាយា បដិវិទិតា ហោន្តិ ចិត្តំ សមាទហតោ តេ កាយា បដិវិទិតា ហោន្តិ បញ្ញា-យ[១] បជានតោ តេ កាយា បដិវិទិតា ហោន្តិ អ-ភិញ្ញេយ្យំ អភិជានតោ តេ កាយា បដិវិទិតា ហោន្តិ បរិញ្ញេយ្យំ បរិជានតោ តេ កាយា បដិវិទិតា ហោន្តិ បហាតព្វំ បជហតោ តេ កាយា បដិវិទិតា ហោន្តិ ភាវេតព្វំ ភាវយតោ តេ កាយា បដិវិទិតា ហោន្តិ

១ ឱ. ម. សញ្ញាយ ។

កាលបុគ្គលពិចារណា កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលអធិដ្ឋានចិត្ត កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលជឿស៊ប់ដោយសទ្ធា កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលផ្គងព្យាយាម កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលតម្កល់សតិ កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលតម្កល់ចិត្ត កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលដឹងច្បាស់ដោយប្រាជ្ញា កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលកំណត់ដឹងនូវធម៌ ដែលគួរកំណត់ដឹង កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលលះបង់នូវធម៌ ដែលគួរលះបង់ កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលចម្រើននូវធម៌ដែលគួរចម្រើន កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ

សច្ចិកាតព្វំ សច្ចិករោតោ តេ កាយា បដិវិទិតា ហោន្តិ ឯវន្តេ កាយា បដិវិទិតា ហោន្តិ សព្វកាយប្បដិសំវេទី អស្សាសប្បស្សាសកាយោ ឧបដ្ឋានំ សតិ អនុបស្សនាញាណំ កាយោ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតីតិ តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា ។

[១១៣] អនុបស្សតីតិ ។ បេ ។ សព្វកាយប្បដិសំវេទី អស្សាសប្បស្សាសា[១] សំវរដ្ឋេន សីលវិសុទ្ធិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្បញ្ញាសិក្ខា

១ ឱ. ម. អស្សាសប្បស្សាសានំ ។

កាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ កាយទាំងឡាយនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាយទាំងឡាយនោះ ដែលបុគ្គលដឹងច្បាស់ហើយ យ៉ាងនេះឯង កាយគឺដង្ហើមចេញនិងដង្ហើមចូល សម្រាប់អ្នកកំណត់ដឹងនូវកាយទាំងពួង ឈ្មោះថាឧបដ្ឋាន សតិឈ្មោះថាអនុបស្សនាញាណ កាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[១១៣] ពាក្យថា ពិចារណាឃើញ ។ បេ ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល នៃបុគ្គលអ្នកកំណត់ដឹងនូវកាយទាំងពួង ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ បណ្ដាធម៌ទាំងនោះ ធម៌ណាមានអត្ថថាសង្រួម ធម៌នេះឈ្មោះថាអធិសីលសិក្ខា បណ្ដាធម៌ទាំងនោះ ធម៌ណាមានអត្ថថាមិនរាយមាយ ធម៌នេះឈ្មោះថាអធិចិត្តសិក្ខា បណ្ដាធម៌ទាំងនោះ ធម៌ណាមានអត្ថថាឃើញ ធម៌នេះឈ្មោះថាអធិប្បញ្ញាសិក្ខា

ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ ជានន្តោ សិក្ខតិ បស្សន្តោ សិក្ខតិ បច្ចវេក្ខន្តោ សិក្ខតិ ចិត្តំ អធិដ្ឋហន្តោ សិក្ខតិ សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ វីរិយំ បគ្គណ្ហន្តោ សិក្ខតិ សតឹ ឧបដ្ឋាបេន្តោ សិក្ខតិ ចិត្តំ សមាទហន្តោ សិក្ខតិ បញ្ញាយ បជានន្តោ សិក្ខតិ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខតិ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខតិ បហាតព្វំ បជហន្តោ សិក្ខតិ ភាវេតព្វំ ភាវេន្តោ សិក្ខតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ សព្វកាយប្បដិសំវេទី អស្សាសប្បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា ឧប្បជ្ជន្តិ ។ បេ ។

បុគ្គលកាលរំពឹង នូវសិក្ខាទាំង ៣ នេះ ឈ្មោះថាសិក្សា កាលដឹង ឈ្មោះថាសិក្សា កាលឃើញ ឈ្មោះថាសិក្សា កាលពិចារណា ឈ្មោះថាសិក្សា កាលអធិដ្ឋានចិត្ត ឈ្មោះថាសិក្សា កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថាសិក្សា កាលផ្គងនូវវីរិយៈ ឈ្មោះថាសិក្សា កាលប្រុងសតិ ឈ្មោះថាសិក្សា កាលតម្កល់ចិត្ត ឈ្មោះថាសិក្សា កាលដឹងច្បាស់ដោយប្រាជ្ញា ឈ្មោះថាសិក្សា កាលត្រាស់ដឹងធម៌ ដែលគួរត្រាស់ដឹង ឈ្មោះថាសិក្សា កាលកំណត់ដឹងនូវធម៌ ដែលគួរកំណត់ដឹង ឈ្មោះថាសិក្សា កាលលះនូវធម៌ ដែលគួរលះ ឈ្មោះថាសិក្សា កាលចម្រើននូវធម៌ ដែលគួរចម្រើន ឈ្មោះថាសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសិក្សា កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល សម្រាប់អ្នកកំណត់ដឹង នូវកាយទាំងពួង វេទនាទាំងឡាយ ដែលប្រាកដ រមែងកើតឡើង ។ បេ ។

សព្វកាយប្បដិសំវេទី អស្សាសប្បស្សាសវសេន ចិត្ត-ស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឥន្ទ្រិយានិ សមោធានេតិ ។ បេ ។ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតីតិ ។

[១១៤] កថំ បស្សម្ភយំ កាយសង្ខារំ អស្ស-សិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្ស-សិស្សាមីតិ សិក្ខតិ ។

កតមោ កាយសង្ខារោ ។ ទីឃំ អស្សាសា កាយិកា ឯតេ ធម្មា កាយប្បដិពទ្ធា[១] កាយស-ង្ខារា តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ ទីឃំ បស្សាសា កាយិកា ឯតេ ធម្មា កាយប្បដិពទ្ធា កាយសង្ខារា តេ កាយ-សង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិ-ក្ខតិ រស្សំ អស្សាសា រស្សំ បស្សាសា សព្វកាយ-ប្បដិសំវេទី អស្សាសា[២] កាយិកា ឯតេ ធម្មា កាយប្បដិពទ្ធា កាយសង្ខារា តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ

១ ឱ. ម. កាយប្បដិពន្ធា ។ ២ ឱ. ម. សព្វកាយប្បដិសំវេទី បស្សាសាតិ ទិស្សតិ ។

បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល សម្រាប់អ្នកកំណត់ដឹងនូវកាយទាំងពួង រមែងប្រមូលនូវឥន្ទ្រិយទាំងឡាយ ។ បេ ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[១១៤] បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល តើដូចម្តេច ។

កាយសង្ខារ តើដូចម្តេច ។ ពួកខ្យល់ដង្ហើមចេញវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថាកាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថាសិក្សា ពួកខ្យល់ដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយ ឈ្មោះថាកាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថាសិក្សា ពួកខ្យល់ដង្ហើមចេញខ្លី ដង្ហើមចូលខ្លី ឬដង្ហើមចេញ សម្រាប់បុគ្គលអ្នកកំណត់ដឹងនូវកាយទាំងពួង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថាកាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថាសិក្សា

យថារូបេហិ កាយសង្ខារេហិ យា កាយស្ស អានមនា វិនមនា សន្នមនា បណាមនា ឥញ្ជនា ផន្ទនា ចលនា កម្បនា បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ យថារូបេហិ កាយសង្ខារេហិ យា កាយស្ស នអានមនា នវិនមនា នសន្នមនា នប្បណាមនា អនិញ្ជនា នផន្ទនា អចលនា អកម្បនា សន្តំ សុខុមំ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ឥតិ កិរ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ឯវំ សន្តេ វាតុបលទ្ធិយា ច បភាវនា ន ហោតិ អស្សាសបស្សាសានញ្ច បភាវនា ន ហោតិ អានាបានស្សតិសមាធិស្ស ច បភាវនា ន ហោតិ អានាបានស្សតិសមាធិស្សយា ច បភាវនា ន ហោតិ ន ច តំ[១] សមាបត្តឹ បណ្ឌិតា

១ ឱ. ម. ន តញ្ច នំ ។ ម. ន ច នំ តំ ។

ការឱន ការផ្អាក ការទម្រេត ការឈម ការរញ្ជួយ ការអន្ទះ-សា ការកម្រើក ការញាប់ញ័រ ណា នៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល ការមិនឱន ការមិនផ្អាក ការមិនទម្រេត ការមិនឈម ការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រ ណា នៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារដ៏ល្អិតសុខុម មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល បានឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការ យ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដ នៃការបាននូវខ្យល់មិនទាន់មាន ការប្រាកដ នៃដង្ហើមចេញនិងដង្ហើមចូល ក៏មិនទាន់មាន ការប្រាកដ នៃអានាបានស្សតិ ក៏មិនទាន់មាន ទាំងការប្រាកដ នៃអានាបានស្សតិសមាធិ ក៏មិនទាន់មានទេ បណ្ឌិត

សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ឥតិ កិរ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ឯវំ សន្តេ វាតុបលទ្ធិយា ច បភាវនា ហោតិ អស្សាសប្ស-ស្សាសានញ្ច បភាវនា ហោតិ អានាបានស្សតិយា ច បភាវនា ហោតិ អានាបានស្សតិសមាធិស្ស ច បភាវនា ហោតិ តញ្ច នំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ យថាកថំ វិយ សេយ្យថាបិ កំសេ អាកោដិតេ បឋមំ ឱឡារិកា សទ្ទា បវត្តន្តិ ឱឡារិកានំ សទ្ទានំ និមិត្តំ សុគ្គហិតត្តា សុមនសិកតត្តា សូបធារិតត្តា និរុទ្ធេបិ ឱឡារិកេ សទ្ទេ អថ បច្ឆា សុខុមកា សទ្ទា បវត្តន្តិ សុខុម-កានំ សទ្ទានំ និមិត្តំ សុគ្គហិតត្តា សុមនសិកតត្តា សូបធារិតត្តា និរុទ្ធេបិ សុខុមកេ សទ្ទេ អថ បច្ឆា សុខុមនិមិត្តារម្មណតាបិ ចិត្តំ បវត្តតិ ឯវមេវ បឋមំ ឱឡារិកា អស្សាសបស្សាសា បវត្តន្តិ

ទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង ៗថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដ នៃការបាននូវខ្យល់ក៏មាន ការប្រាកដ នៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលក៏មាន ការប្រាកដ នៃអានាបានស្សតិក៏មាន ទាំងការប្រាកដ នៃអានាបានស្សតិសមាធិក៏មាន ទើបបណ្ឌិតទាំងឡាយចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះប្រៀបដូចជាអ្វី ប្រៀបដូចជារគាំង ដែលគេគោះ សំឡេងគ្រោតគ្រាតរមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្ត នៃសំឡេងដ៏គ្រោតគ្រាត កាលបើសំឡេងគ្រោតគ្រាតរលត់ហើយ បន្ទាប់មក សំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្ត នៃសំឡេងដ៏ល្អិត កាលសំឡេងដ៏ល្អិតរលត់ហើយ បន្ទាប់មក ចិត្តក៏រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះចិត្តមាននិមិត្តដ៏ល្អិតជាអារម្មណ៍ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល ដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង

ឱឡារិកានំ អស្សាសប្បស្សាសានំ និមិត្តំ សុគ្គហិ-
តត្តា សុមនសិកតត្តា សូបធារិតត្តា និរុទ្ធេបិ ឱឡា-
រិកេ អស្សាសប្បស្សាសេ អថ បច្ឆា សុខុមកា
អស្សាសប្បស្សាសា បវត្តន្តិ សុខុមកានំ អស្សា-
សប្បស្សាសានំ និមិត្តំ សុគ្គហិតត្តា សុមនសិក-
តត្តា សូបធារិតត្តា និរុទ្ធេបិ សុខុមកេ អស្សាស-
ប្បស្សាសេ អថ បច្ឆា សុខុមកានំ អស្សាសប្ប-
ស្សាសានំ និមិត្តារម្មណតាបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ
ឯវំ សន្តេ វាតុបលទ្ធិយា ច បភាវនា ហោតិ
អស្សាសប្បស្សាសានញ្ច បភាវនា ហោតិ អានា-
បានស្សតិយា ច បភាវនា ហោតិ អានាបានស្ស-
តិសមាធិស្ស ច បភាវនា ហោតិ តញ្ច នំ
សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ
បស្សម្ភយំ កាយសង្ខារំ អស្សាសប្បស្សាស-
កាយោ ឧបដ្ឋានំ សតិ អនុបស្សនាញាណំ

ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្ត នៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល ដ៏គ្រោតគ្រាត កាលបើខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល ដ៏គ្រោតគ្រាត រលត់ហើយ បន្ទាប់មក ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាង ក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុក ល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត កាលបើ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រលត់ហើយ បន្ទាប់មក ចិត្តក៏មិនដល់នូវសេចក្តីរាយមាយ ក្នុងកាលខាងក្រោយ ព្រោះចិត្តយក និមិត្តនៃខ្យល់ដង្ហើមចេញនិងដង្ហើមចូលដ៏ល្អិតជាអារម្មណ៍ ក៏យ៉ាងនោះ ដែរ កាលបើយ៉ាងនេះ ការប្រាកដ នៃការបាននូវខ្យល់ក៏មាន ការ ប្រាកដ នៃខ្យល់ដង្ហើមចេញនិងដង្ហើមចូលក៏មាន ការប្រាកដ នៃអា-នាបានស្សតិក៏មាន ការប្រាកដ នៃអានាបានស្សតិសមាធិក៏មាន បណ្ឌិត ទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិ នោះផង កាយគឺខ្យល់ដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលកាលរម្ងាប់ នូវកាយសង្ខារ ឈ្មោះជាឧបដ្ឋាន សតិ ឈ្មោះជាអនុបស្សនាញាណ

កាយោ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា ។

[១១៥] អនុបស្សតីតិ កថំ តំ កាយំ អនុ-បស្សតិ ។ បេ ។ ឯវន្តំ កាយំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បស្សម្ភយំ កាយស-ង្ខារំ អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្បញ្ញាសិក្ខា ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ ។ បេ ។

កាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលរមែងពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនា សតិប្បដ្ឋានភាវនា ។

[១១៥] សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើបុគ្គលពិចារណាឃើញនូវកាយនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញនូវកាយនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ការដកដង្ហើមចេញនិងដកដង្ហើមចូលរបស់បុគ្គលកាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថាទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថាសង្រួម ធម៌នេះឈ្មោះថាអធិសីលសិក្ខា បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថាមិនរាយមាយ ធម៌នេះឈ្មោះថាអធិចិត្តសិក្ខា បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថាឃើញ ធម៌នេះ ឈ្មោះថាអធិប្បញ្ញាសិក្ខា បុគ្គលកាលរំពឹងឃើញ នូវសិក្ខាទាំង ៣ នេះ ឈ្មោះថាសិក្សា ។ បេ ។

សច្ចិកាតព្វំ សច្ចិករោន្តោ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា ឧប្បជ្ជន្តិ ។ បេ ។ បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ ។ បេ ។ តេន វុច្ចតិ សមត្តញ្ច បដិវិជ្ឈតិ[១] អដ្ឋ អនុបស្សនេ ញាណានិ អដ្ឋ ច ឧបដ្ឋានានុបស្សតិយោ ចត្តារិ សុត្តន្តិកវត្ថូនិ កាយេ កាយានុបស្សនាយ ។

ភាណវារំ ។

[១១៦] កថំ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

១ ឱ. ម. បដិវិជ្ឈតីតិ ។

បុគ្គលកាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញនិងដង្ហើមចូល របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ វេទនាទាំងឡាយ ដែលប្រាកដ រមែងកើតឡើង ។ បេ ។ បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។ បេ ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះ នូវអត្ថនៃការស្ងប់ អនុបស្សនាញាណ ៨ ឧបដ្ឋានានុបស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ (រមែងមាន) ក្នុងកាយេកាយានុបស្សនា ។

ចប់ ភាណវារៈ ។

---

[១១៦] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់ នូវបីតិ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់ នូវបីតិ ទើបដកដង្ហើមចូល តើដូចម្តេច ។

១៨១



កតមា បីតិ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ បីតិប្បាមុជ្ជំ ។ បេ ។ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ បីតិប្បាមុជ្ជំ ។ បេ ។ រស្សំ អស្សាសវសេន រស្សំ បស្សាសវសេន សព្វកាយប្បដិសំវេទី អស្សាសវសេន សព្វកាយប្បដិសំវេទី បស្សាសវសេន បស្សម្ភយំ កាយសង្ខារំ អស្សាសវសេន បស្សម្ភយំ កាយសង្ខារំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ បីតិប្បាមុជ្ជំ យា បីតិប្បាមុជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ ចិត្តស្ស[១] ឱទគ្យំ អត្តមនតា ចិត្តស្ស អយំ បីតិ[២] បដិវិទិតា ហោតិ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន សា បីតិ បដិវិទិតា ហោតិ

១ ឱ. ម. វិត្តិ ។ ២ ឱ. ម. ឯត្ថន្តរេ កថំ សា បីតីតិ ទិស្សតិ ។

បីតិ តើដូចម្ដេច ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង បីតិនិងបាមុជ្ជៈ រមែងកើតឡើង ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង បីតិនិងបាមុជ្ជៈ រមែងកើតឡើង ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចូល របស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូល របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ បីតិនិងបាមុជ្ជៈ គឺធម្មជាតិជាគ្រឿងរីករាយ និងរីករាយខ្លាំង ការត្រេកអរ ត្រេកអរខ្លាំង ការស្រស់ស្រាយ ស្រស់ស្រាយខ្លាំង ភាពនៃចិត្តខ្ពស់ឡើង ភាពនៃចិត្តអរសប្បាយ រមែងកើតឡើង នេះឈ្មោះថាបីតិ ដែលបុគ្គលដឹងច្បាស់ហើយ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ បីតិនោះឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ

ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ ប-
ជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន
ញាណេន សា បីតិ បដិវិទិតា ហោតិ រស្សំ អស្សា-
សវសេន រស្សំ បស្សាសវសេន សព្វកាយប្បដិ-
សំវេទី អស្សាសវសេន បស្សម្ភយំ កាយសង្ខារំ
អស្សាសវសេន បស្សម្ភយំ កាយសង្ខារំ បស្សាស-
វសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ
ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន
សា បីតិ បដិវិទិតា ហោតិ អាវជ្ជតោ សា បីតិ
បដិវិទិតា ហោតិ ជានតោ... បស្សតោ បច្ចវេ-
ក្ខតោ ចិត្តំ អធិដ្ឋហតោ សទ្ធាយ អធិមុច្ចតោ វីរិយំ
បគ្គណ្ហតោ សតឹ ឧបដ្ឋាបយតោ ចិត្តំ សមាទហតោ
បញ្ញាយ បជានតោ អភិញ្ញេយ្យំ អភិជានតោ
បរិញ្ញេយ្យំ បរិជានតោ បហាតព្វំ បជហតោ
ភាវេតព្វំ ភាវយតោ សច្ឆិកាតព្វំ សច្ឆិករោតោ

កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកំណត់ដឹង នូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកាលរម្ងាប់ នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូល របស់អ្នកកាលរម្ងាប់ នូវកាយសង្ខារ សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលរំពឹង បីតិនោះ ឈ្មោះថាគេដឹងច្បាស់ហើយ កាលបុគ្គលដឹង... កាលឃើញ កាលពិចារណា កាលអធិដ្ឋាននូវចិត្ត កាលជឿស៊ប់ដោយសទ្ធា កាលផ្គងនូវវិរិយៈ កាលប្រុងទុកនូវសតិ កាលតម្កល់នូវចិត្ត កាលដឹងច្បាស់ ដោយបញ្ញា កាលត្រាស់ដឹង នូវធម៌ដែលគួរត្រាស់ដឹង កាលកំណត់ដឹង នូវធម៌ដែលគួរកំណត់ដឹង កាលលះនូវធម៌ដែលគួរលះ កាលចម្រើននូវធម៌ដែលគួរចម្រើន កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់

១៨៣



សា បីតិ បដិវិទិតា ហោតិ ឯវំ សា[១] បីតិប្បដិ-
សំវេទី អស្សាសប្បស្សាសវសេន វេទនា ឧបដ្ឋានំ
សតិ អនុបស្សនាញាណំ វេទនា ឧបដ្ឋានំ នោ
សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា
តេន ញាណេន តំ វេទនំ អនុបស្សតីតិ តេន
វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ វេទនំ អនុបស្សតីតិ
។ បេ ។ ឯវន្តំ វេទនំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវ-
នដ្ឋេន ភាវនា ។ បីតិប្បដិសំវេទី អស្សាសប្បស្សា-
សា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ បីតិប្បដិសំវេ-
ទី អស្សាសប្បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អ-
វិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ
សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

១ ឱ. ម. ឯត្ថន្តរេ បីតិប្បដិវិទិតា ហោតីតិ ទិស្សតិ ។

បីតិនោះ ឈ្មោះថាគេដឹងច្បាស់ហើយ វេទនា ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់អ្នកកំណត់ដឹងនូវបីតិនោះ ឈ្មោះថាឧបដ្ឋានសតិ ឈ្មោះថាអនុបស្សនាញាណ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង យ៉ាងនេះឯង បុគ្គលរមែងពិចារណាឃើញ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកទើបពោលថា វេទនាសុវេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើ ពិចារណាឃើញនូវវេទនានោះ ដូចម្តេច ។ បេ ។ បុគ្គលរមែងពិចារណាឃើញ នូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនាដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវបីតិ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់អ្នកកំណត់ដឹងនូវបីតិ ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលរមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១១៧] កថំ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ សុខន្តិ ទ្វេ សុខានិ កាយិកញ្ច សុខំ ចេតសិកញ្ច សុខំ ។

កតមំ កាយិកំ សុខំ ។ យំ កាយិកំ សាតំ កាយិកំ សុខំ[១] វេទយិតំ កាយសម្ផស្សជា សាតា សុខា វេទនា ឥទំ កាយិកំ សុខំ ។ កតមំ ចេតសិកំ សុខំ ។ យំ ចេតសិកំ សុខំ[២] ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ ចេតសិកំ សុខំ ។

---

១ ឱ. ម. ឯត្ថន្តរេ កាយសម្ផស្សជំ សាតំ សុខន្តិ ទិស្សតិ ។ ២ ឱ. ម. យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ។

[១១៧] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹង នូវសេចក្តីសុខ ទើបដកដង្ហើមចូល តើដូចម្តេច ។

ពាក្យថា សុខ បានដល់សុខ ២ យ៉ាង គឺ កាយិកសុខ ១ ចេតសិកសុខ ១ ។

កាយិកសុខ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសា ដែលប្រព្រឹត្តទៅក្នុងកាយ សេចក្តីសោយអារម្មណ៍ជាសុខ ដែលប្រព្រឹត្តទៅក្នុងកាយ សុខវេទនា ដ៏ឆ្ងាញ់ពិសា ដែលកើតអំពីកាយសម្ផស្ស ឯណា នេះឈ្មោះថាកាយិកសុខ ។ ចេតសិកសុខ តើដូចម្តេច ។ សេចក្តីសុខ ដែលប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោយអារម្មណ៍ជាសុខ ដ៏ឆ្ងាញ់ពិសា ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាដ៏ឆ្ងាញ់ពិសា ដែលកើតអំពីចេតោសម្ផស្ស ឯណា នេះឈ្មោះថាចេតសិកសុខ ។

កថំ តេ សុខា បដិវិទិតា ហោន្តិ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ សុខា បដិវិទិតា ហោន្តិ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ សុខា បដិវិទិតា ហោន្តិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោតោ តេ សុខា បដិវិទិតា ហោន្តិ ឯវន្តេ សុខា បដិវិទិតា ហោន្តិ សុខប្បដិសំវេទី អស្សាសបស្សាសវសេន វេទនា ឧបដ្ឋានំ សតិ អនុបស្សនា ញាណំ វេទនា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ វេទនំ អនុបស្សតិ តេន វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

សេចក្ដីសុខទាំងនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្ដេច ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ សេចក្ដីសុខទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ សេចក្ដីសុខទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។ បេ ។ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ សេចក្ដីសុខទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ សេចក្ដីសុខទាំងនុ៎ះ បុគ្គលដឹងច្បាស់ហើយ យ៉ាងនេះឯង វេទនា ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនា សតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

អនុបស្សតីតិ កថំ វេទនំ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ ។ បេ ។ ឯវន្តំ វេទនំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ សុខប្បដិសំវេទី អស្សាសបស្សាសសំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ សុខប្បដិសំវេទី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១១៨] កថំ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវវេទនា ដូចម្តេច ។ បុគ្គលពិចារណាឃើញ ថាមិនទៀង ។ បេ ។ បុគ្គលពិចារណាឃើញ នូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងនូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១១៨] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្តសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្តសង្ខារ ទើបដកដង្ហើមចូល តើដូចម្តេច ។

១៨៧



កតមោ ចិត្តសង្ខារោ ។ ទីឃំ អស្សាសវសេន សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្ត-ប្បដិពទ្ធា ចិត្តសង្ខារា ទីឃំ បស្សាសវសេន សញ្ញា ច វេទនា ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា ចិត្តសង្ខារា ។ បេ ។ សុខប្បដិសំវេទី អស្សាសវ-សេន សុខប្បដិសំវេទី បស្សាសវសេន សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា ចិត្តសង្ខារា អយំ ចិត្តសង្ខារោ ។

កថំ តេ ចិត្តសង្ខារា បដិវិទិតា ហោន្តិ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ ចិត្តសង្ខារា បដិវិទិតា ហោន្តិ

ចិត្តសង្ខារ តើដូចម្តេច ។ សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថាចិត្តសង្ខារ សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថាចិត្តសង្ខារ ។ បេ ។ សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនេះជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវសេចក្តីសុខ ដោយអំណាចនៃដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសេចក្តីសុខ ឈ្មោះថាចិត្តសង្ខារ នេះឯងឈ្មោះថាចិត្តសង្ខារ ។

ចិត្តសង្ខារទាំងនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ ចិត្តសង្ខារទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ

ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តេ ចិត្តសង្ខារា បដិវិទិតា ហោន្តិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោតោ តេ ចិត្តសង្ខារា បដិវិទិតា ហោន្តិ ឯវន្តេ ចិត្តសង្ខារា បដិវិទិតា ហោន្តិ ចិត្តសង្ខារប្បដិសំវេទី អស្សាសប្បស្សាសវសេន វេទនា ឧបដ្ឋានំ សតិ អនុបស្សនា ញាណំ វេទនា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ វេទនំ អនុបស្សតីតិ តេន វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ វេទនំ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ ។ បេ ។ ឯវន្តំ វេទនំ អនុបស្សតិ ។

កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ ចិត្តសង្ខារទាំងឡាយនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។ បេ ។ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ចិត្តសង្ខារទាំងនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ចិត្តសង្ខារទាំងនោះ បុគ្គលដឹងច្បាស់ហើយ យ៉ាងនេះឯង វេទនាដោយអំណាច នៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវវេទនានោះ ដូចម្តេច ។ បុគ្គលពិចារណាឃើញ ថាមិនទៀង ។ បេ ។ បុគ្គលពិចារណាឃើញ នូវវេទនានោះ យ៉ាងនេះឯង ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ ចិត្តសង្ខារប្បដិសំវេទី អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ ចិត្តសង្ខារប្បដិសំវេទី អស្សាសប្បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១១៩] កថំ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។

កតមោ ចិត្តសង្ខារោ ។ ទីឃំ អស្សាសវសេន សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា ចិត្តសង្ខារា តេ ចិត្តសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ ទីឃំ បស្សាសវសេន សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា ចិត្តសង្ខារា តេ ចិត្តសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថាបុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[១១៩] បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់ នូវចិត្តសង្ខារទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវចិត្តសង្ខារទើបដកដង្ហើមចូល តើដូចម្តេច ។

ចិត្តសង្ខារ តើដូចម្តេច ។ សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថាចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាប នូវចិត្តសង្ខារទាំងនោះ ឈ្មោះថាសិក្សា សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថាចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាប នូវចិត្តសង្ខារទាំងនោះ ឈ្មោះថាសិក្សា

ចិត្តសង្ខារប្បដិសំវេទី អស្សាសវសេន ចិត្តសង្ខារប្បដិសំវេទី បស្សាសវសេន សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា ចិត្តសង្ខារា តេ ចិត្តសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ អស្សាសប្បស្សាសវសេន វេទនា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ វេទនំ អនុបស្សតីតិ តេន វុច្ចតិ វេទនាសុ វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ វេទនំ អនុបស្សតិ ។ បេ ។ ឯវន្តំ វេទនំ អនុបស្សតិ ។

សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកំណត់ដឹង នូវចិត្តសង្ខារ ដោយអំណាចនៃដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹង នូវចិត្តសង្ខារ ឈ្មោះថាចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាប នូវចិត្តសង្ខារ ទាំងនោះ ឈ្មោះថាសិក្សា វេទនា ដោយអំណាចនៃដង្ហើមចេញនិង ដង្ហើមចូល របស់បុគ្គលកាលរម្ងាប់នូវចិត្តសង្ខារ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ វេទនា ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលរមែងពិចារណាឃើញ នូវវេទនានោះ ដោយ សតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុ- វេទនានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវ វេទនានោះ ដូចម្តេច ។ បេ ។ បុគ្គលរមែងពិចារណាឃើញ នូវវេទនា នោះ យ៉ាងនេះឯង ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ អដ្ឋ អនុបស្សនេ ញាណានិ អដ្ឋ ច ឧបដ្ឋានានុស្សតិយោ ចត្តារិ សុត្តន្តិកវត្ថូនិ វេទនាសុ វេទនានុបស្សនាយ ។

ភាណវារំ ។

[១២០] កថំ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលកាលរម្ងាប់នូវចិត្តសង្ខារ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលកាលរម្ងាប់ នូវចិត្តសង្ខារ ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ (រមែងមាន) ក្នុងវេទនាសុ-វេទនានុបស្សនា ។

ចប់ ភាណវារៈ ។

[១២០] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្ត ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្ត ទើបដកដង្ហើមចូល តើដូចម្ដេច ។

កាតមំ តំ ចិត្តំ ។ ជីឃំ អស្សាសវសេន វិញ្ញា-ណចិត្តំ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ជីឃំ បស្សាសវសេន ។ បេ ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សាសវសេន វិញ្ញាណ-ចិត្តំ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនា-យតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ ។

កាថំ តំ ចិត្តំ បដិវិទិតំ ហោតិ ។ ជីឃំ អ-ស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជាន-តោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន តំ ចិត្តំ បដិវិទិតំ ហោតិ ជីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជាន-តោ សតិ ឧបដ្ឋិតា ហោតិ តាយ សតិយា តេន ញាណេន ចិត្តំ បដិវិទិតំ ហោតិ ។ បេ ។

ចិត្តនោះ តើដូចម្តេច ។ ដោយអំណាចនៃដង្ហើមចេញវែង វិញ្ញាណចិត្ត បានដល់ចិត្ត ការដឹងអារម្មណ៍ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ ធម្មជាតដ៏ផូរផង់គឺភវង្គចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធ (នេះឈ្មោះថាចិត្ត) ដោយអំណាចនៃដង្ហើមចូលវែង ។ បេ ។ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលរម្ងាប់នូវចិត្តសង្ខារ វិញ្ញាណចិត្ត បានដល់ចិត្ត ការដឹងអារម្មណ៍ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ ធម្មជាតដ៏ផូរផង់គឺភវង្គចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធ នេះឈ្មោះថាចិត្ត ។

ចិត្តនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ ចិត្តនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាច នៃដង្ហើមចូលវែង សតិក៏តម្កល់មាំ ចិត្តនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។ បេ ។

សច្ឆិកាតព្វំ សច្ឆិករោតោ តំ ចិត្តំ បដិវិទិតំ ហោតិ ឯវន្តំ ចិត្តំ បដិវិទិតំ ហោតិ ចិត្តប្បដិសំវេទី អស្សាសវសេន[១] វិញ្ញាណចិត្តំ ឧបដ្ឋានំ សតិ អនុបស្សនាញាណំ ចិត្តំ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ ចិត្តំ អនុបស្សតីតិ តេន វុច្ចតិ ចិត្តេ ចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ ចិត្តំ អនុបស្សតិ ។ បេ ។ ឯវន្តំ ចិត្តំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ ចិត្តប្បដិសំវេទី អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ ចិត្តប្បដិសំវេទី អស្សាសប្បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។

---

១ ឱ. ម. អស្សាសប្បស្សាសវសេន ។

កាលបុគ្គលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ចិត្តនោះឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ចិត្តនោះ បុគ្គលដឹងច្បាស់ហើយ យ៉ាងនេះឯង វិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ឈ្មោះថាឧបដ្ឋាន សតិឈ្មោះថាអនុបស្សនាញាណចិត្ត ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញនូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវចិត្តនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវចិត្តនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាច នៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹង នូវចិត្ត ។ បេ ។

បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្តញ្ច បដិវិជ្ឈតិ ។

[១៦១] កាថំ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។

កាតមោ ច ចិត្តស្ស អភិប្បមោទោ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ ចិត្តស្ស អភិប្បមោទោ យា ចិត្តស្ស អាមោទនា បមោទនា ហាសោ បហាសោ ចិត្តស្ស ឱទគ្យំ អត្តមនតា ចិត្តស្ស ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ ចិត្តស្ស អភិប្បមោទោ យា ចិត្តស្ស អាមោទនា បមោទនា ហាសោ បហាសោ ចិត្តស្ស ឱទគ្យំ អត្តមនតា ចិត្តស្ស ។ បេ ។

បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១២១] បុគ្គលសិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរីករាយខ្លាំង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរីករាយខ្លាំង ទើបដកដង្ហើមចូល តើដូចម្តេច ។

សេចក្តីរីករាយខ្លាំងនៃចិត្ត តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សេចក្តីរីករាយខ្លាំងនៃចិត្ត បានដល់ការរីករាយទូទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយក៏កើតឡើង កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សេចក្តីរីករាយខ្លាំងនៃចិត្ត បានដល់ការរីករាយទូទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយ ក៏កើតឡើង ។ បេ ។

ចិត្តប្បដិសំវេទី អស្សាសវសេន ចិត្តប្បដិសំវេទី ប-ស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ ចិត្តស្ស អភិប្បមោទោ យោ ចិត្តស្ស អា-មោទនា បមោទនា ហាសោ បហាសោ ចិត្តស្ស ឱទគ្យំ អត្តមនតា ចិត្តស្ស អយំ ចិត្តស្ស អភិប្ប-មោទោ ។ អភិប្បមោទយំ ចិត្តំ អស្សាសប្បស្សា-សវសេន វិញ្ញាណចិត្តំ ឧបដ្ឋានំ សតិ អនុបស្ស-នាញាណំ ចិត្តំ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋា-នំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ ចិត្តំ អនុបស្សតីតិ តេន វុច្ចតិ ចិត្តេ ចិត្តានុ-បស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ ចិត្តំ អនុបស្សតិ ។ បេ ។ ឯវន្តំ ចិត្តំ អនុបស្សតិ ។

កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ដោយអំណាចនៃដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត សេចក្តីរីករាយខ្លាំងនៃចិត្ត បានដល់ការរីករាយទួទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយ ក៏កើតឡើង នេះឈ្មោះថាសេចក្តីរីករាយខ្លាំងនៃចិត្ត ។ វិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលកាលញ៉ាំងចិត្តឲ្យរីករាយខ្លាំង ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ចិត្ត ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេ-ចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវចិត្តនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវចិត្តនោះ យ៉ាងនេះឯង ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវ-

នដ្ឋេន ភាវនា ។

អភិប្បមោទយំ ចិត្តំ អស្សាសបស្សាសា សំវរ-

ដ្ឋេន សីលវិសុទ្ធិ ។ បេ ។ អភិប្បមោទយំ ចិត្តំ អ-

ស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ

បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោ-

ធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១២២] កាថំ សមាទហំ ចិត្តំ អស្សសិស្សាមីតិ

សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។

ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរីករាយខ្លាំង ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរីករាយខ្លាំង ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[១២២] បុគ្គលសិក្សាថា អាត្មាអញកាលតម្កល់ទុកនូវចិត្ត ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលតម្កល់ទុកនូវចិត្ត ទើបដកដង្ហើមចូល តើដូចម្ដេច ។

១៦៧

កតមោ សមាធិ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សមាទហំ ចិត្តំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អធិដ្ឋិតិ[១] អវិសាហារោ អវិក្ខេបោ ច អវិសាហតមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ អយំ សមាធិ សមាទហំ ចិត្តំ អស្សាសវសេន វិញ្ញាណចិត្តំ ឧបដ្ឋានំ សតិ អនុបស្សនាញាណំ ចិត្តំ ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តំ ចិត្តំ អនុបស្សតីតិ តេន វុច្ចតិ ចិត្តេ ចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តំ ចិត្តំ អនុបស្សតិ ។ បេ ។ ឯវន្តំ ចិត្តំ អនុបស្សតិ ។

---

១ ឱ. ម. អវដ្ឋិតិ ។

សមាធិ តើដូចម្តេច ។ ភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថាសមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថាសមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលតម្កល់នូវចិត្ត ឈ្មោះថាសមាធិ បានដល់ការឋិតនៅនៃចិត្ត ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ នេះឈ្មោះថាសមាធិ វិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលតម្កល់ទុកនូវចិត្ត ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ចិត្ត ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញ នូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាលឃើញ តើពិចារណាឃើញ នូវចិត្តនោះដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ សមាធឹ ចិត្តំ អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ សមាធឹ ចិត្តំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១២៣] កថំ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ រាគតោ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ រាគតោ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ទោសតោ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ ទោសតោ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ មោហតោ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ មោហតោ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលកាលតម្កល់ទុកក្នុងចិត្ត ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលតម្កល់ទុក នូវចិត្ត ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១២៣] បុគ្គលសិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួច ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួច ទើបដកដង្ហើមចូល តើដូចម្តេច ។ បុគ្គលសិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាករាគៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាករាគៈ ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាកទោសៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាកទោសៈ ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួច ចាកមោហៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាកមោហៈ ទើបដកដង្ហើមចូល ។ បេ ។

១៦៩



។ បេ ។ មានតោ វិមោចយំ ចិត្តំ ទិដ្ឋិយា វិមោចយំ ចិត្តំ វិចិកិច្ឆាយ វិមោចយំ ចិត្តំ ថីនមិទ្ធតោ វិមោចយំ ចិត្តំ ឧទ្ធច្ចតោ វិមោចយំ ចិត្តំ អហិរិកតោ វិមោចយំ ចិត្តំ អនោត្តប្បតោ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អនោត្តប្បតោ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ អស្សាសប្បស្សាសវសេន វិញ្ញាណចិត្តំ ឧបដ្ឋានំ សតិ ។ បេ ។

អនុបស្សតីតិ កថំ ចិត្តំ អនុបស្សតិ ។ បេ ។ ឯវន្តំ ចិត្តំ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ វិមោចយំ ចិត្តំ អស្សាសប្បស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។

សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួចចាកមានះ កាលញុំាងចិត្តឲ្យរួចចាកទិដ្ឋិ កាលញុំាងចិត្តឲ្យរួចចាកវិចិកិច្ឆា កាលញុំាងចិត្តឲ្យរួចចាកថីនមិទ្ធៈ កាលញុំាងចិត្តឲ្យរួចចាកឧទ្ធច្ចៈ កាលញុំាងចិត្តឲ្យរួចចាកអហិរិកៈ កាលញុំាងចិត្តឲ្យរួច ចាកអនោត្តប្បៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួច ចាកអនោត្តប្បៈ ទើបដកដង្ហើមចូល វិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរួច ឈ្មោះថាឧបដ្ឋាន ។ បេ ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវចិត្តនោះដូចម្ដេច ។ បេ ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនាដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរួច ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។

វិមោចយំ ចិត្តំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។ អដ្ឋ អនុបស្សនេ ញាណានិ អដ្ឋ ច ឧបដ្ឋានានុស្សតិយោ ចត្តារិ សុត្តន្តិកវត្ថូនិ ចិត្តេ ចិត្តានុបស្សនាយ ។

[១២៤] កថំ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

អនិច្ចន្តិ កឹ អនិច្ចំ ។ បញ្ចក្ខន្ធា អនិច្ចា ។ កេនដ្ឋេន អនិច្ចា ។ ឧប្បាទវយដ្ឋេន អនិច្ចា ។ បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ វយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ ។

កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលកាលញ៉ាំងចិត្តឲ្យរួច ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។ អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ (រមែងមាន) ក្នុងចិត្តេចិត្តានុបស្សនា ។

[១២៤] បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ ថាមិនទៀង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ ថាមិនទៀង ទើបដកដង្ហើមចូល តើដូចម្តេច ។

សំណួរត្រង់ពាក្យថា មិនទៀង តើអ្វីមិនទៀង ។ ខន្ធទាំង ៥ មិនទៀង ។ ខន្ធ ៥ មិនទៀង ដោយអត្ថ ដូចម្តេច ។ មិនទៀង ដោយអត្ថថាកើតឡើងហើយសូន្យទៅវិញ ។ បុគ្គលកាលឃើញ នូវការកើតឡើងនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈប៉ុន្មានយ៉ាង កាលឃើញនូវការសូន្យ រមែងឃើញ នូវលក្ខណៈប៉ុន្មានយ៉ាង កាលឃើញនូវការកើតឡើងនិងការសូន្យ រមែងឃើញ នូវលក្ខណៈប៉ុន្មានយ៉ាង ។

១៧១



បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ បញ្ចវីសតិ ល-
ក្ខណានិ បស្សតិ ។ បេ ។ បញ្ចន្នំ ខន្ធានំ ឧទ-
យព្វយំ បស្សន្តោ ឥមានិ បញ្ញាសំ លក្ខណានិ
បស្សតិ រូបេ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិ-
ក្ខតិ រូបេ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខ-
តិ វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ច-
ក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សី អស្ស-
សិស្សាមីតិ សិក្ខតិ ជរាមរណេ អនិច្ចានុបស្សី ប-
ស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី អស្សាសបស្ស-
ស្សាសវសេន ធម្មា ឧបដ្ឋានំ សតិ អនុបស្សនា-
ញាណំ ធម្មា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋា-
នំ ចេវ សតិ ច តាយ សតិយា តេន ញា-
ណេន តេ ធម្មេ អនុបស្សតីតិ តេន វុច្ចតិ ធម្មេសុ
ធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

បុគ្គលកាលឃើញនូវការកើតឡើងនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈ ២៥ យ៉ាង ។ បេ ។ បុគ្គលកាលឃើញនូវការកើតឡើងនិងការសូន្យនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈ ៥០ នេះឯង បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ ថាមិនទៀងក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ ថាមិនទៀងក្នុងរូប ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ ថាមិនទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារ-ណាឃើញ ថាមិនទៀងក្នុងជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំង-ឡាយ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ធម៌ទាំង-ឡាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង បុគ្គលរមែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កាថំ តេ ធម្មេ អនុបស្សតិ ។ បេ ។ ឯវន្តេ ធម្មេ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ អនិច្ចានុបស្សី អស្សាសបស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ អនិច្ចានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១២៥] កាថំ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវធម៌ទាំងនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវធម៌ទាំងនោះយ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ។ បេ ។ បុគ្គលកាលឃើញច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១២៥] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវការណាយ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវការណាយ ទើបដកដង្ហើមចូល តើដូចម្តេច ។

១៧៣



រូបេ អាទីនវំ ទិស្វា រូបវិរាគេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ រូបេ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ រូបេ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អាទីនវំ ទិស្វា ជរាមរណវិរាគេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ជរាមរណេ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ជរាមរណេ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី អស្សាសបស្សាសវសេន ធម្មា ឧបដ្ឋានំ សតិ អនុបស្សនាញាណំ ធម្មា ឧបដ្ឋានំ នោ

បុគ្គលឃើញទោសក្នុងរូបហើយ ជាអ្នកដុះឆន្ទៈ ក្នុងការណាយចាករូប មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់ស្ងួន បុគ្គលនោះសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការណាយក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវការណាយក្នុងរូប ទើបដកដង្ហើមចូល បុគ្គលឃើញទោសក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈហើយ ជាអ្នកដុះឆន្ទៈ ក្នុងការណាយ ចាកជរាមរណៈ មានចិត្តចុះស៊ប់ ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់ស្ងួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារ-ណាឃើញ នូវការណាយ ក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវការណាយ ក្នុងជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយ ឈ្មោះថាឧបដ្ឋានសតិ ឈ្មោះថាអនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថាឧបដ្ឋាន

សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញាណេន តេ ធម្មេ អនុបស្សតីតិ តេន វុច្ចតិ ធម្មេសុ ធម្មានុបស្សនា សតិបដ្ឋានភាវនា ។

អនុបស្សតីតិ កថំ តេ ធម្មេ អនុបស្សតិ ។ បេ ។ ឯវន្តេ ធម្មេ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវនា ។ វិរាគានុបស្សី អស្សាសបស្សាសសំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ វិរាគានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថាសតិផង ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលជាអ្នកពិចារណាឃើញនូវការណាយ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវធម៌ទាំងនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញនូវការណាយ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលឃើញច្បាស់ នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញនូវការណាយ ។ បេ ។ បុគ្គលកាលឃើញច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១៦៦] កថំ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ រូបេ អាទីនវំ ទិស្វា រូបនិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ រូបេ និរោធានុ-បស្សី អស្សសិស្សាមីតិ សិក្ខតិ រូបេ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វេទនាយ សញ្ញាយ ស-ង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អា-ទីនវំ ទិស្វា ជរាមរណនិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ជរាមរណេ និ-រោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ជរាមរណេ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

[១២៦] បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ ទើបដកដង្ហើមចូល តើដូចម្តេច ។ បុគ្គលឃើញទោសក្នុងរូបហើយ ជាអ្នកជុះឆន្ទៈ ក្នុងការរលត់នៃរូប មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ក្នុងរូប ទើបដកដង្ហើមចូល បុគ្គលឃើញទោស ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈហើយ ជាអ្នកជុះឆន្ទៈ ក្នុងការរលត់នៃជរាមរណៈ មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវការរលត់ក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ក្នុងជរាមរណៈ ទើបដកដង្ហើមចូល ។

[១២៧] កតិហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ កតិហាការេហិ អវិជ្ជា និរុជ្ឈតិ ។ បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ អដ្ឋហាការេហិ អវិជ្ជា និរុជ្ឈតិ ។

កតមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ ។ អនិច្ចដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ ទុក្ខដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ អនត្តដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ សន្តាបដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ វិបរិណាមដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ ឥមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ ។

កតមេហិ អដ្ឋហាការេហិ អវិជ្ជា និរុជ្ឈតិ ។ និទាននិរោធេន អវិជ្ជា និរុជ្ឈតិ សមុទយនិរោធេន អវិជ្ជា និរុជ្ឈតិ ជាតិនិរោធេន អវិជ្ជា និរុជ្ឈតិ អាហារនិរោធេន[១] អវិជ្ជា និរុជ្ឈតិ ហេតុនិរោធេន អវិជ្ជា និរុជ្ឈតិ បច្ចយនិរោធេន អវិជ្ជា និរុជ្ឈតិ

១ ឱ. ម. បភវនិរោធេន ។

[១២៧] ទោសក្នុងអវិជ្ជា ដោយអាការប៉ុន្មានយ៉ាង អវិជ្ជារលត់ ដោយអាការប៉ុន្មានយ៉ាង ។ ទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាង អវិជ្ជារលត់ ដោយអាការ ៨ យ៉ាង ។

ទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាង តើអ្វីខ្លះ ។ ទោសក្នុងអវិជ្ជា ដោយអត្ថថាមិនទៀង ១ ទោសក្នុងអវិជ្ជា ដោយអត្ថថាជាទុក្ខ ១ ទោសក្នុងអវិជ្ជា ដោយអត្ថថាជាអនត្តា ១ ទោសក្នុងអវិជ្ជា ដោយអត្ថថាក្តៅសព្វ ១ ទោសក្នុងអវិជ្ជា ដោយអត្ថថាប្រែប្រួល ១ នេះទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាង ។

អវិជ្ជារលត់ ដោយអាការ ៨ យ៉ាង តើអ្វីខ្លះ ។ អវិជ្ជារលត់ ដោយការរលត់នៃធម៌ជាគ្រឿងប្រគល់ឲ្យនូវផល ១ អវិជ្ជារលត់ ដោយការរលត់ នៃហេតុជាទីប្រជុំកើត ១ អវិជ្ជារលត់ដោយការរលត់ នៃជាតិ ១ អវិជ្ជារលត់ ដោយការរលត់នៃអាហារ ១ អវិជ្ជារលត់ ដោយការរលត់នៃហេតុ ១ អវិជ្ជារលត់ ដោយការរលត់នៃបច្ច័យ ១

ញាណុប្បាទេន អវិជ្ជា និរុជ្ឈតិ និរោធុបដ្ឋានេន អវិជ្ជា និរុជ្ឈតិ ឥមេហិ អដ្ឋហាការេហិ អវិជ្ជា និរុជ្ឈតិ ឥមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវំ ទិស្វា ឥមេហិ អដ្ឋហាការេហិ អវិជ្ជានិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ អវិជ្ជាយ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អវិជ្ជាយ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

[១២៨] កតិហាការេហិ សង្ខារេសុ អាទីនវោ ហោតិ កតិហាការេហិ សង្ខារា និរុជ្ឈន្តិ ។ បេ ។ កតិហាការេហិ វិញ្ញាណេ អាទីនវោ ហោតិ កតិហាការេហិ វិញ្ញាណំ និរុជ្ឈតិ កតិហាការេហិ នាមរូបេ អាទីនវោ ហោតិ កតិហាការេហិ នាមរូបំ និរុជ្ឈតិ កតិហាការេហិ សឡាយតនេ អាទីនវោ ហោតិ កតិហាការេហិ សឡាយតនំ និរុជ្ឈតិ

អវិជ្ជារលត់ ដោយការកើតឡើងនៃញាណ ១ អវិជ្ជារលត់ ដោយការប្រាកដនៃនិរោធធម៌ ១ នេះអវិជ្ជារលត់ ដោយអាការ ៨ យ៉ាង បុគ្គលឃើញទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាងនេះ ហើយជាអ្នកដុះឆន្ទៈក្នុងការរលត់នៃអវិជ្ជា ដោយអាការ ៨ យ៉ាងនេះ មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់នៃអវិជ្ជា ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់នៃអវិជ្ជា ទើបដកដង្ហើមចូល ។

[១២៨] ទោសក្នុងសង្ខារ ដោយអាការប៉ុន្មាន សង្ខាររលត់ដោយអាការប៉ុន្មាន ។ បេ ។ ទោសក្នុងវិញ្ញាណ ដោយអាការប៉ុន្មាន វិញ្ញាណរលត់ ដោយអាការប៉ុន្មាន ទោសក្នុងនាមរូប ដោយអាការប៉ុន្មាន នាមរូបរលត់ ដោយអាការប៉ុន្មាន ទោសក្នុងសឡាយតនៈ ដោយអាការប៉ុន្មាន សឡាយតនៈរលត់ ដោយអាការប៉ុន្មាន

កតិហាការេហិ ផស្សេ អាទីនវោ ហោតិ កតិហាការេហិ ផស្សោ និរុជ្ឈតិ កតិហាការេហិ វេទនាយ អាទីនវោ ហោតិ កតិហាការេហិ វេទនា និរុជ្ឈតិ កតិហាការេហិ តណ្ហាយ អាទីនវោ ហោតិ កតិហាការេហិ តណ្ហា និរុជ្ឈតិ កតិហាការេហិ ឧបាទានេ អាទីនវោ ហោតិ កតិហាការេហិ ឧបាទានំ និរុជ្ឈតិ កតិហាការេហិ ភវេ អាទីនវោ ហោតិ កតិហាការេហិ ភវោ និរុជ្ឈតិ កតិហាការេហិ ជាតិយា អាទីនវោ ហោតិ កតិហាការេហិ ជាតិ និរុជ្ឈតិ កតិហាការេហិ ជរាមរណេ អាទីនវោ ហោតិ កតិហាការេហិ ជរាមរណំ និរុជ្ឈតិ ។ បញ្ចហាការេហិ ជរាមរណេ អាទីនវោ ហោតិ អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ ។

ទោសក្នុងផស្សៈ ដោយអាការប៉ុន្មានយ៉ាង ផស្សៈរលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងវេទនា ដោយអាការប៉ុន្មានយ៉ាង វេទនារលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងតណ្ហា ដោយអាការប៉ុន្មានយ៉ាង តណ្ហារលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងឧបាទាន ដោយអាការប៉ុន្មានយ៉ាង ឧបាទានរលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងភព ដោយអាការប៉ុន្មានយ៉ាង ភពរលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងជាតិ ដោយអាការប៉ុន្មានយ៉ាង ជាតិរលត់ ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងជរាមរណៈ ដោយអាការប៉ុន្មានយ៉ាង ជរាមរណៈរលត់ ដោយអាការប៉ុន្មានយ៉ាង ។ ទោសក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង ជរាមរណៈរលត់ ដោយអាការ ៨ យ៉ាង ។

១៧៩



កតមេហិ បញ្ចហាការេហិ ជរាមរណេ អាទីនវោ ហោតិ ។ អនិច្ចដ្ឋេន ជរាមរណេ អាទីនវោ ហោតិ ទុក្ខដ្ឋេន អនត្តដ្ឋេន សន្តាបដ្ឋេន វិបរិណាមដ្ឋេន ជរាមរណេ អាទីនវោ ហោតិ ឥមេហិ បញ្ចហាការេហិ ជរាមរណេ អាទីនវោ ហោតិ ។

កតមេហិ អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ ។ និទាននិរោធេន ជរាមរណំ និរុជ្ឈតិ សមុទយនិរោធេន ជាតិនិរោធេន ភវនិរោធេន ហេតុនិរោធេន បច្ចយនិរោធេន ញាណុប្បាទេន និរោធុបដ្ឋានេន ជរាមរណំ និរុជ្ឈតិ ឥមេហិ អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ ឥមេហិ បញ្ចហាការេហិ ជរាមរណេ អាទីនវំ ទិស្វា ឥមេហិ អដ្ឋហាការេហិ ជរាមរណនិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ ចិត្តំ ចស្ស ស្វាធិដ្ឋិតំ ជរាមរណេ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ

ទោសក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង តើអ្វីខ្លះ ។ ទោសក្នុងជរាមរណៈ ដោយអត្ថថាមិនទៀង ១ ដោយអត្ថថាជាទុក្ខ ១ ដោយអត្ថថាជាអនត្តា ១ ដោយអត្ថថាក្តៅសព្វ ១ ទោសក្នុងជរាមរណៈ ដោយអត្ថថាប្រែប្រួល ១ នេះទោសក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង ។

ជរាមរណៈរលត់ ដោយអាការ ៨ យ៉ាង តើអ្វីខ្លះ ។ ជរាមរណៈរលត់ ដោយការរលត់ នៃហេតុជាគ្រឿងប្រគល់ឲ្យនូវផល ១ ដោយការរលត់ នៃហេតុជាទីប្រជុំកើត ១ ដោយការរលត់នៃជាតិ ១ ដោយការរលត់ នៃភព ១ ដោយការរលត់ នៃហេតុ ១ ដោយការរលត់ នៃបច្ច័យ ១ ដោយការកើតឡើង នៃញាណ ១ ជរាមរណៈរលត់ ដោយការប្រាកដ នៃនិរោធធម៌ ១ នេះជរាមរណៈ រលត់ ដោយអាការ ៨ យ៉ាង ។ បុគ្គលឃើញទោស ក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង ហើយជាអ្នកដុះឆន្ទៈ ក្នុងការរលត់ នៃជរាមរណៈ ដោយអាការ ៨ យ៉ាង ជាអ្នកមានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ជរាមរណៈ ទើបដកដង្ហើមចេញ

ផាមរណេ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខ-តិ និរោធានុបស្សី អស្សាសបស្សាសវសេន ធម្មា ឧបដ្ឋានំ សតិ អនុបស្សនាញាណំ ធម្មា ឧបដ្ឋានំ នោ សតិ សតិ ឧបដ្ឋានំ ចេវ សតិ ច តាយ សតិ-យា តេន ញាណេន តេ ធម្មេ អនុបស្សតីតិ តេន វុច្ចតិ ធម្មេសុ ធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កថង្គ ធម្មេ អនុបស្សតិ ។ បេ ។ ឯវង្គ ធម្មេ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា ។ បេ ។ អា-សេវនដ្ឋេន ភាវនា ។ និរោធានុបស្សី អស្សា-សបស្សាសា សំវរដ្ឋេន សីលវិសុទ្ធិ ។ បេ ។ និរោធានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។

សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលត់ដកពាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញនូវការរលត់ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវធម៌ទាំងនោះ ដូចម្តេច ។ បេ ។ បុគ្គលពិចារណាឃើញ នូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលត់ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។ បេ ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញនូវការរលត់ ។ បេ ។

បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ ។

[១២៩] កាចំ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ទ្វេ បដិនិស្សគ្គា[1] បរិច្ចាគប្បដិនិស្សគ្គោ ច បក្ខន្ទនប្បដិនិស្សគ្គោ ច ។ រូបំ បរិច្ចជតីតិ បរិច្ចាគប្បដិនិស្សគ្គោ រូបនិរោធេ និព្វានេ ចិត្តំ បក្ខន្ទតីតិ បក្ខន្ទនប្បដិនិស្សគ្គោ ។ រូបេ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ រូបេ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ចក្ខុំ ។ បេ ។

---

១ ឱ. ម. បដិនិស្សគ្គាតិ ទ្វេ បដិនិស្សគ្គា ។

បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមក នូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

[១២៩] បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលាស់ចេញ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញនូវការរលាស់ចេញ ទើបដកដង្ហើមចូល តើដូចម្តេច ។ ការរលាស់ចេញ មាន ២ យ៉ាងគឺ ការរលាស់ចេញគឺការលះបង់ (បរិច្ចាគប្បដិនិស្សគ្គៈ) ១ ការរលាស់ចេញគឺការស្ទុះទៅ (បក្ខន្ទនប្បដិនិស្សគ្គៈ) ១ ។ ធម៌ណា លះស្រឡះនូវរូប ធម៌នោះ ឈ្មោះថា ការរលាស់ចេញគឺការលះបង់ ចិត្តស្ទុះទៅក្នុងព្រះនិព្វាន ជាទីរលត់នៃរូប ឈ្មោះថាការរលាស់ចេញគឺការស្ទុះទៅ ។ បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញនូវការរលាស់រូបចេញ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលាស់រូបចេញ ទើបដកដង្ហើមចូល ធម៌ណា លះស្រឡះនូវវេទនា នូវសញ្ញា នូវសង្ខារ នូវវិញ្ញាណ នូវចក្ខុ ។ បេ ។

ឥរាមរណំ បរិច្ចជតីតិ បរិច្ចាគប្បដិនិស្សគ្គោ ជរាម-
រណោនិរោធេ និព្វានេ ចិត្តំ បក្ខន្ទតីតិ បក្ខន្ទនប្ប-
ដិនិស្សគ្គោ ។ ជរាមរណេ បដិនិស្សគ្គានុបស្សី អ-
ស្សសិស្សាមីតិ សិក្ខតិ ជរាមរណេ បដិនិស្សគ្គានុ-
បស្សី បស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី
អស្សាសប្បស្សាសវសេន ធម្មា ឧបដ្ឋានំ សតិ
អនុបស្សនាញាណំ ធម្មា ឧបដ្ឋានំ នោ សតិ សតិ
ឧបដ្ឋានំ ចេវ សតិ ច តាយ សតិយា តេន ញា-
ណេន តេ ធម្មេ អនុបស្សតីតិ តេន វុច្ចតិ ធម្មេសុ
ធម្មានុបស្សនា សតិប្បដ្ឋានភាវនា ។

នូវជរាមរណៈ ធម៌នោះ ឈ្មោះថាការរលាស់ចេញគឺការលះបង់ ចិត្តស្ទុះទៅក្នុងព្រះនិព្វាន ជាទីរលត់នៃជរាមរណៈ ឈ្មោះថាការរលាស់ចេញគឺការស្ទុះទៅ ។ បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញ នូវការរលាស់ជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចា-រណាឃើញ នូវការរលាស់ជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ធម៌ទាំងឡាយឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ បុគ្គលពិចារណាឃើញ នូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋានភាវនា ។

អនុបស្សតីតិ កាចន្តេ ធម្មេ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ។ បេ ។ បដិ-និស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ។ បេ ។ បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ឯវន្តេ ធម្មេ អនុបស្សតិ ។

ភាវនាតិ ចតស្សោ ភាវនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ។ បេ ។ អាសេវនដ្ឋេន ភាវ-នា ។ បដិនិស្សគ្គានុបស្សី អស្សាសបស្សាសា សំ-វរដ្ឋេន សីលវិសុទ្ធិ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ ទស្សន-ដ្ឋេន ទិដ្ឋិវិសុទ្ធិ យោ តត្ថ សំវរដ្ឋោ អយំ អធិសីល-សិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ នូវធម៌ទាំងនោះ ដូចម្ដេច ។ បុគ្គលពិចារណាឃើញ ថាមិនទៀង មិនមែនថាទៀងទេ ។ បេ ។ រលាស់ចេញ មិនមែនកាន់យកទេ បុគ្គលកាលពិចារណាឃើញ ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា (ការសម្គាល់ថាទៀង) ។ បេ ។ បុគ្គលកាលរលាស់ចេញ ឈ្មោះថាលះបង់ នូវសេចក្ដីប្រកាន់ បុគ្គលពិចារណាឃើញ នូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ភាវនា ៤ យ៉ាង ឈ្មោះថាភាវនាដោយអត្ថថាមិនកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ។ បេ ។ ឈ្មោះថាភាវនា ដោយអត្ថថាសេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ ឈ្មោះថាសីលវិសុទ្ធិ ដោយអត្ថថាសង្រួម ឈ្មោះថាចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ឈ្មោះថាទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ អត្ថថាសង្រួម ក្នុងធម៌នោះ ឯណា នេះ ឈ្មោះថាអធិសីលសិក្ខា អត្ថថាមិនរាយមាយ ក្នុងធម៌នោះ ឯណា នេះ ឈ្មោះថាអធិចិត្តសិក្ខា

យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្បញ្ញាសិក្ខា ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ ជានន្តោ សិក្ខតិ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ បដិនិស្សគ្គានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។ បេ ។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ គោចរញ្ច បជានាតិ សមត្ថញ្ច បដិវិជ្ឈតិ ពលានិ សមោធានេតិ ពោជ្ឈង្គេ សមោធានេតិ មគ្គំ សមោធានេតិ ធម្មេ សមោធានេតិ គោចរញ្ច បជានាតិ សមត្ថញ្ច បដិវិជ្ឈតិ ។

អត្ថថាឃើញក្នុងធម៌នោះ ឯណា នេះ ឈ្មោះថាអធិប្បញ្ញាសិក្ខា បុគ្គល កាលរំពឹងឃើញ នូវសិក្ខាទាំង ៣ នេះ ឈ្មោះថាសិក្សា កាលដឹង ឈ្មោះថាសិក្សា ។ បេ ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យ ជាក់ច្បាស់ ឈ្មោះថាសិក្សា កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមាន អារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញនិង ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ វេទនា ដ៏ប្រាកដ រមែងកើតឡើង វេទនាដ៏ប្រាកដ រមែងតាំងឡើង វេទនា ដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស ។ បេ ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាច នៃដង្ហើមចេញនិងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការ រលាស់ចេញ ។ បេ ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថាប្រមូលមកនូវ ឥន្ទ្រិយទាំងឡាយ ឈ្មោះថាដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថ នៃ ការស្ងប់ផង បុគ្គលប្រមូលមកនូវពលៈ ប្រមូលមកនូវពោជ្ឈង្គ ប្រមូល មកនូវមគ្គ ប្រមូលមកនូវធម៌ ឈ្មោះថាដឹងច្បាស់នូវគោចរផង ចាក់ ធ្លុះនូវអត្ថ នៃការស្ងប់ផង ។

ឥន្ទ្រិយានិ សមោធានេតីតិ កថំ ឥន្ទ្រិយានិ សមោធានេតិ ។ អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ សមោធានេតិ ។ បេ ។ តេន វុច្ចតិ សមត្ថញ្ច បដិវិជ្ឈតិ អដ្ឋ អនុបស្សនេ ញាណានិ អដ្ឋ ច ឧបដ្ឋានានុស្សតិយោ[១] ចត្តារិ សុត្តន្តិកវត្ថូនិ ធម្មេសុ ធម្មានុបស្សនាយ ឥមានិ ពត្តឹសំ សតោការីសុ ញាណានិ ។

[១៣០] កតមានិ ចតុវីសតិ សមាធិវសេន ញាណានិ ។ ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ បេ ។ វិមោចយំ ចិត្តំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ឥមានិ ចតុវីសតិ សមាធិវសេន ញាណានិ ។

១ ម. ឧបដ្ឋានានុបស្សតិយោ ។

សំណួរត្រង់ពាក្យថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ តើប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដូចម្តេច ។ បុគ្គលប្រមូលមកនូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ។ បេ ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ (រមែងមាន) ក្នុងធម្មេសុធម្មានុបស្សនា ទាំងនេះ ឈ្មោះថាសតោការីញាណ ៣២ ប្រការ ។

[១៣០] ញាណ ២៤ ដោយអំណាចនៃសមាធិ តើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថាសមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថាសមាធិ ។ បេ ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលញុំាងចិត្តឲ្យរួច (ចាកកិលេស) ឈ្មោះថាសមាធិ នេះញាណ ២៤ ដោយអំណាចនៃសមាធិ ។

កតមានិ ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ ។ ជីយំ អស្សាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុ-បស្សនដ្ឋេន វិបស្សនា ជីយំ បស្សាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ បេ ។ វិមោចយំ ចិត្តំ អស្សាសំ វិមោចយំ ចិត្តំ បស្សាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ឥមានិ ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ ។

ញាណ ៧២ ប្រការ ដោយអំណាចនៃវិបស្សនា តើដូចម្តេចខ្លះ ។ ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាអនត្តា នូវខ្យល់ដង្ហើមចេញវែង ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាអនត្តា នូវខ្យល់ដង្ហើមចូលវែង ។ បេ ។ ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាមិនទៀង ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាទុក្ខ ឈ្មោះថាវិបស្សនា ដោយអត្ថថាពិចារណាឃើញ ថាជាអនត្តា នូវខ្យល់ដង្ហើមចេញ របស់បុគ្គលកាលញុំាងចិត្តឲ្យរួច នូវខ្យល់ដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរួច នេះញាណ ៧២ ប្រការ ដោយអំណាចនៃវិបស្សនា ។

១៨៧



កតមានិ អដ្ឋ និព្វិទាញាណានិ ។ អនិច្ចានុបស្សី អស្សាសំ យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណំ អនិច្ចានុបស្សី បស្សាសំ យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណំ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសំ យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណំ បដិនិស្សគ្គានុបស្សី បស្សាសំ យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណំ ឥមានិ អដ្ឋ និព្វិទាញាណានិ ។

កតមានិ អដ្ឋ និព្វិទានុលោមេ ញាណានិ ។ អនិច្ចានុបស្សី អស្សាសំ ភយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ អនិច្ចានុបស្សី បស្សាសំ ភយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ ។ បេ ។

និព្វិទាញាណ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ឈ្មោះថានិព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិត នូវខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញថាមិនទៀង ១ ឈ្មោះថានិព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិត នូវខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញថាមិនទៀង ១ ។ បេ ។ ឈ្មោះថានិព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិត នូវខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញនូវការរលាស់ចេញ ១ ឈ្មោះថានិព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិត នូវខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ ១ នេះ និព្វិទាញាណ ៨ យ៉ាង ។

និព្វិទានុលោមញ្ញាណ ៨ យ៉ាង តើដូចម្តេចខ្លះ ។ បញ្ញាក្នុងការប្រាកដថាគួរភ័យ ចំពោះខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ឈ្មោះថានិព្វិទានុលោមញ្ញាណ ១ បញ្ញាក្នុងការប្រាកដថាគួរភ័យ ចំពោះខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ឈ្មោះថានិព្វិទានុលោមញ្ញាណ ១ ។ បេ ។

បដិនិស្សគ្គានុបស្សី អស្សាសំ ភយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ បដិនិស្សគ្គានុបស្សី បស្សា-សំ ភយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ ឥមានិ អដ្ឋ និព្វិទានុលោមេ ញាណានិ ។

កាតមានិ អដ្ឋ និព្វិទាបដិប្បស្សទ្ធិញ្ញាណានិ ។ អនិច្ចានុបស្សី អស្សាសំ បដិសង្ខា សន្តិដ្ឋនា បញ្ញា និព្វិទាបដិប្បស្សទ្ធិញ្ញាណំ អនិច្ចានុបស្សី បស្សាសំ បដិសង្ខា សន្តិដ្ឋនា បញ្ញា និព្វិទាបដិប្បស្សទ្ធិញ្ញាណំ ។ បេ ។ ឥមានិ អដ្ឋ និព្វិទាបដិប្បស្សទ្ធិញ្ញាណានិ ។

កាតមានិ ឯកវីសតិ វិមុត្តិសុខេ ញាណានិ ។ សោតាបត្តិមគ្គេន សក្កាយទិដ្ឋិយា បហីនត្តា សមុ-ច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ វិចិកិច្ឆាយ បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ

បញ្ញាក្នុងការប្រាកដជាគួរភ័យ ចំពោះខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ ឈ្មោះថានិព្វិទានុលោមញ្ញាណ ១ បញ្ញាក្នុងការប្រាកដជាគួរភ័យ ចំពោះខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ នូវការរលាស់ចេញ ឈ្មោះថានិព្វិទានុលោមញ្ញាណ ១ នេះនិព្វិទានុលោមញ្ញាណ ៨ យ៉ាង ។

និព្វិទាបដិប្បស្សទ្ធិញ្ញាណស្ងប់ (ការដឹងក្នុងការនឿយណាយនិងការរម្ងាប់) ៨ យ៉ាង តើដូចម្តេចខ្លះ ។ បញ្ញា គឺការពិចារណា និងការរំពឹង នូវខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ឈ្មោះថានិព្វិទាបដិប្បស្សទ្ធិញ្ញាណ ១ បញ្ញា គឺការពិចារណា និងការរំពឹង នូវខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញ ថាមិនទៀង ឈ្មោះថានិព្វិទាបដិប្បស្សទ្ធិញ្ញាណ ១ ។ បេ ។ នេះនិព្វិទាបដិប្បស្សទ្ធិញ្ញាណ ៨ យ៉ាង ។

វិមុត្តិសុខញ្ញាណ ២១ តើដូចម្តេចខ្លះ ។ ញាណ កើតឡើងព្រោះភាពនៃសក្កាយទិដ្ឋិ ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយសោតាបត្តិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើងព្រោះភាពនៃវិចិកិច្ឆា ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយសោតាបត្តិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង

សីលព្វតបរាមាសស្ស ទិដ្ឋានុសយស្ស វិចិកិច្ឆានុស-
យស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ
ញាណំ សកទាគាមិមគ្គេន ឱឡារិកស្ស កាមរាគ-
សញ្ញោជនស្ស បដិឃសញ្ញោជនស្ស ឱឡារិកស្ស
កាមរាគានុសយស្ស បដិឃានុសយស្ស បហីនត្តា
សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ អនាគាមិ-
មគ្គេន អណុសហគតស្ស កាមរាគសញ្ញោជនស្ស
បដិឃសញ្ញោជនស្ស អណុសហគតស្ស កាមរាគា-
នុសយស្ស បដិឃានុសយស្ស បហីនត្តា សមុច្ឆិន្ន-
ត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ អរហត្តមគ្គេន រូប-
រាគស្ស អរូបរាគស្ស មានស្ស ឧទ្ធច្ចស្ស អវិជ្ជាយ
មានានុសយស្ស ច ភវរាគានុសយស្ស អវិជ្ជានុស-
យស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ
ញាណំ ឥមានិ ឯកវីសតិ វិមុត្តិសុខេ ញាណានិ
សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ
ទ្វេ ញាណសតានិ ឧប្បជ្ជន្តិ ។

អានាបានកថា សមត្តា ។

---

ព្រោះភាពនៃសីលព្វតបរាមាសៈ នៃទិដ្ឋានុស័យ នៃវិចិកិច្ឆានុស័យ ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយ ដោយសោតាបត្តិមគ្គ ឈ្មោះថាវិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃកាមរាគសញ្ញោជនៈ នៃបដិឃសញ្ញោជនៈ ជាកិលេសដ៏គ្រោតគ្រាត នៃកាមរាគានុស័យ នៃបដិឃានុស័យ ជាកិលេសដ៏គ្រោតគ្រាត ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយ ដោយសកទាគាមិមគ្គ ឈ្មោះថាវិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃកាមរាគសញ្ញោជនៈ នៃបដិឃសញ្ញោជនៈ ជាកិលេសដ៏ល្អិត នៃកាមរាគានុស័យ នៃបដិឃានុស័យ ជាកិលេសដ៏ល្អិត ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយ ដោយអនាគាមិមគ្គ ឈ្មោះថាវិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃរូបរាគៈ នៃអរូបរាគៈ នៃមានះ នៃឧទ្ធច្ចៈ នៃអវិជ្ជា នៃមានានុស័យ នៃភវរាគានុស័យ នៃអវិជ្ជា-នុស័យ ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយ ដោយអរហត្តមគ្គ ឈ្មោះថាវិមុត្តិសុខញ្ញាណ នេះវិមុត្តិសុខញ្ញាណ ២១ កាលបុគ្គលចម្រើននូវអានាបានស្សតិសមាធិ មានវត្ថុ ១៦ ញាណ ២២០ នេះ រមែងកើតឡើង ។

ចប់ អានាបានកថា ។

# មហាវគ្គេ ឥន្ទ្រិយកថា

[១៣១] ឯវម្មេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមា-និ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមា-ធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិ-យានិ ។

[១៣២] ឥមានិ បញ្ចិន្ទ្រិយានិ កតិហាការេហិ វិសុជ្ឈន្តិ ។ ឥមានិ បញ្ចិន្ទ្រិយានិ បណ្ណរសហិ អាការេហិ វិសុជ្ឈន្តិ អស្សទ្ធេ បុគ្គលេ បរិវជ្ជ-យតោ សទ្ធេ បុគ្គលេ សេវតោ ភជតោ បយិរុ-បាសតោ បាសាទនីយេ សុត្តន្តេ បច្ចវេក្ខតោ

# មហាវគ្គ ឥន្ទ្រិយកថា

[១៣១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះ មាន ៥ ។ ឥន្ទ្រិយទាំង ៥ តើអ្វីខ្លះ ។ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះ ឥន្ទ្រិយ ៥ យ៉ាង ។

[១៣២] ឥន្ទ្រិយទាំង ៥ នេះ បរិសុទ្ធ ដោយអាការប៉ុន្មាន ។ ឥន្ទ្រិយទាំង ៥ នេះ បរិសុទ្ធ ដោយអាការ ១៥ ដូច្នេះ សទ្ធិន្ទ្រិយ បរិសុទ្ធ ដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលឥតសទ្ធា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានសទ្ធា ១ ពិចារណាព្រះសូត្រដែលជាទីជ្រះថ្លា ១

ឥមេហិ តីហាការេហិ សទ្ធិន្ទ្រិយំ វិសុជ្ឈតិ កុសីតេ បុគ្គលេ បរិវជ្ជយតោ អារទ្ធវីរិយេ បុគ្គលេ សេវតោ ភជតោ បយិរុបាសតោ សម្មប្បធានេ បច្ចវេក្ខតោ ឥមេហិ តីហាការេហិ វីរិយិន្ទ្រិយំ វិសុជ្ឈតិ មុដ្ឋស្សតី បុគ្គលេ បរិវជ្ជយតោ ឧបដ្ឋិតស្សតី បុគ្គលេ សេវតោ ភជតោ បយិរុបាសតោ សតិប្បដ្ឋានេ បច្ចវេក្ខតោ ឥមេហិ តីហាការេហិ សតិន្ទ្រិយំ វិសុជ្ឈតិ អសមាហិតេ បុគ្គលេ បរិវជ្ជយតោ សមាហិតេ បុគ្គលេ សេវតោ ភជតោ បយិរុបាសតោ ឈានវិមោក្ខេ បច្ចវេក្ខតោ ឥមេហិ តីហាការេហិ សមាធិន្ទ្រិយំ វិសុជ្ឈតិ ទុប្បញ្ញេ បុគ្គលេ បរិវជ្ជយតោ បញ្ញវន្តេ បុគ្គលេ សេវតោ ភជតោ បយិរុបាសតោ គម្ភីរញាណចរិយំ បច្ចវេក្ខតោ ឥមេហិ តីហាការេហិ បញ្ញិន្ទ្រិយំ វិសុជ្ឈតិ ឥមេហិ បញ្ច បុគ្គលេ បរិវជ្ជយតោ បញ្ច បុគ្គលេ សេវតោ ភជតោ បយិរុបាសតោ បញ្ច សុត្តន្តក្ខន្ធេ បច្ចវេក្ខតោ ឥមេហិ បណ្ណរសហិ អាការេហិ ឥមានិ បញ្ចិន្ទ្រិយានិ វិសុជ្ឈន្តិ ។

វីរិយិន្ទ្រិយ បរិសុទ្ធ ដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលខ្ជិលច្រអូស ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានសេចក្ដីព្យាយាម ១ ពិចារណាសម្មប្បធាន ១ សតិន្ទ្រិយ បរិសុទ្ធ ដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលភ្លេចស្មារតី ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានស្មារតីតម្កល់មាំ ១ ពិចារណាសតិប្បដ្ឋាន ១ សមាធិន្ទ្រិយបរិសុទ្ធ ដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលមានចិត្តមិននឹងធឹង ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តនឹងធឹង ១ ពិចារណាឈាននិងវិមោក្ខ ១ បញ្ញិន្ទ្រិយ បរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលអាប់ឥតបញ្ញា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រៅ ១ នេះឯង ឥន្ទ្រិយទាំង ៥ បរិសុទ្ធ ដោយអាការ ១៥ នេះ គឺបុគ្គលវៀរបុគ្គល ៥ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ៥ ពិចារណាក្នុងព្រះសូត្រ ៥ ដូចពោលមកនេះឯង ។

[១៣៣] កតិហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ ភាវនា ហោតិ ។

ទសហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ ទសហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ ភាវនា ហោតិ អស្សទ្ធិយំ បជហតោ សទ្ធិន្ទ្រិយំ ភាវេតិ សទ្ធិន្ទ្រិយំ ភាវេតោ អស្សទ្ធិយំ បជហតិ កោសជ្ជំ បជហតោ វីរិយិន្ទ្រិយំ ភាវេតិ វីរិយិន្ទ្រិយំ ភាវេតោ កោសជ្ជំ បជហតិ បមាទំ បជហតោ សតិន្ទ្រិយំ ភាវេតិ សតិន្ទ្រិយំ ភាវេតោ បមាទំ បជហតិ ឧទ្ធច្ចំ បជហតោ សមាធិន្ទ្រិយំ ភាវេតិ សមាធិន្ទ្រិយំ ភាវេតោ ឧទ្ធច្ចំ បជហតិ អវិជ្ជំ បជហតោ បញ្ញិន្ទ្រិយំ ភាវេតិ បញ្ញិន្ទ្រិយំ ភាវេតោ អវិជ្ជំ បជហតិ ឥមេហិ ទសហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ ឥមេហិ ទសហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ ភាវនា ហោតិ ។

[១៣៣] ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ដោយអាការប៉ុន្មានយ៉ាង ការចម្រើននៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ។

ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ដោយអាការៈ ១០ យ៉ាង ការចម្រើននៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ១០ យ៉ាងដែរ គឺបុគ្គលកាលលះនូវអស្សទ្ធិយៈ (ការណ៍មិនគួរជឿ) ឈ្មោះថាចម្រើនសទ្ធិន្ទ្រិយ ១ កាលចម្រើននូវសទ្ធិន្ទ្រិយ ឈ្មោះថាលះអស្សទ្ធិយៈ ១ កាលលះនូវសេចក្តីខ្ជិលច្រអូស ឈ្មោះថាចម្រើនវិរិយិន្ទ្រិយ ១ កាលចម្រើនវិរិយិន្ទ្រិយ ឈ្មោះថាលះសេចក្តីខ្ជិលច្រអូស ១ កាលលះនូវសេចក្តីប្រមាទ ឈ្មោះថាចម្រើនសតិន្ទ្រិយ ១ កាលចម្រើនសតិន្ទ្រិយ ឈ្មោះថាលះសេចក្តីប្រមាទ ១ កាលលះនូវសេចក្តីរាយមាយ ឈ្មោះថាចម្រើនសមាធិន្ទ្រិយ ១ កាលចម្រើនសមាធិន្ទ្រិយ ឈ្មោះថាលះសេចក្តីរាយមាយ ១ កាលលះអវិជ្ជា ឈ្មោះថាចម្រើនបញ្ញិន្ទ្រិយ ១ កាលចម្រើនបញ្ញិន្ទ្រិយ ឈ្មោះថាលះអវិជ្ជា ១ នេះឯងឥន្ទ្រិយទាំង ៥ ដែលបុគ្គលចម្រើនដោយអាការ ១០ យ៉ាង នេះឯង ការចម្រើន នៃឥន្ទ្រិយទាំង ៥ ដោយអាការ ១០ យ៉ាង ។

[១៣៤] កតិហាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ ។ ទសហាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ ។ អស្សទ្ធិយស្ស បហីនត្តា សុប្បហីនត្តា សទ្ធិន្ទ្រិយំ ភាវិតំ ហោតិ សុភាវិតំ សទ្ធិន្ទ្រិយស្ស ភាវិតត្តា សុភាវិតត្តា អស្សទ្ធិយំ បហីនំ ហោតិ សុប្បហីនំ កោសជ្ជស្ស បហីនត្តា សុប្បហីនត្តា វីរិយិន្ទ្រិយំ ភាវិតំ ហោតិ សុភាវិតំ វីរិយិន្ទ្រិយស្ស ភាវិតត្តា សុភាវិតត្តា កោសជ្ជំ បហីនំ ហោតិ សុប្បហីនំ បមាទស្ស បហីនត្តា សុប្បហីនត្តា សតិន្ទ្រិយំ ភាវិតំ ហោតិ សុភាវិតំ សតិន្ទ្រិយស្ស ភាវិតត្តា សុភាវិតត្តា បមាទោ បហីនោ ហោតិ សុប្បហីនោ ឧទ្ធច្ចស្ស បហីនត្តា សុប្បហីនត្តា សមាធិន្ទ្រិយំ ភាវិតំ ហោតិ សុភាវិតំ សមាធិន្ទ្រិយស្ស ភាវិតត្តា សុភាវិតត្តា ឧទ្ធច្ចំ បហីនំ ហោតិ សុប្បហីនំ អវិជ្ជាយ បហីនត្តា សុប្បហីនត្តា បញ្ញិន្ទ្រិយំ ភាវិតំ ហោតិ សុភាវិតំ

[១៣៤] ឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការប៉ុន្មានយ៉ាង ។ ឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការ ១០ យ៉ាង គឺសទ្ធិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវអស្សទ្ធិយៈ ១ អស្សទ្ធិយៈ បុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវសេចក្តីខ្ជិលច្រអូស ១ សេចក្តីខ្ជិលច្រអូស បុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវវីរិយិន្ទ្រិយ ១ សតិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវសេចក្តីប្រមាទ ១ សេចក្តីប្រមាទដែលបុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវសតិន្ទ្រិយ ១ សមាធិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវឧទ្ធច្ចៈ ១ ឧទ្ធច្ចៈ បុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវសមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយនូវអវិជ្ជា ១

បញ្ញិន្ទ្រិយស្ស ភាវិតត្តា សុភាវិតត្តា អវិជ្ជា បហីនា ហោតិ សុប្បហីនា ឥមេហិ ឆសហិ អាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ ។

[១៣៩] កតិហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ កតិហាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច ។ ចតូហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ ចតូហាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច សោតាបត្តិមគ្គក្ខណេ បញ្ចិន្ទ្រិយានិ ភាវិយន្តិ សោតាបត្តិផលក្ខណេ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច សកទាគាមិមគ្គក្ខណេ បញ្ចិន្ទ្រិយានិ ភាវិយន្តិ សកទាគាមិផលក្ខណេ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ

អវិជ្ជា បុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវបញ្ញិន្ទ្រិយ ១ នេះ ឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការ ១០ យ៉ាង ។

[១៣៥] ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ដោយអាការប៉ុន្មានយ៉ាង ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ដោយអាការប៉ុន្មានយ៉ាង ។ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ដោយអាការ ៤ យ៉ាង ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក៏ដោយអាការ ៤ យ៉ាងដែរ គឺឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ក្នុងខណៈនៃសោតាបត្តិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក្នុងខណៈនៃសោតាបត្តិផល ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ក្នុងខណៈនៃសកទាគាមិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក្នុងខណៈនៃសកទាគាមិផល ឥន្ទ្រិយទាំង ៥

ច អនាគាមិមគ្គក្ខណេ បញ្ចិន្ទ្រិយានិ ភាវិយន្តិ អនាគាមិផលក្ខណេ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្ប-ដិប្បស្សទ្ធានិ ច អរហត្តមគ្គក្ខណេ បញ្ចិន្ទ្រិយានិ ភាវិយន្តិ អរហត្តផលក្ខណេ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច ។

ឥតិ ចតស្សោ មគ្គវិសុទ្ធិយោ ចតស្សោ ផល-វិសុទ្ធិយោ ចតស្សោ សមុច្ឆេទវិសុទ្ធិយោ ចតស្សោ បដិប្បស្សទ្ធិវិសុទ្ធិយោ ឥមេហិ ចតូហាការេហិ បញ្ចិន្ទ្រិយានិ ភាវិយន្តិ ឥមេហិ ចតូហាការេហិ បញ្ចិន្ទ្រិយានិ ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច ។

[១៣៦] កតិនំ[១] បុគ្គលានំ ឥន្ទ្រិយភាវនា កតិ បុគ្គលា ភាវិតិន្ទ្រិយា ។ អដ្ឋន្នំ បុគ្គលានំ ឥន្ទ្រិយភាវនា តយោ បុគ្គលា ភាវិតិន្ទ្រិយា ។

១ ឱ. កតិន្នំ ។

បុគ្គលចម្រើន ក្នុងខណៈនៃអនាគាមិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក្នុងខណៈនៃអនាគាមិផល ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនក្នុងខណៈនៃអរហត្តមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក្នុងខណៈនៃអរហត្តផល ។

មគ្គវិសុទ្ធិ ៤ យ៉ាង ផលវិសុទ្ធិ ៤ យ៉ាង សមុច្ឆេទវិសុទ្ធិ ៤ យ៉ាង បដិប្បស្សទ្ធិវិសុទ្ធិ ៤ យ៉ាង ដោយប្រការដូច្នេះ នេះឯង ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើន ដោយអាការ ៤ យ៉ាង នេះឯងឥន្ទ្រិយទាំង ៥ ដែលបុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ដោយអាការ ៤ យ៉ាង ។

[១៣៦] បុគ្គលប៉ុន្មានពួក កំពុងមានការអប់រំឥន្ទ្រិយ បុគ្គលប៉ុន្មានពួក មានឥន្ទ្រិយអប់រំហើយ ។ បុគ្គល ៨ ពួក កំពុងមានការអប់រំឥន្ទ្រិយ បុគ្គល ៣ ពួក មានឥន្ទ្រិយអប់រំហើយ ។

កតមេសំ អជ្ឈត្តំ បុគ្គលានំ ឥន្ទ្រិយភាវនា ។ សត្តន្នញ្ច សេក្ខានំ បុថុជ្ជនកល្យាណកស្ស ច ឥមេសំ អជ្ឈត្តំ បុគ្គលានំ ឥន្ទ្រិយភាវនា ។ កតមេ តយោ បុគ្គលា ។ ភាវិតិន្ទ្រិយវសេន ពុទ្ធោតិ តថាគតស្សាវកោ[១] ខីណាសវោ ភាវិតិន្ទ្រិយោ សយម្ភូតដ្ឋេន បច្ចេកពុទ្ធោ ភាវិតិន្ទ្រិយោ អប្បមេយ្យដ្ឋេន តថាគតោ អរហំ សម្មាសម្ពុទ្ធោ ភាវិតិន្ទ្រិយោ ឥមេ តយោ បុគ្គលា ភាវិតិន្ទ្រិយា ឥតិ ឥមេសំ អជ្ឈត្តំ បុគ្គលានំ ឥន្ទ្រិយភាវនា ឥមេ តយោ បុគ្គលា ភាវិតិន្ទ្រិយា ។

## សាវត្ថីនិទានំ

[១៣៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ កតមានិ បញ្ច សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ

១ ឱ. ម. ភាវិតិន្ទ្រិយា សវនេន ពុទ្ធោ តថាគតស្ស សាវកោ ។

បុគ្គល ៨ ពួក កំពុងមានការអប់រំឥន្ទ្រិយ តើដូចម្ដេចខ្លះ ។ សេក្ខ-បុគ្គល ៧ និងកល្យាណបុថុជ្ជន ១ បុគ្គលទាំង ៨ ពួកនេះ កំពុងមានការអប់រំឥន្ទ្រិយ ។ បុគ្គល ៣ ពួក (មានឥន្ទ្រិយអប់រំហើយ) តើដូចម្ដេចខ្លះ ។ សាវ័ករបស់ព្រះតថាគត ជាព្រះខីណាស្រព មាននាមថាពុទ្ធៈ ដោយអំណាចលោកជាអ្នកមានឥន្ទ្រិយអប់រំហើយ ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ ព្រះបច្ចេកពុទ្ធ ដោយអត្ថថាត្រាស់ដឹងឯង ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដោយអត្ថថាមានគុណរាប់មិនបាន ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ នេះឯង បុគ្គល ៣ ពួកដែលមានឥន្ទ្រិយអប់រំហើយ បុគ្គល ៨ ពួកនេះ កំពុងមានការអប់រំឥន្ទ្រិយ បុគ្គល ៣ ពួកនេះ មានឥន្ទ្រិយអប់រំហើយ ដូចពោលមកនេះឯង ។

## សាវត្ថីនិទាន

[១៣៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះ មាន ៥ យ៉ាង ឥន្ទ្រិយ ៥ យ៉ាង តើអ្វីខ្លះ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិ-ន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ ឯណានីមួយ មិនដឹងច្បាស់ តាមពិត នូវការកើតឡើងផង នូវសេចក្ដីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង របស់ឥន្ទ្រិយទាំង ៥ នេះទេ

ឯមេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា[១] សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ឯ ច បន អាយស្មន្តោ សាមញ្ញត្ថំ វា ព្រាហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

យេ[២] កេចិ ខោ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ច សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រាហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

---

១ ឱ. ម. ចេវ ។ ២ ឱ. ម. យេ ហិ ។

ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនុ៎ះ គេមិនសន្មតថាជាសមណៈ ក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ទេ មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍ ដ៏មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់សម្រេច នូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយបញ្ញាដ៏ឧត្តម របស់ខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានឡើយ ។

ម្នាលភិក្ខុទាំងឡាយ លុះតែសមណៈឬព្រាហ្មណ៍ ឯណានីមួយ ដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង របស់ឥន្ទ្រិយទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ ទើបគេសន្មតថាជាសមណៈ ក្នុងពួកសមណៈ សន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍មែន មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍ ដ៏មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់សម្រេច នូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយបញ្ញាដ៏ឧត្តម របស់ខ្លួនឯង ក្នុងបច្ចុប្បន្នបាន ។

[១៣៨] កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយោ ហោតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយំ បជានាតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមោ ហោតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមំ បជានាតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទោ ហោតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទំ បជានាតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អាទីនវោ ហោតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អាទីនវំ បជានាតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ និស្សរណំ ហោតិ កតិហាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ និស្សរណំ បជានាតិ ។ ចត្តាលីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយោ ហោតិ ចត្តាលីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយំ បជានាតិ ចត្តាលីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមោ ហោតិ

[១៣៨] ការកើត នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវការកើត នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង សេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវសេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង អានិសង្សនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវអានិសង្ស នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ទោសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវទោស នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ការរលាស់ចេញ នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវការរលាស់ចេញ នៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ។ ការកើត នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង បុគ្គលដឹងច្បាស់នូវការកើត នៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ៤០ យ៉ាងដែរ សេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង

ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមំ បជានាតិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទោ ហោតិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទំ បជានាតិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អាទីនវោ ហោតិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អាទីនវំ បជានាតិ អសីតិសតាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ និស្សរណំ ហោតិ អសីតិសតាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ និស្សរណំ បជានាតិ ។

[១៣៩] កតមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយោ ហោតិ កតមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយំ បជានាតិ ។ អធិមោក្ខត្ថាយ អាវជ្ជនាយ សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ អធិមោក្ខវសេន ឆន្ទស្ស សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ អធិមោក្ខវសេន មនសិការស្ស សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ

បុគ្គលដឹងច្បាស់នូវសេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ៤០ យ៉ាងដែរ អានិសង្សនៃឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង បុគ្គលដឹងច្បាស់នូវអានិសង្សនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ២៥ យ៉ាងដែរ ទោសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង បុគ្គលដឹងច្បាស់នូវទោសនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ២៥ យ៉ាងដែរ ការរលាស់ចេញនៃឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ បុគ្គលដឹងច្បាស់នូវការរលាស់ចេញ នៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ១៨០ ដែរ ។

[១៣៩] ការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់ នូវការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ ។ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១

សទ្ធិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហត្ថាយ អាវជ្ជនាយ សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហវសេន ឆន្ទស្ស សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហវសេន មនសិការស្ស សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ វីរិយិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានត្ថាយ អាវជ្ជនាយ សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានវសេន ឆន្ទស្ស សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានវសេន មនសិការស្ស សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ សតិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ សតិន្ទ្រិយស្ស សមុទយោ ហោតិ អវិក្ខេបត្ថាយ អាវជ្ជនាយ សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ អវិក្ខេបវសេន ឆន្ទស្ស សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ

ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃសទ្ធិន្ទ្រិយ ឈ្មោះថាការកើត នៃសទ្ធិន្ទ្រិយ ១ ការកើត នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថាការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការកើតនៃវីរិយិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថាការកើត នៃវីរិយិន្ទ្រិយ ១ ការកើត នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថាការកើតនៃសតិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការកើតនៃសតិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការកើត នៃសតិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថាការកើតនៃសតិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថាការកើត នៃសមាធិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១

អវិក្ខេបវសេន មនសិការស្ស សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ សមាធិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ ទស្សនត្ថាយ អាវជ្ជនាយ សមុទយោ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ ទស្សនវសេន ឆន្ទស្ស សមុទយោ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ ទស្សនវសេន មនសិការស្ស សមុទយោ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ បញ្ញិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ អធិមោក្ខត្ថាយ អាវជ្ជនាយ សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហត្ថាយ អាវជ្ជនាយ សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានត្ថាយ អាវជ្ជនាយ សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ អវិក្ខេបត្ថាយ អាវជ្ជនាយ សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ

*ការកើតនៃមនសិការៈ ដោយអំណាច នៃការមិនរាយមាយ ឈ្មោះថា ការកើត នៃសមាធិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាច នៃការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាច នៃការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថាការកើត នៃវីរិយិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ ដល់ការប្រុងស្មារតី ឈ្មោះថាការកើត នៃសតិន្ទ្រិយ ១ ការកើតនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១*

ទស្សនដ្ឋាយ អាវជ្ជនាយ សមុទយោ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ អធិមោក្ខវសេន ឆន្ទស្ស សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហវសេន ឆន្ទស្ស សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានវសេន ឆន្ទស្ស សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ អវិក្ខេបវសេន ឆន្ទស្ស សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ ទស្សនវសេន ឆន្ទស្ស សមុទយោ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ អធិមោក្ខវសេន មនសិការស្ស សមុទយោ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ បគ្គហវសេន មនសិការស្ស សមុទយោ វីរិយិន្ទ្រិយស្ស សមុទយោ ហោតិ ឧបដ្ឋានវសេន មនសិការស្ស សមុទយោ សតិន្ទ្រិយស្ស សមុទយោ ហោតិ អវិក្ខេបវសេន មនសិការស្ស សមុទយោ សមាធិន្ទ្រិយស្ស សមុទយោ ហោតិ

ការកើត នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការកើត នៃសទ្ធិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការកើតនៃសតិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាច នៃការមិនរាយមាយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការកើត នៃវីរិយិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាច នៃការប្រុងស្មារតី ឈ្មោះថាការកើត នៃសតិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការកើត នៃសមាធិន្ទ្រិយ ១

ឧស្សនវសេន មនសិការស្ស សមុទយោ បញ្ញិន្ទ្រិ-
យស្ស សមុទយោ ហោតិ សទ្ធិន្ទ្រិយស្ស វសេន
ឯកត្តុបដ្ឋានំ សទ្ធិន្ទ្រិយស្ស សមុទយោ ហោតិ
វីរិយិន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ វីរិយិន្ទ្រិយស្ស
សមុទយោ ហោតិ សតិន្ទ្រិយស្ស វសេន ឯកត្តុ-
បដ្ឋានំ សតិន្ទ្រិយស្ស សមុទយោ ហោតិ សមាធិ-
ន្ទ្រិយស្ស វសេន ឯកត្តុបដ្ឋានំ សមាធិន្ទ្រិយស្ស
សមុទយោ ហោតិ បញ្ញិន្ទ្រិយស្ស វសេន ឯកត្តុ-
បដ្ឋានំ បញ្ញិន្ទ្រិយស្ស សមុទយោ ហោតិ ឥមេហិ
ចត្តាវីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ សមុទ-
យោ ហោតិ ឥមេហិ ចត្តាវីសាយ អាការេហិ
បញ្ចន្នំ ឥន្ទ្រិយានំ សមុទយំ បជានាតិ ។

ការកើតនៃមនសិការៈ ដោយអំណាចនៃការឃើញ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថាការកើត នៃសទ្ធិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថាការកើតនៃវីរិយិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថាការកើត នៃសតិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១ ការប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថាការកើតនៃបញ្ញិន្ទ្រិយ ១ នេះឯង ការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង នេះឯងបុគ្គលដឹងច្បាស់នូវការកើត នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង ។

[១៤០] កាតមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមោ ហោតិ កាតមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមំ បជានាតិ ។ អធិមោក្ខត្ថាយ អាវជ្ជ-ជាយ អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អធិមោក្ខវសេន ឆន្ទស្ស អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អធិមោក្ខវសេន មនសិការស្ស អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សទ្ធិន្ទ្រិ-យស្ស វសេន ឯកត្តំ[១] អនុបដ្ឋានំ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ បគ្គហត្ថាយ អាវជ្ជជាយ អត្ថង្គមោ វិរិយិន្ទ្រិយស្ស អត្ថង្គមោ ហោតិ បគ្គហវសេន ឆន្ទស្ស អត្ថង្គមោ វិរិយិន្ទ្រិយស្ស អត្ថង្គមោ ហោតិ បគ្គហវសេន មនសិការស្ស អត្ថង្គមោ វិរិយិ-ន្ទ្រិយស្ស អត្ថង្គមោ ហោតិ វិរិយិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ វិរិយិន្ទ្រិយស្ស អត្ថង្គមោ ហោតិ

១ ម. ឯកត្ត ។

[១៤០] សេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវសេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ ។ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាស នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថាការវិនាស នៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាស នៃមនសិការៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការវិនាស នៃវីរិយិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថាការវិនាសនៃវីរិយិន្ទ្រិយ ១

ឧបដ្ឋានត្ថាយ អាវជ្ជនាយ អត្ថង្គមោ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ឧបដ្ឋានវសេន ឆន្ទស្ស អត្ថង្គមោ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ឧបដ្ឋានវសេន មនសិការស្ស អត្ថង្គមោ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សតិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អវិក្ខេបត្ថាយ អាវ-ជ្ជនាយ អត្ថង្គមោ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អវិក្ខេបវសេន ឆន្ទស្ស អត្ថង្គមោ សមា-ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អវិក្ខេបវសេន មន-សិការស្ស អត្ថង្គមោ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សមាធិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ទស្សនត្ថាយ អាវជ្ជនាយ អត្ថង្គមោ បញ្ញិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ទស្សនវសេន ឆន្ទស្ស អត្ថង្គមោ បញ្ញិន្ទ្រិ-យស្ស អត្ថង្គមោ ហោតិ ទស្សនវសេន មនសិ-ការស្ស អត្ថង្គមោ បញ្ញិន្ទ្រិយស្ស អត្ថង្គមោ ហោតិ

សេចក្តីវិនាស នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថាការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការវិនាសនៃសតិន្ទ្រិយ ១ ការមិនប្រាកដឡើង នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថាការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថាការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការវិនាសនៃសមាធិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថាការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថាការវិនាសនៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាស នៃឆន្ទៈ ដោយអំណាច នៃការឃើញ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការឃើញ ឈ្មោះថាការវិនាសនៃបញ្ញិន្ទ្រិយ ១

បញ្ញិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ បញ្ញិន្ទ្រិ-
យស្ស អត្ថង្គមោ ហោតិ អធិមោក្ខត្ថាយ អាវជ្ជ-
នាយ អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ
បគ្គហត្ថាយ អាវជ្ជនាយ អត្ថង្គមោ វីរិយិន្ទ្រិយស្ស
អត្ថង្គមោ ហោតិ ឧបដ្ឋានត្ថាយ អាវជ្ជនាយ អត្ថង្គ-
មោ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អវិក្ខេបត្ថាយ
អាវជ្ជនាយ អត្ថង្គមោ សមាធិន្ទ្រិយស្ស អត្ថង្គមោ
ហោតិ ទស្សនត្ថាយ អាវជ្ជនាយ អត្ថង្គមោ បញ្ញិ-
ន្ទ្រិយស្ស អត្ថង្គមោ ហោតិ អធិមោក្ខវសេន ឆន្ទស្ស
អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ បគ្គហ-
វសេន ឆន្ទស្ស អត្ថង្គមោ វីរិយិន្ទ្រិយស្ស អត្ថង្គមោ
ហោតិ ឧបដ្ឋានវសេន ឆន្ទស្ស អត្ថង្គមោ សតិន្ទ្រិយ-
ស្ស អត្ថង្គមោ ហោតិ អវិក្ខេបវសេន ឆន្ទស្ស អត្ថង្គ-
មោ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ទស្សនវសេ-
ន ឆន្ទស្ស អត្ថង្គមោ បញ្ញិន្ទ្រិយស្ស អត្ថង្គមោ ហោតិ

ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថាការវិនាស នៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាស នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថាការវិនាស នៃសតិន្ទ្រិយ ១ សេចក្តីវិនាស នៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថាការវិនាស នៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាច នៃការជឿស៊ប់ ឈ្មោះថាការវិនាស នៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាច នៃការផ្គង ឈ្មោះថាការវិនាស នៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាស នៃឆន្ទៈ ដោយអំណាច នៃការប្រុងស្មារតី ឈ្មោះថាការវិនាស នៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការវិនាស នៃសមាធិន្ទ្រិយ ១ សេចក្តីវិនាស នៃឆន្ទៈ ដោយអំណាចនៃការឃើញ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១

អធិមោក្ខវសេន មនសិការស្ស អត្ថង្គមោ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ បគ្គហវសេន មនសិការស្ស អត្ថង្គមោ វីរិយិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ឧបដ្ឋានវសេន មនសិការស្ស អត្ថង្គមោ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ អវិក្ខេបវសេន មនសិការស្ស អត្ថង្គមោ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ទស្សនវសេន មនសិការស្ស អត្ថង្គមោ បញ្ញិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សទ្ធិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ សទ្ធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ វីរិយិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ វីរិយិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សតិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ សតិន្ទ្រិយស្ស អត្ថង្គមោ ហោតិ សមាធិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ សមាធិន្ទ្រិយស្ស អត្ថង្គមោ ហោតិ

សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថាការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការផ្គង ឈ្មោះថាការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិ-ការ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាស នៃមនសិការៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការវិនាស នៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការឃើញ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃសទ្ធិ-ន្ទ្រិយ ឈ្មោះថាការវិនាស នៃសទ្ធិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃវីរិយិន្ទ្រិយ ឈ្មោះថាការវិនាស នៃវីរិយិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃសតិន្ទ្រិយ ឈ្មោះថាការវិនាស នៃសតិន្ទ្រិយ ១ ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃសមាធិន្ទ្រិយ ឈ្មោះថាការវិនាស នៃសមាធិន្ទ្រិយ ១

បញ្ញិន្ទ្រិយស្ស វសេន ឯកត្តំ អនុបដ្ឋានំ បញ្ញិន្ទ្រិយស្ស អត្ថង្គមោ ហោតិ ឥមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមោ ហោតិ ឥមេហិ ចត្តារីសាយ អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អត្ថង្គមំ បជានាតិ ។

[១៤១] កតមេហិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទោ ហោតិ កតមេហិ បញ្ចវីសតិយា អាការេហិ បញ្ចន្នំ ឥន្ទ្រិយានំ អស្សាទំ បជានាតិ ។ អស្សទ្ធិយស្ស អនុបដ្ឋានំ សទ្ធិន្ទ្រិយស្ស អស្សាទោ ហោតិ អស្សទ្ធិយស្ស បរិឡាហស្ស អនុបដ្ឋានំ សទ្ធិន្ទ្រិយស្ស អស្សាទោ ហោតិ អធិមោក្ខចរិយាយ វេសារជ្ជំ សទ្ធិន្ទ្រិយស្ស អស្សាទោ ហោតិ សន្តោ ច វិហារាធិគមោ ច សទ្ធិន្ទ្រិយស្ស អស្សាទោ ហោតិ យំ សទ្ធិន្ទ្រិយំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ សទ្ធិន្ទ្រិយស្ស អស្សាទោ ហោតិ

ការមិនប្រាកដ នៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃបញ្ញិន្ទ្រិយ ឈ្មោះថាការវិនាស នៃបញ្ញិន្ទ្រិយ ១ នេះឯងសេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង នេះឯង បុគ្គលដឹងច្បាស់នូវសេចក្តីវិនាស នៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង ។

[១៤១] អានិសង្សរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវអានិសង្ស របស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង តើអ្វីខ្លះ ។ ការមិនប្រាកដនៃសេចក្តីមិនជឿ ឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្តីក្តៅក្រហាយ ព្រោះការមិនជឿ ឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១ សេចក្តីក្លៀវក្លានៃការប្រព្រឹត្តតាមជំនឿ ឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១ ការស្ងប់ក្តី ការបាននូវវិហារធម៌ក្តី ឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១ សុខនិងសោមនស្សកើតឡើង ព្រោះអាស្រ័យសទ្ធិន្ទ្រិយ ឯណា នេះឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១

កោសជ្ជស្ស អនុបដ្ឋានំ វីរិយិន្ទ្រិយស្ស អស្សាទោ ហោតិ កោសជ្ជស្ស បរិឡាហស្ស អនុបដ្ឋានំ វីរិយិន្ទ្រិយស្ស អស្សាទោ ហោតិ បគ្គហចរិយាយ វេសារជ្ជំ វីរិយិន្ទ្រិយស្ស អស្សាទោ ហោតិ សន្តោ ច វិហារាធិគមោ ច វីរិយិន្ទ្រិយស្ស អស្សាទោ ហោតិ យំ វីរិយិន្ទ្រិយំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វីរិយិន្ទ្រិយស្ស អស្សាទោ ហោតិ បមាទស្ស អនុបដ្ឋានំ សតិន្ទ្រិយស្ស អស្សាទោ ហោតិ បមាទស្ស បរិឡាហស្ស អនុបដ្ឋានំ សតិ-ន្ទ្រិយស្ស អស្សាទោ ហោតិ ឧបដ្ឋានចរិយាយ វេសារជ្ជំ សតិន្ទ្រិយស្ស អស្សាទោ ហោតិ សន្តោ ច វិហារាធិគមោ ច សតិន្ទ្រិយស្ស អស្សាទោ ហោតិ យំ សតិន្ទ្រិយំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ សតិន្ទ្រិយស្ស អស្សាទោ ហោតិ ឧទ្ធច្ចស្ស អនុបដ្ឋានំ សមាធិន្ទ្រិយស្ស អស្សាទោ ហោតិ ឧទ្ធច្ចស្ស បរិឡាហស្ស អនុបដ្ឋានំ សមាធិន្ទ្រិយស្ស អស្សាទោ ហោតិ

ធម្មជាតដែលបុគ្គលជឿហើយ ព្រោះដឹងច្បាស់ ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះតម្កល់មាំ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះជឿ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះតម្កល់មាំ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះផ្គងឡើង ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយ ព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះតម្កល់មាំ

បគ្គហិតត្តា សមាធបិតំ សមាធបិតត្តា ឧបដ្ឋាបិតំ ឧបដ្ឋាបិតត្តា សមាធហិតំ បជានិតត្តា សច្ឆហិតំ សច្ឆហិតត្តា បជានិតំ បជានិតត្តា បគ្គហិតំ បគ្គហិតត្តា បជានិតំ បជានិតត្តា ឧបដ្ឋាបិតំ ឧបដ្ឋាបិតត្តា បជានិតំ បជានិតត្តា សមាធបិតំ សមាធបិតត្តា បជានិតំ យំ ពុទ្ធចក្ខុំ តំ ពុទ្ធញ្ញាណំ យំ ពុទ្ធញ្ញាណំ តំ ពុទ្ធចក្ខុំ យេន ចក្ខុនា តថាគតោ សត្តេ បស្សតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ អប្បេកច្ចេ នបរលោកវជ្ជភយទស្សាវិនោ ។

ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះប្រុងប្រយ័ត្ន ធម្មជាតដែលបុគ្គលជឿហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះតម្កល់មាំ ធម្មជាតណា ដែលជាពុទ្ធចក្ខុ ធម្មជាតនោះ ក៏គឺពុទ្ធញ្ញាណ ធម្មជាតណា ដែលជាពុទ្ធញ្ញាណ ធម្មជាតនោះ គឺពុទ្ធចក្ខុ ព្រះតថាគតទ្រង់ឃើញ ដោយចក្ខុណា នូវសត្វទាំងឡាយដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការមិនល្អ គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ ពួកខ្លះឃើញភ័យចំពោះទោសក្នុងបរលោក ពួកខ្លះមិនឃើញភ័យ ចំពោះទោសក្នុងបរលោក (ចក្ខុនោះ ក៏គឺពុទ្ធញ្ញាណ) ។

[១៧៦] អប្បរជក្ខេ មហារជក្ខេតិ សង្ខោ បុគ្គលោ អប្បរជក្ខោ អស្សទ្ធោ បុគ្គលោ មហារជ-ក្ខោ អារទ្ធវីរិយោ បុគ្គលោ អប្បរជក្ខោ កុសីតោ បុគ្គលោ មហារជក្ខោ ឧបដ្ឋិតស្សតិ បុគ្គលោ អ-ប្បរជក្ខោ មុដ្ឋស្សតិ បុគ្គលោ មហារជក្ខោ សមា-ហិតោ បុគ្គលោ អប្បរជក្ខោ អសមាហិតោ បុគ្គ-លោ មហារជក្ខោ បញ្ញវា បុគ្គលោ អប្បរជក្ខោ ទុប្បញ្ញោ បុគ្គលោ មហារជក្ខោ ។

តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេតិ សទ្ធោ បុគ្គលោ តិ-ក្ខិន្ទ្រិយោ អស្សទ្ធោ បុគ្គលោ មុទិន្ទ្រិយោ ។ បេ ។ បញ្ញវា បុគ្គលោ តិក្ខិន្ទ្រិយោ ទុប្បញ្ញោ បុគ្គលោ មុទិន្ទ្រិយោ ។

ស្វាការេ ទ្វាការេតិ សទ្ធោ បុគ្គលោ ស្វា-ការោ ។ បេ ។ បញ្ញវា បុគ្គលោ ស្វាការោ ទុប្បញ្ញោ បុគ្គលោ ទ្វាការោ ។

[១៧៦] ពាក្យថា មានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក គឺ បុគ្គលមានសទ្ធា ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមិនមានសទ្ធា ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលខ្ជិលច្រអូស ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានស្មារតីតម្កល់មាំ ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមានស្មារតីភ្លេចភ្លាំង ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានចិត្តតម្កល់ខ្ជាប់ ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមានចិត្តមិនតម្កល់ខ្ជាប់ ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានប្រាជ្ញា ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលឥតប្រាជ្ញា ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក ។

ពាក្យថា មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ គឺ បុគ្គលមានសទ្ធា ឈ្មោះថាមានឥន្ទ្រិយក្លៀវក្លា បុគ្គលមិនមានសទ្ធា ឈ្មោះថាមានឥន្ទ្រិយទន់ ។ បេ ។ បុគ្គលមានប្រាជ្ញា ឈ្មោះថាមានឥន្ទ្រិយក្លៀវក្លា បុគ្គលឥតប្រាជ្ញា ឈ្មោះថាមានឥន្ទ្រិយទន់ ។

ពាក្យថា មានអាការល្អ មានអាការមិនល្អ គឺ បុគ្គលមានសទ្ធា ឈ្មោះថាមានអាការល្អ ។ បេ ។ បុគ្គលមានប្រាជ្ញា ឈ្មោះថាមានអាការល្អ បុគ្គលឥតប្រាជ្ញា ឈ្មោះថាមានអាការមិនល្អ ។

សុវិញ្ញាបយេ ទុវិញ្ញាបយេតិ សទ្ធោ បុគ្គលោ សុវិញ្ញាបយោ អស្សទ្ធោ បុគ្គលោ ទុវិញ្ញាបយោ ។ បេ ។ បញ្ញវា បុគ្គលោ សុវិញ្ញាបយោ ទុប្បញ្ញោ បុគ្គលោ ទុវិញ្ញាបយោ ។

អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ អប្បេកច្ចេ នបរលោកវជ្ជភយទស្សាវិនោតិ សទ្ធោ បុគ្គលោ បរលោកវជ្ជភយទស្សាវី អស្សទ្ធោ បុគ្គលោ នបរលោកវជ្ជភយទស្សាវី អារទ្ធវីរិយោ បុគ្គលោ បរលោកវជ្ជភយទស្សាវី កុសីតោ បុគ្គលោ នបរលោកវជ្ជភយទស្សាវី ។ បេ ។ បញ្ញវា បុគ្គលោ បរលោកវជ្ជភយទស្សាវី ទុប្បញ្ញោ បុគ្គលោ នបរលោកវជ្ជភយទស្សាវី ។

លោកោតិ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ វិបត្តិភវលោកោ វិបត្តិសម្ភវលោកោ សម្បត្តិភវលោកោ សម្បត្តិសម្ភវលោកោ ។ ឯកោ លោកោ សព្វេ សត្តា អាហារដ្ឋិតិកា ។

ពាក្យថា គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ គឺ បុគ្គលមានសទ្ធា ឈ្មោះថាគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលមិនមានសទ្ធា ឈ្មោះថាគួរឲ្យត្រាស់ដឹងបានដោយក្រ ។ បេ ។ បុគ្គលមានប្រាជ្ញា ឈ្មោះថាគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលឥតប្រាជ្ញា ឈ្មោះថាគួរឲ្យត្រាស់ដឹងបានដោយក្រ ។

ពាក្យថា ពួកខ្លះឃើញភ័យ ចំពោះទោសក្នុងបរលោក ពួកខ្លះមិនឃើញភ័យ ចំពោះទោសក្នុងបរលោក គឺបុគ្គលមានសទ្ធា ឈ្មោះថាឃើញភ័យ ចំពោះទោសក្នុងបរលោក បុគ្គលមិនមានសទ្ធា ឈ្មោះថាមិនឃើញភ័យ ចំពោះទោសក្នុងបរលោក បុគ្គលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាឃើញភ័យ ចំពោះទោសក្នុងបរលោក បុគ្គលខ្ជិលច្រអូស ឈ្មោះថាមិនឃើញភ័យ ចំពោះទោសក្នុងបរលោក ។ បេ ។ បុគ្គលមានប្រាជ្ញា ឈ្មោះថាឃើញភ័យ ចំពោះទោសក្នុងបរលោក បុគ្គលឥតប្រាជ្ញា ឈ្មោះថាមិនឃើញភ័យ ចំពោះទោសក្នុងបរលោក ។

ពាក្យថា លោក បានដល់ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក វិបត្តិសម្ភវលោក សម្បត្តិភវលោក សម្បត្តិសម្ភវលោក ។ លោក ១ គឺសត្វទាំងអស់ ដែលតាំងនៅបានដោយសារ

២៧៩



ទ្វេ លោកា នាមញ្ច រូបញ្ច ។ តយោ លោកា តិស្សោ វេទនា ។ ចត្តារោ លោកា ចត្តារោ អាហារា ។ បញ្ច លោកា បញ្ចុបាទានក្ខន្ធា ។ ឆ លោកា ឆ អជ្ឈត្តិកានិ អាយតនានិ ។ សត្ត លោកា សត្ត វិញ្ញាណដ្ឋិតិយោ ។ អដ្ឋ លោកា អដ្ឋ លោកធម្មា ។ នវ លោកា នវ សត្តាវាសា ។ ទស លោកា ទសាយតនានិ ។ ទ្វាទស លោកា ទ្វាទសាយតនានិ ។ អដ្ឋារស លោកា អដ្ឋារស ធាតុយោ ។

វជ្ជន្តិ សព្វេ កិលេសា វជ្ជា សព្វេ ទុច្ចរិតា វជ្ជា សព្វេ អភិសង្ខារា វជ្ជា សព្វេ ភវគាមិកម្មា វជ្ជា ឥតិ ឥមស្មិញ្ច លោកេ ឥមស្មិញ្ច វជ្ជេ តិព្វា ភយសញ្ញា បច្ចុបដ្ឋិតា ហោតិ សេយ្យថាបិ ឧក្ខិត្តាសិកេ វធកេ ឥមេហិ បញ្ញាសាយ អាការេហិ ឥមានិ បញ្ចិន្ទ្រិយានិ ជានាតិ បស្សតិ អញ្ញាតិ បដិវិជ្ឈតិ ។

តតិយភាណវារំ និដ្ឋិតំ ។

ឥន្ទ្រិយកថា និដ្ឋិតា ។

*អាហារ ។ លោក ២ គឺនាម ១ រូប ១ ។ លោក ៣ គឺវេទនា ៣ ។ លោក ៤ គឺអាហារ ៤ ។ លោក ៥ គឺឧបាទានក្ខន្ធទាំង ៥ ។ លោក ៦ គឺអាយតនៈខាងក្នុង ទាំង ៦ ។ លោក ៧ គឺវិញ្ញាណដ្ឋិតិ ៧ ។ លោក ៨ គឺលោកធម៌ ៨ ។ លោក ៩ គឺសត្តាវាសៈ ៩ ។ លោក ១០ គឺអាយតនៈ ១០ ។ លោក ១២ គឺអាយតនៈ ១២ ។ លោក ១៨ គឺធាតុ ១៨ ។*

*ពាក្យថា ទោស គឺ កិលេសទាំងអស់ ឈ្មោះថាទោស (ទោសដែលបុគ្គលគួរវៀរ) ទុច្ចរិតទាំងអស់ ឈ្មោះថាទោស អភិសង្ខារទាំងអស់ ឈ្មោះថាទោស ភវគាមិកម្ម (កម្មដែលនាំសត្វកាន់ភព) ទាំងអស់ ឈ្មោះថាទោស ព្រោះហេតុនោះ សេចក្តីសម្គាល់ក្នុងលោកនេះ និងក្នុងទោសនេះ ថាជាភ័យ យ៉ាងខ្លាំងក្លា រមែងតាំងឡើងប្រាកដ ដូចជាពេជ្ឈឃាដ ដែលយារដាវឡើង (ប្រុងប្រហារ) ព្រះតថាគតទ្រង់ជ្រាបឃើញ ត្រាស់ដឹង ចាក់ធ្លុះ នូវឥន្ទ្រិយ ៥ នេះ ដោយអាការ ៥០ នេះឯង ។*

ចប់ តតិយភាណវារៈ ។

ចប់ ឥន្ទ្រិយកថា ។

---

# មហាវគ្គេ វិមោក្ខកថា

## បរិបុណ្ណនិទានា

[១៧៧] តយោមេ ភិក្ខវេ វិមោក្ខា កតមេ តយោ សុញ្ញតោ វិមោក្ខោ អនិមិត្តោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ ឥមេ ភិក្ខវេ តយោ វិមោក្ខា ។

អបិ ច អដ្ឋសដ្ឋី វិមោក្ខា សុញ្ញតោ វិមោ-ក្ខោ អនិមិត្តោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ អជ្ឈត្តវុដ្ឋានោ វិមោក្ខោ ពហិទ្ធាវុដ្ឋានោ វិមោក្ខោ ទុភតោវុដ្ឋានោ វិមោក្ខោ អជ្ឈត្តវុដ្ឋានា ចត្តារោ វិមោក្ខា ពហិទ្ធាវុដ្ឋានា ចត្តារោ វិមោក្ខា ទុភតោ-វុដ្ឋានា ចត្តារោ វិមោក្ខា អជ្ឈត្តវុដ្ឋានានំ អនុលោ-មា ចត្តារោ វិមោក្ខា ពហិទ្ធាវុដ្ឋានានំ អនុលោមា ចត្តារោ វិមោក្ខា ទុភតោវុដ្ឋានានំ អនុលោមា ច-ត្តារោ វិមោក្ខា អជ្ឈត្តវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ពហិទ្ធាវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោ-ក្ខា ទុភតោវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា

# មហាវគ្គ វិមោក្ខកថា

## បរិបុណ្ណនិទាន

[១៧៧] ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះ មាន ៣ យ៉ាង វិមោក្ខ ៣ យ៉ាង តើដូចម្តេច គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ម្នាលភិក្ខុទាំងឡាយ នេះវិមោក្ខ ៣ យ៉ាង ។

ម្យ៉ាងទៀត វិមោក្ខ មាន[១] ៦៨ យ៉ាង គឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ អជ្ឈត្តវុដ្ឋានវិមោក្ខ ១ ពហិទ្ធាវុដ្ឋានវិមោក្ខ ១ ទុភតោវុដ្ឋានវិមោក្ខ ១ អជ្ឈត្តវុដ្ឋានវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានវិមោក្ខ ៤ ទុភតោវុដ្ឋានវិមោក្ខ ៤ អជ្ឈត្តវុដ្ឋានានុលោមវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ ទុភតោវុដ្ឋានានុលោមវិមោក្ខ ៤ អជ្ឈត្តវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ ទុភតោវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤

១ តាមចំនួនសំខ្យាថា ៦៨ តែរាប់ទៅឃើញលើសកំណត់ចំនួន ៧ មិនដឹងថាហេតុអ្វី ។

២៨១



រូបី រូបានិ បស្សតីតិ វិមោក្ខោ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខោ សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខោ អាកាសានញ្ចាយតនសមាបត្តិវិមោក្ខោ វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខោ អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខោ នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខោ សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខោ សមយវិមោក្ខោ អសមយវិមោក្ខោ សាមយិកោ វិមោក្ខោ អសាមយិកោ វិមោក្ខោ កុប្បោ វិមោក្ខោ អកុប្បោ វិមោក្ខោ លោកិយោ វិមោក្ខោ លោកុត្តរោ វិមោក្ខោ សាសវោ វិមោក្ខោ អនាសវោ វិមោក្ខោ សាមិសោ វិមោក្ខោ និរាមិសោ វិមោក្ខោ និរាមិសតរោ[១] វិមោក្ខោ បណិហិតោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ បណិហិតប្បដិប្បស្សទ្ធិវិមោក្ខោ សញ្ញុត្តោ

---

១ ឱ. និរាមិសានិរាមិសតរោ ។

រូបី រូបានិ បស្សតីតិ វិមោក្ខោ (បុគ្គលមានរូប ឃើញរូប ហៅថាវិមោក្ខ) ១ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធារូបានិ បស្សតីតិ វិមោក្ខោ (បុគ្គលមានសេចក្តីសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅ ហៅថាវិមោក្ខ) ១ សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខោ (បុគ្គលមានចិត្តចុះស៊ប់ក្នុងទីបំផុតនៃអារម្មណ៍ដ៏ល្អ ហៅថាវិមោក្ខ) ១ អាកាសានញ្ចាយតនសមាបត្តិវិមោក្ខោ ១ វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខោ ១ អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខោ ១ នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខោ ១ សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខោ ១ សមយវិមោក្ខោ ១ អសមយវិមោក្ខោ ១ សាមយិកវិមោក្ខោ ១ អសាមយិកវិមោក្ខោ ១ កុប្បវិមោក្ខោ ១ អកុប្បវិមោក្ខោ ១ លោកិយវិមោក្ខោ ១ លោកុត្តរវិមោក្ខោ ១ សាសវវិមោក្ខោ ១ អនាសវវិមោក្ខោ ១ សាមិសវិមោក្ខោ ១ និរាមិសវិមោក្ខោ ១ និរាមិសតរវិមោក្ខោ ១ បណិហិតវិមោក្ខោ ១ អប្បណិហិតវិមោក្ខោ ១ បណិហិតប្បដិប្បស្សទ្ធិវិមោក្ខោ ១ សញ្ញុត្តវិមោក្ខោ ១

វិមោក្ខោ វិសញ្ញុត្តោ វិមោក្ខោ ឯកត្តវិមោក្ខោ ឆានត្តវិមោក្ខោ សញ្ញាវិមោក្ខោ ញាណវិមោក្ខោ សីតិសិយាវិមោក្ខោ ឈានវិមោក្ខោ អនុបាទាចិត្តស្ស វិមោក្ខោ ។

[១៧៨] កតមោ សុញ្ញតោ វិមោក្ខោ ។ ឥធ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនិយេន វាតិ សោ តត្ថ អភិនិវេសំ ន ករោតីតិ សុញ្ញតោ វិមោក្ខោ អយំ សុញ្ញតោ វិមោក្ខោ ។

កតមោ អនិមិត្តោ វិមោក្ខោ ។ ឥធ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនិយេន វាតិ សោ តត្ថ និមិត្តំ ន ករោតីតិ អនិមិត្តោ វិមោក្ខោ អយំ អនិមិត្តោ វិមោក្ខោ ។

វិសញ្ញុត្តវិមោក្ខ ១ ឯកត្តវិមោក្ខ ១ នានត្តវិមោក្ខ ១ សញ្ញាវិមោក្ខ ១ ញាណវិមោក្ខ ១ សីតិសិយាវិមោក្ខ ១ ឈានវិមោក្ខ ១ អនុបាទាចិត្ត-វិមោក្ខ ១ ។

[១៧៨] សុញ្ញតវិមោក្ខ តើដូចម្ដេច ។ ភិក្ខុ ក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្ដី ទៅនៅក្រោមម្លប់ឈើក្ដី ទៅនៅក្នុងផ្ទះស្ងាត់ក្ដី រមែងពិចារណាដូច្នេះថា នេះ ជារបស់សូន្យ ចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះមិនធ្វើនូវសេចក្ដីប្រកាន់មាំ ក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់នៃខ្លួននោះទេ ហេតុនោះ ទើបឈ្មោះថាសុញ្ញតវិមោក្ខ នេះ សុញ្ញតវិមោក្ខ ។

អនិមិត្តវិមោក្ខ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្ដី ទៅនៅក្រោមម្លប់ឈើក្ដី ទៅនៅក្នុងផ្ទះស្ងាត់ក្ដី រមែងពិចារណាដូច្នេះថា នេះ ជារបស់សូន្យ ចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះមិនធ្វើនូវនិមិត្ត ក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់ខ្លួននោះទេ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ នេះ អនិមិត្តវិមោក្ខ ។

កតមោ អប្បណិហិតោ វិមោក្ខោ ។ ឥធ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនិយេន វាតិ សោ តត្ថ បណិធឹ ន ករោតីតិ អប្បណិហិតោ វិមោក្ខោ អយំ អប្បណិហិតោ វិមោក្ខោ ។

កតមោ អជ្ឈត្តវុដ្ឋានោ វិមោក្ខោ ។ ចត្តារិ ឈានានិ អយំ អជ្ឈត្តវុដ្ឋានោ វិមោក្ខោ ។

កតមោ ពហិទ្ធាវុដ្ឋានោ វិមោក្ខោ ។ ចតស្សោ អរូបសមាបត្តិយោ អយំ ពហិទ្ធាវុដ្ឋានោ វិមោក្ខោ ។

កតមោ ទុភតោវុដ្ឋានោ វិមោក្ខោ ។ ចត្តារោ អរិយមគ្គា អយំ ទុភតោវុដ្ឋានោ វិមោក្ខោ ។

អប្បណិហិតវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាដូច្នេះថា នេះ ជារបស់សូន្យ ចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះ មិនធ្វើនូវសេចក្តីប្រាថ្នា ក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់នៃខ្លួននោះទេ ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ នេះ អប្បណិហិតវិមោក្ខ ។

អជ្ឈត្តវុដ្ឋានវិមោក្ខ តើដូចម្តេច ។ ឈាន ទាំង ៤ នេះ អជ្ឈត្តវុដ្ឋានវិមោក្ខ ។

ពហិទ្ធាវុដ្ឋានវិមោក្ខ តើដូចម្តេច ។ អរូបសមាបត្តិ ទាំង ៤ នេះ ពហិទ្ធាវុដ្ឋានវិមោក្ខ ។

ទុភតោវុដ្ឋានវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ទាំង ៤ នេះ ទុភតោវុដ្ឋានវិមោក្ខ ។

[១៧៩] កតមេ អជ្ឈត្តវុដ្ឋានា ចត្តារោ វិមោក្ខា ។ បឋមជ្ឈានំ នីវរណេហិ វុដ្ឋាតិ ទុតិយជ្ឈានំ វិតក្កវិចារេហិ វុដ្ឋាតិ តតិយជ្ឈានំ បីតិយា វុដ្ឋាតិ ចតុត្ថជ្ឈានំ សុខទុក្ខេហិ វុដ្ឋាតិ ឥមេ អជ្ឈត្តវុដ្ឋានា ចត្តារោ វិមោក្ខា ។

កតមេ ពហិទ្ធាវុដ្ឋានា ចត្តារោ វិមោក្ខា ។ អាកាសានញ្ចាយតនសមាបត្តិ រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ វុដ្ឋាតិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកាសានញ្ចាយតនសញ្ញាយ វុដ្ឋាតិ អាកិញ្ចញ្ញាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសញ្ញាយ វុដ្ឋាតិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសញ្ញាយ វុដ្ឋាតិ ឥមេ ពហិទ្ធាវុដ្ឋានា ចត្តារោ វិមោក្ខា ។

[១៧៩] អជ្ឈត្តវុដ្ឋានវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ បឋមជ្ឈាន ចេញចាកនីវរណៈទាំងឡាយ ១ ទុតិយជ្ឈាន ចេញចាកវិតក្កៈ និង វិចារៈទាំងឡាយ ១ តតិយជ្ឈាន ចេញចាកបីតិ ១ ចតុត្ថជ្ឈានចេញ ចាកសុខៈនិងទុក្ខទាំងឡាយ ១ នេះ អជ្ឈត្តវុដ្ឋានវិមោក្ខ ៤ ។

ពហិទ្ធាវុដ្ឋានវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ អាកាសានញ្ចា-យតនសមាបត្តិ ចេញចាករូបសញ្ញា បដិឃសញ្ញា និងនានត្ត-សញ្ញា ១ វិញ្ញាណញ្ចាយតនសមាបត្តិ ចេញចាកអាកាសានញ្ចា-យតនសញ្ញា ១ អាកិញ្ចញ្ញាយតនសមាបត្តិ ចេញចាកវិញ្ញាណ-ញ្ចាយតនសញ្ញា ១ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ចេញចាក អាកិញ្ចញ្ញាយតនសញ្ញា ១ នេះ ពហិទ្ធាវុដ្ឋានវិមោក្ខ ៤ ។

កតមេ ឧភតោវុដ្ឋានា ចត្តារោ វិមោក្ខា ។ សោតាបត្តិមគ្គោ សក្កាយទិដ្ឋិវិចិកិច្ឆាសីលព្វតបរាមាសា ទិដ្ឋានុសយា វិចិកិច្ឆានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ សកទាគាមិមគ្គោ ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ អនាគាមិមគ្គោ អណុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អណុសហគតា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ អរហត្តមគ្គោ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ ឥមេ ឧភតោវុដ្ឋានា ចត្តារោ វិមោក្ខា ។

ទុកតោវុដ្ឋានវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ សោតាបត្តិមគ្គ ចេញចាកសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមសក្កាយទិដ្ឋិជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ សកទាគាមិមគ្គ ចេញចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ បដិឃានុស័យ ដ៏គ្រោតគ្រាត ចេញចាកកិលេស ដែលប្រព្រឹត្តទៅតាមកាមរាគសញ្ញោជនៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ អនាគាមិមគ្គ ចេញចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ដ៏ល្អិត ចាកកាមរាគានុស័យ បដិឃានុស័យ ដ៏ល្អិត ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមកាមរាគសញ្ញោជនៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ អរហត្តមគ្គ ចេញចាករូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមរូបរាគៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ នេះ ទុកតោវុដ្ឋានវិមោក្ខ ៤ ។

[១៨០] កតមេ អជ្ឈត្តវុដ្ឋានជា អនុលោមា ចត្តារោ វិមោក្ខា ។ បឋមជ្ឈានំ បដិលាភត្ថាយ វិ-តក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ទុតិយជ្ឈានំ បដិលាភត្ថាយ តតិយជ្ឈានំ បដិ-លាភត្ថាយ ចតុត្ថជ្ឈានំ បដិលាភត្ថាយ វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ឥមេ អជ្ឈត្តវុដ្ឋានជា អនុលោមា ចត្តារោ វិមោក្ខា ។

កតមេ ពហិទ្ធាវុដ្ឋានជា អនុលោមា ចត្តារោ វិមោក្ខា ។ អាកាសានញ្ចាយតនសមាបត្តឹ បដិលា-ភត្ថាយ វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច វិញ្ញាណញ្ចាយតនសមាបត្តឹ អាកិញ្ច-ញ្ញាយតនសមាបត្តឹ នេវសញ្ញានាសញ្ញាយតនសមាប-ត្តឹ បដិលាភត្ថាយ វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ឥមេ ពហិទ្ធាវុដ្ឋានជា អនុលោមា ចត្តារោ វិមោក្ខា ។

[១៨០] អជ្ឈត្តវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្ដេច ។ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ប្រព្រឹត្តទៅដើម្បីបាននូវបឋមជ្ឈាន ១ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ប្រព្រឹត្តទៅដើម្បីបាននូវទុតិយជ្ឈាន ១ ដើម្បីបាននូវតតិយជ្ឈាន ១ ដើម្បីបាននូវចតុត្ថជ្ឈាន ១ នេះ អជ្ឈត្តវុដ្ឋានានុលោមវិមោក្ខ ៤ ។

ពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្ដេច ។ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ប្រព្រឹត្តទៅដើម្បីបាននូវអាកាសានញ្ចាយតនសមាបត្តិ ១ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ប្រព្រឹត្តទៅដើម្បីបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ១ នូវអាកិញ្ចញ្ញាយតនសមាបត្តិ ១ នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ នេះ ពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ ។

កតមេ ឧភតោវុដ្ឋានា អនុលោមា ចត្តារោ វិមោក្ខា ។ សោតាបត្តិមគ្គំ បដិលាភត្ថាយ អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា សកទាគាមិមគ្គំ បដិលាភត្ថាយ អនាគាមិមគ្គំ បដិលាភត្ថាយ អរហត្តមគ្គំ បដិលាភត្ថាយ អនិច្ចា-នុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា ឥមេ ឧភតោវុដ្ឋានា អនុលោមា ចត្តារោ វិមោក្ខា ។

[១៨១] កតមេ អជ្ឈត្តវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។ បឋមជ្ឈានស្ស បដិលាភោ វា វិចារោ វា ទុតិយជ្ឈានស្ស តតិយជ្ឈានស្ស ចតុត្ថជ្ឈានស្ស បដិលាភោ វា វិចារោ វា ឥមេ អជ្ឈត្តវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។

ទុកតោវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្ដេច ។ អនិច្ចានុ-បស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ប្រព្រឹត្តទៅដើម្បីបាននូវសោតាបត្តិមគ្គ ១ អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ប្រព្រឹត្តទៅដើម្បីបាននូវសកទាគាមិមគ្គ ១ ដើម្បីបាននូវអនាគាមិមគ្គ ១ ដើម្បីបាននូវអរហត្តមគ្គ ១ នេះ ទុកតោវុដ្ឋានានុលោមវិមោក្ខ ៤ ។

[១៨១] អជ្ឈត្តវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្ដេច ។ ការបាននូវបឋមជ្ឈាន ឬវិបាករបស់បឋមជ្ឈាន ១ ការបាននូវទុតិយ-ជ្ឈាន ឬវិបាករបស់ទុតិយជ្ឈាន ១ ការបាននូវតតិយជ្ឈាន ឬវិបាករបស់តតិយជ្ឈាន ១ ការបាននូវចតុត្ថជ្ឈាន ឬវិបាករបស់ចតុត្ថជ្ឈាន ១ នេះ អជ្ឈត្តវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ ។

កតមេ ពហិទ្ធាវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។ អាកាសានញ្ចាយតនសមាបត្តិយា បដិ-លាភោ វា វិចារោ វា វិញ្ញាណញ្ចាយតនសមាប-ត្តិយា អាកិញ្ចញ្ញាយតនសមាបត្តិយា នេវសញ្ញានា-សញ្ញាយតនសមាបត្តិយា បដិលាភោ វា វិចារោ វា ឥមេ ពហិទ្ធាវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។

កតមេ ទុភតោវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។ សោតាបត្តិមគ្គស្ស សោតាបត្តិផលំ សកទាគាមិមគ្គស្ស សកទាគាមិផលំ អនាគាមិ-មគ្គស្ស អនាគាមិផលំ អរហត្តមគ្គស្ស អរហត្ត-ផលំ ឥមេ ទុភតោវុដ្ឋានា បដិប្បស្សទ្ធី ចត្តារោ វិមោក្ខា ។

ពហិទ្ធាវុដ្ឋានបដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ ការបាននូវអាកាសានញ្ចាយតនសមាបត្តិ ឬវិបាករបស់អាកាសានញ្ចាយតន-សមាបត្តិ ១ ការបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ឬវិបាករបស់វិញ្ញាណញ្ចាយតនសមាបត្តិ ១ ការបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ឬវិបាករបស់អាកិញ្ចញ្ញាយតនសមាបត្តិ ១ ការបាននូវនេវសញ្ញានាស-ញ្ញាយតនសមាបត្តិ ឬវិបាករបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ នេះ ពហិទ្ធាវុដ្ឋានបដិប្បស្សទ្ធិវិមោក្ខ ៤ ។

ទុភតោវុដ្ឋានបដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ សោតាបត្តិផល របស់សោតាបត្តិមគ្គ ១ សកទាគាមិផល របស់សក-ទាគាមិមគ្គ ១ អនាគាមិផល របស់អនាគាមិមគ្គ ១ អរហត្តផល របស់អរហត្តមគ្គ ១ នេះ ទុភតោវុដ្ឋានបដិប្បស្សទ្ធិវិមោក្ខ ៤ ។

មហាវគ្គេ ឥន្ទ្រិយកថា

[១៨២] កាចំ រូបី រូបានិ បស្សតីតិ វិមោក្ខោ ។ ឥធេកច្ចោ អជ្ឈត្តំ បច្ចត្តំ នីលនិមិត្តំ មនសិករោតិ នីលសញ្ញំ បដិលភតិ សោ តំ និមិត្តំ សុគ្គហិតំ ករោតិ សូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គហិតំ កត្វា សូបធារិតំ ឧប-ធារេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា ពហិទ្ធា នីលនិមិត្តេ ចិត្តំ ឧបសំហរតិ នីលសញ្ញំ បដិលភតិ សោ តំ និមិត្តំ សុគ្គហិតំ ករោតិ សូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គហិតំ កត្វា សូបធារិតំ ឧបធារេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស ឯវំ ហោតិ អជ្ឈត្តញ្ច ពហិទ្ធា ច ឧភយមិទំ រូបន្តិ

[១៨២] រូបី រូបានិ បស្សតីតិ វិមោក្ខ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌ខៀវ ដ៏ប្រាកដ ជានិមិត្តខាងក្នុង តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវ បុគ្គលនោះ ក៏ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃហើយ ក៏ប្រមូលចិត្តទៅក្នុងនិមិត្តមានពណ៌ខៀវ ជានិមិត្តខាងក្រៅ តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវ បុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណា ដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុក ដោយប្រពៃ លុះបុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យក ដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណា ដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុក ដោយប្រពៃហើយ ក៏សេព ចម្រើន ធ្វើឲ្យច្រើន (នូវនិមិត្តនោះ) បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា រូបខាងក្នុង និង រូបខាងក្រៅ ទាំងពីរនេះ ឈ្មោះថារូប (ដូចគ្នា)

រូបសញ្ញី ហោតិ ឯកេកាច្ចោ អជ្ឈត្តំ បច្ចត្តំ បីតនិ-មិត្តំ លោហិតនិមិត្តំ ឱទាតនិមិត្តំ មនសិករោតិ ឱទាតសញ្ញំ បដិលភតិ សោ តំ និមិត្តំ សុគ្គហិតំ ករោតិ សូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គហិតំ កត្វា សូបធារិតំ ឧបធា-រេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា ពហិទ្ធា ឱទាតនិមិត្តេ ចិត្តំ ឧបសំហរតិ ឱទាតសញ្ញំ បដិលភតិ សោ តំ និមិត្តំ សុគ្គហិតំ ករោតិ សូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គ-ហិតំ កត្វា សូបធារិតំ ឧបធារេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា អាសេវតិ ភាវេតិ ពហុលីករោតិ

បុគ្គលនោះឈ្មោះថាអ្នកមានសេចក្តីសម្គាល់ក្នុងរូប បុគ្គលខ្លះក្នុងលោកនេះ ធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌លឿង នូវនិមិត្តមានពណ៌ក្រហម នូវនិមិត្តមានពណ៌ស ដ៏ប្រាកដ ជានិមិត្តខាងក្នុង តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ស បុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃហើយ ក៏ប្រមូលចិត្តទៅក្នុងនិ-មិត្ត មានពណ៌ស ជានិមិត្តខាងក្រៅ តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ស បុគ្គលនោះក៏ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះ ធ្វើទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចាណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃហើយ ក៏សេព ចម្រើន ធ្វើឲ្យច្រើន

តស្ស ឯវំ ហោតិ អជ្ឈត្តញ្ច ពហិទ្ធា ច ឧភយមិទំ រូបន្តិ រូបសញ្ញី ហោតិ ឯវំ រូបី រូបានិ បស្សតីតិ វិមោក្ខោ ។

[១៨៣] កថំ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខោ ។ ឥធេកច្ចោ អជ្ឈត្តំ បច្ចត្តំ នីលនិមិត្តំ ន មនសិករោតិ នីលសញ្ញំ ន បដិលភតិ ពហិទ្ធា នីលនិមិត្តេ ចិត្តំ ឧបសំហរតិ នីលសញ្ញំ បដិលភតិ សោ តំ និមិត្តំ ករោតិ ស្វូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គហិតំ កត្វា ស្វូបធារិតំ ឧបធារេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស ឯវំ ហោតិ

នូវនិមិត្តនោះ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា រូបខាងក្នុងនិងរូបខាងក្រៅ ទាំងពីរនេះ ឈ្មោះថារូបដូចគ្នា បុគ្គលនោះ ឈ្មោះថាជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប យ៉ាងនេះឯង ឈ្មោះថា រូបី រូបានិ បស្សតីតិ វិមោក្ខ ។

[១៨៣] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខ តើដូចម្តេច ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនធ្វើទុកក្នុងចិត្ត នូវនិមិត្តមានពណ៌ខៀវ ដ៏ប្រាកដ ជានិមិត្តខាងក្នុង មិនបាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវទេ តែប្រមូលចិត្តទៅក្នុងនិមិត្ត មានពណ៌ខៀវជានិមិត្តខាងក្រៅ បាននូវសេចក្តីសម្គាល់ ក្នុងពណ៌ខៀវ បុគ្គលនោះក៏ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យក ដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណា ដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុក ដោយប្រពៃ លុះបុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃហើយ ក៏សេព ចម្រើន ធ្វើឲ្យច្រើន នូវនិមិត្តនោះ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា

អជ្ឈត្តំ អរូបំ ពហិទ្ធា រូបមិចន្តិ រូបសញ្ញី ហោតិ ឥធេកច្ចោ អជ្ឈត្តំ បច្ចត្តំ បីតនិមិត្តំ លោហិតនិមិត្តំ ឱទាតនិមិត្តំ ន មនសិករោតិ ឱទាតសញ្ញំ ន បដិលភតិ ពហិទ្ធា ឱទាតនិមិត្តេ ចិត្តំ ឧបសំហរតិ ឱទាតសញ្ញំ បដិលភតិ សោ តំ និមិត្តំ សុគ្គហិតំ ករោតិ សូបធារិតំ ឧបធារេតិ ស្វាវត្ថិតំ អវត្ថាបេតិ សោ តំ និមិត្តំ សុគ្គហិតំ កត្វា សូបធារិតំ ឧបធារេត្វា ស្វាវត្ថិតំ អវត្ថាបេត្វា អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស ឯវំ ហោតិ អជ្ឈត្តំ អរូបំ ពហិទ្ធា រូបមិចន្តិ រូបសញ្ញី ហោតិ ឯវំ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខោ ។

អរូបគឺរបស់ឥតរូបខាងក្នុង នេះឯងជារូបខាងក្រៅ បុគ្គលនោះឈ្មោះថាជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប បុគ្គលខ្លះក្នុងលោកនេះ មិនធ្វើទុកក្នុងចិត្តនូវនិមិត្ត មានពណ៌លឿង នូវនិមិត្តមានពណ៌ក្រហម នូវនិមិត្តមានពណ៌ស ដ៏ប្រាកដ ជានិមិត្តខាងក្នុង មិនបាននូវសេចក្តីសម្គាល់ក្នុងពណ៌ស តែប្រមូលចិត្តទៅក្នុងនិមិត្ត មានពណ៌ស ជានិមិត្តខាងក្រៅ បាននូវសេចក្តីសម្គាល់ ក្នុងពណ៌ស បុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់ទុកដោយប្រពៃហើយ ក៏សេព ចម្រើន ធ្វើឲ្យច្រើន នូវនិមិត្តនោះ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អរូបគឺរបស់ឥតរូបខាងក្នុង នេះឯងជារូបខាងក្រៅ បុគ្គលនោះ ឈ្មោះថាជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប ។ យ៉ាងនេះឯង ឈ្មោះថាអជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខោ ។

[១៨៤] កថំ សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខោ ។ ឥធ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ មេត្តាយ ភាវិតត្តា សត្តា អប្បដិកូលា ហោន្តិ ករុណាសហគតេន ចេតសា ឯកំ ទិសំ ។ បេ ។ ករុណាយ ភាវិតត្តា សត្តា អប្បដិកូលា ហោន្តិ មុទិតាសហគតេន ចេតសា ។ បេ ។ មុទិតាយ ភាវិតត្តា សត្តា អប្បដិកូលា ហោន្តិ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ បេ ។ ឧបេក្ខាយ ភាវិតត្តា សត្តា អប្បដិកូលា ហោន្តិ ឯវំ សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខោ ។

[១៨៤] *សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនង នេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកប ដោយមេត្តា ដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតចងពៀរ ឥតព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀប ផ្ទឹមខ្លួនឲ្យស្មើនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង សត្វទាំងឡាយដែល គេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមេត្តា ភិក្ខុមានចិត្តប្រកបដោយ ករុណា ផ្សាយទៅកាន់ទិសទី ១ ។ បេ ។ សត្វទាំងឡាយ ដែលគេ មិនគួរខ្ពើមរអើម ព្រោះបានចម្រើនករុណា ភិក្ខុមានចិត្តប្រកបដោយ មុទិតា ។ បេ ។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបាន ចម្រើនមុទិតា ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។ បេ ។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើន ឧបេក្ខា យ៉ាងនេះឯង ឈ្មោះថា សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ ។*

[១៨៤] កតមោ អាកាសានញ្ចាយតនសមាបត្តិវិមោក្ខោ ។ ឥធ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ អាកាសានញ្ចាយតនសមាបត្តិ[១] ។

កតមោ វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខោ ។ ឥធ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខោ ។

កតមោ អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខោ ។ ឥធ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខោ ។

---

១ ឱ. អាកាសានញ្ចាយតនសមាបត្តិវិមោក្ខោ ។

[១៨៥] អាកាសានញ្ចាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះ ឈ្មោះថាអាកាសានញ្ចាយតនសមាបត្តិវិមោក្ខ ។

វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះ ឈ្មោះថាវិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខ ។

អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីតិចតួច មិនមាន នេះ ឈ្មោះថាអាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខ ។

កតមោ នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខោ ។ ឥធ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខោ ។

កតមោ សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខោ ។ ឥធ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខោ ។

[១៨៦] កតមោ សមយវិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ សមយវិមោក្ខោ ។

កតមោ អសមយវិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ អសមយវិមោក្ខោ ។

កតមោ សាមយិកោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ សាមយិកោ វិមោក្ខោ ។

នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះ ឈ្មោះថានេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខ ។

សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុ ក្នុងសាសនានេះ កន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) នេះ ឈ្មោះថាសញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខ ។

[១៨៦] សមយវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាសមយវិមោក្ខ ។

អសមយវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាអសមយវិមោក្ខ ។

សាមយិកវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាសាមយិកវិមោក្ខ ។

កតមោ អសាមយិកោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ អសាមយិកោ វិមោក្ខោ ។

កតមោ កុប្បោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ កុប្បោ វិមោក្ខោ ។

កតមោ អកុប្បោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ អកុប្បោ វិមោក្ខោ ។

កតមោ លោកិយោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ លោកិយោ វិមោក្ខោ ។

កតមោ លោកុត្តរោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ លោកុត្តរោ វិមោក្ខោ ។

កតមោ សាសវោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ សាសវោ វិមោក្ខោ ។

អសាមយិកវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាអសាមយិកវិមោក្ខ ។

កុប្បវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាកុប្បវិមោក្ខ ។

អកុប្បវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាអកុប្បវិមោក្ខ ។

លោកិយវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាលោកិយវិមោក្ខ ។

លោកុត្តរវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាលោកុត្តរវិមោក្ខ ។

សាសវវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាសាសវវិមោក្ខ ។

កតមោ អនាសវោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ អនាសវោ វិមោក្ខោ ។

[១៨៧] កតមោ សាមិសោ វិមោក្ខោ ។ រូបប្បដិសញ្ញុត្តោ វិមោក្ខោ អយំ សាមិសោ វិមោក្ខោ ។

កតមោ និរាមិសោ វិមោក្ខោ ។ អរូបប្បដិសញ្ញុត្តោ វិមោក្ខោ អយំ និរាមិសោ វិមោក្ខោ ។

កតមោ និរាមិសតរោ[១] វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ និរាមិសតរោ វិមោក្ខោ ។

កតមោ បណិហិតោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ បណិហិតោ វិមោក្ខោ ។

កតមោ អប្បណិហិតោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ អប្បណិហិតោ វិមោក្ខោ ។

---

១ ឱ. និរាមិសានិរាមិសតរោ ។

អនាសវវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាអនាសវវិមោក្ខ ។

[១៨៧] សាមិសវិមោក្ខ តើដូចម្តេច ។ វិមោក្ខ ប្រកបព្រម ដោយរូប នេះ ឈ្មោះថាសាមិសវិមោក្ខ ។

និរាមិសវិមោក្ខ តើដូចម្តេច ។ វិមោក្ខ មិនប្រកបព្រមដោយរូប នេះ ឈ្មោះថានិរាមិសវិមោក្ខ ។

និរាមិសតរវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថានិរាមិសតរវិមោក្ខ ។

បណិហិតវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាបណិហិតវិមោក្ខ ។

អប្បណិហិតវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាអប្បណិហិតវិមោក្ខ ។

កតមោ បណិហិតប្បដិបស្សទ្ធិវិមោក្ខោ ។ បឋមជ្ឈានស្ស បដិលាភោ វា វិបាកោ វា ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា បដិលាភោ វា វិបាកោ វា អយំ បណិហិតប្បដិប្បស្សទ្ធិវិមោក្ខោ ។

កតមោ សញ្ញុត្តោ វិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ សញ្ញុត្តោ វិមោក្ខោ ។

កតមោ វិសញ្ញុត្តោ វិមោក្ខោ ។ ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ វិសញ្ញុត្តោ វិមោក្ខោ ។

កតមោ ឯកត្តវិមោក្ខោ ។ ចត្តារោ ច អរិយ-មគ្គា ចត្តារិ ច សាមញ្ញផលានិ និព្វានញ្ច អយំ ឯកត្តវិមោក្ខោ ។

កតមោ នានត្តវិមោក្ខោ ។ ចត្តារិ ឈានានិ ចតស្សោ ច អរូបសមាបត្តិយោ អយំ នានត្តវិមោ-ក្ខោ ។

បណិហិតប្បដិប្បស្សទ្ធិវិមោក្ខ តើដូចម្តេច ។ ការបាននូវបឋមជ្ឈាន ឬវិបាករបស់បឋមជ្ឈាន ។ បេ ។ ការបាននូវនេវសញ្ញានាសញ្ញា-យតនសមាបត្តិ ឬវិបាករបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះ ឈ្មោះថាបណិហិតប្បដិប្បស្សទ្ធិវិមោក្ខ ។

សញ្ញុត្តវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថាសញ្ញុត្តវិមោក្ខ ។

វិសញ្ញុត្តវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាវិសញ្ញុត្តវិមោក្ខ ។

ឯកត្តវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះ ឈ្មោះថាឯកត្តវិមោក្ខ ។

នានត្តវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះ ឈ្មោះថានានត្តវិមោក្ខ ។

[១៨៨] កតមោ សញ្ញាវិមោក្ខោ ។ សិយា ឯកោ សញ្ញាវិមោក្ខោ ទស សញ្ញាវិមោក្ខា ហោន្តិ ទស សញ្ញាវិមោក្ខា ឯកោ សញ្ញាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

សិយាតិ កថញ្ច សិយា ។ អនិច្ចានុបស្សនាញាណំ និច្ចតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ទុក្ខានុបស្សនាញាណំ សុខតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ អនត្តានុបស្សនាញាណំ អត្តតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ និព្វិទានុបស្សនាញាណំ នន្ទិយា សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ វិរាគានុបស្សនាញាណំ រាគតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ

[១៨៨] សញ្ញាវិមោក្ខ តើដូចម្តេច ។ សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មាន ដូចម្តេច ។ អនិច្ចានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាមិនទៀង) ផុតស្រឡះចាកសេចក្តីសម្គាល់ ថាទៀង ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ ទុក្ខានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញថាជាទុក្ខ) ផុតស្រឡះចាកសេចក្តីសម្គាល់ ថាជាសុខ ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ អនត្តានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួន) ផុតស្រឡះចាកសេចក្តីសម្គាល់ ថាជាខ្លួន ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ និព្វិទានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាគួរនឿយណាយ) ផុតស្រឡះ ចាកសេចក្តីសម្គាល់ក្នុងការត្រេកអរ ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ វិរាគានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងប្រាសចាករាគៈ) ផុតស្រឡះចាកសេចក្តីសម្គាល់ ថារាគៈ ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ

និព្វេធានុបស្សនាញាណំ សមុទយតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ បដិនិស្សគ្គានុបស្សនាញាណំ អាទានតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ អនិមិត្តានុបស្សនាញាណំ និមិត្តតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ អប្បណិហិតានុបស្សនាញាណំ បណិធិយា សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ឯវំ សិយា ឯកោ សញ្ញាវិមោក្ខោ ទស សញ្ញាវិមោក្ខា ហោន្តិ ទស សញ្ញាវិមោក្ខា ឯកោ សញ្ញាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

និរោធានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ នូវសេចក្ដីរលត់) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ ថាកើតឡើង ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងរលាស់ចេញ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ ថាគួរប្រកាន់ ហេតុនោះ ឈ្មោះថា សញ្ញាវិមោក្ខ អនិមិត្តានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ នូវធម៌មិនមាននិមិត្ត) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ ថាជានិមិត្ត ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ អប្បណិហិតានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ នូវធម៌មិនមានតម្កល់ទុក) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ ថាតម្កល់ទុក ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ សុញ្ញតានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញថាសូន្យ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ ថាគួរប្រកាន់ស្អិត ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ យ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

៣០១



រូបេ អនិច្ចានុបស្សនាញាណំ និច្ចតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ។ បេ ។ រូបេ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ឯវំ សិយា ឯកោ សញ្ញាវិមោក្ខោ ទស សញ្ញាវិមោក្ខា ហោន្តិ ទស សញ្ញាវិមោក្ខា ឯកោ សញ្ញាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនាញាណំ និច្ចតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ។ បេ ។ ជរាមរណេ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ សញ្ញាយ មុច្ចតីតិ សញ្ញាវិមោក្ខោ ឯវំ សិយា ឯកោ សញ្ញាវិមោក្ខោ ទស សញ្ញាវិមោក្ខា ហោន្តិ ទស សញ្ញាវិមោក្ខា ឯកោ សញ្ញាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន អយំ សញ្ញាវិមោក្ខោ ។

អនិច្ចានុបស្សនាញាណ (ញាណ ជាគ្រឿងពិចារណាឃើញ ថាមិនទៀង) ក្នុងរូប ផុតស្រឡះចាកសេចក្តីសម្គាល់ ថាទៀង ហេតុនោះ ឈ្មោះថា សញ្ញាវិមោក្ខ ។ បេ ។ សុញ្ញតានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាសូន្យ) ក្នុងរូប ផុតស្រឡះ ចាកសេចក្តីសម្គាល់ ដោយការប្រកាន់ស្អិត ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ យ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញ ជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។ អនិច្ចានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាមិនទៀង) ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីសម្គាល់ ថាទៀង ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ ។ បេ ។ សុញ្ញតានុបស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញ ថាសូន្យ) ក្នុងជរាមរណៈ ផុតស្រឡះ ចាកសេចក្តីសម្គាល់ ថាគួរប្រកាន់ស្អិត ហេតុនោះ ឈ្មោះថាសញ្ញាវិមោក្ខ យ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន នេះ សញ្ញាវិមោក្ខ ។

[១៨៩] កតមោ ញាណវិមោក្ខោ ។ សិយា ឯកោ ញាណវិមោក្ខោ ទស ញាណវិមោក្ខា ហោ-ន្តិ ទស ញាណវិមោក្ខា ឯកោ ញាណវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

សិយាតិ កថញ្ច សិយា ។ អនិច្ចានុបស្សនា យថាភូតំ ញាណំ និច្ចតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ទុក្ខានុបស្សនា យថាភូតំ ញាណំ សុខតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ អនត្តានុបស្សនា យថាភូតំ ញាណំ អត្តតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិ-មោក្ខោ និព្វិទានុបស្សនា យថាភូតំ ញាណំ នន្ទិយា សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិ-មោក្ខោ វិរាគានុបស្សនា យថាភូតំ ញាណំ រាគតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ

[១៨៩] ញាណវិមោក្ខ តើដូចម្តេច ។ ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មាន ដូចម្តេច ។ សេចក្តីដឹងតាមពិតជាគ្រឿងពិចារណាឃើញ ថាមិនទៀង ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាទៀង ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្តីដឹងតាមពិតជាគ្រឿងពិចារណាឃើញ ថាជាទុក្ខ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាជាសុខ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្តីដឹងតាមពិតជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួន ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាជាខ្លួន ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងនឿយណាយ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ក្នុងសេចក្តីត្រេកអរ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្តីដឹងតាមពិតជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងប្រាសចាកតម្រេក ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថារាគៈ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ

និពេធានុបស្សនា យថាភូតំ ញាណំ សមុទយតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ បដិនិស្សគ្គានុបស្សនា យថាភូតំ ញាណំ អាទានតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ អនិមិត្តានុបស្សនា យថាភូតំ ញាណំ និមិត្តតោ ស-ម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ អប្ប-ណិហិតានុបស្សនា យថាភូតំ ញាណំ បណិធិយា សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ សុញ្ញតានុបស្សនា យថាភូតំ ញាណំ អភិនិវេសតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ឯវំ សិយា ឯកោ ញាណវិមោក្ខោ ទស ញាណវិ-មោក្ខា ហោន្តិ ទស ញាណវិមោក្ខា ឯកោ ញាណវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

សេចក្ដីដឹងតាមពិត ជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងរលត់ ផុតស្រឡះចាកសេចក្ដីវង្វេង ចាកសេចក្ដីមិនដឹង ជាកើតឡើង ហេតុនោះឈ្មោះថាញាណវិមោក្ខ សេចក្ដីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ចេញ ផុតស្រឡះចាកសេចក្ដីវង្វេង ចាកសេចក្ដីមិនដឹង ជាគួរប្រកាន់មាំ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្ដីដឹងតាមពិតជាគ្រឿងពិចារណាឃើញ នូវធម៌មិនមាននិមិត្ត ផុតស្រឡះចាកសេចក្ដីវង្វេង ចាកសេចក្ដីមិនដឹង ជាមាននិមិត្ត ហេតុនោះ ឈ្មោះថាញាណវិ-មោក្ខ សេចក្ដីដឹងតាមពិតជាគ្រឿងពិចារណាឃើញ នូវធម៌មិនមានការតម្កល់ទុក ផុតស្រឡះចាកសេចក្ដីវង្វេង ចាកសេចក្ដីមិនដឹង ក្នុងការតម្កល់ទុក ហេតុនោះ ឈ្មោះថាញាណវិមោក្ខ សេចក្ដីដឹងតាមពិតជាគ្រឿងពិចា-រណាឃើញ ជាសូន្យ ផុតស្រឡះចាកសេចក្ដីវង្វេង ចាកសេចក្ដីមិនដឹង ជាគួរប្រកាន់មាំ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

រូបេ អនិច្ចានុបស្សនា យថាភូតំ ញាណំ និច្ចតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ។ បេ ។ រូបេ សុញ្ញតានុបស្សនា យថាភូតំ ញាណំ អភិនិវេសតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ឯវំ សិយា ឯកោ ញាណវិមោក្ខោ ទស ញាណវិមោក្ខា ហោន្តិ ទស ញាណវិមោក្ខា ឯកោ ញាណវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា យថាភូតំ ញាណំ និច្ចតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ។ បេ ។ ជរាមរណេ សុញ្ញតានុបស្សនា យថាភូតំ ញាណំ អភិនិវេសតោ សម្មោហា អញ្ញាណា មុច្ចតីតិ ញាណវិមោក្ខោ ឯវំ សិយា ឯកោ ញាណវិមោក្ខោ ទស ញាណវិមោក្ខា ហោន្តិ ទស ញាណវិមោក្ខា ឯកោ ញាណវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន អយំ ញាណវិមោក្ខោ ។

សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងរូប ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាទៀង ហេតុនោះ ឈ្មោះថាញាណវិមោក្ខ ។ បេ ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញ ថាសូន្យ ក្នុងរូប ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាគួរប្រកាន់ស្អិត ហេតុនោះ ឈ្មោះថាញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាទៀង ហេតុនោះ ឈ្មោះថាញាណវិមោក្ខ ។ បេ ។ សេចក្តីដឹងតាមពិតជាគ្រឿងពិចារណាឃើញ ថាសូន្យ ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាគួរប្រកាន់មាំ ហេតុនោះ ឈ្មោះថាញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន នេះញាណវិមោក្ខ ។

[១៩០] កតមោ សីតិសិយាវិមោក្ខោ ។ សិ-
យា ឯកោ សីតិសិយាវិមោក្ខោ ចស សីតិសិយា-
វិមោក្ខា ហោន្តិ ចស សីតិសិយាវិមោក្ខា ឯកោ
សីតិសិយាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

សិយាតិ កថញ្ច សិយា ។ អនិច្ចានុបស្សនា
អនុត្តរំ សីតិភាវំ ញាណំ និច្ចតោ សន្តាបបរិឡា-
ហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ ទុក្ខា-
នុបស្សនា អនុត្តរំ សីតិភាវំ ញាណំ សុខតោ
សន្តាបបរិឡាហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ
អនត្តានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ អត្តតោ
សន្តាបបរិឡាហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ

[១៩០] សីតិសិយាវិមោក្ខ តើដូចម្តេច ។ សីតិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសីតិសិយាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មាន ដូចម្តេច ។ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាល និងសេចក្តីក្រវល់ក្រវាយ ថាទៀង ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាជាទុក្ខ ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាលនិងសេចក្តីក្រវល់ក្រវាយ ថាជាសុខ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួន ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាល និងសេចក្តីក្រវល់ក្រវាយ ថាខ្លួន ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ

និព្វិទានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ ជន្ទិយា

សព្ភាវបរិឡាហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ

វិរាគានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ

រាគតោ សព្ភាវបរិឡាហទរថា មុច្ចតីតិ សីតិសិ-

យាវិមោក្ខោ និរោធានុបស្សនា អនុត្តរំ សីតិភាវំ

ញាណំ សមុទយតោ សព្ភាវបរិឡាហទរថា

មុច្ចតីតិ សីតិសិយាវិមោក្ខោ បដិនិស្សគ្គានុប-

ស្សនា អនុត្តរំ សីតិភាវំ ញាណំ អាទានតោ

សព្ភាវបរិឡាហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ

សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញថាគួរនឿយណាយ ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីពោលពាល និងសេចក្តីក្រវល់ក្រវាយ ក្នុងសេចក្តីត្រេកអរ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាករាគៈ ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពោលពាល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងរំលត់ ផុតស្រឡះចាកហេតុជាដែនកើត ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពោលពាល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងរលាស់ចេញ ផុតស្រឡះចាកសេចក្តីប្រកាន់ ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពោលពាល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថា សីតិសិយាវិមោក្ខ

អនិមិត្តានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ និមិត្ត-
តោ សង្ខារបរិឡាហនវថា មុច្ចតីតិ សីតិសិយាវិមោ-
ក្ខោ អប្បណិហិតានុបស្សនា អនុត្តរំ សីតិភាវំ ញា-
ណំ បណិធិយា សង្ខារបរិឡាហនវថា មុច្ចតីតិ សី-
តិសិយាវិមោក្ខោ សុញ្ញតានុបស្សនា អនុត្តរំ សីតិភាវំ
ញាណំ អភិនិវេសតោ សង្ខារបរិឡាហនវថា មុច្ច-
តីតិ សីតិសិយាវិមោក្ខោ ឯវំ សិយា ឯកោ សីតិសិ-
យាវិមោក្ខោ ទស សីតិសិយាវិមោក្ខា ហោន្តិ ទស
សីតិសិយាវិមោក្ខា ឯកោ សីតិសិយាវិមោក្ខោ
ហោតិ វត្ថុវសេន បរិយាយេន ។ រូបេ អនិច្ចានុ-
បស្សនា អនុត្តរំ សីតិភាវំ ញាណំ និច្ចតោ សង្ខារ-
បរិឡាហនវថា មុច្ចតីតិ សីតិសិយាវិមោក្ខោ ។ បេ ។

សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ផុតស្រឡះចាកធម៌មាននិមិត្ត ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ នូវធម៌មិនមានការតម្កល់ទុក ផុតស្រឡះចាកការតម្កល់ទុក ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពល និងសេចក្តីក្រវល់ក្រវាយ ដោយហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាសូន្យ ផុតស្រឡះចាកការប្រកាន់ ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពលនិងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ ។ យ៉ាងនេះឯង សីតិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសីតិសិយាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងរូប ផុតស្រឡះចាកការទៀង ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថាសីតិសិយាវិមោក្ខ ។ បេ ។

វត្ថុវសេន បរិយាយេន ។ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ និច្ចតោ សន្តាបបរិឡាហទរថា មុច្ចតីតិ សីតិសិយាវិមោក្ខោ ។ បេ ។ ឯវំ សិយា ឯកោ សីតិសិយាវិមោក្ខោ ទស សីតិសិយាវិមោក្ខា ហោន្តិ ទស សីតិសិយាវិមោក្ខា ឯកោ សីតិសិយាវិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន អយំ សីតិសិយាវិមោក្ខោ ។

[១៩១] កតមោ ឈានវិមោក្ខោ ។ នេក្ខម្មំ ជាយតីតិ[១] ឈានំ កាមច្ឆន្ទំ ឈាបេតីតិ ឈានំ ជាយន្តោ[២] មុច្ចតីតិ ឈានវិមោក្ខោ ឈាបេន្តោ មុច្ចតីតិ ឈានវិមោក្ខោ ជាយន្តីតិ ធម្មា ឈាបេតីតិ កិលេសេ ជាតេ ច ឈាបេ ច ជានាតីតិ ឈានវិមោក្ខោ

១ ឱ. ម. ឈាយតីតិ ។ ២ ឱ. ម. ឈាយន្តោ ។

ដោយបរិយាយ ដោយអំណាចនៃវត្ថុ ។ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ផុតស្រឡះចាកការទៀង ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពោលពាល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះ ឈ្មោះថា សីតិសិយាវិមោក្ខ ។ បេ ។ យ៉ាងនេះឯង សីតិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសីតិសិយាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន នេះ សីតិសិយាវិមោក្ខ ។

[១៩១] ឈានវិមោក្ខ តើដូចម្តេច ។ នេក្ខម្មៈ កើតឡើង ឈ្មោះថាឈាន ធម្មជាតដុត នូវកាមឆន្ទៈ ឈ្មោះថាឈាន សភាវៈកាលកើតឡើង ផុតស្រឡះ (ចាកកិលេសទាំងឡាយ) ឈ្មោះថាឈានវិមោក្ខ សភាវៈ កាលដុត ផុតស្រឡះ (ចាកកិលេសទាំងឡាយ) ឈ្មោះថាឈានវិមោក្ខ ធម៌ទាំងឡាយកើតឡើង សភាវៈដុត (នូវកិលេសទាំងឡាយ) សភាវៈដឹង នូវកិលេសទាំងឡាយ ដែលកើតឡើងផង នូវកិលេសទាំងឡាយ ដែលឆេះផង ឈ្មោះថា ឈានវិមោក្ខ

អព្យាបាទោ ជាយតីតិ[១] ឈានំ ព្យាបាទំ ឈា-
បេតីតិ ឈានំ ជាយន្តោ មុច្ចតីតិ ឈានវិមោក្ខោ
ឈាបេន្តោ មុច្ចតីតិ ឈានវិមោក្ខោ ជាយន្តីតិ
ធម្មា ឈាបេតីតិ កិលេសេ ជាតេ ច ឈាបេ
ច ជានាតីតិ ឈានវិមោក្ខោ អាលោកសញ្ញា
ជាយតីតិ ឈានំ ថីនមិទ្ធំ ឈាបេតីតិ ឈានំ អ-
វិក្ខេបោ ជាយតីតិ ឈានំ ឧទ្ធច្ចំ ឈាបេតីតិ
ឈានំ ធម្មវវត្ថានំ ជាយតីតិ ឈានំ វិចិកិច្ឆំ ឈា-
បេតីតិ ឈានំ ញាណំ ជាយតីតិ ឈានំ អវិជ្ជំ
ឈាបេតីតិ ឈានំ បាមុជ្ជំ ជាយតីតិ ឈានំ

១ ឱ. ម. ឈាយតីតិ ។

ការមិនមានព្យាបាទ កើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវព្យាបាទ ឈ្មោះថាឈាន សភាវៈ កាលកើតឡើង ផុតស្រឡះ (ចាកកិលេសទាំងឡាយ) ឈ្មោះថា ឈានវិមោក្ខ សភាវៈ កាលដុត ផុតស្រឡះ (ចាកកិលេសទាំងឡាយ) ឈ្មោះថា ឈានវិមោក្ខ ធម៌ទាំងឡាយកើតឡើង សភាវៈ កាលដុត (នូវកិលេសទាំងឡាយ) សភាវៈដឹងនូវកិលេសទាំងឡាយ ដែលកើតឡើងផង នូវកិលេសទាំងឡាយដែលឆេះផង ឈ្មោះថាឈានវិមោក្ខ អាលោកសញ្ញា កើតឡើង ឈ្មោះថាឈាន ធម្មជាត ដុតនូវថីនមិទ្ធៈ ឈ្មោះថាឈាន ការមិនរាយមាយកើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវឧទ្ធច្ចៈ ឈ្មោះថាឈាន ការកំណត់នូវធម៌ កើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវវិចិកិច្ឆា ឈ្មោះថាឈាន ញាណកើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវអវិជ្ជា ឈ្មោះថាឈាន បាមុជ្ជៈ កើតឡើង ឈ្មោះថាឈាន

អរតឹ ឈាបេតីតិ ឈានំ បឋមជ្ឈានំ ជាយតីតិ ឈានំ នីវរណំ ឈាបេតីតិ ឈានំ ។ បេ ។ អរហត្តមគ្គោ ជាយតីតិ ឈានំ សព្វក្កិលេសេ ឈាបេតីតិ ឈានំ ជាយន្តោ មុច្ចតីតិ ឈានវិមោក្ខោ ឈាបេន្តោ មុច្ចតីតិ ឈានវិមោក្ខោ ជាយន្តីតិ ធម្មា ឈាបេតីតិ កិលេសេ ជានេ ច ឈាបេ ច ជានាតីតិ ឈានវិមោក្ខោ អយំ ឈានវិមោក្ខោ ។

[១៩២] កតមោ អនុបាទាចិត្តស្ស វិមោក្ខោ ។ សិយា ឯកោ អនុបាទាចិត្តស្ស វិមោក្ខោ ទស អនុបាទាចិត្តស្ស វិមោក្ខា ហោន្តិ ទស អនុបាទាចិត្តស្ស វិមោក្ខា ឯកោ អនុបាទាចិត្តស្ស វិមោក្ខោ ហោតិ វត្ថុវសេន បរិយាយេន ។

ធម្មជាតដុតនូវសេចក្តីមិនត្រេកអរ ឈ្មោះថា ឈាន បឋមជ្ឈាន កើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវនីវរណធម៌ ឈ្មោះថាឈាន ។ បេ ។ អរហត្តមគ្គ កើតឡើង ឈ្មោះថាឈាន ធម្មជាតដុតនូវកិលេសទាំងពួង ឈ្មោះថាឈាន សភាវៈ កាលកើតឡើង ផុតស្រឡះ(ចាកកិលេសទាំងឡាយ) ឈ្មោះថា ឈានវិមោក្ខ សភាវៈ កាលដុតផុតស្រឡះ (ចាកកិលេសទាំងឡាយ) ឈ្មោះថាឈានវិមោក្ខ ធម៌ទាំងឡាយ កើតឡើង សភាវៈដុត (នូវកិលេសទាំងឡាយ) សភាវៈដឹងនូវកិលេសទាំងឡាយ ដែលកើតឡើងផង នូវកិលេសទាំងឡាយដែលឆេះផង ឈ្មោះថា ឈានវិមោក្ខ នេះ ឈានវិមោក្ខ ។

[១៩២] អនុបាទាចិត្តវិមោក្ខ (ការរួចនៃចិត្តមិនមានសេចក្តីប្រកាន់) តើដូចម្តេច ។ អនុបាទាចិត្តវិមោក្ខ ១ បែកចេញជាអនុបាទាចិត្តវិមោក្ខ ១០ អនុបាទាចិត្តវិមោក្ខ ១០ រួមមកជាអនុបាទាចិត្តវិមោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

៣១១



សិយាតិ កាចញ្ច សិយា ។ អនិច្ចានុបស្សនាញាណំ និច្ចតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ ទុក្ខានុបស្សនាញាណំ សុខតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ អនត្តានុបស្សនាញាណំ អត្តតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ និព្វិទានុបស្សនាញាណំ នន្ទិយា ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ វិរាគានុបស្សនាញាណំ រាគតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ និរោធានុបស្សនាញាណំ សមុទយតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ បដិនិស្សគ្គានុបស្សនាញាណំ អាទានតោ ឧប្បាទា មុច្ចតីតិ អនុប្បាទចិត្តស្ស វិមោក្ខោ

អនិច្ចតោ មនសិករោតោ កឹពហុលំ ចិត្តំ ហោតិ ទុក្ខតោ មនសិករោតោ កឹពហុលំ ចិត្តំ ហោតិ អនត្តតោ មនសិករោតោ កឹពហុលំ ចិត្តំ ហោតិ ។ អនិច្ចតោ មនសិករោតោ អធិមោក្ខពហុលំ[២] ហោតិ ទុក្ខតោ មនសិករោតោ បស្សទ្ធិពហុលំ[៣] ហោតិ អនត្តតោ មនសិករោតោ វេទពហុលំ[៤] ហោតិ ។

---

១ ឱ. ឧបដ្ឋហន្តិ ។ ២ ឱ. ម. អធិមោក្ខពហុលំ ចិត្តំ ។ ៣-៤ ឱ. ម. ឯត្ថន្តរេ ចិត្តន្តិ ទិស្សតិ ។

[២០៨] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច ។ កាលព្រះយោ-គាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយ ប្រាកដឡើង ថាអស់ទៅ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សង្ខារទាំងឡាយ ប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សង្ខារទាំងឡាយ ប្រាកដឡើង ថាសូន្យ ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តច្រើនដោយអ្វី កាលលោក ធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយអ្វី កាលលោក ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយអ្វី ។ កាលព្រះយោ-គាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តច្រើនដោយអធិមោក្ខ (សេចក្ដីជឿស៊ប់) កាលលោក ធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយបស្សទ្ធិ (សេចក្ដីស្ងប់) កាលលោក ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយវេទៈ[១] ។

១ វេទៈ សំដៅយកញាណក្នុងមគ្គ ៤ ។ អដ្ឋកថា ។

អនិច្ចតោ មនសិករោន្តោ អធិមោក្ខពហុលោ កតមំ វិមោក្ខំ បដិលភតិ ទុក្ខតោ មនសិករោ-ន្តោ បស្សទ្ធិពហុលោ កតមំ វិមោក្ខំ បដិលភតិ អនត្តតោ មនសិករោន្តោ វេទពហុលោ កតមំ វិមោក្ខំ បដិលភតិ ។ អនិច្ចតោ មនសិករោន្តោ អធិមោក្ខពហុលោ អនិមិត្តវិមោក្ខំ បដិលភតិ ទុក្ខ-តោ មនសិករោន្តោ បស្សទ្ធិពហុលោ អប្បណិហិត-វិមោក្ខំ បដិលភតិ អនត្តតោ មនសិករោន្តោ វេទ-ពហុលោ សុញ្ញតវិមោក្ខំ បដិលភតិ ។

[២០៩] អនិច្ចតោ មនសិករោតោ អធិមោក្ខព-ហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជា-តប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្ស-យប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯ-ករសា ហោន្តិ កេនដ្ឋេន ភាវនា កោ ភាវេតិ ។

ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអ-ធិមោក្ខ តើនឹងបាននូវវិមោក្ខដូចម្តេច កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើនឹងបាននូវវិមោក្ខដូចម្តេច កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទ តើនឹងបាននូវវិមោក្ខដូចម្តេច ។ ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ រមែងបាននូវអនិមិត្តវិមោក្ខ[១] កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបាននូវអប្បណិហិតវិមោក្ខ[២] កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ រមែងបាននូវសុញ្ញតវិមោក្ខ[៣] ។

[២០៩] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើមានវិមោក្ខដូចម្តេច ជាអធិបតី ។ ក្នុងភាវនា វិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមវិមោក្ខជាអធិបតីនោះ ទាំងជាសហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាដូចម្តេច បុគ្គលណាចម្រើន ។

១. ២. ៣. ទាំង ៣ ស័ព្ទនេះជាឈ្មោះនៃអរិយមគ្គ ដោយអត្ថថារួចចាកកិលេស ។ វិសុទ្ធិមគ្គ ។

ទុក្ខតោ មនសិករោតោ បស្សទ្ធិពហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ កេនដ្ឋេន ភាវនា កោ ភាវេតិ ។

អនត្តតោ មនសិករោតោ វេទពហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ កេនដ្ឋេន ភាវនា កោ ភាវេតិ ។

អនិច្ចតោ មនសិករោតោ អធិមោក្ខពហុលស្ស អនិមិត្តោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបសទ្ធិ តើវិមោក្ខអ្វី ជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថជាដូចម្តេច បុគ្គលណា ចម្រើន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើវិមោក្ខអ្វី ជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថជាដូចម្តេច បុគ្គលណា ចម្រើន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ អនិមិត្តវិមោក្ខ ជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ

ហោន្តិ ឯការសង្គេន ភាវនា យោ សម្មាបដិបន្នោ សោ ភាវេតិ នត្ថិ មិច្ឆាបដិបន្នស្ស វិមោក្ខភាវនា ។

ទុក្ខតោ មនសិការោតោ បស្សទ្ធិពហុលស្ស អប្បណិហិតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហ-ជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯការសា ហោន្តិ ឯការសង្គេន ភាវនា យោ សម្មាបដិបន្នោ សោ ភាវេតិ នត្ថិ មិច្ឆាបដិបន្នស្ស វិមោក្ខភាវនា ។

អនត្តតោ មនសិការោតោ វេទពហុលស្ស សុ-ញ្ញតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯការសា ហោន្តិ

មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះ ឈ្មោះថាចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ អប្បណិហិតវិមោក្ខ ជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះ ឈ្មោះថាចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ សុញ្ញតវិមោក្ខ ជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ

ឯការសដ្ឋេន ភាវនា យោ សម្មាបដិបន្នោ សោ ភាវេតិ នត្ថិ មិច្ឆាបដិបន្នស្ស វិមោក្ខភាវនា ។

[២១០] អនិច្ចតោ មនសិការោតោ អនិមោក្ខព-ហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជា-តប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្ស-យប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯក-រសា ហោន្តិ ឯការសដ្ឋេន ភាវនា បដិវេធកាលេ កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធា-យ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្ប-ច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្ប-ច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ កេនដ្ឋេន ភាវនា កេនដ្ឋេន បដិវេធោ ។

ភាវនា ដោយអត្ថថាមានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះឈ្មោះថាចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

[២១០] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើវិមោក្ខអ្វី ជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ, ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វី ជាអធិបតី, ក្នុងការត្រាស់ដឹង មានវិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាដូចម្តេច ការត្រាស់ដឹង ដោយអត្ថថាដូចម្តេច ។

៣៤៩



ទុក្ខតោ មនសិករោតោ បស្សទ្ធិពហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ ឯករសដ្ឋេន ភាវនា បដិវេធកាលេ កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ កេនដ្ឋេន ភាវនា កេនដ្ឋេន បដិវេធោ ។

អនត្តតោ មនសិករោតោ វេទពហុលស្ស កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ ឯករសដ្ឋេន ភាវនា

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើវិមោក្ខអ្វីជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខ ជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាមានកិច្ចតែមួយ, ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វី ជាអធិបតី, ក្នុងការត្រាស់ដឹង តើវិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយ-ប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាដូចម្តេច ការត្រាស់ដឹង ដោយអត្ថថាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើវិមោក្ខអ្វី ជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាម នូវវិមោក្ខ ជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្ត-ប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ,

បដិវេធកាលេ កតមោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធាយ កតិ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ កេនដ្ឋេន ភាវនា កេនដ្ឋេន បដិវេធោ ។

អនិច្ចតោ មនសិការោតោ អធិមោក្ខពហុលស្ស អនិមិត្តោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ បដិវេធកាលេបិ អនិមិត្តោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ ឯករសដ្ឋេន ភាវនា ឧស្សដ្ឋេន បដិវេធោ ឯវំ បដិវិជ្ឈន្តោបិ ភាវេតិ ភាវេន្តោបិ បដិវិជ្ឈតិ ។

ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វី ជាអធិបតី, ក្នុងការត្រាស់ដឹង វិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាដូចម្ដេច ការត្រាស់ដឹង ដោយអត្ថថាដូចម្ដេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ អនិមិត្តវិមោក្ខ ជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានអនិមិត្តវិមោក្ខជាអធិបតីដែរ ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ ការត្រាស់ដឹង ដោយអត្ថថាឃើញ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើន ក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹង ក៏បាន ។

ទុក្ខតោ មនសិករោតោ បស្សទ្ធិពហុលស្ស អប្បណិហិតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ បដិវេធកាលេបិ អប្បណិហិតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ ឯករសដ្ឋេន ភាវនា ទស្សនដ្ឋេន បដិវេធោ ឯវំ បដិវិជ្ឈន្តោបិ ភាវេតិ ភាវេន្តោបិ បដិវិជ្ឈតិ ។

អនត្តតោ មនសិករោតោ វេទពហុលស្ស សុញ្ញតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ភាវនាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ អប្បណិហិតវិមោក្ខជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានអប្បណិហិតវិមោក្ខជាអធិបតីដែរ, ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ ការត្រាស់ដឹង ដោយអត្ថថាឃើញ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើន ក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹង ក៏បាន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ សុញ្ញតវិមោក្ខជាអធិបតី, ក្នុងភាវនា មានវិមោក្ខ ២ ប្រព្រឹត្តទៅតាម នូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ

អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ បដិវេធកាលេបិ សុញ្ញតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ បដិវេធាយ ទ្វេ វិមោក្ខា តទន្វយា ហោន្តិ សហជាតប្បច្ចយា ហោន្តិ អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ សម្បយុត្តប្បច្ចយា ហោន្តិ ឯករសា ហោន្តិ ឯករសដ្ឋេន ភាវនា ទស្សនដ្ឋេន បដិវេធោ ឯវំ បដិវិជ្ឈន្តោបិ ភាវេតិ ភាវេន្តោបិ បដិវិជ្ឈតិ ។

[២១១] អនិច្ចតោ មនសិករោតោ កតមោ វិមោក្ខោ អធិមត្តោ ហោតិ កតម[១]វិមោក្ខស្ស អធិមត្តត្តា សទ្ធាធិមុត្តោ ហោតិ ទុក្ខតោ មនសិករោតោ កតមោ វិមោក្ខោ អធិមត្តោ ហោតិ កតមវិមោក្ខស្ស អធិមត្តត្តា កាយសក្ខិ ហោតិ អនត្តតោ មនសិករោតោ កតមោ វិមោក្ខោ អធិមត្តោ ហោតិ កតមវិមោក្ខស្ស អធិមត្តត្តា ទិដ្ឋិប្បត្តោ ហោតិ ។

---

១ ម. កតមំ ។

អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានសុញ្ញតវិមោក្ខ ជាអធិបតីដែរ ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថថាមានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថាឃើញ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើន ក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹង ក៏បាន ។

[២១១] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង តើវិមោក្ខអ្វី ដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាសទ្ធាធិមុត្ត តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើវិមោក្ខអ្វីដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាកាយសក្ខិ តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើវិមោក្ខអ្វីដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាទិដ្ឋិប្បត្តៈ តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង ។

អនិច្ចតោ មនសិករោតោ អនិមិត្តោ វិមោក្ខោ អធិមត្តោ ហោតិ អនិមិត្តវិមោក្ខស្ស អធិមត្តត្តា សទ្ធាធិមុត្តោ ហោតិ ទុក្ខតោ មនសិករោតោ អប្បណិហិតោ វិមោក្ខោ អធិមត្តោ ហោតិ អប្បណិហិតវិមោក្ខស្ស អធិមត្តត្តា កាយសក្ខិ ហោតិ អនត្តតោ មនសិករោតោ សុញ្ញតោ វិមោក្ខោ អធិមត្តោ ហោតិ សុញ្ញតវិមោក្ខស្ស អធិមត្តត្តា ទិដ្ឋិប្បត្តោ ហោតិ ។

[២១២] សទ្ទហន្តោ អធិមុត្តោតិ[១] សទ្ធាធិមុត្តោ ផុដ្ឋត្តា សច្ឆិករោតីតិ[២] កាយសក្ខិ ទិដ្ឋត្តា បត្តោតិ ទិដ្ឋិប្បត្តោ សទ្ទហន្តោ អធិមុច្ចតីតិ សទ្ធាធិមុត្តោ ឈានផស្សំ បឋមំ ផុសតិ បច្ឆា និរោធំ និព្វានំ សច្ឆិករោតីតិ កាយសក្ខិ ទុក្ខា សង្ខារា សុខោ និរោធោតិ ញាណំ[៣] ហោតិ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផស្សិតំ បញ្ញាយាតិ ទិដ្ឋិប្បត្តោ ។

---

១ ឱ. ម. វិមុត្តោតិ ។ ២ ម. សច្ឆិកតោតិ ។ ៣ ឱ. ម. ញាតំ ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង អនិមិត្តវិមោក្ខ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាសទ្ធាធិមុត្ត ព្រោះមានអនិមិត្តវិមោក្ខដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ អប្បណិហិត-វិមោក្ខ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាកាយសក្ខិ ព្រោះមានអប្បណិហិតវិមោក្ខដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សុញ្ញតវិមោក្ខ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថាទិដ្ឋិប្បត្តៈ ព្រោះមានសុញ្ញតវិមោក្ខដ៏ក្រៃលែង ។

[២១២] ព្រះយោគាវចរកាលជឿ ចុះចិត្តស៊ប់ ហេតុនោះ ឈ្មោះថាសទ្ធាធិមុត្តបុគ្គល ព្រះយោគាវចរធ្វើឲ្យជាក់ច្បាស់ ព្រោះពាល់ត្រូវ (នូវឈាន) ហេតុនោះ ឈ្មោះថាកាយសក្ខិបុគ្គល ព្រះយោគាវចរសម្រេចហើយ ព្រោះយល់ត្រូវ ហេតុនោះ ឈ្មោះថាទិដ្ឋិប្បត្តបុគ្គល ព្រះយោគាវចរកាលជឿ ចុះចិត្តស៊ប់ ហេតុនោះ ឈ្មោះថាសទ្ធាធិមុត្ត-បុគ្គល ព្រះយោគាវចរពាល់ត្រូវជាដំបូងនូវឈានផស្សៈ ក្នុងកាលខាងក្រោយទើបធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានជាទីរលត់ (កិលេស) ហេតុនោះ ឈ្មោះថាកាយសក្ខិបុគ្គល ញាណ គឺជាធម្មជាតដែលខ្លួនឃើញហើយ ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ថាសង្ខារជាទុក្ខ និរោធជាសុខ ហេតុនោះ ឈ្មោះថាទិដ្ឋិប្បត្តបុគ្គល ។

យេ ហិ កេចិ នេក្ខម្មំ ភាវិតា វា ភាវេន្តិ វា ភាវិស្សន្តិ វា ។ បេ ។ សព្វេ តេ អនិមិត្តវិមោក្ខ-ស្ស វសេន សទ្ធាធិមុត្តា អប្បណិហិតវិមោក្ខស្ស វសេន កាយសក្ខី សុញ្ញតវិមោក្ខស្ស វសេន ទិដ្ឋិ-ប្បត្តា ។ យេ ហិ កេចិ អព្យាបាទំ ។ បេ ។ អា-លោកសញ្ញំ អវិក្ខេបំ ។ បេ ។

យេ ហិ កេចិ ទុក្ខំ បរិជានន្តិ សមុទយំ បជ-ហន្តិ និរោធំ សច្ឆិករោន្តិ មគ្គំ ភាវេន្តិ សព្វេ តេ អនិមិត្តវិមោក្ខស្ស វសេន សទ្ធាធិមុត្តា អប្បណិហិ-តវិមោក្ខស្ស វសេន កាយសក្ខី សុញ្ញតវិមោក្ខ-ស្ស វសេន ទិដ្ឋិប្បត្តា ។

យោគាវចរណាមួយ អប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី នូវនេក្ខម្មៈ ។ បេ ។ យោគាវចរ ទាំងអស់នោះ ឈ្មោះថាសទ្ធាធិមុត្ត ដោយអំណាច នៃអនិមិត្តវិមោក្ខ ឈ្មោះថាកាយសក្ខិ ដោយអំណាច នៃអប្បណិហិតវិមោក្ខ ឈ្មោះថាទិដ្ឋិប្បត្តៈ ដោយអំណាច នៃសុញ្ញត-វិមោក្ខ ។ យោគាវចរណាមួយ (អប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី) នូវអព្យាបាទ ។ បេ ។ នូវអាលោកសញ្ញា នូវអវិក្ខេបៈ ។ បេ ។

យោគាវចរ ណាមួយ កំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ យោគាវចរ ទាំងអស់នោះ ឈ្មោះថាសទ្ធាធិមុត្ត ដោយអំណាច នៃអនិមិត្តវិមោក្ខ ឈ្មោះថា កាយសក្ខិ ដោយអំណាច នៃអប្បណិហិតវិមោក្ខ ឈ្មោះថាទិដ្ឋិប្បត្តៈ ដោយអំណាច នៃសុញ្ញតវិមោក្ខ ។

[២១៣] កតិហាការេហិ សច្ចប្បដិវេធោ ហោតិ កតិហាការេហិ សច្ចានិ បដិវិជ្ឈតិ ។ ចតូហាការេហិ សច្ចប្បដិវេធោ ហោតិ ចតូហាការេហិ សច្ចានិ បដិវិជ្ឈតិ ទុក្ខសច្ចំ បរិញ្ញាបដិវេធំ បដិវិជ្ឈតិ សមុទយសច្ចំ បហានប្បដិវេធំ បដិវិជ្ឈតិ និរោធសច្ចំ សច្ឆិកិរិយាបដិវេធំ បដិវិជ្ឈតិ មគ្គសច្ចំ ភាវនាបដិវេធំ បដិវិជ្ឈតិ ឥមេហិ ចតូហាការេហិ សច្ចប្បដិវេធោ ហោតិ ឥមេហិ ចតូហាការេហិ សច្ចានិ បដិវិជ្ឈន្តោ អនិមិត្តវិមោក្ខស្ស វសេន សទ្ធានិមុត្តោ អប្បណិហិតវិមោក្ខស្ស វសេន កាយសក្ខិ សុញ្ញតវិមោក្ខស្ស វសេន ទិដ្ឋិប្បត្តោ ។

កតិហាការេហិ សច្ចប្បដិវេធោ ហោតិ កតិហាការេហិ សច្ចានិ បដិវិជ្ឈតិ ។ នវហាការេហិ សច្ចប្បដិវេធោ ហោតិ នវហាការេហិ សច្ចានិ បដិវិជ្ឈតិ ទុក្ខសច្ចំ បរិញ្ញាបដិវេធំ បដិវិជ្ឈតិ ។ បេ ។

[២១៣] ការត្រាស់ដឹង នូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹង នូវសច្ចៈ ដោយអាការ ៤ យ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ក៏ដោយ អាការ ៤ យ៉ាងដែរ គឺ បុគ្គលត្រាស់ដឹង នូវទុក្ខសច្ច ដែលជាបរិញ្ញា-បដិវេធ ១ ត្រាស់ដឹង នូវសមុទយសច្ច ដែលជាបហានប្បដិវេធ ១ ត្រាស់ដឹងនូវនិរោធសច្ច ដែលជាសច្ឆិកិរិយាបដិវេធ ១ ត្រាស់ដឹង នូវមគ្គ-សច្ច ដែលជាភាវនាបដិវេធ ១ នេះឯង ការត្រាស់ដឹងនូវសច្ចៈ ដោយ អាការ ៤ យ៉ាង នេះឯង ព្រះយោគាវចរកាលត្រាស់ដឹងនូវសច្ចៈ ដោយ អាការទាំង ៤ យ៉ាង ដែលឈ្មោះថាសទ្ធាធិមុត្ត ដោយអំណាចនៃ អនិមិត្តវិមោក្ខ ឈ្មោះថាកាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថាទិដ្ឋិប្បត្តៈ ដោយអំណាចនៃសុញ្ញតវិមោក្ខ ។

ការត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹងនូវសច្ចៈ ដោយ អាការ ៩ យ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាងដែរ គឺ បុគ្គលត្រាស់ដឹង នូវទុក្ខសច្ច ដែលជាបរិញ្ញាបដិវេធ ១ ។ បេ ។

សច្ចិកិរិយាបដិវេធោ ច និរោធស្ស ឥមេហិ នវ-
ហាការេហិ សច្ចប្បដិវេធោ ហោតិ ឥមេហិ នវ-
ហាការេហិ សច្ចានិ បដិវិជ្ឈន្តោ អនិមិត្តវិមោក្ខស្ស
វសេន សទ្ធាធិមុត្តោ អប្បណិហិតវិមោក្ខស្ស
វសេន កាយសក្ខិ សុញ្ញតវិមោក្ខស្ស វសេន
ទិដ្ឋិប្បត្តោ ។

[២១៤] អនិច្ចតោ មនសិករោន្តោ កតមេ
ធម្មេ យថាភូតំ បជានាតិ បស្សតិ កថំ សម្មាទ-
ស្សនំ ហោតិ កថំ តទន្វយេន សព្វេ សង្ខារា
អនិច្ចតោ សុទិដ្ឋា ហោន្តិ កត្ថ កង្ខា បហីយតិ ។
ទុក្ខតោ មនសិករោន្តោ កតមេ ធម្មេ
យថាភូតំ បជានាតិ បស្សតិ កថំ សម្មាទស្សនំ
ហោតិ កថំ តទន្វយេន សព្វេ សង្ខារា ទុក្ខតោ
សុទិដ្ឋា ហោន្តិ កត្ថ កង្ខា បហីយតិ ។

ការត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ១ នេះឯង ការត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាង នេះឯង យោគាវចរកាលត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាង ដែលឈ្មោះថាសទ្ធាធិមុត្ត ដោយអំណាចនៃអនិមិត្តវិមោក្ខ ឈ្មោះថាកាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថាទិដ្ឋិប្បត្តៈ ដោយអំណាចនៃសុញ្ញតវិមោក្ខ ។

[២១៤] យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងដឹង ឃើញ តាមពិត នូវធម៌ទាំងឡាយ តើដូចម្ដេច ការឃើញប្រពៃ តើដូចម្ដេច សង្ខារទាំងពួង ដែលយោគាវចរ ឃើញប្រពៃហើយ ថាមិនទៀង ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ តើដូចម្ដេច សេចក្ដីសង្ស័យក្នុងធម៌ ដូចម្ដេច ដែលយោគាវចរ លះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងដឹង ឃើញ តាមពិត នូវធម៌ទាំងឡាយ តើដូចម្ដេច ការឃើញប្រពៃ តើដូចម្ដេច សង្ខារទាំងពួង ដែលយោគាវចរ ឃើញប្រពៃហើយ ថាជាទុក្ខ ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ តើដូចម្ដេច សេចក្ដីសង្ស័យក្នុងធម៌ ដូចម្ដេច ដែលយោគាវចរ លះបង់បាន ។

៣៤៧



អនត្តតោ មនសិករោន្តោ កតមេ ធម្មេ យថាភូតំ បជានាតិ បស្សតិ កថំ សម្មាទស្សនំ ហោតិ កថំ តទន្វយេន សព្វេ ធម្មា[១] អនត្តតោ សុទិដ្ឋា ហោន្តិ កត្ថ កង្ខា បហីយតិ ។

អនិច្ចតោ មនសិករោន្តោ និមិត្តំ យថាភូតំ បជានាតិ បស្សតិ តេន វុច្ចតិ សម្មាទស្សនំ ឯវំ តទន្វយេន សព្វេ សង្ខារា អនិច្ចតោ សុទិដ្ឋា ហោន្តិ ឯត្ថ កង្ខា បហីយតិ ។

ទុក្ខតោ មនសិករោន្តោ បវត្តំ យថាភូតំ បជានាតិ បស្សតិ តេន វុច្ចតិ សម្មាទស្សនំ ឯវំ តទន្វយេន សព្វេ សង្ខារា ទុក្ខតោ សុទិដ្ឋា ហោន្តិ ឯត្ថ កង្ខា បហីយតិ ។

---

១ ឱ. ម. សង្ខារា អនត្តតោ ។

យោគាវចរ កាលធ្វើទុក ក្នុងចិត្ត ថាមិនមែនខ្លួន រមែងដឹង ឃើញ តាមពិត នូវធម៌ទាំងឡាយ តើដូចម្តេច ការឃើញប្រពៃ តើដូចម្តេច ធម៌ទាំងពួង ដែលយោគាវចរ ឃើញប្រពៃហើយ ថាមិនមែនខ្លួន ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ តើដូចម្តេច សេចក្តីជឿងឆ្ងល់ក្នុងធម៌ ដូចម្តេច ដែលយោគាវចរលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងដឹង ឃើញតាមពិត នូវនិមិត្ត ព្រោះតែហេតុនោះ លោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ សង្ខារទាំងពួង ឈ្មោះថាយោគាវចរឃើញប្រពៃហើយ ថាមិនទៀង ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីជឿងឆ្ងល់ក្នុងសង្ខារទាំងនុ៎ះ ក៏លោកលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងដឹង ឃើញតាមពិត នូវបវត្តៈ (ការប្រព្រឹត្តទៅ) ព្រោះតែហេតុនោះ លោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ សង្ខារទាំងពួង ឈ្មោះថាយោគាវចរឃើញប្រពៃហើយ ថាជាទុក្ខ ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីជឿងឆ្ងល់ក្នុងសង្ខារទាំងនុ៎ះ ក៏លោកលះបង់បាន ។

អនត្តតោ មនសិករោន្តោ និមិត្តញ្ច បវត្តញ្ច យថាភូតំ បជានាតិ បស្សតិ តេន វុច្ចតិ សម្មាទស្សនំ ឯវំ តទនុយេន សព្វេ ធម្មា អនត្តតោ សុទិដ្ឋា ហោន្តិ ឯត្ថ កង្ខា បហីយតិ ។

យញ្ច យថាភូតំ ញាណំ យញ្ច សម្មាទស្សនំ យា ច កង្ខាវិតរណា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ យញ្ច យថាភូតំ ញាណំ យញ្ច សម្មាទស្សនំ យា ច កង្ខាវិតរណា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។

[២១៩] អនិច្ចតោ មនសិករោតោ កឹ ភយតោ ឧបដ្ឋាតិ ទុក្ខតោ មនសិករោតោ កឹ ភយតោ ឧបដ្ឋាតិ អនត្តតោ មនសិករោតោ កឹ ភយតោ ឧបដ្ឋាតិ ។ អនិច្ចតោ មនសិករោតោ និមិត្តំ

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងដឹងឃើញតាមពិត នូវនិមិត្តផង នូវបវត្តៈផង ព្រោះតែហេតុនោះ លោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ ធម៌ទាំងពួង ឈ្មោះថាយោគាវចរឃើញប្រពៃហើយ ថាមិនមែនខ្លួន ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីសង្ស័យ ក្នុងធម៌ទាំងនុ៎ះ ក៏លោកលះបង់បាន ។

ការដឹងតាមពិតណាក្តី ការឃើញប្រពៃណាក្តី ការឆ្លងចាកសេចក្តីសង្ស័យណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ការដឹងតាមពិតណាក្តី ការឃើញប្រពៃណាក្តី ការឆ្លងចាកសេចក្តីសង្ស័យណាក្តី ធម៌ទាំងនេះ មានសេចក្តីដូចគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

[២១៥] កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង តើមានអ្វីប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើមានអ្វីប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើមានអ្វីប្រាកដឡើង ថាជាភ័យ ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង

៣៤៩



ភយតោ ឧបដ្ឋាតិ ទុក្ខតោ មនសិករោតោ បវត្តំ ភយតោ ឧបដ្ឋាតិ អនត្តតោ មនសិករោតោ និមិ-តញ្ច បវត្តញ្ច ភយតោ ឧបដ្ឋាតិ ។

យា ច ភយតុបដ្ឋានេ បញ្ញា យញ្ច អាទីនវេ ញាណំ យា ច និព្វិទា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នា-នន្តិ ។ យា ច ភយតុបដ្ឋានេ បញ្ញា យញ្ច អាទីន-វេ ញាណំ យា ច និព្វិទា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។

យា ច អនត្តានុបស្សនា យា ច សុញ្ញតានុប-ស្សនា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ យា ច អនត្តានុបស្សនា យា ច សុញ្ញតានុបស្សនា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។

មាននិមិត្តប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ មានបវត្តៈប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន មាននិមិត្តផង មានបវត្តៈផង ប្រាកដឡើង ថាជាភ័យ ។

បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឯណាក្តី[១] ការដឹងក្នុងទោស ឯណាក្តី[២] ការនឿយណាយឯណាក្តី[៣] តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឯណាក្តី ការដឹងក្នុងទោស ឯណាក្តី ការនឿយណាយឯណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

ការយល់ឃើញថាមិនមែនខ្លួន ឯណាក្តី ការយល់ឃើញថាសូន្យ ឯណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ការយល់ឃើញថាមិនមែនខ្លួន ឯណាក្តី ការយល់ឃើញថាសូន្យ ឯណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

---

១-២-៣ ទាំង ៣ សព្ទនេះ គឺជាឈ្មោះភយតូបដ្ឋានញ្ញាណ អាទីនវញ្ញាណ និព្វិទាញ្ញាណ នោះឯង ។

[២១៦] អនិច្ចតោ មនសិការោតោ កឹ បដិស-
ង្ខា ញាណំ ឧប្បជ្ជតិ ទុក្ខតោ មនសិការោតោ កឹ
បដិសង្ខា ញាណំ ឧប្បជ្ជតិ អនត្តតោ មនសិការោ-
តោ កឹ បដិសង្ខា ញាណំ ឧប្បជ្ជតិ ។ អនិច្ចតោ
មនសិការោតោ និមិត្តំ បដិសង្ខា ញាណំ ឧប្បជ្ជតិ
ទុក្ខតោ មនសិការោតោ បវត្តំ បដិសង្ខា ញាណំ
ឧប្បជ្ជតិ អនត្តតោ មនសិការោតោ និមិត្តញ្ច បវ-
ត្តញ្ច បដិសង្ខា ញាណំ ឧប្បជ្ជតិ ។

យា ច មុញ្ចិតុកម្យតា យា ច បដិសង្ខានុ-
បស្សនា យា ច សង្ខារុបេក្ខា ឥមេ ធម្មា នាន-
ត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យ-
ញ្ជនមេវ នានន្តិ ។ យា ច មុញ្ចិតុកម្យតា យា
ច បដិសង្ខានុបស្សនា យា ច សង្ខារុបេក្ខា ឥមេ
ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។

[២១៦] កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណកើតឡើង ព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ញាណកើតឡើង ព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ញាណកើតឡើង ព្រោះពិចារណានូវអ្វី ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណកើតឡើង ព្រោះពិចារណានូវនិមិត្ត កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ញាណកើតឡើង ព្រោះពិចារណានូវបវត្តៈ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ញាណកើតឡើង ព្រោះពិចារណា នូវនិមិត្តនិងបវត្តៈ ។

មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

៣៦១



អនិច្ចតោ មនសិករោតោ កុតោ ចិត្តំ វុដ្ឋាតិ កត្ថ ចិត្តំ បក្ខន្ទតិ ទុក្ខតោ មនសិករោតោ កុតោ ចិត្តំ វុដ្ឋាតិ កត្ថ ចិត្តំ បក្ខន្ទតិ អនត្តតោ មនសិករោតោ កុតោ ចិត្តំ វុដ្ឋាតិ កត្ថ ចិត្តំ បក្ខន្ទតិ ។ អនិច្ចតោ មនសិករោតោ និមិត្តា ចិត្តំ វុដ្ឋាតិ អនិមិត្តេ ចិត្តំ បក្ខន្ទតិ ទុក្ខតោ មនសិករោតោ បវត្តា ចិត្តំ វុដ្ឋាតិ អប្បវត្តេ ចិត្តំ បក្ខន្ទតិ អនត្តតោ មនសិករោតោ និមិត្តា ច បវត្តា ច ចិត្តំ វុដ្ឋាតិ អនិមិត្តេ អប្បវត្តេ និរោធនិព្វានធាតុយា ចិត្តំ បក្ខន្ទតិ ។

យា ច ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា យេ ច គោត្រភូធម្មា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ យា ច ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា យេ ច គោត្រភូធម្មា ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។

កាលយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តចេញចាកនិមិត្ត ចិត្តស្ទុះទៅក្នុងអនិមិត្ត កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តចេញចាកបវត្តៈ ចិត្តស្ទុះទៅក្នុងអប្បវត្តៈ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តចេញចាកនិមិត្តផង ចេញចាកបវត្តៈផង ចិត្តស្ទុះទៅក្នុងអនិមិត្តផង ក្នុងអប្បវត្តៈ គឺនិរោធនិព្វានធាតុផង ។

បញ្ញាក្នុងការងាកចេញ បែរចេញ ចាកសង្ខារនិមិត្តខាងក្រៅ ឯណាក្តី គោត្រភូធម៌ទាំងឡាយឯណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញា ក្នុងការងាកចេញ បែរចេញ ចាកសង្ខារនិមិត្តខាងក្រៅឯណាក្តី គោត្រភូធម៌ទាំងឡាយឯណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

អនិច្ចតោ មនសិករោន្តោ កតមវិមោក្ខេន វិមុច្ចតិ ទុក្ខតោ មនសិករោន្តោ កតមវិមោក្ខេន វិមុច្ចតិ អនត្តតោ មនសិករោន្តោ កតមវិមោក្ខេន វិមុច្ចតិ ។ អនិច្ចតោ មនសិករោន្តោ អនិមិត្តវិ-មោក្ខេន វិមុច្ចតិ ទុក្ខតោ មនសិករោន្តោ អប្បណិ-ហិតវិមោក្ខេន វិមុច្ចតិ អនត្តតោ មនសិករោន្តោ សុញ្ញតវិមោក្ខេន វិមុច្ចតិ ។

យា ច ទុភតោវុដ្ឋានវិវដ្ដនេ បញ្ញា យញ្ច មគ្គេ ញាណំ ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ យា ច ទុភតោវុដ្ឋានវិវដ្ដនេ បញ្ញា យញ្ច មគ្គេ ញាណំ ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងរួច (ចាកកិលេស) ដោយវិមោក្ខអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងរួច (ចាកកិលេស) ដោយវិមោក្ខអ្វី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងរួច (ចាកកិលេស) ដោយវិមោក្ខអ្វី ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងរួច (ចាកកិលេស) ដោយអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ រមែងរួច (ចាកកិលេស) ដោយអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងរួច (ចាកកិលេស) ដោយសុញ្ញតវិមោក្ខ ។

បញ្ញាក្នុងការងាកចេញ បែរចេញ ចាកហេតុទាំងពីរណាក្តី[១] ការដឹងក្នុងមគ្គណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញាក្នុងការងាកចេញ បែរចេញ ចាកហេតុទាំងពីរណាក្តី ការដឹងក្នុងមគ្គណាក្តី ធម៌ទាំងនេះ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

---

១ បញ្ញាជ្រាបច្បាស់ក្នុងការងាកចេញ បែរចេញ ចាកកិលេសនិងខន្ធដែលប្រព្រឹត្តទៅតាមកិលេសនោះ ព្រោះផ្តាច់បង់នូវកិលេស ១ ចាកសង្ខារនិមិត្តជាខាងក្រៅ ព្រោះធ្វើព្រះនិព្វានជាអារម្មណ៍ ១ ឈ្មោះថាឧភតោវុដ្ឋានវិវដ្តនប្បញ្ញា បានដល់មគ្គញ្ញាណ ។ អដ្ឋកថា ។

[២១៧] កតិហាការេហិ តយោ វិមោក្ខា នានាខណេ ហោន្តិ កតិហាការេហិ តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ។ ចតូហាការេហិ តយោ វិមោក្ខា នានាខណេ ហោន្តិ សត្តហាការេហិ តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ។

កតមេហិ ចតូហាការេហិ តយោ វិមោក្ខា នានាខណេ ហោន្តិ អាធិបតេយ្យដ្ឋេន អធិដ្ឋានដ្ឋេន អភិនីហារដ្ឋេន និយ្យានដ្ឋេន ។

កថំ អាធិបតេយ្យដ្ឋេន តយោ វិមោក្ខា នានាខណេ ហោន្តិ ។ អនិច្ចតោ មនសិករោតោ អនិមិត្តោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ទុក្ខតោ មនសិករោតោ អប្បណិហិតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ អនត្តតោ មនសិករោតោ សុញ្ញតោ វិមោក្ខោ អាធិបតេយ្យោ ហោតិ ឯវំ អាធិបតេយ្យដ្ឋេន តយោ វិមោក្ខា នានាខណេ ហោន្តិ ។

[២១៧] វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា តើដោយអាការប៉ុន្មានយ៉ាង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា តើដោយអាការប៉ុន្មានយ៉ាង ។ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអាការ ៧ យ៉ាង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាង តើអ្វីខ្លះ គឺ ដោយអត្ថថាជាអធិបតី ១ ដោយអត្ថថាអធិដ្ឋាន ១ ដោយអត្ថថាបង្អោន ១ ដោយអត្ថថាចេញទៅ ១ ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាជាអធិបតី តើដូចម្តេច ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង មានអនិមិត្តវិមោក្ខ ជាអធិបតី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ មានអប្បណិហិតវិមោក្ខ ជាអធិបតី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន មានសុញ្ញតវិមោក្ខជាអធិបតី វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាជាអធិបតី យ៉ាងនេះឯង ។

កថំ អធិដ្ឋានដ្ឋេន តយោ វិមោក្ខា នានាខ-ណោ ហោន្តិ ។ អនិច្ចតោ មនសិករោន្តោ អនិ-មិត្តវិមោក្ខស្ស វសេន ចិត្តំ អធិដ្ឋាតិ ទុក្ខតោ មនសិករោន្តោ អប្បណិហិតវិមោក្ខស្ស វសេន ចិត្តំ អធិដ្ឋាតិ អនត្តតោ មនសិករោន្តោ សុញ្ញតវិ-មោក្ខស្ស វសេន ចិត្តំ អធិដ្ឋាតិ ឯវំ អធិដ្ឋានដ្ឋេន តយោ វិមោក្ខា នានាខណោ ហោន្តិ ។

កថំ អភិនីហារដ្ឋេន តយោ វិមោក្ខា នានា-ខណោ ហោន្តិ ។ អនិច្ចតោ មនសិករោន្តោ អនិ-មិត្តវិមោក្ខស្ស វសេន ចិត្តំ អភិនីហរតិ ទុក្ខតោ មនសិករោន្តោ អប្បណិហិតវិមោក្ខស្ស វសេន ចិត្តំ អភិនីហរតិ អនត្តតោ មនសិករោន្តោ សុញ្ញតវិមោ-ក្ខស្ស វសេន ចិត្តំ អភិនីហរតិ ឯវំ អភិនីហារដ្ឋេន តយោ វិមោក្ខា នានាខណោ ហោន្តិ ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា អធិដ្ឋាន តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងអធិដ្ឋាននូវចិត្ត ដោយអំណាច នៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងអធិដ្ឋាននូវចិត្ត ដោយអំណាច នៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តែងអធិដ្ឋាននូវចិត្ត ដោយអំណាច នៃសុញ្ញតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាអធិដ្ឋាន យ៉ាងនេះឯង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាបង្អោន តើដូចម្តេច ។ ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងបង្អោនចិត្ត ដោយអំណាច នៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងបង្អោនចិត្ត ដោយអំណាច នៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តែបង្អោនចិត្ត ដោយអំណាចនៃសុញ្ញតវិមោក្ខ វិ-មោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាបង្អោន យ៉ាងនេះឯង ។

កថំ និយ្យានដ្ឋេន តយោ វិមោក្ខា នានាខណេ ហោន្តិ ។ អនិច្ចតោ មនសិករោន្តោ អនិមិត្តវិមោក្ខ-ស្ស វសេន និរោធំ និព្វានំ និយ្យាតិ ទុក្ខតោ មន-សិករោន្តោ អប្បណិហិតវិមោក្ខស្ស វសេន និរោធំ និព្វានំ និយ្យាតិ អនត្តតោ មនសិករោន្តោ សុញ្ញត-វិមោក្ខស្ស វសេន និរោធំ និព្វានំ និយ្យាតិ ឯវំ និយ្យានដ្ឋេន តយោ វិមោក្ខា នានាខណេ ហោន្តិ ឥមេហិ ចតូហាការេហិ តយោ វិមោក្ខា នានាខ-ណេ ហោន្តិ ។

[២១៨] កតមេហិ សត្តហាការេហិ តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ សមោធានដ្ឋេន អធិ-គមដ្ឋេន[១] បដិលាភដ្ឋេន បដិវេធដ្ឋេន សច្ឆិកិរិយ-ដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន ។

---

១ ឱ. ម. អធិគមនដ្ឋេន ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាចេញទៅ តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងចេញទៅកាន់ព្រះនិព្វាន ជាទីរលត់កិលេស ដោយអំណាចនៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងចេញទៅកាន់ព្រះនិព្វាន ជាទីរលត់កិលេស ដោយអំណាចនៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តែងចេញទៅកាន់ព្រះនិព្វាន ជាទីរលត់កិលេស ដោយអំណាចនៃសុញ្ញតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាចេញទៅ យ៉ាងនេះឯង វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាងនេះឯង ។

[២១៨] វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអាការ ៧ យ៉ាង តើអ្វីខ្លះ គឺ ដោយអត្ថថាប្រជុំចុះ ១ ដោយអត្ថថាបានលុះ ១ ដោយអត្ថថាបានចំពោះ ១ ដោយអត្ថថាចាក់ធ្លុះ ១ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថាប៉ះពាល់ ១ ដោយអត្ថថាត្រាស់ដឹង ១ ។

កថំ សមោធានដ្ឋេន អធិគមដ្ឋេន បដិលាភដ្ឋេន បដិវេធដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ។ អនិច្ចតោ មនសិករោន្តោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ យតោ មុច្ចតិ តត្ថ ន បណិទហតីតិ អប្បណិហិតោ វិមោក្ខោ យត្ថ ន បណិទហតិ តេន សុញ្ញោតិ សុញ្ញតោ វិមោក្ខោ យេន សុញ្ញតេន និមិត្តេន អនិមិត្តោតិ អនិមិត្តោ វិមោក្ខោ ឯវំ សមោធានដ្ឋេន អធិគមដ្ឋេន បដិលាភដ្ឋេន បដិវេធដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ទុក្ខតោ មនសិករោន្តោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ

វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថាប្រជុំចុះ ដោយអត្ថថាបានលុះ ដោយអត្ថថាបានចំពោះ ដោយអត្ថថាចាក់ធ្លុះ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថាប៉ះពាល់ ដោយអត្ថថាត្រាស់ដឹង តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងរួចចាកនិមិត្ត (ដោយសភាវៈណា) ហេតុនោះ សភាវៈនោះ ឈ្មោះថា អនិមិត្តវិមោក្ខ យោគាវចរ រួចចាកនិមិត្តណា មិនតាំងនៅ ក្នុងនិមិត្តនោះទៀត ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ យោគាវចរ មិនតម្កល់នៅ ក្នុងនិមិត្តណា សូន្យចាកនិមិត្តនោះ ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយសុញ្ញតនិមិត្តណា ហេតុនោះ និមិត្តនោះ ឈ្មោះថា អនិមិត្តវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថាប្រជុំចុះ ដោយអត្ថថាបានលុះ ដោយអត្ថថាបានចំពោះ ដោយអត្ថថាចាក់ធ្លុះ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថាប៉ះពាល់ ដោយអត្ថថាត្រាស់ដឹង យ៉ាងនេះឯង ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងរួចចាកទីតម្កល់ (ដោយសភាវៈណា) ហេតុនោះ សភាវៈនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ

៣៦៧



យត្ថ ន បណិទហតិ តេន សុញ្ញោតិ សុញ្ញតោ វិមោក្ខោ យេន សុញ្ញតេន និមិត្តេន អនិមិត្តោតិ អនិមិត្តោ វិមោក្ខោ យេន និមិត្តេន អនិមិត្តោ តត្ថ ន បណិទហតីតិ អប្បណិហិតោ វិមោក្ខោ ឯវំ សមោធានដ្ឋេន អធិគមដ្ឋេន បដិលាភដ្ឋេន បដិវេធ-ដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ អនត្តតោ មនសិករោន្តោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ យេន សុញ្ញតេន និមិត្តេន អនិមិត្តោតិ អនិមិត្តោ វិមោក្ខោ យេន និមិត្តេន អនិមិត្តោ តត្ថ ន បណិទហតីតិ អប្បណិហិតោ វិមោក្ខោ យត្ថ ន បណិទហតិ តេន សុញ្ញោតិ សុញ្ញតោ វិមោក្ខោ

យោគាវចរ មិនតាំងនៅ ក្នុងនិមិត្តណា សូន្យចាកនិមិត្តនោះ ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយសុញ្ញតនិមិត្តណា ហេតុនោះ និមិត្តនោះ ឈ្មោះថាអនិមិត្ត-វិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយនិមិត្តណា មិនតាំងនៅ ក្នុងនិមិត្តនោះទៀត ហេតុនោះ និមិត្តនោះ ឈ្មោះថាអប្បណិ-ហិតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថា ប្រជុំចុះ ដោយអត្ថថាបានលុះ ដោយអត្ថថាបានចំពោះ ដោយអត្ថថា ចាក់ធ្លុះ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថាប៉ះពាល់ ដោយ អត្ថថាត្រាស់ដឹង យ៉ាងនេះឯង ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងរួចចាកសេចក្តីប្រកាន់ស្អិត (ដោយសភាវៈណា) ហេតុនោះ សភាវៈនោះ ឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយសុញ្ញតនិមិត្តណា ហេតុនោះ និមិត្តនោះ ឈ្មោះថា អនិមិត្តវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយ និមិត្តណា មិនតាំងនៅ ក្នុងនិមិត្តនោះទៀត ហេតុនោះ ឈ្មោះ ថា អប្បណិហិតវិមោក្ខ យោគាវចរ មិនតាំងនៅ ក្នុងនិមិត្ត ណា សូន្យចាកនិមិត្តនោះ ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ

ឯវំ សមោធានដ្ឋេន អធិគមដ្ឋេន បដិលាភដ្ឋេន បដិវេធដ្ឋេន សច្ឆិកិរិយដ្ឋេន ផស្សនដ្ឋេន អភិសមយដ្ឋេន តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ឥមេហិ សត្តហាការេហិ តយោ វិមោក្ខា ឯកក្ខណេ ហោន្តិ ។

[២១៩] អត្ថិ វិមោក្ខោ អត្ថិ មុខំ អត្ថិ វិមោក្ខមុខំ អត្ថិ វិមោក្ខបច្ចនីកំ អត្ថិ វិមោក្ខានុលោមំ អត្ថិ វិមោក្ខវិវដ្ដោ អត្ថិ វិមោក្ខភាវនា អត្ថិ វិមោក្ខប្បដិប្បស្សទ្ធិ ។

កតមោ វិមោក្ខោ ។ សុញ្ញតោ វិមោក្ខោ អនិមិត្តោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ ។

វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថាប្រជុំចុះ ដោយអត្ថថាបានលុះ ដោយអត្ថថាបានចំពោះ ដោយអត្ថថាចាក់ធ្លុះ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថាប៉ះពាល់ ដោយអត្ថថាត្រាស់ដឹង យ៉ាងនេះឯង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអាការ ៧ យ៉ាងនេះឯង ។

[២១៩] វិមោក្ខ ក៏មាន មុខ ក៏មាន វិមោក្ខមុខ ក៏មាន វិមោក្ខបច្ចនីកៈ ក៏មាន វិមោក្ខានុលោម[១] ក៏មាន វិមោក្ខវិវដ្តៈ ក៏មាន វិមោក្ខភាវនា ក៏មាន វិមោក្ខប្បដិបស្សទ្ធិ ក៏មាន ។

វិមោក្ខ មានប៉ុន្មាន ។ មាន ៣ គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ។

១ ធម៌ដែលស្របតាមនូវវិមោក្ខ ។

៣៦៩



កតមោ សុញ្ញតោ វិមោក្ខោ ។ អនិច្ចានុបស្សនាញាណំ និច្ចតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ ទុក្ខានុបស្សនាញាណំ សុខតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ អនត្តានុបស្សនាញាណំ អត្តតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ និព្វិទានុបស្សនាញាណំ នន្ទិយា អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ វិរាគានុបស្សនាញាណំ រាគតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ និរោធានុបស្សនាញាណំ សមុទយតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ បដិនិស្សគ្គានុបស្សនាញាណំ អាទានតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ អនិមិត្តានុបស្សនាញាណំ និមិត្តតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ អប្បណិហិតានុបស្សនាញាណំ បណិធិយា អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ

សុញ្ញតវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទៀង ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាសុខ ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាខ្លួន ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាគួររីករាយ ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ វិរាគានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថារាគៈ ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ និរោធានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាកើតឡើងព្រម ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាគួរប្រកាន់[១] ហេតុនោះ ឈ្មោះថា សុញ្ញតវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ស្អិត ថាជានិមិត្ត ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទីតម្កល់ ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ

---

១ បានដល់ឧបាទានទាំង ៤ គឺកាមូបាទាន ១ ទិដ្ឋុប្បាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ អដ្ឋកថា ។

សុញ្ញតានុបស្សនាញាណំ សព្វាភិនិវេសេហិ មុច្ចតីតិ សុញ្ញតោ វិមោក្ខោ រូបេ អនិច្ចានុបស្សនាញាណំ និច្ចតោ អភិនិវេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ ។ បេ ។ រូបេ សុញ្ញតានុបស្សនាញាណំ សព្វាភិនិ-វេសេហិ មុច្ចតីតិ សុញ្ញតោ វិមោក្ខោ វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនាញាណំ និច្ចតោ អភិនិ-វេសា មុច្ចតីតិ សុញ្ញតោ វិមោក្ខោ ។ បេ ។ ជរាម-រណេ សុញ្ញតានុបស្សនាញាណំ សព្វាភិនិវេសេហិ មុច្ចតីតិ សុញ្ញតោ វិមោក្ខោ អយំ សុញ្ញតោ វិមោក្ខោ ។

[២២០] កតមោ អនិមិត្តោ វិមោក្ខោ ។ អនិច្ចានុបស្សនាញាណំ និច្ចតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ ទុក្ខានុបស្សនាញាណំ សុខតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ អនត្តានុបស្សនា-ញាណំ អត្តតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ និព្វិទានុបស្សនាញាណំ នន្ទិយា និមិត្តា មុច្ចតីតិ

សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ទាំងពួង ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទៀង ក្នុងរូប ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ ។ បេ ។ សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ទាំងពួង ក្នុងរូប ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាក សេចក្តីប្រកាន់ថាទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ ។ បេ ។ សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ទាំងពួង ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាសុញ្ញតវិមោក្ខ នេះ ឯង សុញ្ញតវិមោក្ខ ។

[២២០] អនិមិត្តវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកនិមិត្ត ថាទៀង ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកនិមិត្ត ថាជាសុខ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកនិមិត្ត ថាជាខ្លួន ហេតុនោះ ឈ្មោះ ថាអនិមិត្តវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកនិមិត្តថាគួររីករាយ

អនិមិត្តោ វិមោក្ខោ វិរាគានុបស្សនាញាណំ រាគតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ និរោធានុ-បស្សនាញាណំ សមុទយតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ បដិនិស្សគ្គានុបស្សនាញាណំ អាទានតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ អនិមិត្តានុបស្សនាញាណំ សព្វនិមិត្តេហិ មុច្ចតីតិ អនិមិត្តោ វិមោក្ខោ អប្បណិហិតានុបស្សនាញាណំ បណិធិយា និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ និមិត្តា មុ-ច្ចតីតិ អនិមិត្តោ វិមោក្ខោ រូបេ អនិច្ចានុបស្សនា-ញាណំ និច្ចតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោ-ក្ខោ ។ បេ ។ រូបេ អនិមិត្តានុបស្សនាញាណំ សព្វនិ-មិត្តេហិ មុច្ចតីតិ អនិមិត្តោ វិមោក្ខោ រូបេ អប្បណិ-ហិតានុបស្សនាញាណំ បណិធិយា និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ រូបេ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ

ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ វិរាគានុបស្សនាញាណ រួចចាក និមិត្ត ថាតម្រេក ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ និរោធានុប-ស្សនាញាណ រួចចាកនិមិត្ត ថាកើតឡើងព្រម ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាក និមិត្តទាំងពួង ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិតានុប-ស្សនាញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ ស្អិត ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកនិមិត្ត ថាទៀង ក្នុងរូប ហេតុនោះ ឈ្មោះថាអនិមិត្ត-វិមោក្ខ ។ បេ ។ អនិមិត្តានុបស្សនាញាណ រួចចាកនិមិត្តទាំងពួង ក្នុងរូប ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិតានុបស្សនា-ញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ ក្នុងរូប ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ស្អិត ក្នុងរូប ហេតុនោះ ឈ្មោះថា អនិមិត្តវិមោក្ខ

វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនាញាណំ និច្ចតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ ។ បេ ។ ជរាមរណេ អនិមិត្តានុបស្សនាញាណំ សព្វនិមិត្តេហិ មុច្ចតីតិ អនិមិត្តោ វិមោក្ខោ ជរាមរណេ អប្បណិ-ហិតានុបស្សនាញាណំ បណិធិយា និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ ជរាមរណេ សុញ្ញតានុបស្ស-នាញាណំ អភិនិវេសតោ និមិត្តា មុច្ចតីតិ អនិមិត្តោ វិមោក្ខោ អយំ អនិមិត្តោ វិមោក្ខោ ។

[២២១] កតមោ អប្បណិហិតោ វិមោក្ខោ ។ អនិច្ចានុបស្សនាញាណំ និច្ចតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ ទុក្ខានុបស្សនាញាណំ សុ-ខតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ អនត្តានុបស្សនាញាណំ អត្តតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ និព្វិទានុបស្សនាញាណំ ន-ន្ទិយា បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ

អនិច្ចានុបស្សនាញាណ រួចចាកនិមិត្តថាទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ ។ បេ ។ អនិមិត្តានុបស្សនាញាណ រួចចាកនិមិត្តទាំងពួង ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ស្អិតក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអនិមិត្តវិមោក្ខ នេះឯង អនិមិត្តវិមោក្ខ ។

[២២១] អប្បណិហិតវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ ថាទៀង ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកការតម្កល់ ថាជាសុខ ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកការតម្កល់ ថាជាខ្លួន ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកការតម្កល់ ថាគួររីករាយ ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ

វិរាគានុបស្សនាញាណំ រាគតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ និរោធានុបស្សនាញាណំ សមុទយតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ បដិនិស្សគ្គានុបស្សនាញាណំ អាទានតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ អនិមិត្តានុបស្សនាញាណំ និមិត្តតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ អប្បណិហិតានុបស្សនាញាណំ សព្វប្បណិធីហិ មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ រូបេ អនិច្ចានុបស្សនាញាណំ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ ។ បេ ។ រូបេ អប្បណិហិតានុបស្សនាញាណំ សព្វប្បណិធីហិ មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ រូបេ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ

វិរាគានុបស្សនាញាណ រួចចាកការតម្កល់ ថាជាតម្រេក ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ និរោធានុបស្សនាញាណ រួចចាកការតម្កល់ ថាកើតឡើងព្រម ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ រួចចាកការតម្កល់ ថាគួរប្រកាន់ ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាកការតម្កល់ ថាជានិមិត្ត ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកការតម្កល់ទាំងពួង ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកការតម្កល់ ថាគួរប្រកាន់ស្អិត ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ ក្នុងរូប ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ ។ បេ ។ អប្បណិហិតានុបស្សនាញាណ រួចចាកការតម្កល់ទាំងពួង ក្នុងរូប ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកការតម្កល់ ថាគួរប្រកាន់ស្អិតក្នុងរូប ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ

វេទនាយ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនាញាណំ និច្ចតោ បណិធិយា មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ ។ បេ ។ ជរាមរណេ អប្បណិហិតានុបស្សនាញាណំ សព្វប្បណិធីហិ មុច្ចតីតិ អប្បណិហិតោ វិមោក្ខោ ជរាមរណេ សុញ្ញតានុបស្សនាញាណំ អភិនិវេសតោ បណិធិយា មុច្ចតីតិ អប្បណិតោ វិមោក្ខោ អយំ អប្បណិហិតោ វិមោក្ខោ ។

[២២២] កតមំ មុខំ ។ យេ តត្ថ ជាតា អនវជ្ជា កុសលា ពោធិបក្ខិយា ធម្មា ឥទំ មុខំ ។

កតមំ វិមោក្ខមុខំ ។ យំ តេសន្តេសំ[១] ធម្មានំ អារម្មណំ និរោធោ និព្វានំ ឥទំ វិមោក្ខមុខំ[២] ។

១ ឱ. ម. តេសំ ។ ២ ម. ឯត្ថន្តរេ វិមោក្ខញ្ច មុខញ្ច វិមោក្ខមុខំ ។ ឥទំ វិមោក្ខន្តិ ទិស្សន្តិ ។

អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ថាទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ ។ បេ ។ អប្បណិហិតានុបស្សនាញាណ រួចចាកការតម្កល់ទាំងពួង ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកការតម្កល់ថាគួរប្រកាន់ស្អិត ក្នុងជរាមរណៈ ហេតុនោះ ឈ្មោះថាអប្បណិហិតវិមោក្ខ នេះឯង អប្បណិហិតវិមោក្ខ ។

[២២២] មុខ តើដូចម្តេច ។ ពោធិបក្ខិយធម៌ទាំងឡាយណា ជាធម្មជាតមិនមានទោស ជាកុសល កើតហើយ ក្នុងវិមោក្ខទាំងនោះ នេះឯង ឈ្មោះថាមុខ ។

វិមោក្ខមុខ តើដូចម្តេច ។ អារម្មណ៍ណា របស់ធម៌ទាំងឡាយនោះៗ គឺនិរោធ និព្វាន នេះឯង ឈ្មោះថាវិមោក្ខមុខ ។

កតមំ វិមោក្ខបច្ចនីកំ ។ តីណិ អកុសលមូលានិ វិមោក្ខបច្ចនីកានិ តីណិ ទុច្ចរិតានិ វិមោក្ខបច្ចនីកានិ សព្វេបិ អកុសលា ធម្មា វិមោក្ខបច្ចនីកា ឥទំ វិមោក្ខបច្ចនីកំ ។

កតមំ វិមោក្ខានុលោមំ ។ តីណិ កុសលមូលានិ វិមោក្ខានុលោមានិ តីណិ សុចរិតានិ វិមោក្ខានុលោមានិ សព្វេបិ កុសលា ធម្មា វិមោក្ខានុលោមា ឥទំ វិមោក្ខានុលោមំ ។

[២២៣] កតមោ វិមោក្ខវិវដ្ដោ ។ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវដ្ដោ វិមោក្ខវិវដ្ដោ សច្ចវិវដ្ដោ ។ សញ្ជានន្តោ វិវដ្ដតីតិ សញ្ញាវិវដ្ដោ ចេតយន្តោ វិវដ្ដតីតិ ចេតោវិវដ្ដោ

វិមោក្ខបច្ចនិកៈ (ធម៌ជាសត្រូវរបស់វិមោក្ខ) តើដូចម្តេច ។ អកុសលមូលទាំង ៣ ជាសឹកសត្រូវរបស់វិមោក្ខ ទុច្ចរិតទាំង ៣ ជាសឹកសត្រូវរបស់វិមោក្ខ អកុសលធម៌ទាំងពួង ជាសឹកសត្រូវរបស់វិមោក្ខ នេះឯង ឈ្មោះថាវិមោក្ខបច្ចនិកៈ (ធម៌ជាសត្រូវរបស់វិមោក្ខ) ។

វិមោក្ខានុលោម តើដូចម្តេច ។ កុសលមូលទាំង ៣ ចាត់ជាវិមោក្ខានុលោម សុចរិតទាំង ៣ ចាត់ជាវិមោក្ខានុលោម កុសលធម៌ទាំងអស់ ចាត់ជាវិមោក្ខានុលោម នេះឯង ឈ្មោះថាវិមោក្ខានុលោម ។

[២២៣] វិមោក្ខវិវដ្តៈ តើដូចម្តេច ។ (វិវដ្តៈ មាន ៦) គឺ សញ្ញាវិវដ្តៈ ១ ចេតោវិវដ្តៈ ១ ចិត្តវិវដ្តៈ ១ ញាណវិវដ្តៈ ១ វិមោក្ខវិវដ្តៈ ១ សច្ចវិវដ្តៈ ១ ។ យោគាវចរ កាលដឹងច្បាស់ រមែងងាកចេញ (ចាកសង្ខារនិមិត្ត) ហេតុនោះ ឈ្មោះថាសញ្ញាវិវដ្តៈ យោគាវចរ កាលត្រិះរិះរមែងងាកចេញ ហេតុនោះ ឈ្មោះថាចេតោវិវដ្តៈ

វិជានដ្ដោ វិវដ្ដតីតិ ចិត្តវិវដ្ដោ ញាណំ កហដ្ដោ វិវដ្ដតីតិ ញាណវិវដ្ដោ ហស្សដ្ឋដ្ដោ វិវដ្ដតីតិ វិមោក្ខវិវដ្ដោ តថដ្ឋេ វិវដ្ដតីតិ សច្ចវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ តត្ថ ចេតោវិវដ្ដោ យត្ថ ចេតោវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ តត្ថ ចិត្តវិវដ្ដោ យត្ថ ចិត្តវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ តត្ថ ញាណវិវដ្ដោ យត្ថ ញាណវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវដ្ដោ តត្ថ វិមោក្ខវិវដ្ដោ យត្ថ វិមោក្ខវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវដ្ដោ

យោគាវចរកាលដឹងច្បាស់ រមែងផាកចេញ ហេតុនោះ ឈ្មោះថាចិត្តវិវដ្ដៈ យោគាវចរ កាលធ្វើនូវញាណ រមែងផាកចេញ ហេតុនោះ ឈ្មោះថាញាណវិវដ្ដៈ កាលលះបង់ រមែងផាកចេញ ហេតុនោះ ឈ្មោះថាវិមោក្ខវិវដ្ដៈ យោគាវចរ ផាកចិត្តទៅ ក្នុងអត្ថដ៏ពិត ហេតុនោះ ឈ្មោះថាសច្ចវិវដ្ដៈ សញ្ញាវិវដ្ដៈ មានក្នុងទីណា ចេតោវិវដ្ដៈ ក៏មានក្នុងទីនោះ ចេតោវិវដ្ដៈ មានក្នុងទីណា សញ្ញាវិវដ្ដៈ ក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈនិងចេតោវិវដ្ដៈ មានក្នុងទីណា ចិត្តវិវដ្ដៈ ក៏មានក្នុងទីនោះ ចិត្តវិវដ្ដៈ មានក្នុងទីណា សញ្ញាវិវដ្ដៈនិងចេតោវិវដ្ដៈ ក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ និងចិត្តវិវដ្ដៈ មានក្នុងទីណា ញាណវិវដ្ដៈ ក៏មានក្នុងទីនោះ ញាណវិវដ្ដៈ មានក្នុងទីណា សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ និងចិត្តវិវដ្ដៈ ក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងញាណវិវដ្ដៈ មានក្នុងទីណា វិមោក្ខវិវដ្ដៈ ក៏មានក្នុងទីនោះ វិមោក្ខវិវដ្ដៈ មានក្នុងទីណា សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងញាណវិវដ្ដៈ ក៏មានក្នុងទីនោះ

យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណ-
វិវដ្ដោ វិមោក្ខវិវដ្ដោ តត្ថ សច្ចវិវដ្ដោ យត្ថ សច្ចវិ-
វដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ
ញាណវិវដ្ដោ វិមោក្ខវិវដ្ដោ អយំ វិមោក្ខវិវដ្ដោ ។

[២២៤] កតមា វិមោក្ខភាវនា ។ បឋមជ្ឈានស្ស
អាសេវនា ភាវនា ពហុលីកម្មំ ទុតិយជ្ឈានស្ស អា-
សេវនា ភាវនា ពហុលីកម្មំ តតិយជ្ឈានស្ស អាសេ-
វនា ភាវនា ពហុលីកម្មំ ចតុត្ថជ្ឈានស្ស អាសេវនា
ភាវនា ពហុលីកម្មំ អាកាសានញ្ចាយតនសមាបត្តិ-
យា អាសេវនា ភាវនា ពហុលីកម្មំ វិញ្ញាណញ្ចាយ-
តនសមាបត្តិយា អាកិញ្ចញ្ញាយតនសមាបត្តិយា នេវ-
សញ្ញានាសញ្ញាយតនសមាបត្តិយា អាសេវនា ភាវនា
ពហុលីកម្មំ សោតាបត្តិមគ្គស្ស អាសេវនា ភាវនា

សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ ញាណវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ មានក្នុងទីណា សច្ចវិវដ្ដៈ ក៏មានក្នុងទីនោះ សច្ចវិវដ្ដៈ មានក្នុងទីណា សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ ញាណវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ ក៏មានក្នុងទីនោះដែរ នេះឯង ឈ្មោះថាវិមោក្ខវិវដ្ដៈ ។

